ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលព្រៃឈើ

កម្មវិធីព្រៃឈើជាតិ

# កម្រងរបាយការណ៍

## នៃសិក្ខាសាលាកិច្ចពិគ្រោះយោបល់ជាសាធារណៈស្តីពីកម្មវិធីព្រៃឈើជាតិ



ខេត្តក្រចេះ ថ្ងៃទី ២៥-២៦ មីនា ឆ្នាំ២០០៩

# **មាតិកាឿង**

-របាយការណ៍សង្ខេប

-របាយការណ៍ស្តីពីលទ្ធផលកិច្ចពិគ្រោះយោបល់ជាសាធារណៈលើកម្មវិធីព្រៃឈើជាតិ នៅអធិការដ្ឋាន រដ្ឋបាលព្រៃឈើមេគង្គ

-អត្ថបទឧបសម្ព័ន្ធទី ១: របៀបវារៈកម្មវិធីសិក្ខាសាលាកិច្ចពិគ្រោះយោបល់ជាសាធារណៈនៅខេត្តក្រចេះ

- អត្ថបទឧបសម្ព័ន្ធទី ២: សុន្ទរកថាស្វាគមន៍របស់ឯកឧត្តម **ធុន គ្រី** អភិបាលរងខេត្តក្រចេះ

- អត្ថបទឧបសម្ព័ន្ធទី ៣: បទបង្ហាញពីកម្មវិធីព្រៃឈើជាតិ

- អត្ថបទឧបសម្ព័ន្ធទី ៤: សំណួរ ចម្លើយ បន្ទាប់ពីបទបង្ហាញកម្មវិធីព្រៃឈើជាតិ

- អត្ថបទឧបសម្ព័ន្ធទី ៥: បញ្ជីឈ្មោះសិក្ខាកាមពិភាក្សាតាមក្រុម

- អត្ថបទឧបសម្ព័ន្ធទី ៦: បទបង្ហាញពីលទ្ធផលរបស់ក្រុមពិភាក្សា

- អត្ថបទឧបសម្ព័ន្ធទី ៧: សំណួរ ចម្លើយ ពីលទ្ធផលពិភាក្សាតាមក្រុម

- អត្ថបទឧបសម្ព័ន្ធទី ៨: របាយការណ៍បូកសរុបសទ្ធផលសិក្ខាសាលា របស់លោក**អៀង សាវៃត** នាយអធិការដ្ឋាន រដ្ឋបាលព្រៃឈើមេគង្គ

-អត្ថបទឧបសម្ព័ន្ធ,ទី ៩ លត្ធផលពិភាក្សាតមក្រុម និងមតិដែលបានដកស្រង់ដើម្បីធ្វើកាអភិវឌ្ឍន៍កម្មវិធី

## របាយការណ៍សង្ខេប

ក្នុងគោលបំណងគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព កម្មវិធីព្រៃឈើជាតិមួយត្រូវបានរៀបចំឡើងដោយឱ្យក្រុមការងាររបស់រដ្ឋបាលព្រៃឈើ ។ ដើម្បីឱ្យកម្មវិធីនេះធានាបាននិរន្តរភាពព្រៃឈើផង និងផលប្រយោជន៍របស់បណ្តាភាគីដែលពាក់ព័ន្ធផង កិច្ចពិគ្រោះយោបល់ជាសាធារណៈស្តីពីកម្មវិធីនេះ ត្រូវបានរៀបចំឡើងនៅគ្រប់អធិការដ្ឋានរដ្ឋបាលព្រៃឈើទាំងបួននៅទូទាំងប្រទេស ។

ដោយឡែកនៅអធិការដ្ឋានរដ្ឋបាលព្រៃឈើមេគង្គ សិក្ខាសាលាកិច្ចពិគ្រោះយោបល់ជាសាធាណៈស្តីពីកម្មវិធីព្រៃឈើជាតិនេះ ត្រូវបានរៀបចំឡើងនៅសាលមហោស្របខេត្តក្រចេះ ដែលមានរយៈពេល២ថ្ងៃ ២៥-២៦ មិនា ឆ្នាំ២០០៩ ដើម្បីប្រមូលយកមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធពីខេត្តចំនួន៧ៈ កំពង់ចាម ក្រចេះ ស្ទឹងត្រែង រតនគីរី មណ្ឌលគីរី ព្រៃវែង និងស្វាយរៀង ។ សមាជិកចូលរួមក្នុងសិក្ខាសាលានេះ មានចំនួន ១៨១នាក់ ។

នៅថ្ងៃទីមួយក្រុមការងាររៀបចំកម្មវិធីព្រៃឈើជាតិ បានធ្វើបទបង្ហាញពីពង្រាងឯកសារគោលនិង កម្មវិធីទាំង៦របស់កម្មវិធីព្រៃឈើជាតិ ។ពេលបញ្ចប់បទបង្ហាញនិមួយៗ សិក្ខាកាមបានអនុញ្ញាតឱ្យសួរសំនួរដែលទាក់ទងនឹងកម្មវិធីហើយនៅចុងកម្មវិធីនៅថ្ងៃទីមួយនេះ សិក្ខាកាមបានជ្រើសរើសក្រុមរបស់ខ្លួន សម្រាប់ធ្វើការពិភាក្សា ។

នៅថ្ងៃបន្ទាប់ សមាជិក សិក្ខាសាលាបានពិភាក្សា និងដាក់បញ្ចូលគំនិតយោបល់របស់ខ្លួនទៅក្នុងកម្មវិធីព្រៃឈើជាតិ ។ ពេលបញ្ចប់ការពិភាក្សា ក្រុមបានជ្រើសរើសតំណាងរបស់ខ្លួន ដើម្បីធ្វើបទបង្ហាញពីលទ្ធផលពិភក្សាជូនអង្គសិក្ខាសាលា ។ ជារួម ចំពោះកម្មវិធីទី១ សិក្ខាកាមកំណត់បានបញ្ហាប្រឈមជាច្រើនក្នុងការកំណត់ព្រំប្រទល់ និងការចាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ហើយបានផ្តល់ជូននូវដំណោះស្រាយមួយចំនួនដែលពាក់ព័ន្ធសំខាន់ទៅលើការអនុវត្តន៍ច្បាប់ ការផ្សព្វផ្សាយ និងកិច្ចសហការរវាងស្ថាប័ន ។ ចំពោះកម្មវិធីទី ២ ក្រុមបានដាក់បញ្ចូលសកម្មភាពជាច្រើន ទាក់ទងសំខាន់ទៅនឹងការគ្រប់គ្រង និងការអភិរក្ស ទៅក្នុងអនុកម្មវិធីទាំង ៨ សំដៅធ្វើឱ្យកម្មវិធីនេះមានដំណើរការល្អ ។ ដោយឡែក កម្មវិធីទី ៣ ក្រុមបានដាក់បញ្ចូលគំនិតយោបល់របស់ខ្លួន ដែលផ្តោតសំខាន់ទៅលើការពង្រឹងកាអនុវត្តន៏ច្បាប់ បង្កើនការផ្សព្វផ្សាយ និងកសាងបណ្តាញផ្តល់ ព័តិមានពីបទល្មើសព្រៃឈើនៅថ្នាក់មូលដ្ឋាន ។ ចំពោះកម្មវិធីទី ៤ ក្រុមបានស្នើរដាក់បញ្ចូលបន្ថែមនូវសកម្មភាពខ្លះ ទៀត ទៅក្នុងអនុកម្មវិធីទាំង ៣ របស់កម្មវិធីសហគមន៏ព្រៃឈើ ដែលសកម្មភាពតាំងនោះមានគោលបំណង សំខាន់សម្រាប់ការងាយស្រួលក្នុងការបង្កើតសហគមន៏ព្រៃឈើ និងបង្កើនជីវភាពសហគមន៏ ។ នៅក្នុងកម្មវិធីទី៥ ក្រុមបានដាក់បញ្ចូលនូវយុទ្ធសាស្រ្តសំខាន់ ២ គឺៈ យុទ្ធាសាស្រ្តសម្រាប់ការអភិវឌ្ឍន៏ធនធានមនុស្ស និងយុទ្ធសាស្រ្តសម្រាប់ការស្រាវជ្រាវ ។ ដោយឡែក ចំពោះឯកសារគោលរបស់កម្មវិធីព្រៃឈើជាតិ ក្រុមបានស្នើរឱ្យមានការកែ លំអគោលបំណង និងទិសដៅរបស់កម្មវិធីព្រៃឈើជាតិ និងស្នើរដាក់បញ្ចូលការបញ្រ្ជាបយេនឌ័រទៅក្នុងកម្មវិធីផង ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍

# ស្តីពីលទ្ធផលកិច្ចពិគ្រោះយោបល់ជាសាធារណៈ

# លើកម្មវិធីព្រៃឈើជាតិ នៅអធិការដ្ឋានរដ្ឋបាលព្រៃឈើមេគង្គ

ក្នុងគោលបំណងគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព កម្មវិធីព្រៃឈើជាតិមួយត្រូវបានរៀបចំឡើងដោយក្រុមការងាររបស់រដ្ឋបាលព្រៃឈើ ។ ដើម្បីឱ្យកម្មវិធីនេះធានាបាននិរន្តរភាពព្រៃឈើផង និងផលប្រយោជន៍របស់បណ្តាភាគីដែលពាក់ព័ន្ធផង កិច្ចពិគ្រោះយោបល់ជាសាធារណៈស្តីពីកម្មវិធីនេះ ត្រូវបានរៀបចំឡើងនៅគ្រប់អធិការដ្ឋានរដ្ឋបាលព្រៃឈើទាំងបួននៅទូទាំងប្រទេស ។

ដោយឡែកនៅអធិការដ្ឋានរដ្ឋបាលព្រៃឈើមេគង្គ សិក្ខាសាលាកិច្ចពិគ្រោះយោបល់ជាសាធាណៈស្តីពីកម្មវិធីព្រៃឈើជាតិ ត្រូវបានរៀបចំឡើង ដើម្បីប្រមូលយកមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធ មកពីខេត្តចំនួន៧: កំពង់ចាម ក្រចេះ ស្ទឹងត្រែង រតនគីរី មណ្ឌលគីរី ព្រៃវែង និងស្វាយរៀង ។ ចំពោះលទ្ធផលដែលទទួលបាន មាន:

## ១: ទីកន្លែង ពេលវេលា និងអ្នកចូលរួម

កិច្ចពិគ្រោះយោបល់ជាសាធារណៈស្តីពីកម្មវិធីព្រៃឈើជាតិនៅអធិការដ្ឋានរដ្ឋបាលព្រៃឈើមេគង្គ ត្រូវបានរៀបចំឡើងនៅសាលមហោស្រពខេត្តក្រចេះ ក្រោមអធិបតីភាពឯកឧត្តម **ធុន ត្រី** អភិបាលរងខេត្តក្រចេះ ឯកឧត្តម **ជា សំអាង** អនុប្រធានរដ្ឋបាលព្រៃឈើ និងលោក **អៀង សាវ៉េត** នាយអធិការដ្ឋានរដ្ឋបាលព្រៃឈើមេគង្គ ។ កិច្ចពិគ្រោះយោបល់នេះបានប្រព្រឹត្តទៅរយៈពេល២ថ្ងៃ ២៥-២៦ មិនា ឆ្នាំ២០០៩ (ចំពោះរបៀបវារៈរបស់សិក្ខាសាលា មានជូនភ្ជាប់ក្នុងអត្ថបទឧបសម្ព័ន្ធទី ១) ។ សិក្ខាកាម ចូលរួមក្នុងកិច្ចពិគ្រោះយោបល់នេះ មានចំនួនសរុប១៨១នាក់ មកពីអង្គភាព: សហគមន៍ ព្រៃឈើ អជ្ញាធរមូលដ្ឋាន អង្គការក្រៅរដ្ឋាធិបាល ព្រះសង្ឃ កងកម្លាំងប្រដាប់អាវុធ អ្នកយកព័ត៌មាន... ។




**រូបភាពទិ១:** គណៈអធិបតីរបស់អង្គសិក្ខាសាលា



**រូបភាពទិ២:** សមាជិកអង្គសិក្ខាសាលា

## ២: បទបង្ហាញពីពង្រាងកម្មវិធីព្រៃឈើជាតិ

បន្ទាប់ពីការថ្លែងសុន្ទរកថាស្វាគមន៍របស់ឯកឧត្តមអភិបាលរងខេត្តក្រចេះ (អត្ថបទឧបសម្ព័ន្ធទី ២) រួចមក ឯកឧត្តម **ជា សំអាង** អនុប្រធានរដ្ឋបាលព្រៃឈើ បានឡើងថ្លែងសុន្ទរកថាបើកកិច្ចពិគ្រោះយោបល់ ដោយបានគូសបញ្ជាក់ជូនអង្គ សិក្ខាសាលាពីការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ដើម្បីកិច្ចការពារបរិស្ថាន ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងកាត់បន្ថយភាពក្រីក្រ។ ដើម្បីសម្រេចគោលបំណងនេះ កម្មវិធីព្រៃឈើជាតិ ជាតម្រូវការចាំបាច់ក្នុងការគ្រប់គ្រងព្រៃឈើនៅទូទាំងប្រទេស។

បន្ទាប់មក ការធ្វើបទបង្ហាញពីពង្រាងកម្មវិធីព្រៃឈើជាតិបានចាប់ផ្ដើម (ចំពោះបទបង្ហាញលំអិតអំពីកម្មវិធីព្រៃឈើជាតិមានជូនភ្ជាប់ក្នុងអត្ថបទឧបសម្ព័ន្ធទី ៣)។ បទបង្ហាញដែលបានធ្វើនៅពេលនោះមាន:

- គោលបំណង និងលទ្ធផលរំពឹងទុករបស់កម្មវិធីព្រៃឈើជាតិ (ដោយបណ្ឌិត **សុខ ហេង**)
- ដំណើរកាអភិវឌ្ឍន៍របស់កម្មវិធីព្រៃឈើជាតិ (ដោយបណ្ឌិត **សុខ ហេង**)
- ឯកសារគោលនៃកម្មវិធីព្រៃឈើជាតិ (ដោយបណ្ឌិត **សុខ ហេង**)។

● កម្មវិធីទី១: ការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ក្នុងកម្មវិធីនេះមានអនុកម្មវិធីចំនួនពីរ: (១) អនុកម្មវិធីកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ និង (២) អនុកម្មវិធីការចាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ (ដោយលោក **ប៉ក់ ជាលី** និងលោក **លាង ហ៊ន**)។

● កម្មវិធីទី២: ការគ្រប់គ្រងធនធានព្រៃឈើ និងការអភិរក្ស។ ក្នុងនោះមានអនុកម្មវិធីចំនួន៨: (១) អនុកម្មវិធី ផែនការគ្រប់គ្រងព្រៃឈើជាតិ (២) អនុកម្មវិធី សារពើភ័ណ្ឌព្រៃឈើជាតិ (៣) អនុកម្មវិធី ការអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងព្រៃផ្ដល់ផលក្រៅព្រៃសហគមន៍ (៤) អនុកម្មវិធី ការអភិរក្សធនធាន សេនេទិច

និងការបង្កើតប្រភពគ្រាប់ពូជ (៥) អនុកម្មវិធី ការអភិវឌ្ឍន៍ចំការដាំឈើសម្រាប់ការប្រើប្រាស់ច្រើនយ៉ាង (៦) អនុកម្មវិធី ការរៀបចំប្រព័ន្ធគ្រប់គ្រងព្រៃការពារដែលរួមមានការអភិរក្សធនធានជីវចម្រុះ និងការ អភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ (៧) អនុកម្មវិធី ការកែច្នៃផលិតផលឈើ និងទីផ្សារ និង (៨) អនុកម្មវិធី ការអភិវឌ្ឍន៍បច្ចេកវិជ្ជាឈើ និងការកែច្នៃ (ដោយលោក **ឃន សារ៉េត** លោក **អួន សំអុល** លោក **ឈុំ សំណាង** លោក **សូ លន** និងលោក **សារ មករា**) ។

● កម្មវិធីទី៣: ពង្រឹងការអនុវត្តន៍ច្បាប់ និងអភិបាលកិច្ច ។ មានបីអនុកម្មវិធី: (១) អនុកម្មវិធី កំណែទំរង់ច្បាប់ និងរដ្ឋបាល (២) អនុកម្មវិធី ការពង្រឹងការអនុវត្តច្បាប់ និងការតាមដាន និងរាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើ (៣) អនុកម្មវិធី ការឆ្លើយតបរហ័សចំពោះព័ត៌មានបទល្មើសព្រៃឈើ (ដោយលោក **សួន សុវណ្ណ**) ។

● កម្មវិធីទី៤: សហគមន៍ព្រៃឈើ មានអនុកម្មវិធី៣: (១) អនុកម្មវិធី ការកំណត់តំបន់ និងការបង្កើតសហគមន៍ព្រៃឈើ (២) អនុកម្មវិធី ការពង្រឹងសហគមន៍ និងការបង្កើនជីវភាព និង (៣) អនុកម្មវិធីការគាំទ្រការអភិវឌ្ឍន៍សហគមន៍ព្រៃឈើ (ដោយ លោក **ឡាវ សេដ្ឋាផល**) ។

● កម្មវិធីទី៥: ការកសាងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្ស ។ មាន៤អនុកម្មវិធី: (១) អនុកម្មវិធី ការអភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស (២) អនុកម្មវិធី ការផ្សព្វផ្សាយព្រៃឈើ (៣) អនុកម្មវិធី ការអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ និងបង្កើនការយល់ដឹងសាធារណៈ និង(៤) អនុកម្មវិធីវិញ្ញាបនប័ត្រព្រៃឈើ (ដោយលោក **ចាន់ សុផល** លោក **ប៊ុន រ៉ាដា** លោក **នុព សុធា** និង លោក **ស៊ិរិទ្ធ វណ្ណា**) ។

● កម្មវិធីទី៦: ហិរញ្ញវត្ថុព្រៃឈើមាន ៤អនុកម្មវិធី: (១) អនុកម្មវិធីហិរញ្ញប្បទានផ្តល់ដោយរាជរដ្ឋាភិបាល (២) អនុកម្មវិធីហិរញ្ញប្បទានផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាល និងប្រទេសផ្តល់ជំនួយ (៣) អនុកម្មវិធីហិរញ្ញប្បទានផ្តល់ដោយប្រភពធនធានព្រៃឈើ (៤) អនុកម្មវិធី ហិរញ្ញប្បទានផ្តល់ដោយក្រុមហ៊ុនឯកជន (ដោយលោក **អួន សំអុល**) ។

នៅចុងបញ្ចប់បទបង្ហាញនីមួយៗ សំនួរចំនួន៣ ឬ៤ ត្រូវបានអនុញ្ញាតជូនសិក្ខាកាម ដើម្បីធ្វើការសាកសួរពីបញ្ហាដែលពាក់ព័ន្ធនឹងកម្មវិធី (អត្ថបទឧបសម្ព័ន្ធទី ៤) ។



**រូបភាពទិ៣:** ការធ្វើបទបង្ហាញពីកម្មវិធីព្រៃឈើជាតិ



**រូបភាពទិ៤:** សំនួរពីសមាជិកសិក្ខាសាលា

**៣:  ការពិភាក្សាតាមក្រុម**

**ក) ការបែងចែកក្រុម:** សមាជិកសិក្ខាសាលាត្រូវបានអនុញ្ញាតឱ្យជ្រើសរើសក្រុម សម្រាប់ធ្វើការពីភាក្សាលើកម្មវិធីទាំង៦ របស់កម្មវិធីព្រៃឈើជាតិ។ ដោយឡែកកម្មវិធីហិរញ្ញវត្ថុព្រៃឈើ ត្រូវបានពីភាក្សាលើឯកសារគោលរបស់កម្មវិធីព្រៃឈើជាតិជំនួសវិញ។ ចំពោះសមាជិកក្រុមពិភាក្សាមានៈ

● ក្រុម១ ពិភាក្សាលើកម្មវិធីការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ មានសមាជិក ៣២នាក់ (សម្របសម្រួលដោយលោក **ហុង គីមហ៊ាន**)។

● ក្រុម២ ពិភាក្សាលើកម្មវិធីការគ្រប់គ្រងធនធានព្រៃឈើ និងអភិរក្ស មានសមាជិក១៨នាក់ (សម្របសម្រួលដោយ**ក្រុមការងាររៀបចំកម្មវិធី**)។

● ក្រុម៣ ពិភាក្សាលើកម្មវិធីពង្រឹងការអនុវត្តន៍ច្បាប់ និងអភិបាលកិច្ច មានសមាជិក២៩នាក់ (សម្របសម្រួលដោយលោក **ឡុង ប៊ុង**)។

● ក្រុម៤ ពីភាក្សាលើកម្មវិធីសហគមន៍ព្រៃឈើ មានសមាជិក៣០នាក់ (សម្របសម្រួលដោយលោក **ហាក់ សារុំ**)។

● ក្រុម៥ ពិភាក្សាលើកម្មវិធីការកសាងសមត្ថភាព និងអភិវឌ្ឍន៍ការស្រាវជ្រាវ មានសមាជិក១៨នាក់ (សម្របសម្រួលដោយលោក **ហែម ចន្ទិរិទ្ធី**)។

● ក្រុម៦ ពិភាក្សាលើឯកសារគោលកម្មវិធិព្រៃឈើជាតិ មានសមាជិក១០នាក់ (សម្របសម្រួលដោយលោកបណ្ឌិត **សុខ ហេង**)។

(បញ្ជីឈ្មោះសមាជិកពិភាក្សាតាមក្រុម មានជូនភ្ជាប់ក្នុងអត្ថបទឧបសម្ព័ន្ធទី ៥)។

**ខ) វិធីសាស្ត្រសម្រាប់ការប្រមូលមតិយោបល់:** នៅក្នុងការពិភាក្សា បញ្ហា ផ្សេងៗទាក់ទងនឹងកម្មវិធី ត្រូវបានបំផុសឡើងដោយអ្នកសម្របសម្រួល សម្រាប់ឱ្យក្រុមមានមូលដ្ឋានធ្វើការពិភាក្សា។ ដើម្បីប្រមូលយក មតិយោបល់ពីគ្រប់សមាជិកទាំងអស់ អ្នកសម្របសម្រួលបានចែកក្រដាល និងប៊ិចជូនគ្រប់សមាជិកទាំងអស់ ក្នុងក្រុម ដើម្បីសរសេរបញ្ចូលមតិ យោបល់របស់ខ្លួន។ នៅរយៈពេល១០-១៥នាទី ក្រោយមក ចម្លើយទាំងនេះ ក៏ត្រូវបានប្រមូលយកមកវិញ ហើយសរសេរបញ្ចូលទៅលើក្រដាសផ្ទាំងធំ ដើម្បីបង្ហាញជូនក្រុមសម្រាប់ជា យោបល់សម្រេចចុងក្រោយ។ នៅក្នុងការសរសេរបញ្ចូលនេះ រាល់គំនិត និងយោបល់ដែលដូចគ្នា ត្រូវបានចម្លងចូល តែមួយដងប៉ុណ្ណោះ។

**គ) លទ្ធផល:** បន្ទាប់ពីការពិភាក្សា គ្រប់ក្រុមបានជ្រើសរើសតំណាងរបស់ខ្លួនដើម្បីធ្វើបទបង្ហាញពី លទ្ធផល ដែលទទួលបាន (បទបង្ហាញលំអិតរបស់ក្រុមពិភាក្សានិមួយៗ មានជូនភ្ជាប់ក្នុងអត្ថបទឧបសម្ព័ន្ធទី ៦):

● **ក្រុម១** ធ្វើបទបង្ហាញដោយលោកស្រី **កែវ ស៊ីយ៉ា** តំណាងសហគមន៍មកពីស្រុកស្នួល ខេត្តក្រចេះ:

កម្មវិធីនេះមានសារៈសំខាន់ណាស់សម្រាប់ការដោះស្រាយទំនាស់ដីធ្លី ទប់ស្កាត់បទល្មើសព្រៃឈើ និងការ កាប់ទន្ទ្រានដីព្រៃឈើធ្វើជាកម្មសិទ្ធ ផ្តលនូវការធានាកម្មសិទ្ធដីធ្លីស្របច្បាប់ដល់ដីរបស់រដ្ឋ និងដីសហគមន៍ដែលរស់ នៅក្បែរតំបន់ព្រៃ។ ផ្តើមចេញពីកម្មវិធីនេះ សហគមន៍នឹងមានព្រំប្រទល់ច្បាស់លាស់រវាងដីព្រៃឈើ និងដី សហគមន៍ ដែលនាំឱ្យមានការងាយស្រួលក្នុងការគ្រប់គ្រង និងប្រើប្រាស់ព្រៃឈើស្របទៅតាមមុខងាររបស់វា និងដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ។

សម្រាប់កម្មវិធីនេះ គួរជម្រុញឱ្យមានសកម្មភាពមួយចំនួនថែមទៀតដូចជា ជំរុញឱ្យមានការផ្សព្វផ្សាយឱ្យ បានទូលំទូលាយឡើងថែមទៀតពីច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធ ដើម្បីផ្តល់ចំណេះដឹង ជាសាធារណៈពីវិស័យព្រៃឈើ។ ត្រូវមានការព្រមព្រៀងពីប្រជាជនសហគមន៍ជាមុន មុននឹងបោះបង្គោលព្រំ។ ត្រូវធ្វើការបែងចែកឱ្យបានច្បាស់លាស់រវាងដីព្រៃសម្រាប់ធ្វើសម្បទានសង្គមកិច្ច និងសម្បទានសេដ្ឋកិច្ច និងត្រូវ ផ្តន្ទាទោសឱ្យបានម៉ឺងម៉ាត់ចំពោះជនល្មើសដែលទន្ទ្រានយកដីព្រៃដោយខុសច្បាប់។

នៅក្នុងអនុកម្មវិធីកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើឯចិន្ត្រៃយ៍ មានបញ្ហាប្រឈមជាច្រើនៈ ដោយការយល់ ដឹងពីសារៈសំខាន់របស់ការបោះបង្គោលព្រំ របស់ប្រជាជននៅមានកំរិត នាំឱ្យការចូលរួមរបស់ពួកគាត់មិនបានល្អ និងនាំឱ្យមានការលួចវាយបំផ្លាញបង្គោលព្រំទៀតផង។ ដោយសារចលនានៃការធ្វើពាណិជ្ជកម្មដីធ្លី និងការគ្រប់ គ្រងចំណាក ចំណូលស្រុកមិនបានច្បាស់លាស់ នាំឱ្យមានការកាប់រានដីព្រៃថ្មីៗថែមទៀត ចូលទៅក្នុងដែនព្រៃឈើ និងជាហេតុនាំឱ្យព្រំប្រទល់ដីព្រៃឈើនៅទិវាលជាក់ស្តែង ខុសនឹងដីព្រៃឈើ ដែលនៅក្នុងផែនទីគម្របព្រៃ ឆ្នាំ២០០២ និងនាំឱ្យមានការតវ៉ាពីប្រជាជនដែលរស់នៅក្បែរតំបន់ព្រៃទៀតផង។ ប្រជាជននៅមានអារម្មណ៍

ខ្លាចមានការប៉ះពាល់ដល់ការប្រើប្រាស់ផល អនុផលព្រៃឈើ ជាប្រពៃណី និងដីបង្កបង្កើនផលរបស់ពួកគាត់ នៅពេលបោះបង្គោលព្រំ នាំឱ្យការចូលរួមរបស់ពួកគាត់មិនបានល្អ និងនាំឱ្យមានការលួច វាយបំផ្លាញបង្គោលព្រំទៀតផង ។ ម៉្យាងទៀត ការចូលរួមរបស់អជ្ញាធរមូលដ្ឋានក៏នៅមានកំរិត នៅក្នុងការ បោះបង្គោលព្រំ និងមានអ្នកមានអំណាចមានដីក្នុងដែនព្រៃឈើ ជាហេតុនាំឱ្យដំណើរការបោះបង្គោលព្រំ ប្រព្រឹត្តទៅពុំបានល្អ និងប្រកបដោយទំនាស់ ។ ក្រៅពីនេះ ការបោះបង្គោលព្រំ នៅមានការខ្វះខាតការផ្សព្វផ្សាយ ជាសាធារណៈពីការកំណត់ព្រំប្រទល់ និងខ្វះខាតមធ្យោបាយដឹកជញ្ជូន នៅពេលដែលការបោះបង្គោលព្រំត្រូវធ្វើ ឡើងនៅតំបន់ដែលមានភូមិសាស្ត្រស្មុគ្រស្មាញ ដូចជា តំបន់ភ្នំ ជ្រោះ ជាដើម ។

ដើម្បីជំរុញឱ្យអនុកម្មវិធីកំណត់ព្រំប្រទល់ប្រព្រឹត្តទៅបានល្អ ត្រូវមានដំណោះស្រាយមួយចំនួនៈ ជំរុញការអនុវត្តន៍ច្បាប់ក្នុងការដោះស្រាយទំនាស់ និងជំរុញការផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានផ្សេងៗឱ្យបានទូលំទូលាយជាសាធារណៈ ដើម្បីទាក់ទាញការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ។ ត្រូវមានការចូលរួមប្រកបដោយឆន្ទៈខ្ពស់ ពីអជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ និងគ្រប់អង្គភាពពាក់ព័ន្ធ ។ គួរដោះស្រាយដី ឬគោលនយោបាយជូនគ្រួសារក្រីក្រដែលគ្មានដីធ្វើស្រែចំការ ។ ត្រូវទប់ស្កាត់មិនឱ្យមានការកាប់រានដីព្រៃធ្វើជាកម្មសិទ្ធបន្តទៀត ដើម្បីឱ្យដីព្រៃឈើនៅទីវាលជាក់ស្តែង និងនៅលើផែនទីកុំឱ្យខុសគ្នាច្រើនពេក ។

ដើម្បីបង្កើនការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ឱ្យសម្រេចបានឆាប់រហ័សៈ ត្រូវមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយពីសារៈសំខាន់នៃការបោះបង្គោលព្រំ និងត្រូវមានថវិកា មធ្យោបាយ សម្ភារៈឱ្យបានគ្រប់គ្រាន់ និងមានកិច្ចសហការឯកភាពគ្នាជាមួយគ្រប់ភាគីពាក់ព័ន្ធ ។ ត្រូវសិក្សាពីផលប៉ះពាល់ជាមុន មុននឹងបោះបង្គោលព្រំ ហើយនៅពេលចូលរួម គ្រប់ភាគីទាំងអស់ត្រូវមានឆន្ទៈខ្ពស់ក្នុងការចូលរួម និងគួរមានវត្តមានរបស់ចាស់ព្រឹទ្ធាចារ្យក្នុងភូមិផងដែរ ។

ចំពោះការចូលរួមរបស់អជ្ញាធរដែនដី សហគមន៍មូលដ្ឋាន និងប្រជាពលរដ្ឋ គឺមានសារសំខាន់ណាស់ ហើយភាគីទាំងនេះត្រូវៈ គោរពពេលវេលាឱ្យបានទៀងទាត់ក្នុងការបោះបង្គោលព្រំ ។ អាជ្ញាធរត្រូវបង្កលក្ខណៈងាយស្រួលដល់មន្ត្រីរដ្ឋបាលព្រៃឈើក្នុងការបោះបង្គោលព្រំ និងត្រូវទទួលស្គាល់ការផ្តល់យោបល់របស់ សហគមន៍មូលដ្ឋាន និងប្រជាពលរដ្ឋ ។ អជ្ញាធរដែនដី សហគមន៍មូលដ្ឋាន និងប្រជាពលរដ្ឋ ត្រូវចូលរួមចង្អុលបង្ហាញទីតាំងទប់ស្កាត់ និងដោះស្រាយទំនាស់ក្នុងមូលដ្ឋានរបស់ខ្លួន ។ ត្រូវចូលរួមរក្សាចំណុច និងរៀបចំឯកសារក្នុងការកំណត់ទីតាំងដែលត្រូវបោះបង្គោលព្រំ ។

នៅក្នុងការចាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ត្រូវមានការពាក់ព័ន្ធទៅនឹងភាគីជាច្រើនៈ អាជ្ញាធរដែនដីមូលដ្ឋាន មន្ទីរកសិកម្ម មន្ទីរសុរិយោដី កងកម្លាំងប្រដាប់អាវុធ ចាស់ទុំក្នុងភូមិ សហគមន៍ រដ្ឋបាលព្រៃឈើ មន្ទីរ

បរិស្ថាន អង្គការ NGOs (ម្ចាស់ជំនួយ) មន្ទីរទេសចរណ៍(ស្រាវជ្រាវកន្លែងទេសចរណ៍) និងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ។

បន្ទាប់ពីបោះបង្គោលព្រំរួច អាជ្ញាធរដែនដី សហគមន៍ និងប្រជាពលរដ្ឋ មូលដ្ឋាន ត្រូវចូលរួមថែរក្សាបង្គោលព្រំ ដោយៈ ត្រូវធ្វើផែនការការពារបង្គោលព្រំ សហការល្បាយាមល្បាតបង្គោលព្រំឱ្យបានជាប្រចាំ និងត្រូវរាយការណ៍ទៅអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ ពីការរំលោភបំពានដីព្រៃ និងការបំផ្លាញបង្គោលព្រំ ។ ត្រូវទប់ស្កាត់ភ្លើងឆេះព្រៃ ដើម្បីរក្សាព្រំប្រទល់ឱ្យនៅគង់វង់ច្បាស់ល្អ និងត្រូវអប់រំ ណែនាំជាប្រចាំ ឱ្យប្រជាជនមូលដ្ឋានយល់ដឹងពីសារៈសំខាន់នៃបង្គោលព្រំ ។

● **ក្រុម២** ធ្វើបទបង្ហាញដោយព្រះភិក្ខុ **ជឹម ពាន់** គង់នៅវត្តសិរីសន្ធរវង្ស ភូមិវត្ត ឃុំក្រចេះ ស្រុកចិត្របុរី ខេត្តក្រចេះៈ

នៅក្នុងអនុកម្មវិធីទី១ ផែនការគ្រប់គ្រងព្រៃឈើជាតិត្រូវតែផ្សាភ្ជាប់ទៅនឹង ផលប្រយោជន៍របស់ប្រជាពលរដ្ឋ ហើយផែនការនេះត្រូវមានរយៈពេលពី១០ ទៅ១៥ឆ្នាំ ។ ផែនការគ្រប់គ្រងព្រៃឈើជាតិនេះនឹងផ្តោតការយកចិត្តទុកដាក់លើការរៀបចំ និងពង្រឹងរចនាសម្ព័ន្ធសម្រាប់ការគ្រប់គ្រងព្រៃឈើជាតិ ។ បង្កើនកិច្ចសហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការរៀបចំផែនការគ្រប់គ្រងព្រៃឈើជាតិមាន កសិកម្ម សុរិយោដី បរិស្ថាន ឧស្សាហកម្ម មហាផ្ទៃ សេដ្ឋកិច្ចហិរញ្ញវត្ថុ អភិវឌ្ឍន៍ជនបទ យុត្តិធម៌ អជ្ញាធរដែនដី សហគមន៍មូលដ្ឋាន វិស័យឯកជន និងសង្គមស៊ីវិល ។ ផែនការនេះនឹងផ្តោតការយកចិត្តទុកដាក់ផងដែរ ដល់ការបណ្តុះបណ្តាលធនធានមនុស្សនៅថ្នាក់មូលដ្ឋាន និងរៀបចំថវិកាឱ្យបានសមស្របសម្រាប់ការគ្រប់គ្រងព្រៃឈើនៅទូទាំងប្រទេស ។

ចំពោះអនុកម្មវិធីទី២ ការធ្វើសារពើភ័ណ្ឌព្រៃឈើជាតិ គឺមានសារៈសំខាន់ណាស់សម្រាប់ ប្រមូលទិន្នន័យព្រៃឈើ ដើម្បីងាយស្រួលធ្វើផែនការ និងគ្រប់គ្រងធនធានព្រៃឈើ ។ ដើម្បីឱ្យលទ្ធផលសារពើភ័ណ្ឌ មានគុណភាពអាចទុកចិត្តបាន ការធ្វើសារពើភ័ណ្ឌនេះគួរធ្វើឡើងវិញនៅរៀងរាល់៥ឆ្នាំម្តង ហើយត្រូវធ្វើការ បណ្តុះបណ្តាលបច្ចេកទេសសារពើភ័ណ្ឌព្រៃឈើនេះ ដល់មន្ត្រីរដ្ឋបាលព្រៃឈើ និងបណ្តាអ្នកពាក់ព័ន្ធផងដែរ ។ ផ្សេងពីនេះ ដើម្បីបង្កើនប្រសិទ្ធភាពសម្រាប់អនុកម្មវិធីនេះ ត្រូវមានការត្រួតពិនិត្យ តាមដាន វាយតម្លៃ និងរបាយការណ៍ អំពីផលប៉ះពាល់ដែលកើតមានឡើង និងរិះរកវិធានការណ៍ដោះស្រាយឱ្យបានទាន់ពេលវេលា ។

អនុកម្មវិធីទី៣ ការអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងព្រៃបម្រុងទុកអចិន្ត្រៃយ៍ក្រៅព្រៃសហគមន៍ ។ ត្រូវមានការសិក្សាហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គមជាមុន មុននឹងកែប្រែតំបន់ ទាំងនេះសម្រាប់ការអភិវឌ្ឍន៍ផ្សេងទៀត ។ ត្រូវមានការដាំដើមឈើឡើងវិញនៅតំបន់រេចរិល និងធ្វើការបែងចែកផល ប្រយោជន៍ឱ្យបាន

សមរម្យដល់ប្រជាជនដែលបានចូលរួម ។ ធ្វើការអភិវឌ្ឍន៍តំបន់មួយចំនួន ឱ្យក្លាយជាតំបន់ទេសចរណ៍ធម្មជាតិ ដើម្បីជួយបង្កើនជីវភាពប្រជាជននៅមូលដ្ឋាន ។

អនុកម្មវិធីទី៤ ការអភិរក្សធនធានសេនេទិច និងបង្កើតប្រភពគ្រាប់ពូជសម្រាប់កម្មវិធីដាំឈើ ។ ត្រូវបង្កើតចំការពូជឈើឱ្យបានច្រើនកន្លែង និងធ្វើការប្រមូលគ្រាប់ ពីចំការទាំងនេះសម្រាប់ការដាំដុះព្រៃឈើ ។ ជម្រុញការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដើម្បីបណ្តុះស្មារតីប្រជាជនមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ឱ្យយល់ច្បាស់ពីតម្លៃធនធានសេនេទិចព្រៃឈើ និងចូលរួមក្នុងការអភិរក្សធនធានសេនេទិចនេះ ។ ផ្តើមចេញពីការអភិរក្សធនធានសេនេទិចនេះ ធនធានព្រៃឈើល្អៗនឹងត្រូវបានរក្សាទុក សម្រាប់រួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ជាពិសេសរក្សាបាននូវប្រភេទឈើដែលជិតផុតពូជ និងប្រភេទឈើដែលមានដោយកម្រ សម្រាប់កូនចៅយើងជំនាន់ក្រោយ ។

អនុកម្មវិធីទី៥ ការអភិវឌ្ឍន៍ចំការដាំឈើសម្រាប់ការប្រើប្រាស់ច្រើនយ៉ាង ។ មានប្រភេទឈើជាច្រើន ដែលសមស្របសម្រាប់ដាំដុះក្នុងអនុកម្មវិធីនេះ: បេង នាងនួន ធ្នង់ គ្រើល គគីរ ឈើទាល កន្ទុំថេត អង្កាដី ខ្លឹមចន្ទន៍ អង្កាញ់ ម៉ៃសាក់ ប្រេងខ្យល់ អាកាស្យា ។ល ។ ត្រូវមានការលើកទឹកចិត្ត និងបណ្តុះបណ្តាលបច្ចេកទេសដល់សហគមន៍ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ដើម្បីឱ្យចូលរួមក្នុងការបង្កើតចំការដាំឈើ សម្រាប់ការប្រើប្រាស់ច្រើនយ៉ាងនេះ ។ ពីចំការដាំឈើទាំងនេះ គម្របព្រៃឈើនឹងត្រូវបានបង្កើន ហើយចំការដាំឈើទាំងនេះនឹងរួមចំណែកក្នុងកិច្ចការពារបរិស្ថាន ជួយបង្កើនជីវភាពប្រជាជន និងកាត់បន្ថយការដកហូតយកធនធានព្រៃឈើពីព្រៃធម្មជាតិ ។

អនុកម្មវិធីទី៦ ការអភិរក្សធនធានជីវៈចំរុះ និងការអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ ។ មានបញ្ហាប្រឈមជាច្រើន នៅក្នុងអនុកម្មវិធីនេះ: ប្រជាជនខ្វះមុខរបរចិញ្ចឹមជីវិត ជំរុញឱ្យមានការបរបាញ់ និងជួញដូរសត្វព្រៃ ។ មានជនប្រដាប់អាវុធ និងអ្នកមានអំណាចនៅពីក្រោយខ្នងក្នុងការកាប់បំផ្លាញព្រៃឈើ និងការជួញដូរ សត្វព្រៃ ហើយការអនុវត្តន៍ច្បាប់នៅមានកម្រិតនៅឡើយ ។ ខ្វះការចូលរួមឱ្យបានទូលំទូលាយពីសហគមន៍មូលដ្ឋាន ក្នុងការទប់ស្កាត់ និងបង្រ្កាបបទល្មើសព្រៃឈើ និងសត្វព្រៃ ។ សម្រាប់ការដោះស្រាយបញ្ហាទាំងនេះ ត្រូវបង្កើនការិតជីវភាពរស់នៅរបស់ប្រជាជនកុំឱ្យពឹងផ្អែកលើការកាប់បំផ្លាញព្រៃឈើនិងជួញដូរសត្វព្រៃ ។ ត្រូវបង្កើតប្រព័ន្ធផ្សព្វផ្សាយច្បាប់និងការគ្រប់គ្រងជីវចម្រុះ និងជម្រុញកាអនុវត្តន៍ច្បាប់ឱ្យបានម៉ឺងម៉ាង់ ។

អនុកម្មវិធីទី៧ ការកែច្នៃផលិតផលឈើ និងទីផ្សារ ។ ដើម្បីពង្រឹងការកែច្នៃផល អនុផលព្រៃឈើ ត្រូវមានរោងចក្រកែច្នៃផលអនុផលព្រៃឈើឱ្យបានច្រើន ហើយការកែច្នៃត្រូវមានស្តង់ដា ដើម្បីតម្រូវទៅតាមទីផ្សារ ។ ត្រូវកែច្នៃឈើដែលមិនមានតម្លៃ ឱ្យទៅជាផលិតផល ដែលមានតម្លៃវិញ ។ ត្រូវបំផុសប្រជាជនឱ្យកែច្នៃ

ផល អនុផលព្រៃឈើជាវត្ថុអនុស្សាវរីយ៍ ដូចជា រូបផ្សោត រូបត្រី ចង្កេ ល្អី ។ល។ ដើម្បីសម្រេចបានការងារនេះ ត្រូវមានវគ្គបណ្តុះបណ្តាលដល់សហគមន៍ស្តីពីការកែច្នៃផល អនុផលព្រៃឈើ ។ ដើម្បីឱ្យមានទីផ្សារទូលំទូលាយ សម្រាប់ផលិតផលកែច្នៃ សហគមន៍ត្រូវសហការជាមួយរដ្ឋបាលព្រៃឈើ និងអង្គការនានា ដើម្បីលក់ផលិតផល ដែលខ្លួនធ្វើបាន ហើយត្រូវបញ្ឈប់ការនាំចូលផលិតផលកែច្នៃពីបរទេស និងបង្កើនការផ្សព្វផ្សាយពីផលិតផល ដែលសហគមន៍ធ្វើបាន ។ ចំពោះ ផលិតផលកែច្នៃដោយដៃរបស់សហគមន៍មូលដ្ឋាន ត្រូវបានគេនិយមយ៉ាងខ្លាំងលើទីផ្សារ តែត្រូវចំណាយពេលយូរ បើប្រៀបធៀបទៅនឹងការកែច្នៃដោយម៉ាស៊ីន ។

អនុកម្មវិធីទី៨ អភិវឌ្ឍបច្ចេកវិជ្ជាឈើ និងការកែច្នៃឈើ ។ អនុកម្មវិធីនេះផ្តល់ប្រយោជន៍ យ៉ាងច្រើនដល់សហគមន៍ សម្រាប់អភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយបានផ្តល់ការងារ ប្រាក់ចំណូលដល់សហគមន៍ និងអភិវឌ្ឍន៍ចំណេះដឹងពីបច្ចេកទេសកែច្នៃឈើទៀតផង ។ ចំពោះដៃគូសម្រាប់ការអភិវឌ្ឍន៍បច្ចេកវិជ្ជាឈើ និងការកែច្នៃ មាន: សហគមន៍មូលដ្ឋាន រដ្ឋបាលព្រៃឈើ អង្គការជាតិ អន្តរជាតិ ក្រសួងរ៉ែកិច្ច និងហិរញ្ញវត្ថុ ម្ចាស់រោងសិប្បកម្ម ក្រុមហ៊ុនឯកជន ។ល។ ការអភិវឌ្ឍន៍បច្ចេកវិជ្ជាឈើ និងការកែច្នៃនេះ មានបញ្ហាប្រឈមជាច្រើន: ខ្វះធនធានមនុស្ស បច្ចេកទេស ថវិកា បទពិសោធន៍ និងគ្មានទីផ្សារពិតប្រាកដ ។

● **ក្រុម៣** ធ្វើបទបង្ហាញដោយលោក **សែ សូភី** តំណាងអង្គការ DPA ខេត្តរតនគីរី:

អនុកម្មវិធីទី១ ការកែទំរង់ច្បាប់ និងរដ្ឋបាល ។ សម្រាប់អនុកម្មវិធីនេះ ត្រូវមានការរៀបចំ លិខិតបទដ្ឋានដោយមានការចូលរួមផ្តល់យោបល់ពីគ្រប់ភាគីពាក់ព័ន្ធ ។ ត្រូវធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធគ្រប់គ្រងឱ្យបានល្អប្រសើរជាងមុន ឧទាហរណ៍ ខណ្ឌរដ្ឋបាលព្រៃឈើខ្លះ ដែលគ្រប់គ្រងលើទឹកដីបីខេត្ត គួរសំរួលមកឱ្យគ្រប់គ្រងតែមួយខេត្តបានហើយ ។ ត្រូវធ្វើការបណ្តុះ បណ្តាលក្នុងការដោះស្រាយទំនាស់ ក្នុង និងក្រៅប្រព័ន្ធតុលាការ ។

អនុកម្មវិធីទី២ ពង្រឹងការអនុវត្តច្បាប់ ការតាមដាននិងរាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើ ។ ចំពោះអនុកម្មវិធីនេះ គួរធ្វើការប្តូរពាក្យ “កិច្ចសហប្រតិបត្តិការជាមួយគណៈកម្មាធិការជាតិ អនុគណៈកម្មាធិការខេត្ត...” ទៅជា “ពង្រឹងតួនាទីជាលេខាប្រតិបត្តិក្នុងគណៈកម្មាធិការជាតិ អនុគណៈកម្មាធិការខេត្ត...” វិញ ។ ដើម្បីពង្រឹងការអនុវត្តន៍ច្បាប់ និងអភិបាលកិច្ច ត្រូវមានការពាក់ព័ន្ធទៅនឹងស្ថាប័នជាច្រើន: ស្ថាប័នតុលាការ សម្រាប់បើកសវនាការជំនុំជំរះរឿងបទល្មើសព្រៃឈើឱ្យទាន់ពេលវេលា ព្រះរាជអាជ្ញាដើម្បីធ្វើការស្រាវជ្រាវ ទប់ស្កាត់ និង បង្ក្រាប បទល្មើសព្រៃឈើ និង គណៈមេធាវី សម្រាប់ការការពារក្តីបទល្មើសព្រៃឈើ ដោយមិនគិតកំរៃសេវាកម្ម ។ អជ្ញាធរមូលដ្ឋាន សម្រាប់ការចូលរួមសហការជាមួយរដ្ឋបាលព្រៃឈើក្នុងការស្រាវជ្រាវ ទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើគ្រប់ប្រភេទ គ្រប់គ្រងជនចំណាក ចំណូលស្រុក និងបញ្ឈប់ការចេញលិខិត លក់ ទិញ និងកាន់កាប់ដីព្រៃឈើ ។ កងកំលាំងប្រដាប់អាវុធ សម្រាប់កំលាំងសហការ និងអន្តរាគមន៍តាមការស្នើសុំ

ពីសមត្ថកិច្ចជំនាញក្នុងការស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ ។ មន្ទីរពាក់ព័ន្ធនានាសម្រាប់ការផ្តល់ពតិមាន និងអប់រំផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងវិស័យព្រៃឈើ ។ សហគមន៍មូលដ្ឋានដើម្បីផ្តល់ពតិមាន និងចូលរួមស្រាវជ្រាវ ទប់ស្កាត់បទល្មើសព្រៃឈើនិងចូលរួមថែរក្សាការពារធនធានព្រៃឈើ ។ អង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ដើម្បីផ្តល់នូវការគាំទ្រខាងផ្នែកថវិកា បច្ចេកទេស និងការបណ្តុះបណ្តាលធនធានមនុស្ស ។

ដើម្បីទទួលបានអភិបាលកិច្ចល្អក្នុងវិស័យព្រៃឈើ ត្រូវមានផែនការសកម្មភាព មានថវិកា មធ្យោបាយសម្ភារៈគ្រប់គ្រាន់សម្រាប់បំពេញការងារ ។ ត្រូវបង្កើនការផ្សព្វផ្សាយជាសាធារណៈ ដើម្បីទាក់ទាញការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ។ ត្រូវពង្រឹងការអនុវត្តន៍ច្បាប និងបង្កើនកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ ។

ដើម្បីបង្កើនការយល់ដឹងជាសាធារណៈអំពីច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋាននានា ការផ្សព្វផ្សាយគួរធ្វើឡើងតាមរូបភាព: ការបើកសិក្ខាសាលា ការចុះប្រជុំដល់មូលដ្ឋាន ផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី ផ្ទាំងប៉ាណូ ការសំដែងសិល្បៈ វេទិកាសាធារណៈ គេហទំព័រ និងកម្មវិធីសិក្សា ។

ចំពោះមធ្យោបាយផ្តល់ព័ត៌មានបទល្មើសព្រៃឈើ គួរធ្វើតាមទូរស័ព្ទ វិទ្យុទាក់ទង លិខិតស្នាម ផ្ទាល់មាត់ បណ្តាញផ្តល់ពតិមាន ជនបង្គោល ។ល ។

● **ក្រុម៤** ធ្វើបទបង្ហាញដោយលោក **ជីញ ស៊ីម** តំណាងសហគមន៍ប៊ុរីអូរស្វាយ ខេត្តស្ទឹងត្រែង ។

ចំពោះការចូលរួមគ្រប់គ្រងធនធានព្រៃឈើគឺមានការលំបាកដោយៈ ការយល់ដឹងពីផលប្រយោជន៍សហគមន៍ព្រៃឈើនៅមានកំរិត ខ្វះថវិកាសម្រាប់ការរៀបចំសហគមន៍ព្រៃឈើ ល្បឿននៃការបំផ្លាញព្រៃឈើលឿនជាងល្បឿននៃការអភិវឌ្ឍន៍សហគមន៍ព្រៃឈើ ។ ខ្វះការសហការជាមួយអជ្ញាធរ និងស្ថាប័នពាក់ព័ន្ធ ក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើ ។ មានការគាំទ្រការបំផ្លាញព្រៃឈើពីអ្នកមានប្រាក់ អ្នកមានអំណាច និងជនប្រដាប់អាវុធ ។ ការអនុវត្តន៍ច្បាប់លើបទល្មើសព្រៃឈើនៅមានកំរិត ។ ភាពក្រីក្រជំរុញឱ្យមានការបំផ្លាញព្រៃឈើ និងសត្វព្រៃ និងបង្កឱ្យមានទំនាស់ផ្សេងៗក្នុង និងក្រៅសហគមន៍ ។ ខ្វះការផ្សព្វផ្សាយពីការផ្ទេរដីព្រៃឈើទៅជាដីសម្បទានសេដ្ឋកិច្ចដល់សហគមន៍មូលដ្ឋាន ។

ដើម្បីឱ្យការគ្រប់គ្រងសហគមន៍ព្រៃឈើបានល្អប្រសើរៈ គួរប្តូរចំណងជើង “ ការកំណត់សក្តានុពលសហគមន៍ព្រៃឈើ ” ទៅជា “ ការបង្កើតសហគមន៍ព្រៃឈើ ” វិញ ។ ហើយត្រូវបន្ថែមអនុកម្មវិធីទី៤ “ ការត្រួតពិនិត និងវាយតំលៃ ” ដើម្បីតំរង់ទិស អនុកម្មវិធិទី ១ ទី២ និងទី៣ និងគួរបន្ថែមសកម្មភាពទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃ ។

សម្រាប់អនុកម្មវិធីនិមួយៗ គួរមានសកម្មភាពខ្លះបន្ថែមទៀតៈ

ក្នុងអនុកម្មវិធីទិ១ នៅចន្លោះជំហាន០ និងជំហាន១ គួរបន្ថែមជំហាន "ផ្សព្វផ្សាយ" ។ ចន្លោះជំហាន ៣ និង ៤ គួរបន្ថែម "ការស្នើសុំបង្កើតព្រៃសហគមន៍ទៅនាយខ័ណ្ឌរដ្ឋបាលព្រៃឈើ " និងត្រូវជំរុញឱ្យមានការទទួលស្គាល់សហគមន៍ព្រៃឈើឱ្យបានឆាប់ ។

នៅក្នុងអនុកម្មវិធីទី២ គួរបន្ថែម ការបណ្តុះបណ្តាលជំនាញកែច្នៃផល អនុផលព្រៃឈើ និងស្វែងរកទីផ្សារផល អនុផលព្រៃឈើដល់សហគមន៍ និងត្រូវជួយសហគមន៍ក្នុងការរក្សាគុណភាពអនុផលព្រៃឈើដូចជា ជ័រ ទឹកឃ្មុំ... ។

ក្នុងអនុកម្មវិធីទី៣ គួរបន្ថែម សកម្មភាពទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃក្នុងព្រៃសហគមន៍ និងតម្រូវឱ្យមានការត្រួតពិនិត្យ និងវាយតំលៃឱ្យបានសមស្រប ។

សម្រាប់រយៈពេល៥ឆ្នាំដំបូងក្នុងការងារសហគមន៍ព្រៃឈើ ត្រូវមានសកម្មភាពសំខាន់ៗមួយចំនួនៈ ជំរុញការចុះកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើដែលមានស្រាប់ឱ្យបានលឿន និងបន្តការគាំទ្រដល់សហគមន៍ព្រៃឈើ ដែលបង្កើតថ្មី ។ បង្កើនសមត្ថភាពសមាជិកសហគមន៍ព្រៃឈើ និងត្រូវជួយស្វែងរកទីផ្សារ អនុផលព្រៃឈើសម្រាប់សហគមន៍ ។ ត្រូវជំរុញការផ្សព្វផ្សាយច្បាប់ស្តីពី ការបង្កើតសហគមន៍ព្រៃឈើ និងច្បាប់ពាក់ព័ន្ធ ។ រៀបចំក្រុមយុវជន យុវនារីដើម្បីចូលរួមក្នុងសកម្មភាពការងារសហគមន៍ព្រៃឈើ ។ ប្រើប្រាស់ថវិកា វិនិយោគឃុំ ស្រុក ខេត្តដើម្បីគាំទ្រការងារសហគមន៍ព្រៃឈើ និងត្រូវពង្រឹងការអនុវត្តច្បាប់ ក្នុងការទប់ស្កាត់ បទល្មើសព្រៃឈើ ។

ចំពោះការងារសហការរវាងសហគមន៍ព្រៃឈើ និងស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតក្រុមការងារមួយនៅថ្នាក់ឃុំ ស្រុក និងខេត្ត ដើម្បីធ្វើការគាំទ្រដល់សហគមន៍ព្រៃឈើ និងត្រូវជំរុញឱ្យមានការគាំទ្រដល់សហគមន៍ព្រៃឈើបន្ថែមទៀតពីសំណាក់អជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ។

ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ សហគមន៍ព្រៃឈើត្រូវៈ ធ្វើការដាំដុះបន្ថែម និងរៀចំការការពារព្រៃសហគមន៍ឱ្យបានគង់វង់ និងធ្វើការអភិវឌ្ឍន៍ឱ្យក្លាយជាតំបន់ទេសចរណ៍ធម្មជាតិ ។ ត្រូវធ្វើការដកហូតផល អនុផល ព្រៃឈើទៅតាមបទដ្ឋានបច្ចេកទេស ដើម្បីធានានូវនិរន្តរភាពព្រៃឈើ និងត្រូវបង្កើនទីផ្សារផល អនុផលព្រៃឈើរបស់សហគមន៍ ។

នៅក្នុងកាអនុវត្តន៍ សហគមន៍ព្រៃឈើត្រូវមានចំណេះដឹង និងជំនាញថ្មីៗបន្ថែមទៀតៈ ជំនាញបច្ចេកទេសសម្រាប់ការគ្រប់គ្រងសហគមន៍ព្រៃឈើ ជំនាញក្នុងការដោះស្រាយទំនាស់ និងសម្របសម្រួល ជំនាញកសិកម្ម និងការកែច្នៃផល អនុផលព្រៃឈើ និងចំណេះដឹងលើផ្នែកច្បាប់ ។

- **ក្រុម៩** ធ្វើបទបង្ហាញដោយលោកស្រី **នេត សុខសាន** ជំទប់ទិ១ ឃុំវឌ្ឍនៈ ស្រុកសំបូរ ខេត្តក្រចេះ

អនុកម្មវិធីទី១ ការអភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស ។ ត្រូវធ្វើការផ្សព្វផ្សាយអំពីកម្មវិធីព្រៃឈើជាតិដល់សហគមន៍មូលដ្ឋានដើម្បីឱ្យមានការយល់ដឹងទូលំទូលាយ និងធ្វើការបណ្តុះបណ្តាលពីផលប្រយោជន៍ ព្រៃឈើ និងជំនាញផ្សេងទៀតពាក់ព័ន្ធនឹងវិស័យព្រៃឈើដល់សហគមន៍មូលដ្ឋាន ។ ធ្វើការជ្រើសរើសមន្ត្រីថ្មី និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងរដ្ឋបាលព្រៃឈើ ។

អនុកម្មវិធីទី២ ការផ្សព្វផ្សាយព្រៃឈើ និងបង្កើនការយល់ដឹងជាសាធារណៈ ។ បង្កើនសកម្មភាពផ្សព្វផ្សាយពីវិស័យព្រៃឈើ ដល់គ្រូបង្រៀន សិស្ស និស្សិត និងកំណត់ក្រុមគោលដៅឱ្យបានច្បាស់សម្រាប់ការផ្សព្វផ្សាយ ។ បង្កើតមធ្យោបាយ និងសម្ភារៈផ្សព្វផ្សាយ មានៈ ការដាក់តាំងឯកសារសំខាន់ៗពាក់ព័ន្ធវិស័យព្រៃឈើ ការប្រជុំ ការលើកប៉ាណូ ការបញ្ចាំងវីដេអូ ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍... ។

អនុកម្មវិធីទី៣ ការអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ ។ បង្កើតគណៈកម្មាធិការតម្រង់ទិសមួយ សម្រាប់ការស្រាវជ្រាវព្រៃឈើ ដែលនឹងផ្តោតសំខាន់ទៅលើផ្នែក សេដ្ឋកិច្ច សង្គម បរិស្ថាន និងច្បាប់ ។ នៅក្នុងវិទ្យាស្ថានស្រាវជ្រាវព្រៃឈេិ និងសត្វព្រៃ ត្រូវមានធនធានមនុស្ស សម្ភារៈបរិក្ខា និងថវិកាគ្រប់គ្រាន់ សម្រាប់ការស្រាវជ្រាវ ។ ការស្រាវជ្រាវ គួរយកចិត្តទុកដាក់លើៈការកំណត់អត្តសញ្ញាណព្រៃជំនឿសាសនា ដែលពាក់ព័ន្ធទៅនឹងការរស់នៅរបស់ប្រជាជន ។ ប្រសិទ្ធិភាពនៃការចូលរួមគ្រប់គ្រងព្រៃឈើរបស់សហគមន៍ មូលដ្ឋាន ។ សិក្សាស្រាវជ្រាវអំពីធនធានធម្មជាតិគ្រប់ប្រភេទដែលជាតម្រូវការសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ការអភិរក្ស និងមុខងារ បរិស្ថាន ។ សិក្សាស្រាវជ្រាវពីរុក្ខជាតិសម្រាប់ធ្វើជាឱសថ ប្រភេទឈើ និងសត្វព្រៃ ដែលមានដោយកម្រ និងជិតផុតពូជ ។

ចំពោះអនុកម្មវិធីទី៤ វិញ្ញាបនប័ត្រព្រៃឈើ គួរដាក់បញ្ចូលកម្មវិធីនេះក្នុងកម្មវិធីព្រៃឈើជាតិ ព្រោះវាមានសារសំខាន់ណាស់ក្នុងការគ្រប់គ្រងព្រៃឈើតាមក្រមបច្ចេកទេសដើម្បីធានានិរន្តរភាពព្រៃឈើ បង្កើនតម្លៃផលិត ផល និងទីផ្សារព្រៃឈើ ។ លើសពីនេះ វិញ្ញាបនប័ត្រព្រៃឈើ នឹងជួយដល់រដ្ឋបាលព្រៃឈើ និងសហគមន៍មូលដ្ឋានឱ្យមានការងាយស្រួលក្នុងការអនុវត្តន៍ច្បាប់ដើម្បីធានានិរន្តរភាពព្រៃឈើទៀតផង ។

● **ក្រុម៦** ធ្វើបទបង្ហាញដោយលោកស្រី **មុំ សាគីន** តំណាងបណ្តាញ CPN ខេត្តក្រចេះ ។ ឯកសារគោលកម្មវិធីព្រៃឈើជាតិ នៅមានចំណុចខ្វះខាតមួយចំនួន ហើយគួរៈ ដូរពាក្យ “ទស្សនទាន” ទៅជា “ទស្សនវិស័យ” វិញ ហើយត្រូវដាក់គោលបំណង និងគោលដៅឱ្យបានច្បាស់លាស់ ។ ត្រូវកែចំណងជើងផ្នែកទី៣ នៃឯកសារគោល “បញ្ហាប្រឈមក្នុងវិស័យព្រៃឈើ” ទៅជា “បញ្ហាប្រឈម និងសក្តានុពលក្នុងវិស័យព្រៃឈើ” វិញ ។ គួរមានដាក់បញ្ហាបញ្ច្រាបយេនឌ័រ ក្នុងផ្នែកណាមួយនៃកម្មវិធីព្រៃឈើជាតិផង ។

ភាគីពាក់ពន្ធ័នៅថ្នាក់មូលដ្ឋានអាចចូលរួមតាមដាន និងវាយតំលៃការអនុវត្តន៍កម្មវិធីព្រៃឈើជាតិតាមរយៈ ក្រុមការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃ ដែលមានការចូលរួមពីគ្រប់ភាគីពាក់ពន្ធ័ រួមទាំងសហគមន៍

មូលដ្ឋាន និងតាមរយៈសិក្ខាសាលាសម្រាប់ការឆ្លុះបញ្ចាំងកម្មវិធីព្រៃឈើជាតិនៅថ្នាក់ខេត្ត ដែលនឹងរៀបចំឡើង ១ឆ្នាំម្តង និងនៅថ្នាក់ជាតិ ២ឆ្នាំម្តង ។

ចំពោះសូចនករ សំរាប់តាមដានវាយតំលៃការអនុវត្តកម្មវិធីព្រៃឈើជាតិមានៈ គោលដៅអភិវឌ្ឍន៍សហសវត្សឆ្នាំ២០១៥ ដែលគម្របព្រៃឈើនឹងត្រូវឱ្យកើនឡើងដល់៦០% ។ របាយការណ៍តាមដានត្រួតពិនិត្យ ការប្រជុំបូកសរុបវាយតម្លៃលទ្ធផល និងផែនការអនុវត្តន៍ ។

ដើម្បីគ្រប់គ្រងព្រៃសម្បទានដែលត្រូវបានផ្អាកដំណើរការ ត្រូវកំណត់រយៈពេលរៀបចំផែនការគ្រប់គ្រងរបស់ក្រុមហ៊ុនព្រៃសម្បទាន មិនឱ្យលើសពីដំណាច់ឆ្នាំ២០១០ ។ ដោយឡែក ចំពោះព្រៃសម្បទានដែលត្រូវបានលុបកិច្ចព្រមព្រៀង ត្រូវធ្វើការដាំដើមឈើឡើងវិញ ឬត្រូវបង្កើតសហគមន៍ព្រៃឈើ ឬត្រូវរៀបចំជាព្រៃការពារ ។

ក្នុងការដោះស្រាយទំនាស់ដែលកើតឡើងពីការផ្តល់ដីសម្បទានសេដ្ឋកិច្ច កម្មវិធីព្រៃឈើជាតិមានសារសំខាន់ណាស់ ដោយធ្វើឱ្យអជ្ញាធរមូលដ្ឋានអាចគ្រប់គ្រងដីព្រៃឈើ ដីភោគៈ និងដីលំនៅដ្ឋានបានច្បាស់លាស់ ។ រាល់ការផ្តល់ដីសម្បទានសេដ្ឋកិច្ចនឹងត្រូវមានការផ្សព្វផ្សាយជាសាធារណៈ និងមានការចូលរួមគ្រប់ភាគីពាក់ព័ន្ធ ហើយដីរបស់ក្រុមហ៊ុននឹងត្រូវបានបោះបង្គោលព្រំរបស់ខ្លួនបានច្បាស់លាស់ ។

បន្ទាប់ពីបទបង្ហាញរបស់ក្រុម សំនួរពាក់ព័ន្ធនឹងលទ្ធផលពិភាក្សា ត្រូវបានអនុញ្ញាតជូនសិក្ខាកាម ( អត្ថបទឧបសម្ព័ន្ធទី ៧) ។



**រូបភាពទី៥:** ការធ្វើបទបង្ហាញពីលទ្ធផលពិភាក្សាតាមក្រុម



**រូបភាពទី៦:** សំនួរលើលទ្ធផលពិភាក្សាតាមក្រុម

### ៩: ពិធីបិទសិក្ខាសាលា

បន្ទាប់ពីការធ្វើបទបង្ហាញពីលទ្ធផលពិភាក្សាតាមក្រុម និងសំនួរ ចម្លើយរួចមក លោក **អៀង សាវៃត** នាយអធិការដ្ឋានរដ្ឋបាលព្រៃឈើមេគង្គ បានឡើងធ្វើសេចក្តីរាយការណ៍បូកសរុបលទ្ធផលរបស់សិក្ខាសាលា ( អត្ថបទឧបសម្ព័ន្ធទី ៨) ដែលទទួលបានក្នុងថ្ងៃនេះ ។

បន្ទាប់មក លោក **ហ៊ុល សឿង** តំណាងសិក្ខាកាមបានឡើងសំដែងការចាប់អារម្មណ៍របស់ខ្លួន និងសិក្ខាកាមទាំងអស់ថា លោក និងសិក្ខាកាមទាំងអស់មានសេចក្តីរីករាយណាស់ ដោយបានចូលរួមផ្តល់យោបល់សម្រាប់រៀបចំកម្មវិធីព្រៃឈើជាតិ នាពេលនេះ ។ សិក្ខាសាលានេះ មិនត្រឹមតែបានទទួលយកមតិយោបល់ប៉ុណ្ណោះទេ ថែមទាំងបានផ្តល់នូវចំណេះដឹង និងបទពិសោធន៍ដល់ភាគីដែលពាក់ព័ន្ធទៀតផង ។ នៅពេលត្រឡប់ទៅលំនៅដ្ឋានរបស់ខ្លួនវិញ លោកនិងសិក្ខាកាមទាំងអស់ នឹងធ្វើការផ្សព្វផ្សាយបន្តពីចំណេះដឹង ដែលទទួលបានក្នុងថ្ងៃនេះ ដល់សមាជិកសហគមន៍ដទៃទៀតឱ្យមានការចេះដឹងដូចគ្នា ដើម្បីរួមចំណែកគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព ។

បន្ទាប់មក ឯកឧត្តម **ធុន គ្រី** អភិបាលរងខេត្តក្រចេះ បានវាយតម្លៃខ្ពស់ពីការរៀបចំសិក្ខាសាលានាថ្ងៃនេះ ទោះជាដំណើរការសិក្ខាសាលាមានរយៈពេលត្រឹមតែ២ថ្ងៃក៏ដោយ តែលទ្ធផលដែលទទួលបានគឺមានទំហំធំធេង ដែលធ្វើឱ្យយើងទទួលបានមតិយោបល់យ៉ាងច្រើនសម្រាប់ធ្វើការអភិវឌ្ឍន៍កម្មវិធីព្រៃឈើជាតិមួយ ដែលបម្រើផលប្រយោជន៍ ឱ្យគ្រប់ភាគីពាក់ព័ន្ធ ។

នៅចុងបបញ្ចប់នៃកម្មវិធី ឯកឧត្តម **ជា សំអាង** អនុប្រធានរដ្ឋបាលព្រៃឈើ បានឡើងថ្លែងសុន្ទរកថាបិទសិក្ខាសាលា ដោយបានថ្លែងអំណរគុណដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ដែលបានចូលរួមផ្តល់យោបល់ក្នុងថ្ងៃនេះ ។ ដូចនេះនាពេលដ៏ខ្លីខាងមុខនេះ យើងនឹងមានកម្មវិធីព្រៃឈើជាតិមួយសម្រាប់ការគ្រប់គ្រងព្រៃឈើនៅទូទាំងប្រទេសឱ្យមាននិរន្តរភាព ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីរួមចំណែកក្នុងកិច្ចការបរិស្ថាន ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងកាត់បន្ថយភាពក្រីក្រ ។

### ៥: សេចក្តីសន្និដ្ឋាន

សិក្ខាសាលាបានប្រព្រឹត្តទៅប្រកបដោយជោគជ័យ ដោយទទួលបានការចូលរួមផ្តល់យោបល់យ៉ាងផុលផុស ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ។ មតិយោបល់របស់សិក្ខាកាមដែលបានលើកឡើង មានការពាក់ព័ន្ធភាគច្រើនទៅនឹង ការអនុវត្តន៍ច្បាប់ ការផ្សព្វផ្សាយ កិច្ចសហការ និងការបណ្តុះបណ្តាល ។

រាល់មតិយោបល់ទាំងនេះ សុទ្ធតែមានសុឆន្ទៈខ្ពស់ក្នុងការអភិវឌ្ឍន៍កម្មវិធីព្រៃឈើជាតិមួយ ដើម្បីឱ្យការគ្រប់គ្រងព្រៃឈើទទួលបាននិរន្តរភាពផង និងធានាបាននូវផលប្រយោជន៍របស់សហគមន៍មូលដ្ឋានផង ។

### ៦: អនុសាសន៍

ដើម្បីឱ្យកម្មវិធីព្រៃឈើជាតិ ធានាបាននិរន្តរភាពក្នុងការគ្រប់គ្រងព្រៃឈើ និងធានាបានផលប្រយោជន៍របស់បណ្តាភាគីពាក់ព័ន្ធទាំងអស់ កម្មវិធីនេះគួរផ្តោតការយកចិត្តទុកដាក់លើ:

-ពង្រឹងការអនុវត្តន៍ច្បាប់សម្រាប់វិស័យព្រៃឈើឱ្យបានរឹងមាំបន្ថែមទៀត ក្នុងការទប់ស្កាត់ការកាប់ទន្រ្ទានយកដីព្រៃឈើ និងបង្ក្រាបបទល្មើសព្រៃឈើ

-លើកកំពស់ការផ្សព្វផ្សាយជាសាធារណៈស្តីពីវិស័យព្រៃឈើឱ្យបានទូលំទូលាយឡើងថែមទៀត ដើម្បីទាក់ទាញការចូលរួមពីភាគីពាក់ព័ន្ធ និងបង្កើនការយល់ដឹងពីព្រៃឈើ ។

-បង្កើនកិច្ចសហការជាមួយបណ្តាស្ថាប័នពាក់ព័ន្ធ សម្រាប់ការផ្សព្វផ្សាយពីវិស័យព្រៃឈើ ទប់ស្កាត់ និងបង្ក្រាបបទ ល្មើសព្រៃឈើ ។

-ជំរុញឱ្យមានការបណ្តុះបណ្តាលលើជំនាញ និងចំណេះដឹងផ្សេងទៀតពាក់ព័ន្ធនឹងវិស័យព្រៃឈើ ដល់មន្ត្រីរដ្ឋបាលព្រៃឈើ សហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធ ។

-គួរដាក់បញ្ចូល បញ្ហាបញ្ច្រាបយេនឌ័រទៅក្នុងកម្មវិធីណាមួយនៃកម្មវិធីព្រៃឈើជាតិ ។

- រាល់មតិយោបល់ដែលទទួលបាន នឹងយកទៅពិគ្រោះបន្តជាមួយអ្នករៀបចំកម្មវិធី ដើម្បីជ្រើសរើសយកមតិយោបល់ល្អៗ សម្រាប់ធ្វើការអភិវឌ្ឍន៍កម្មវិធី ( អត្ថបទឧបសម្ព័ន្ធទី ៩) ។

# សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ

## សណ្ឋាគារ ហូលីដេ ផាលេស ក្រុងព្រះសីហនុ ថ្ងៃទី ១៦-១៧ ខែមិនា ឆ្នាំ២០០៩

| កាលបរិច្ឆេទ | ពេលវេលា | កម្មវត្ថុ | វិធីសាស្ត្រ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ១៦ មិនា | ០៨:០០-០៨:៣០ | ចុះឈ្មោះ | ចុះហត្ថលេខា | អ្នកជំនួយការ |
| | ០៨:៣០-០៩:០០ | - សុន្ទរកថាស្វាគមន៍<br>- សុន្ទរកថាបើក | មតិ | - អភិបាលខេត្តពោធិសាត់<br>- ប្រធាន រដ្ឋបាលព្រៃឈើ |
| | ០៩:០០-១០:០០ | សេចក្តីផ្តើម<br>- គោលបំណង និងលទ្ធផលរំពឹងទុកពីសិក្ខាសាលា<br>- ដំណើរការអភិវឌ្ឍកម្មវិធីព្រៃឈើជាតិ | បទបង្ហាញ | សុខ ហេង |
| | ១០:០០-១០:៣០ | **អាហារសំរន់** | | |
| | ១០:៣០-១០:៥០ | បទបង្ហាញអំពីឯកសារគោលកម្មវិធីព្រៃឈើជាតិ | បទបង្ហាញ | សុខ ហេង |
| | ១០:៥០-១១:២០ | បទបង្ហាញកម្មវិធីទី១: ការកំណត់ព្រំប្រទល់ | បទបង្ហាញ | លោក មាស មករា និង លោក លាង ហ៊ន |
| | ១១:២០-១២:០០ | បទបង្ហាញកម្មវិធីទី២: ការគ្រប់គ្រង និងអភិរក្សព្រៃឈើ | បទបង្ហាញ | លោក ឃន សារ៉េត លោក សា មករា លោក ហង់ ស៊ុនត្រា លោក អួន សំអុល លោក ឈាង ដានី |
| | ១២:០០-១៣:២០ | **អាហារថ្ងៃត្រង់** | | |
| | ១៣:២០-១៤:០០ | បទបង្ហាញកម្មវិធីទី៣: ការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ | បទបង្ហាញ | លោក សួន សុវណ្ណ |
| | ១៤:០០-១៤:៤០ | បទបង្ហាញកម្មវិធីទី៤: សហគមន៍ព្រៃឈើ | បទបង្ហាញ | លោក ឡាវ សេដ្ឋាផល |
| | ១៤:៤០-១៥:១០ | បទបង្ហាញកម្មវិធីទី៥: ការកសាងសមត្ថភាព និងអភិវឌ្ឍការស្រាវជ្រាវ | បទបង្ហាញ | លោក ចាន់ សុផល លោក ប៊ុន រ៉ាដា លោក នុព សុធា លោក សិរិទ្ធ វណ្ណា |
| | ១៥:១០-១៥:៤០ | **អាហារសំរន់** | | |
| | ១៥:៤០-១៦:០០ | បទបង្ហាញកម្មវិធីទី៦: ហិរញ្ញវត្ថុ ព្រៃឈើ | បទបង្ហាញ | លោក ម៉ា សុខថា |
| | ១៦:០០-១៧:៣០ | សំនួរ និងចំលើយ | | សុខ ហេង និងអ្នកចងក្រងកម្មវិធី |
| ១៧ មិនា | ០៨:០០-០៩:៣០ | ពិភាក្សាតាមក្រុម | ប្រមូលមតិ | អ្នកបច្ចេកទេស និងអ្នកចងក្រង |
| | ០៩:៣០-១០:០០ | **អាហារសំរន់** | | |
| | ១០:០០-១២:០០ | ពិភាក្សាតាមក្រុម | ប្រមូលមតិ | អ្នកបច្ចេកទេស និងអ្នកចងក្រង |
| | ១២:០០-១៤:០០ | **អាហារថ្ងៃត្រង់** | | |
| | ១៤:០០-១៥:៣០ | ចែករំលែកលទ្ធផលពីក្រុមពិភាក្សា | ប្រមូលមតិ | អ្នកបច្ចេកទេស និងអ្នកចងក្រង |
| | ១៥:៣០-១៦:០០ | **អាហារសំរន់** | | |
| | ១៦:០០-១៧:៣០ | - -សុន្ទរកថាចាប់អារម្មណ៍<br>- សុន្ទរកថាចាប់អារម្មណ៍<br>- បិទអង្គសិក្ខាសាលា | បទបង្ហាញ | - អ្នកបច្ចេកទេស<br>- ឯ.ឧ. ជា សំអាង |

# សិក្ខាសាលាពិគ្រោះយោបល់លើសេចក្ដីព្រាងកម្មវិធីព្រៃឈើជាតិ

**ទីកន្លែង: មជ្ឈមណ្ឌលអភិវឌ្ឍន៍ ប៊ុន រ៉ានី ហ៊ុន សែន ខេត្តពោធិ៍សាត់ ថ្ងៃទី ១៩-២០ ខែមិនា ឆ្នាំ២០០៩**

| កាលបរិច្ឆេទ | ពេលវេលា | កម្មវត្ថុ | វិធីសាស្ត្រ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ១៩ មិនា | ០៨:០០-០៨:៣០ | ចុះឈ្មោះ | ចុះហត្ថលេខា | អ្នកជំនួយការ |
| | ០៨:៣០-០៩:០០ | - គោរពទង់ជាតិ<br>- សុន្ទរកថាស្វាគមន៍<br>- សុន្ទរកថាបើក | មតិ | - អ្នកសំរបសំរួល<br>- ឯ.ឧ. អភិបាលខេត្តពោធិសាត់<br>- ឯ.ឧ. ប្រធាន រដ្ឋបាលព្រៃឈើ |
| | ០៩:០០-១០:០០ | សេចក្ដីផ្ដើម<br>- គោលបំណង និងលទ្ធផលរំពឹងទុកពីសិក្ខាសាលា<br>- ដំណើរការអភិវឌ្ឍកម្មវិធីព្រៃឈើជាតិ | បទបង្ហាញ | បណ្ឌិត សុខ ហេង |
| | ១០:០០-១០:៣០ | **អាហារសំរន់** | | |
| | ១០:៣០-១០:៤០ | បទបង្ហាញអំពី ឯកសារគោលកម្មវិធីព្រៃឈើជាតិ | បទបង្ហាញ | បណ្ឌិត សុខ ហេង |
| | ១០:៤០-១១:០០ | បទបង្ហាញកម្មវិធីទី១: ការកំណត់ព្រំប្រទល់ | បទបង្ហាញ | លោក មាស មករា និង លោក លាង ហ៊ន |
| | ១១:០០-១១:៤០ | បទបង្ហាញកម្មវិធីទី២: ការគ្រប់គ្រង និងអភិរក្សព្រៃឈើ | បទបង្ហាញ | លោក ឃន សារ៉េត លោក សា មករា លោក ហង់ ស៊ុនត្រា លោក អួន សំអុល លោក ឈាង ដានី |
| | ១១:៤០-១២:០០ | បទបង្ហាញកម្មវិធីទី៣: ការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ | បទបង្ហាញ | លោក សួន សុវណ្ណ |
| | ១២:០០-១៣:០០ | **អាហារថ្ងៃត្រង់** | | |
| | ១៣:០០-១៣:២០ | បទបង្ហាញកម្មវិធីទី៤: សហគមន៍ព្រៃឈើ | បទបង្ហាញ | លោក ឡាវ សេដ្ឋាផល |
| | ១៣:២០-១៣:៤០ | បទបង្ហាញកម្មវិធីទី៥: ការកសាងសមត្ថភាព និងអភិវឌ្ឍការស្រាវជ្រាវ | បទបង្ហាញ | លោក ចាន់ សុផល លោក ប៊ុន រ៉ាដា លោក នុព សុធា លោក សិរិទ្ធ វណ្ណា |
| | ១៣:៤០-១៤:០០ | បទបង្ហាញកម្មវិធីទី៦: ហិរញ្ញវត្ថុព្រៃឈើ | បទបង្ហាញ | លោក ម៉ា សុខថា |
| | ១៤:០០-១៥:៣០ | សំនួរ និងចំលើយ | | លោក ឡុង ប៊ុង និងអ្នកចងក្រងកម្មវិធី |
| | ១៥:៣០-១៦:០០ | **អាហារសំរន់** | | |
| | ១៦:០០-១៧:៣០ | ពិភាក្សាតាមក្រុម | ប្រមូលមតិ | អ្នកបច្ចេកទេស និងអ្នកចងក្រង |
| ២០ មិនា | ០៨:០០-១០:០០ | ពិភាក្សាតាមក្រុម | ប្រមូលមតិ | អ្នកបច្ចេកទេស និងអ្នកចងក្រង |
| | ១០:០០-១០:៣០ | **អាហារសំរន់** | | |
| | ១០:០០-១២:០០ | ចែករំលែកលទ្ធផលពីក្រុមពិភាក្សា | ប្រមូលមតិ | អ្នកបច្ចេកទេស និងអ្នកចងក្រង |
| | ១២:០០-១៣:៣០ | **អាហារថ្ងៃត្រង់** | | |
| | ១៣:៣០-១៥:០០ | - -របាយការណ៍បូកសរុប<br>- មតិចាប់អារម្មណ៍របស់អ្នកចូលរួម<br>- មតិចាប់អារម្មណ៍របស់គណៈអធិបតី<br>- សុន្ទរកថាបិទអង្គសិក្ខាសាលា | | លោក ពិន ផានី<br>?<br>ឯ.ឧ. អភិបាលខេត្ត<br>ឯ.ឧ. ទឹម ស៊ីផា |
| | ១៥:០០-១៥:៣០ | **អាហារសំរន់** | | |

# សិក្ខាសាលាពិគ្រោះយោបល់សាធារណៈលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ

**ទីកន្លែង: សាលមហោស្រពខេត្ត ខេត្តក្រចេះ ថ្ងៃទី ២៥-២៦ ខែមិនា ឆ្នាំ២០០៩**

| កាលបរិច្ឆេទ | ពេលវេលា | កម្មវត្ថុ | វិធីសាស្ត្រ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ២៥ មិនា | ០៨:០០-០៨:៣០ | ចុះឈ្មោះ | ចុះហត្ថលេខា | អ្នកជំនួយការអធិការដ្ឋាន |
| | ០៨:៣០-០៩:០០ | - គោរពភ្លេងជាតិ<br>- សុន្ទរកថាស្វាគមន៍<br>- សុន្ទរកថាបើក | | - អ្នកសំរបសំរួល<br>- ឯ.ឧ. ប្រាក់ សារុំធ អភិបាលរងខេត្តក្រចេះ<br>- ឯ.ឧ. ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើ |
| | ០៩:០០-១០:០០ | សេចក្តីផ្តើម<br>- គោលបំណង និងលទ្ធផលរំពឹងទុកពីសិក្ខាសាលា<br>- ដំណើរការអភិវឌ្ឍកម្មវិធីព្រៃឈើជាតិ | បទបង្ហាញ | បណ្ឌិត សុខ ហេង |
| | ១០:០០-១០:៣០ | **អាហារសំរន់** | | |
| | ១០:៣០-១០:៥០ | បទបង្ហាញអំពីឯកសារគោលកម្មវិធីព្រៃឈើជាតិ | បទបង្ហាញ | បណ្ឌិត សុខ ហេង |
| | ១០:៥០-១១:២០ | បទបង្ហាញកម្មវិធីទី១: ការកំណត់ព្រំប្រទល់ | បទបង្ហាញ | លោក មាស មករា និង លោក លាង ហ៊ន |
| | ១១:២០-១២:០០ | បទបង្ហាញកម្មវិធីទី២: ការគ្រប់គ្រង និងអភិរក្សព្រៃឈើ | បទបង្ហាញ | លោក ឃន សារ៉េត លោក សា មករា លោក ហង់ ស៊ុនត្រា លោក អួន សំអុល លោក ឈាង ដានី |
| | ១២:០០-១៣:៣០ | **អាហារថ្ងៃត្រង់** | | |
| | ១៣:៣០-១៤:០០ | បទបង្ហាញកម្មវិធីទី៣: ការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ | បទបង្ហាញ | លោក សួន សុវណ្ណ |
| | ១៤:០០-១៤:៣០ | បទបង្ហាញកម្មវិធីទី៤: សហគមន៍ព្រៃឈើ | បទបង្ហាញ | លោក ឡាវ សេដ្ឋាផល |
| | ១៤:៣០-១៥:០០ | បទបង្ហាញកម្មវិធីទី៥: ការកសាងសមត្ថភាព និងការស្រាវជ្រាវ | បទបង្ហាញ | លោក ចាន់ សុផល លោក ប៊ុន រ៉ាដា លោក នុព សុធា លោក ស៊ីរិទ្ធ វណ្ណា |
| | ១៥:០០-១៥:៣០ | **អាហារសំរន់** | | |
| | ១៥:៣០-១៦:០០ | បទបង្ហាញកម្មវិធីទី៦: ហិរញ្ញវត្ថុ ព្រៃឈើ | បទបង្ហាញ | លោក ម៉ា សុខថា |
| | ១៦:០០-១៧:០០ | សំនួរ និងចំលើយ | | អ្នកជំនួយការបច្ចេកទេស |
| ២៦ មិនា | ០៨:០០-១០:០០ | ពិភាក្សាតាមក្រុម | ប្រមូលមតិ | អ្នកជំនួយការបច្ចេកទេស និងអ្នកចងក្រង |
| | ១០:០០-១០:៣០ | **អាហារសំរន់** | | |
| | ១០:៣០-១២:០០ | ពិភាក្សាតាមក្រុម | ប្រមូលមតិ | អ្នកជំនួយការបច្ចេកទេស និងអ្នកចងក្រង |
| | ១២:០០-១៤:០០ | **អាហារថ្ងៃត្រង់** | | |
| | ១៤:០០-១៥:៣០ | បង្ហាញលទ្ធផលនៃការពិភាក្សាតាមក្រុម | បទបង្ហាញ | តំណាងក្រុម |
| | ១៥:៣០-១៦:០០ | **អាហារសំរន់** | | |
| | ១៦:០០-១៧:០០ | - របាយការណ៍បូកសរុប<br>- មតិចាប់អារម្មណ៍របស់អ្នកចូលរួម<br>- មតិចាប់អារម្មណ៍របស់គណៈអធិបតី<br>- សុន្ទរកថាបិទអង្គសិក្ខាសាលា | | - លោក អៀង សារ៉េត នាយអធិការដ្ឋាន រព.មត<br>-<br>-<br>- ឯ.ឧ. ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើ |

# សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ

**ទីកន្លែង: សណ្ឋាគារ អលសាន់អង្គរប៉ារាឌី ខេត្តសៀមរាប ថ្ងៃទី ៣០-៣១ ខែមិនា ឆ្នាំ២០០៩**

| កាលបរិច្ឆេទ | ពេលវេលា | កម្មវត្ថុ | វិធីសាស្ត្រ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ៣០ មិនា | ០៨:០០-០៨:៣០ | ចុះឈ្មោះ | ចុះហត្ថលេខា | អ្នកជំនួយការអធិការដ្ឋាន |
| | ០៨:៣០-០៩:០០ | - គោរពទង់ជាតិ<br>- ចំណាប់អារម្មណ៍<br>- ចំណាប់អារម្មណ៍<br>- សុន្ទរកថាស្វាគមន៍<br>- សុន្ទរកថាបើក | មតិ | - អ្នកសំរបសំរួល<br>- លោក Jacob K. Jepsen<br>- អ្នកស្រី Fan Xiajie NFP Facility<br>- ឯ.ឧ. អភិបាលខេត្តសៀមរាប<br>- ឯ.ឧ. ប្រធាន រដ្ឋបាលព្រៃឈើ |
| | ០៩:០០-១០:០០ | **អាហារសំរន់** | | |
| | ១០:០០-១០:២០ | សេចក្តីផ្តើម<br>- គោលបំណង និងលទ្ធផលរំពឹងទុកពីសិក្ខាសាលា<br>- ដំណើរការអភិវឌ្ឍកម្មវិធីព្រៃឈើជាតិ | បទបង្ហាញ | បណ្ឌិត សុខ ហេង |
| | ១០:២០-១០:៤០ | បទបង្ហាញអំពីឯកសារគោលកម្មវិធីព្រៃឈើជាតិ | បទបង្ហាញ | បណ្ឌិត សុខ ហេង |
| | ១០:៤០-១១:១០ | បទបង្ហាញកម្មវិធីទី១: ការកំណត់ព្រំប្រទល់ | បទបង្ហាញ | លោក មាស មករា និង លោក លាង ហ៊ន |
| | ១១:១០-១២:០០ | បទបង្ហាញកម្មវិធីទី២: ការគ្រប់គ្រង និងអភិរក្សព្រៃឈើ | បទបង្ហាញ | លោក យន សារ៉េត លោក សា មករា លោក ហង់ ស៊ុនត្រា លោក អួន សំអុល លោក ឈាង ដានី |
| | ១២:០០-១៣:៣០ | **អាហារថ្ងៃត្រង់** | | |
| | ១៣:៣០-១៤:០០ | បទបង្ហាញកម្មវិធីទី៣: ការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ | បទបង្ហាញ | លោក សួន សុវណ្ណ |
| | ១៤:០០-១៤:៣០ | បទបង្ហាញកម្មវិធីទី៤: សហគមន៍ព្រៃឈើ | បទបង្ហាញ | លោក ឡាវ សេដ្ឋាផល |
| | ១៤:៣០-១៥:០០ | បទបង្ហាញកម្មវិធីទី៥: ការកសាងសមត្ថភាព និងការស្រាវជ្រាវ | បទបង្ហាញ | លោក ចាន់ សុផល លោក ប៊ុន រ៉ាដា លោក នុព សុធា លោក សិរីទ្ធ វណ្ណា |
| | ១៥:០០-១៥:៣០ | **អាហារសំរន់** | | |
| | ១៥:៣០-១៦:០០ | បទបង្ហាញកម្មវិធីទី៦: ហិរញ្ញវត្ថុ ព្រៃឈើ | បទបង្ហាញ | លោក ម៉ា សុខថា |
| | ១៦:០០-១៧:០០ | សំនួរ និងចំលើយ | | អ្នកជំនួយការបច្ចេកទេស |
| ៣១ មិនា | ០៨:០០-៩:៣០ | ពិភាក្សាតាមក្រុម | ប្រមូលមតិ | អ្នកជំនួយការបច្ចេកទេស និងអ្នកចងក្រង |
| | ៩:៣០-១០:០០ | **អាហារសំរន់** | | |
| | ១០:០០-១២:០០ | ពិភាក្សាតាមក្រុម | ប្រមូលមតិ | អ្នកជំនួយការបច្ចេកទេស និងអ្នកចងក្រង |
| | ១២:០០-១៤:០០ | **អាហារថ្ងៃត្រង់** | | |
| | ១៤:០០-១៥:៣០ | ចែករំលែកលទ្ធផលពីក្រុមពិភាក្សា | បទបង្ហាញ | អ្នកជំនួយការបច្ចេកទេស និងអ្នកចងក្រង |
| | ១៥:៣០-១៦:០០ | **អាហារសំរន់** | | |
| | ១៦:០០-១៧:០០ | - -របាយការណ៍បូកសរុប<br>- មតិចាប់អារម្មណ៍របស់អ្នកចូលរួម<br>- មតិចាប់អារម្មណ៍របស់គណៈអធិបតី<br>- សុន្ទរកថាបិទអង្គសិក្ខាសាលា | | - លោក គង់ ណារិន នាយអធិការដ្ឋាន រ.ព<br>-<br>-<br>- ឯ.ឧ. ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើ |

**សុន្ទរកថាស្វាគមន៍**

**ថ្លែងដោយ ឯកឧត្តម ធុន គ្រី អភិបាលរងខេត្តក្រចេះ**

**ក្នុងឱកាសបើកសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ**

**ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៩ , សាលមហោស្រពខេត្តក្រចេះ**

-សូមគោរព ឯកឧត្តម **ផា សំអាង** អនុប្រធានរដ្ឋបាលព្រៃឈើ

-សូមគោរព លោក **អៀង សាវ៉េត** នាយអធិការដ្ឋានរដ្ឋបាលព្រៃឈើមេគង្គ

-សូមគោរព គណៈអធិបតី ឯកឧត្តម អស់លោក លោកស្រី ភ្ញៀវជាតិ និង អន្តរជាតិទាំងអស់ជាទីគោរពនិងជាទីមេត្រី

ជាបឋម តាងនាមអោយអាជ្ញាធរខេត្ត និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅនិងសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម អស់លោក លោកស្រី ជាភ្ញៀវជាតិ និង អន្តរជាតិ ដែលបានអញ្ជើញចូលរួមក្នុងអង្គ សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ ដ៏មានសារសំខាន់នាថ្ងៃនេះ ។

ខ្ញុំមានសេចក្តីរីករាយជាពន្លឹកដោយបានដឹងថា យើងមានសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ ហើយសិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណងប្រមូលមតិ និង យោបល់ពីសំណាក់ភាគីពាក់ព័ន្ធនានានៅក្នុងភូមិភាគមេគង្គ ដើម្បីកែលំអរសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិនេះ អោយក្លាយជាយុទ្ធសាស្ត្រប្រកបដោយតម្លាភាព និង ប្រសិទ្ធិភាពខ្ពស់សំរាប់រៀបចំផែនការគ្រប់គ្រងការប្រើប្រាស់ ការការពារ និង ការទាញយកផលប្រយោជន៍ដោយចិរភាពសំរាប់សង្គមមនុស្សនាពេលបច្ចុប្បន្ននិងតទៅអនាគត ។ ខ្ញុំយល់ឃើញថា អង្គសិក្ខាសាលានេះ មានសារៈប្រយោជន៍ណាស់ដើម្បីផ្សព្វផ្សាយ និង ពន្យល់ពីកម្មវិធីសំខាន់ៗសំរាប់អនុវត្តន៍និងបង្កើនការចូលរួមអនុវត្តន៍ពីភាគីពាក់ពន្ធ័នៅមូលដ្ឋានដើម្បីជំរុញការគ្រប់គ្រងធនធានព្រៃឈើសំដៅចូលរួមចំណែកកាត់បន្ថយភាពក្រីក្រដែលជាទិសដៅដ៏សំខាន់មួយនៃផែនការយុទ្ធសាស្ត្រចតុកោណជំហាន II របស់រាជរដ្ឋាភិបាលកម្ពុជា ។

**គណៈអធិបតី ឯកឧត្តម អស់លោក លោកស្រី ជាទីគោរព !**

ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព មានសារៈសំខាន់ណាស់សំរាប់ការរស់រានមានជីវិតរបស់មនុស្ស និង ការអភិវឌ្ឍន៍ដោយចិរភាពរបស់ពិភពលោក ។ ព្រៃឈើនៅតំបន់មេគង្គ ក៏ដូចជានៅទូទាំងប្រទេសបានរងនូវការគំរាមកំហែងច្រើនយ៉ាងនៃការរិចរឹល និង ប្រែក្លាយដីព្រៃឈើទៅជាការប្រើប្រាស់ផ្សេងៗទៀត ។ ចំពោះមុខជាតំរូវការបន្ទាន់ និងចាំបាច់បំផុតត្រូវគ្រប់គ្រងព្រៃឈើប្រកបដោយចិរភាព និង ប្រើប្រាស់ព្រៃឈើដោយសមធមិ តាមរយៈក្របខ័ណ្ឌកម្មវិធីជាតិរយៈពេលវែងមួយ ។

ខ្ញុំសូមឆ្លៀតឱកាសនេះជំរាបជូនអង្គសិក្ខាសាលាមេត្តាជ្រាបថា សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិនៅខេត្តក្រចេះរយៈពេល ២ ថ្ងៃនេះ មានអ្នកចូលរួមអញ្ជើញមកពីបណ្តាខេត្តនានាក្នុងអធិការដ្ឋានរដ្ឋបាលព្រៃឈើមេគង្គក្នុងនោះមាន : ខេត្តក្រចេះ កំពង់ចាម ព្រៃវែង ស្វាយរៀង ស្ទឹងត្រែង រតនគីរី និង មណ្ឌលគីរី ព្រមទាំងមានការចូលរួមពីអង្គភាពពាក់ពន្ធ័ក្នុងខេត្តក្រចេះ រដ្ឋបាលព្រៃឈើ វិស័យឯកជន អង្គការសង្គមស៊ីវិល និង សារពតិមាន ។ ជាមួយគ្នា

នេះខ្ញុំសូមជំរាបជូនពតិមានត្រួសៗអំពីស្ថានភាពព្រៃឈើនៅខេត្តក្រចេះ ជូនឯកឧត្តម អស់លោក លោកស្រី ឱ្យបានជ្រាបថា ខេត្តក្រចេះ មានផ្ទៃដីព្រៃឈើចំនួន **៨១,២១%** នៃផ្ទៃដីសរុបរបស់ខេត្ត ត្រូវជា **៩៧២.៣៨៧** ហិកតា ក្នុងនោះមាន : ព្រៃស្រោងចំនួន ២៦៦.៤៧៨ ហិកតា, ព្រៃពាក់កណ្តាលស្រោង ១៤០.៤៣៤ ហិកតា ព្រៃល្បោះ ៥១០.៩០៤ ហិកតា ព្រៃផ្សេង ៗ ២៨.៧០១ ហិកតា ព្រៃគម្ពោតស្ងួត ១៣.៧១៩ ហិកតា ព្រៃគម្ពោតបៃតងជានិច្ច ៩.៩៨៤ ហិកតា ព្រៃឫស្សី ២.១៦៩ ហិកតា ។

កន្លងមកក៏ដូចបច្ចុប្បន្នខេត្តក្រចេះបានជួបប្រទះនឹងបញ្ហាប្រឈមជាច្រើនក្នុងការគ្រប់គ្រងព្រៃឈើដូចជា :

-អ្នកកាប់រាន ដុត ឈូសឆាយដីព្រៃឈើ ដើម្បីយកធ្វើកម្មសិទ្ធិភាគច្រើនជាអ្នកចំណូលថ្មីមកពីបណ្តាលខេត្តផ្សេងៗ ។

-សកម្មភាពកាប់រានដីព្រៃច្រើនប្រព្រឹត្តិនាវេលាយប់ កាប់ គ្រៀវ ម្តងបន្តិចៗ ។

-រូបភាពកាប់រាន ដុត ឈូសឆាយព្រៃឈើ ដើម្បីចាប់យកដីមានលក្ខណៈស្មុគ្រស្មាញ ដោយគេប្រើប្រាស់កំលាំងប្រជាពលរដ្ឋក្រីក្រ តាមរយៈការជួលផ្ទាល់ ឬ ទិញបន្តក្នុងតំលៃថោក ។

- ការដឹកជញ្ជូនឈើល្មើសច្បាប់តាមការបំបែកជារូបភាពតូចៗ និង ប្រព្រឹត្តទៅនៅពេលយប់ ។

-ស្ថាប័នពាក់ព័ន្ធពុំទាន់បានយកចិត្តទុកដាក់ សហការល្អ ក្នុងការអនុវត្តន៏បទបញ្ជា នានា។

កត្តាទាំងនេះ បានជះឥទ្ធិពលដល់ការបាត់បង់ព្រៃឈើ ជាបន្តបន្ទាប់។

ដោយអនុវត្តតាមអនុសាសន៏ និង ការដឹកនាំដ៏ត្រឹមត្រូវ និង ឈ្លាសវៃបំផុតរបស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** អជ្ញាធរខេត្តបានរួមសហការជាមួយស្ថាប័នពាក់ពន្ធ័ ពិសេសខណ្ឌរដ្ឋបាលព្រៃឈើក្រចេះក្នុងការទប់ស្កាត់ និង បង្រ្កាបសកម្មភាពល្មើសច្បាប់ក្នុងវិស័យព្រៃឈើ ហើយទទួលបានលទ្ធផលជាបន្តបន្ទាប់ មានដូចជា :

| | | | |
|---|---|---|---|
| បង្រ្កាបបទល្មើសព្រៃឈើ និង សត្វព្រៃ | ចំនួន | ៧៥២ | ករណី |
| បង្រ្កាបបទល្មើសការកាប់រានយកដីព្រៃឈើចំនួន ៨៨ ករណី ត្រូវជាផ្ទៃដីចំនួន ៣៤៩ ហាត | | | |
| ដកហូតរណារយន្តកាត់ អារ ច្រៀកឈើ | ចំនួន | ៥៥៨ | គ្រឿង |
| បានចេញដីកាដកហូតដីព្រៃដែលបានកាប់រាន កាន់កាប់ដោយខុសច្បាប់ | ចំនួន | ២១.៩៥៨ | ហិកតា |
| ដាំដើមឈើតាមទីសាធារណៈ | ចំនួន | ៤២.៧៧០ | ដើម |
| ដាំឈើក្នុងឱកាសបុណ្យរុក្ខទិវា | ចំនួន | ១៦.២១២ | ដើម |
| បានកំណត់តំបន់សក្តានុពលសហគមន៏ព្រៃឈើ | ចំនួន | ៣២ | កន្លែង |
| រាជរដ្ឋាភិបាលបានចេញសេចក្តីសំរេចលុបចោលកិច្ចព្រមព្រៀងព្រៃសម្បទាន | ចំនួន | ៣ | |

ដូច្នេះដើម្បីគ្រប់គ្រងព្រៃឈើអោយមាននិរន្តរភាពត្រូវរៀបចំគោលនយោបាយព្រៃឈើជាតិអោយមានភាពរលូន ដែលចាំបាច់ត្រូវប្រមូលមតិ និង យោបល់ពីសំណាក់ភាគីពាក់ព័ន្ធនានា ដើម្បីកែលំអរសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិនេះ អោយមានតម្លាភាព និង ប្រសិទ្ធិភាពខ្ពស់សំរាប់រៀបចំផែនការ ការគ្រប់គ្រង ការការពារ ការអភិរក្ស ការប្រើប្រាស់ ដោយចិរភាពសំរាប់សង្គមមនុស្សនាពេលបច្ចុប្បន្ន និង ជំនាន់ក្រោយៗទៀត។

**គណៈអធិបតី ឯកឧត្តម អស់លោក លោកស្រី ជាទីគោរព !**

ខ្ញុំសង្ឃឹមថា អង្គសិក្ខាសាលារយៈពេល ០២ ថ្ងៃនេះ នឹងផ្តល់អត្ថប្រយោជន៍យ៉ាងសំខាន់ណាស់ក្នុងការចូលរួមផ្តល់មតិ កែលំអរសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិនេះ ក៏ដូចជាការចូលរួមការពារធនធានព្រៃឈើនៅកម្ពុជាអោយបានកាន់តែប្រសើរ និង សូមអោយឯកឧត្តម អស់លោក លោកស្រីទាំងអស់ចូលរួមស្វែងយល់ពិភាក្សា និង ផ្តល់មតិអោយបានផុលផុសដើម្បីអោយកម្មវិធីព្រៃឈើជាតិនេះឆ្លើយតបទៅនឹងតំរូវការថ្នាក់មូលដ្ឋាន និង អោយមានភាពស៊ីចង្វាក់និងមានការគាំទ្រដល់ផែនការអភិវឌ្ឍន៍ជាតិ និងគោលដៅសហសវត្សន៍កម្ពុជា។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជាថ្មីម្តងទៀត ចំពោះ ឯកឧត្តម អស់លោក លោកស្រី ជាភ្ញៀវជាតិ និង អន្តរជាតិ ដែលបានអញ្ជើញចូលរួមក្នុងអង្គសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ នាថ្ងៃនេះ។ សូមគោរពជូនពរ ដល់ ឯកឧត្តម អស់លោក លោកស្រី ជាភ្ញៀវជាតិ និង អន្តរជាតិ ទាំងអស់ សូមប្រកបតែពុទ្ធិពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**

# សិក្ខាសាលាស្តីពី

# ការពិគ្រោះយោបល់សាធារណៈលើកម្មវិធីព្រៃឈើជាតិ

# អំពីសិក្ខាសាលា

សុខ ហោខ

# មាតិកាបទបង្ហាញ

- មូលដ្ឋាន និង ប្រវត្តិ
- គោលបំណង
- លទ្ធផលរំពឹងទុក
- ដំណើរការអន្តសិក្សាសាលា

# មូលដ្ឋាន និង ប្រវត្តិ

- ក្រុមការងារកម្មវិធីព្រៃឈើជាតិត្រូវបានបង្កើត នៅ ឆ្នាំ ២០០៧
- កម្មវិធីការងារជាអទិភាពចំនួនឆ្នាំមួយត្រូវបានព្រាងសំរាប់អនុវត្ត ក្នុងរយះពេល ២០ ឆ្នាំខាងមុខ
- ការពិគ្រោះយោបល់ត្រូវបានកំណត់ក្នុងវិធីគោចរ នៃការអភិវឌ្ឍ កម្មវិធីព្រៃឈើជាតិ
- ការអភិវឌ្ឍកម្មវិធីព្រៃឈើជាតិត្រូវបានកំណត់ ជាសូចនករក្នុង តារាងសូចនករតាមដានរួម

# អ្នកចូលរួម

| ប្រភេទអ្នកចូលរួម | ចំនួន | សំគាល់ |
|---|---|---|
| មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន | ៤០ | សង្កាត់រដ្ឋបាលព្រៃឈើ, ផ្នែក និង ខ័ណ្ឌ, អធិការដ្ឋាន |
| អាជ្ញាធរមូលដ្ឋាន | ៣០ | ឃុំ, ស្រុក, ខេត្ត |
| សហគមន៍មូលដ្ឋាន | ៤០ | សហគមន៍ព្រៃឈើ និង ព្រះសង្ឃ |
| អង្គការ, វិស័យឯកជន, សារព័ត៌មាន | ៣០ | អ្នកធ្វើការពាក់ព័ន្ធព្រៃឈើ និង បរិស្ថាន និងបណ្តាញផ្សព្វផ្សាយ |
| មន្ទីរពាក់ព័ន្ធ | ១០ | សុរិយោដី, បរិស្ថាន, ឧស្សាហកម្ម, អភិវឌ្ឍនិងជនបទ,កសិកម្ម, អប់រំ, វប្បធម៌និងព័ត៌មាន, សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ,ពាណិជ្ជកម្ម, ធម្មការនិងសាសនា ។ |
| អ្នកផ្សេងទៀត | ២៣ | ក្រុមពិគ្រោះយោបល់ និង អ្នកជំនួយការសិក្ខាសាលា |
| សរុប | ១៧៣ | |

# គោលបំណង

*ដើម្បីកែលំអឯកសារពង្រាងកម្មវិធីព្រៃឈើជាតិឱ្យកាន់តែប្រសើរ*

- បង្កើនការផ្សព្វផ្សាយ និងការយល់ដឹងអំពីកម្មវិធីព្រៃឈើជាតិ
- ប្រមូលមតិ, ទស្សនៈ និង យោបល់ពីអ្នកពាក់ព័ន្ធនានា នៅថ្នាក់មូលដ្ឋាន
- បង្កើនការគាំទ្រ និងការចូលរួមពីអ្នកពាក់ព័ន្ធក្នុងការអភិវ និងការអនុវត្តកម្មវិធីព្រៃឈើជាតិ

# ដំណើរការនៃអង្គសិក្ខាសាលា

- ថ្ងៃទី ១: បទបង្ហាញរួម-វគ្គពេញអង្គ
- ថ្ងៃទី ២: ពិភាក្សាតាមក្រុម

- ចែកជា ៦ ក្រុមតាមវិធានបទ
- ចុះឈ្មោះតាមក្រុមដែលខ្លួនពេញចិត្ត

# វិធាននៃការពិភាក្សាពិគ្រោះយោបល់

- សំនួរ និង ការពិភាក្សាត្រូវ ផ្ដោតលើខ្លឹមសារសំខាន់ៗ ក្នុងឯកសារសេចក្ដីព្រាង
- សិក្ខាកាមគ្រប់រូប មានសិទ្ធិស្មើគ្នា និង ត្រូវគោរពសិទ្ធិគ្នា
- ជៀសវាង ការវាយប្រហារពាក្យសំដី និង ការចោទប្រកាន់
- ការផ្ដល់មតិត្រូវមានលក្ខណៈរិះគន់ស្ថាបនា

# កំណត់ចំណាំ

- នេះជាកិច្ចពិគ្រោះយោបល់លើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ
- នេះមិនមែនជាវេទិកាសួរដេញដោលបញ្ហាក្នុងវិស័យព្រៃឈើទេ
- មតិទាំងអស់នឹងត្រូវទទួលយកទៅពិចារណា និង សំយោគជាមួយមតិទទួលបានពីអង្គសិក្ខាសាលាផ្សេងៗទៀត
- មិនតំរូវអោយមានការឯកភាព រឺ បដិសេដលើសេចក្តីព្រាងទេ
- ក្រុមការងាររៀបចំសិក្ខាសាលា រក្សាសិទ្ធិ បញ្ឈប់ការចូលរួមរបស់សិក្ខាកាមណាដែល មិនគោរពវិធានក្នុងការពិភាក្សាពិគ្រោះយោបល់ រឺ បង្កភាពអសកម្មដល់ដំណើរការអង្គសិក្ខាសាលា

**សិក្ខាសាលាស្តីពី**

**ការពិគ្រោះយោបល់សាធារណៈលើកម្មវិធីព្រៃឈើជាតិ**

# ដំណើរការអភិវឌ្ឍន៍កម្មវិធីព្រៃឈើជាតិ

**សុខ ហេខ**

# មាតិកាបទបង្ហាញ

- និយមន័យ គោលបំណង គោលការណ៍សកល
- ប្រវត្តិដើមរឿងនៃដំណើរការចងក្រង និងលទ្ធផល
- ទិសដៅបន្ត

# និយមន័យ និងគោលបំណង នៃកម្មវិធីព្រៃឈើជាតិ

- **និយមន័យ:**

កម្មវិធីព្រៃឈើជាតិ គឺជាដំណើរការដែលមានការចូលរួមពីដៃគូជាច្រើននៅក្នុងការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យលើសកម្មភាពក្នុងវិស័យព្រៃឈើក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើដោយចីរភាព៕

- **គោលបំណង:**

ដើម្បីគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និង ប្រើប្រាស់ ព្រៃឈើដោយសមធម៌តាមរយៈក្របខ័ណ្ឌកម្មវិធីជាតិរយៈពេលវែងមួយ

# គោលការណ៍កម្មវិធីព្រៃឈើជាតិ

គោលការណ៍

- ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព
- អធិបតេយ្យភាពជាតិ និងភាពជាម្ចាស់
- ការចូលរួមពីគ្រប់ភាគីពាក់ពន្ធ័
- មានលក្ខណៈស៊ីចង្វាក់ និងតភ្ជាប់ជាមួយវិស័យផ្សេងៗ
- ដំណើរការមានរយៈពេលវែង និងមានការត្រួតពិនិត្យកែសំរួលជាប្រចាំ
- មានភាពស៊ីចង្វាក់ជាមួយនឹងគោលនយោបាយជាតិ និងអន្តរជាតិ
- មានការលើកកំពស់ការយល់ដឹង និង ផ្សព្វផ្សាយជាសាធារណៈ

# ដំណាក់កាលនៃកម្មវិធីព្រៃឈើជាតិ

- ការសិក្សា វាយតំលៃ និង វិភាគ
- ការចងក្រងអភិវឌ្ឍកម្មវិធី
- ការអនុវត្តកម្មវិធី
- ការតាមដានត្រួតពិនិត្យ និង វាយតំលៃការអនុវត្តកម្មវិធី

# ដំណើរការនៃការអភិវឌ្ឍកម្មវិធីព្រៃឈើជាតិ



# សមាសភាព ក្រុមការងារកម្មវិធីព្រៃឈើជាតិ

- រដ្ឋាភិបាលៈ រដ្ឋបាលព្រៃឈើ នៃ កសក
- ដៃគូអភិវឌ្ឍៈ Danida, Jica, UNDP, FAO , WB ...
- ស្ថាប័នពាក់ព័ន្ធៈ ក្រសួងដែនដី បរិស្ថាន មហាផ្ទៃ ព័រ សេដ្ឋកិច្ច
- អង្គការក្រៅរដ្ឋាភិបាល ទាំងជាតិ និង អន្តរជាតិ
- វិស័យឯកជន

## កម្មវិធី៦ ដែលបានរៀបចំជាពង្រាងៈ

១. កម្មវិធី កំនត់ព្រំប្រទល់ ការចាត់ថ្នាក់ ការចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍

២. កម្មវិធីការគ្រប់គ្រងធនធានព្រៃឈើ និងអភិរក្ស

៣. កម្មវិធីការពង្រឹងច្បាប់ និងអភិបាលកិច្ច

៤. កម្មវិធីសហគមន៍ព្រៃឈើ

៥. កម្មវិធីកសាងសមត្ថភាព និងអភិវឌ្ឍន៍ការស្រាវជ្រាវ

៦. កម្មវិធីហិរញ្ញវត្ថុព្រៃឈើប្រកបដោយនិរន្តរភាព

# ផែនការបន្ទះ   ការពិគ្រោះយោបល់លើឯកសារកម្មវិធីព្រៃឈើជាតិ

| អធិការដ្ឋាន | ខេត្ត | ទីតាំង | កាលបរិច្ឆេទ |
|---|---|---|---|
| ឈូងសមុទ្រ | ព្រះសីហនុ | សណ្ឋាគារ  ហូលីដេ | ១៦_១៧ |
| ខាងត្បូងបឹងទន្លេសាប | ពោធិសាត់ | មជ្ឈមណ្ឌលអភិវឌ្ឍន៍<br>ប៊ុន  រ៉ានី  ហ៊ុន  សែន | ១៩_២០ |
| មេគង្គ | ក្រចេះ | សាលមហោស្រព  ខេត្ត | ២៥_២៦ |
| ខាងជើងបឹងទន្លេសាប | សៀមរាប | សណ្ឋាគារ  អង្គរធំរាជា | ៣០_៣១ |

# ផែនការបន្ទះ

- កែលំអ លើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិនេះ
- ពិនិត្យទាយតំលៃ និង កែលំអដោយអ្នកជំនាញការអន្តរជាតិ
- ពិគ្រោះយោបល់ថ្នាក់ជាតិលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ
- ការកែលំអចុងក្រោយ
- ក្រុមការងារកម្មវិធីព្រៃឈើជាតិ ពិនិត្យអនុម័ត
- រដ្ឋាភិបាលពិនិត្យ និង អនុម័ត

សូមអរគុណ

# កម្មវិធីព្រៃឈើជាតិ

## មាតិការឿង នៃឯកសារកម្មវិធីព្រៃឈើជាតិ

សុខ ហេង

# បញ្ជីមាតិការឿងសំខាន់ៗ

១. សេចក្ដីផ្ដើម

២. គោលនយោបាយជាតិក្នុងវិស័យព្រៃឈើ

៣. បញ្ហាប្រឈមក្នុងវិស័យព្រៃឈើ

៤. ដំណើរអភិវឌ្ឍ កម្មវិធីព្រៃឈើជាតិ

៥. លក្ខខណ្ឌប្រកបសំរាប់ការអនុវត្ត មូលដ្ឋានគ្រឹះសំរាប់ការអនុវត្ត

៦. កម្មវិធីសំរាប់ការអនុវត្ត

៧. ប្រព័ន្ធតាមដាន និង វាយតំលៃការអនុវត្ត

# សេចក្ដីផ្ដើម

- សារៈប្រយោជន៍របស់ព្រៃឈើ
- មូលហេតុនៃការអភិវឌ្ឍកម្មវិធីព្រៃឈើជាតិ
- គោលគំនិត និង គោលបំណងកម្មវិធី
- ទស្សនៈទានកម្មវិធី
- បេសកកម្មកម្មវិធី

# ២. គោលនយោបាយជាតិក្នុងវិស័យព្រៃឈើ

- គោលនយោបាយព្រៃឈើអន្តរជាតិ
- គោលនយោបាយជាតិទាក់ទងនឹងព្រៃឈើ
- ច្បាប់និងលិខិតបទដ្ឋាននានាក្នុងវិស័យព្រៃឈើ

# ៣. បញ្ហាប្រឈមក្នុងវិស័យព្រៃឈើ

១. ការវិភាគលើបញ្ហាសំខាន់ៗក្នុងវិស័យព្រៃឈើ

២. ការវាយតម្លៃលើស្ថានភាពបច្ចុប្បន្នក្នុងវិស័យព្រៃឈើ ដូចជាការផ្តល់ដីព្រៃ អភិបាលកិច្ច ការប្រើប្រាស់ ការអភិរក្ស កិច្ចសហការអន្តរវិស័យ ធនធានហិរញ្ញវត្ថុ ។ល។

៣. សក្តានុពលនៃប្រព័ន្ធគ្រប់គ្រងព្រៃឈើផ្សេងៗ

# ៤. ដំណើរអភិវឌ្ឍ កម្មវិធីព្រៃឈើជាតិ

១. ប្រវត្តិដើមរឿងកម្មវិធីព្រៃឈើជាតិ

២. ដំណើរការចងក្រង និង សំរបសំរួល

៣. ការចូលរួមពីភាគីពាក់ព័ន្ធ

៤. ការកំណត់ កម្មវិធីការងារអាទិភាព

៥. ការពិគ្រោះយោបល់

៦. ការអនុម័ត

# លក្ខខណ្ឌប្រកបសំរាប់ការអនុវត្ត

## ជំនួសៈ មូលដ្ឋានគ្រឹះសំរាប់ការអនុវត្ត

១. យុទ្ធសាស្ត្រតភ្ជាប់ការគ្រប់គ្រងព្រៃឈើនឹង ការកាត់បន្ថយភាពក្រីក្រ

២. យុទ្ធសាស្ត្របង្កើនប្រសិទ្ធភាពការងារក្នុងវិស័យព្រៃឈើ

៣. យុទ្ធសាស្ត្រសំរាប់ការអនុវត្តយន្តការ REDD

៥. យុទ្ធសាស្ត្របញ្ជ្រៀបមុខវិជ្ជាព្រៃឈើនៅក្នុងវិស័យអប់រំ

# ៦. កម្មវិធីសំរាប់ការអនុវត្ត

១. កម្មវិធីកំណត់ព្រំប្រទល់ដែនព្រៃឈើ

២. កម្មវិធី គ្រប់គ្រង និងអភិរក្សព្រៃឈើ

៣. កម្មវិធីពង្រឹងការអនុវត្តច្បាប់ និង អភិបាលកិច្ច

៤. កម្មវិធីសហគមន៍ព្រៃឈើ

៥. កម្មវិធីកសាងសមត្ថភាព និងស្រាវជ្រាវ និង

៦. កម្មវិធីវិនិយោគធុន

៧. យន្តការដោះស្រាយទំនាស់

៨. ប្រព័ន្ធតាមដាន និង ត្រួតពិនិត្យ






# សិក្ខាសាលាពិគ្រោះយោបល់លើកម្មវិធីព្រៃឈើជាតិ

## កម្មវិធីស្តីពី

## "ការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និង ការចុះបញ្ជិកា សម្បត្តិព្រៃឈើអចិន្ត្រៃយ៍"

ក្រុងក្រចេះ, ថ្ងៃទី ២៥-២៦ខែ មីនា ឆ្នាំ ២០០៩

# កម្មវិធីព្រៃឈើជាតិ

កម្មវិធីស្តីពី ” ការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និង ការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ”

១.អនុកម្មវិធី : ការកំណត់ព្រំប្រទល់ និង ការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍

២.អនុកម្មវិធី : ការធ្វើចំណាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍

# កម្មវិធីស្តីពី " ការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និង ការចុះបញ្ជិកា សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ "

១. គោលបំណងនៃកម្មវិធី ការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និងការចុះបញ្ជិកា សម្បត្តិព្រៃឈើអចិន្ត្រៃយ៍

២. ឆ្លើយតបទៅនឹងចក្ខុវិស័យនៃកម្មវិធីព្រៃឈើជាតិ

៣. ឆ្លើយតបទៅនឹងគោលបំណងនៃកម្មវិធីព្រៃឈើជាតិ

៤. អនុកម្មវិធី ការកំណត់ព្រំប្រទល់ និង ចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍

៥. អនុកម្មវិធី ការធ្វើចំណាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍

## ១.គោលបំណងនៃកម្មវិធីការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និង ការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ :

- ទប់ស្កាត់ការរំលោភកាប់រានដីព្រៃឈើធ្វើជាកម្មសិទ្ធិដោយខុសច្បាប់
- កាត់បន្ថយ និងទប់ស្កាត់ជំលោះពាក់ព័ន្ធនឹងដីព្រៃឈើ
- ដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍តាមរយៈការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព
- រៀបចំបង្កើតផែនទីប្រើប្រាស់ដីសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- បង្កើតនូវសុវត្ថិភាពកម្មសិទ្ធិ និងសិទ្ធិជាប្រពៃណីរបស់សហគមន៍មូលដ្ឋានក្នុងការប្រើប្រាស់ធនធានព្រៃឈើ ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ

## ២.ការឆ្លើយតបទៅនឹងចក្ខុវិស័យនៃកម្មវិធីព្រៃឈើជាតិ

-ផ្ដល់មូលដ្ឋានទិន្នន័យ និងមូលដ្ឋានច្បាប់ សំរាប់ការអភិវឌ្ឍន៍ និង ការអភិរក្ស ដើម្បីធានាភាពស្ថិតស្ថេរនៃអេកូឡូស៊ី សង្គម និង សេដ្ឋកិច្ច

-រៀបចំផែនការដើម្បីគ្រប់គ្រងធនធានព្រៃឈើជាតិប្រកបដោយនិរន្តរភាព

-ទទួលស្គាល់សិទ្ធិប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍មូលដ្ឋានពឹងអាស្រ័យលើផល អនុផលព្រៃឈើ ។

## ៣.ឆ្លើយតបទៅនឹងគោលបំណងនៃកម្មវិធីព្រៃឈើជាតិ

-ផ្ដល់នូវវិភាគទានជាអតិបរមា ចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ប្រកបដោយចីរភាព

-សំដៅស្ដារឡើងវិញឱ្យបានផលជាអតិបរមានៃដីព្រៃឈើ និងធនធានព្រៃឈើ

-សំដៅចូលរួមកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម

-មានការចូលរួមពីអាជ្ញាធរដែនដី សហគមន៍មូលដ្ឋាន ឬ សមត្ថកិច្ចដែលពាក់ព័ន្ធនឹងដីព្រៃឈើ ដើម្បីសំរួលដល់ដំណើរការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និងចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ។

# ៤.អនុកម្មវិធី ការកំណត់ព្រំប្រទល់ និង ចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍

## ៤.១.ការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍

-ការប្តេជ្ញារបស់រាជរដ្ឋាភិបាលតាមរយៈសេចក្តីថ្លែងការណ៍ស្តីពីគោលនយោបាយវិស័យព្រៃឈើជាតិ និង ផ្អែកលើច្បាប់ស្តីពីព្រៃឈើ ច្បាប់ភូមិបាល អនុក្រឹត្យលេខ ៥៣អនក្រ.បក ស្តីពីនីតិវិធី ការបង្កើត ការចាត់ថ្នាក់ និង ការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា

-សកម្មភាពកាប់រានដីព្រៃឈើដោយខុសច្បាប់ និងជំលោះត្រូវបានកាត់បន្ថយ និង ទប់ស្កាត់

-រៀបចំផែនការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព

-ដើម្បីធានាបាននូវសុវត្ថិភាពកម្មសិទ្ធិដីធ្លី

-ព្រំប្រទល់ដែនសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ត្រូវបានកំណត់នៅទីវាល និងគូសបញ្ចូលនៅលើផែនទី

-បង្កើតផែនទីប្រើប្រាស់ដីសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ។

# ៤.អនុកម្មវិធី  ការកំណត់ព្រំប្រទល់ និង ចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍

## ៤.២.ដំណើរការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍

-បង្កើតក្រុមការងារថ្នាក់ខេត្ត ដែលមានអភិបាលខេត្តជាប្រធាន សមាជិក ខណ្ឌ ផ្នែក សង្កាត់រដ្ឋបាលព្រៃឈើ មន្ទីរកសិកម្ម/ការិ.ស្រុក មន្ទីរបរិស្ថាន មន្ទីររៀបចំដែនដី/ការិ.ស្រុក អភិបាលស្រុក មេឃុំ ពាក់ព័ន្ធ ស្នងការនរគបាលខេត្ត មេបញ្ជាការប្រតិបត្តិការសឹកខេត្ត

-សេចក្តីជូនដំណឹង តំបន់ព្រៃឈើដែលត្រូវធ្វើការកំណត់ព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍

-ផ្សព្វផ្សាយ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ភូមិបាល អនុក្រឹត្យលេខ ៥៣ និងលិខិតបទដ្ឋានពាក់ព័ន្ធ ផែនទីគំរបព្រៃឈើឆ្នាំ២០០២ ជាផែនទីគោលជាមូលដ្ឋានក្នុងការកំណត់ព្រំប្រទល់ដែនព្រៃ ដល់ប្រជាពលរដ្ឋមូលដ្ឋាន

-បោះបង្គោលបណ្តោះអាសន្ន(លេខសំគាល់) ដោយមានការចូលរួមពីប្រជាពលរដ្ឋ អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ

-ទទួលពាក្យតវ៉ា និងដោះស្រាយពាក្យតវ៉ា (សារាចរ លេខ ០២ស.រ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់)

-បោះបង្គោលអចិន្ត្រៃយ៍ព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍នៅទីវាល និង គូសបញ្ចូលនៅលើផែនទី ដោយមានការទទួលស្គាល់ពីអាជ្ញាធរខេត្ត។

# ៤.អនុកម្មវិធី  ការកំណត់ព្រំប្រទល់ និង ចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍

## ៤.២.ដំណើរការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍




បង្គោលព្រំមេ




បង្គោលព្រំបន្ទាប់

## ៤.៣.ការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍

-ជាមូលដ្ឋានច្បាប់សំរាប់រៀបចំផែនការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយចីរភាព

-ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៏ត្រូវចុះបញ្ជិកានៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសម្បត្តិសាធារណៈរបស់រដ្ឋ

-រាល់ដែនព្រៃបំរុងទុកអចិន្ត្រៃយ៏ត្រូវប្រកាសជាផ្លូវការ តាមរយៈអនុក្រឹត្យស្តីពីការបង្កើតដែនព្រៃបំរុងទុកអចិន្ត្រៃយ៏( អនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ០១-០៤-២០០៥ មាត្រា៧)

-ចំណាត់ថ្នាក់ព្រៃបំរុងទុកអចិន្ត្រៃយ៏នឹងត្រូវចុះបញ្ជិកា និង ចេញប្រកាសដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-រាល់ការសំរេចរំសាយចំណាត់ថ្នាក់ព្រៃឈើ និង ការផ្លាស់ប្តូរចំណាត់ថ្នាក់ព្រៃឈើណាមួយត្រូវកំណត់ដោយអនុក្រឹត្យ( ច្បាប់ស្តីពីព្រៃឈើ មាត្រា១២) ។

# ៥.អនុកម្មវិធី ការធ្វើចំណាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍

សម្បត្តិព្រៃឈើអចិន្ត្រៃយ៍រួមមាន ៈព្រៃបំរុងទុកអចិន្ត្រៃយ៍ និង ព្រៃឯកជន។

**៥.១.ព្រៃបំរុងទុកអចិន្ត្រៃយ៍** រួមមានបីប្រភេទ ៈ

**ក.ព្រៃផ្តល់ផល( មុខងារការពារត្រូវចាត់ទុកជាអាទិភាពបន្ទាប់) មានជាអាទិ៍ ៈ**

-ព្រៃសម្បទាន

-ព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន

-ព្រៃឈើត្រូវស្តារឡើងវិញ

-ផ្ទៃដីព្រៃបម្រុងទុកសម្រាប់ដាំដើមឈើឡើងវិញ ឬចំការព្រៃឈើ

-ផ្ទៃដីបម្រុងទុកសំរាប់បន្តពូជព្រៃឈើ

-ផ្ទៃដីព្រៃរេចរឹល

-ព្រៃសហគមន៏ក្រោមកិច្ចព្រមព្រៀង

**ខ.ព្រៃការពារ ( មុខងារការពារប្រព័ន្ធមជ្ឈដ្ឋាន និងធនធានធម្មជាតិជាចម្បង) មានជាអាទិ៍ ៖**

-ព្រៃបម្រុងទុកសំរាប់ប្រព័ន្ធមជ្ឈដ្ឋានពិសេស

-ព្រៃសម្រាប់សិក្សាស្រាវជ្រាវ

-ព្រៃនិយតកម្មប្រភពទឹក

-ព្រៃការពារទីជំរាល

-ព្រៃលំហែកំសាន្ត

-សួនភូតគាម

-ព្រៃជំនឿសាសនា

**គ.ផ្ទៃដីព្រៃសម្រាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍផ្សេងទៀត ។**

## ៥.២.ដំណើរការចាត់ថ្នាក់ព្រៃបម្រុងទុកអចិន្ត្រៃយ៍

-បង្កើតក្រុមការងាររបស់រដ្ឋបាលព្រៃឈើ ធ្វើការសម្របសម្រួល និង ពិគ្រោះយោបល់ជាមួយ អាជ្ញាធរដែនដី សហគមន៍មូលដ្ឋាន ឬសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីសម្រួលដល់ដំណើរការចាត់ថ្នាក់ ព្រៃបម្រុងទុកអចិន្ត្រៃយ៍នៅតាមខេត្តក្រុង នីមួយៗ

-ចុះអង្កេត វាស់វែងចំណុចនិយាមកា និង សិក្សាស្ថានភាពព្រៃឈើជាក់ស្តែង ដោយប្រមូលទិន្នន័យ អំពីប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ ធនធានព្រៃឈើ ព័ត៌មានអំពីតម្រូវការសង្គម សេដ្ឋកិច្ច និងសក្តានុពល ផ្សេងទៀត តាមតំបន់ ឬ ភូមិសាស្ត្រព្រៃឈើនីមួយៗ។

-ធ្វើការវិភាគលើទិន្នន័យ និង ព័ត៌មាន ធ្វើអត្តសញ្ញាណព្រៃបម្រុងទុកអចិន្ត្រៃយ៍នីមួយៗ

-ដៅចំណុចនិយាមកាសំគាល់ព្រំសីមាគោល នៅលើផែនទីព្រៃបម្រុងទុកអចិន្ត្រៃយ៍ និង នៅលើទីវាល

-រៀបចំឯកសារសម្រាប់គំរោងចំណាត់ថ្នាក់ព្រៃបម្រុងទុកអចិន្ត្រៃយ៍នីមួយៗ ដើម្បីស្នើសុំប្រកាសពី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។



សូមអរគុណ

សិក្ខាសាលាស្តីពី
ការពិគ្រោះយោបល់លើសេចក្តីព្រាងឯកសារកម្មវិធីព្រៃឈើជាតិ

# កម្មវិធីការគ្រប់គ្រងធនធាន
# ព្រៃឈើជាតិ និងការអភិរក្សជីវចម្រុះ

# ខ្លឹមសារគន្លឹះសំខាន់ៗ នៃកម្មវិធី

- ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព
- ប្រព័ន្ធការគ្រប់គ្រងព្រៃឈើជាតិ
- ការដាំឈើជាចំការ
- ការអភិរក្សធនធានព្រៃឈើ និងជីវចម្រុះ
- ការរៀបចំ និងអភិវឌ្ឍន៍អេកូទេសចរណ៍
- ការប្រមូលផលព្រៃឈើ
- ការកែច្នៃផល អនុផលព្រៃឈើ
- បង្កើនបច្ចេកទេស និងទីផ្សារផលិតផលឈើ

# សេចក្តីផ្តើម

ព្រៃឈើគឺជាជីវិត និងវប្បធម៌របស់ពលរដ្ឋកម្ពុជា។ ប្រជាពលរដ្ឋជនបទភាគច្រើនមាន ជីវភាពរស់នៅប្រចាំថ្ងៃ ពឹងអាស្រ័យនឹងព្រៃឈើ។ ដូចច្នេះហើយ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់លើវិស័យព្រៃឈើជាតិ និងដាក់ចេញនូវគោលដៅអភិវឌ្ឍសហស្សវត្ស ដែលផ្តោតលើការការពារ ថែរក្សាគម្របព្រៃឈើ៦០ភាគរយនៅឆ្នាំ ២០១៥ និង លើសពីនេះបានដាក់ចេញនូវគោលនយោបាយយុទ្ធសាស្រ្តចតុកោណ ដែលផ្តោតលើការគ្រប់គ្រងធនធានព្រៃឈើ និងអភិរក្សជីវចម្រុះ ការពារបរិស្ថានធម្មជាតិ រួមចំណែកកាត់បន្ថយ ភាពក្រីក្រ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។

# ទស្សនទានកម្មវិធី

កម្មវិធីការគ្រប់គ្រងធនធានព្រៃឈើ និងការអភិរក្ស ផ្តោតសំខាន់លើការគ្រប់គ្រងនិងអភិរក្សជីវចម្រុះ សង្គម និងសេដ្ឋកិច្ច ព្រមទាំងបង្កើនការការពារពាបរិស្ថាន ការបន្ថយភាពក្រីក្រ និងអភិវឌ្ឍសេដ្ឋកិច្ច សង្គមដោយចេរភាព។

គោលបំណងសំខាន់នៃកម្មវិធី :

- ពង្រឹងការគ្រប់គ្រងព្រៃឈើប្រកបដោយចេរភាព ព្រមទាំងអភិរក្សជីវចម្រុះ
- គាំទ្រការអភិវឌ្ឍសង្គមសេដ្ឋកិច្ច
- ការអភិវឌ្ឍនបច្ចេកទេសកែច្នៃ និងពង្រីកទីផ្សារផលិតផល ផលអនុផលព្រៃឈើ

# អនុកម្មវិធីទី១.ការរៀបចំផែនការគ្រប់គ្រងព្រៃឈើជាតិ

១. ការអធិប្បាយ: អនុកម្មវិធីនេះ គឺសកម្មភាពសំខាន់ដែលរដ្ឋបាលព្រៃឈើទទួល អនុវត្ត ស្របគ្នានឹងដំណើរការរៀបចំកម្មវិធីព្រៃឈើជាតិ

២. មធ្យោបាយអនុវត្ត: ការរៀបចំផែនការព្រៃឈើជាតិ តាមគោលមាគ៌ា កែទំរង់ នយោបាយយ៉ាងស៊ីជំរៅ របស់រាជរដ្ឋាភិបាល ដើម្បីធានាបាន នូវផែនការគ្រប់គ្រង ព្រៃឈើមានលក្ខណ:ល្អប្រសើរសំរាប់អនុវត្ត និងមានការចូលរួមក្នុងដំណើរការរៀបចំ

៣. ក្រុមការងារ: រដ្ឋបាលព្រៃឈើ, ដៃគូរផ្តល់ជំនួយ, និងស្ថាប័នពាក់ ព័ន្ធ។ផែនការនេះ រៀបចំស្របតាមយុទ្ធសាស្រ្តអភិវឌ្ឍជាតិ ដូចជាសេចក្តីថ្លែងការគោលនយោបាយ ព្រៃឈើជាតិ, ផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិ, យុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រ, គោលដៅអភិវឌ្ឍសហសវត្ស និងកម្មវិធីព្រៃឈើជាតិ

៤. ផែនការគ្រប់គ្រងព្រៃឈើជាតិ រៀបចំតាមយុទ្ធសាស្រ្តអភិវឌ្ឍជាតិ និងមានការចូល រួមជាសាធារណ:ក្នុងដំណើរការរៀបចំ និងផ្តល់ជាឧបករណ៍ដ៏ពិសិដ្ឋសំរាប់គ្រប់គ្រង ព្រៃឈើប្រកបដោយនិរន្តរភាព

# អនុកម្មវិធីទី២.  សារពើភ័ណ្ឌព្រៃឈើជាតិ

## ២.១  សារពើភ័ណ្ឌព្រៃឈើជាតិ

១-ការពិពណ៌នា

សារពើភ័ណ្ឌព្រៃឈើ  គឺជានីតិវិធីសំរាប់ប្រមូលពត៌មានពី  បរិមាណ  និង  គុណភាពនៃធនធានព្រៃឈើ និង លក្ខណៈនៃដីព្រៃឈើ។ កាលពីសម័យមុន ការធ្វើសារពើភ័ណ្ឌព្រៃឈើគឺសំរាប់ធ្វើការប៉ាន់ស្មានបរិមាណឈើដែលអាចកាប់បាន  ប៉ុន្តែបច្ចុប្បន្នការធ្វើសារពើភ័ណ្ឌនៅកម្ពុជាបានគិតគូរដល់បរិស្ថាន  សារព័ន្ធរុក្ខជាតិ  សារព័ន្ធសត្វព្រៃ  និង  អនុផលព្រៃឈើ  ដែលរួមមាន  ផលស្តុករបស់ព្រៃឈើ  ជំរកស្នាក់នៅ  និង  ប្រភេទនៃការអភិរក្ស  ជាពិសេសបានគិតគូរដល់ការធ្វើសារពើភ័ណ្ឌកាបូនស្តុកដែលមានក្នុងព្រៃឈើជាតិ។

សារពើភ័ណ្ឌព្រៃឈើ គឺជានីតិវិធីសំរាប់ប្រមូលពត៌មានពី បរិមាណ និង គុណភាព នៃធនធានព្រៃឈើ និង លក្ខណៈនៃដីព្រៃឈើ។ កាលពីសម័យមុន ការធ្វើសារពើភ័ណ្ឌព្រៃឈើគឺសំរាប់ធ្វើការប៉ាន់ស្មានបរិមាណឈើដែលអាចកាប់បាន ប៉ុន្តែបច្ចុប្បន្នការធ្វើសារពើភ័ណ្ឌនៅកម្ពុជាបានគិតគូរដល់បរិស្ថាន សារព័ន្ធរុក្ខជាតិ សារព័ន្ធសត្វព្រៃ និង អនុផលព្រៃឈើ ដែលរួមមាន ផលស្តុករបស់ព្រៃឈើ ជំរកស្នាក់នៅ និង ប្រភេទនៃការអភិរក្ស ជាពិសេសបានគិតគូរដល់ការធ្វើសារពើភ័ណ្ឌកាបូនស្តុកដែលមានក្នុងព្រៃឈើជាតិ។

ដំណើរការរៀបចំផែនការគ្រប់គ្រងព្រៃឈើនៅកម្ពុជារួមមាន ៣កំរិត ដែលកំរិតនិមួយៗផែនការគ្រប់គ្រងត្រូវរៀបចំដោយផ្អែកទៅលើទិន្នន័យសារពើភ័ណ្ឌ ដែលបានប្រមូលពីទីវាលជាក់ស្តែង។ អនុកម្មវិធីនេះ គឺសំដៅតែលើការធ្វើសារពើភ័ណ្ឌកំរិតខ្ពស់ គឺ **សារពើភ័ណ្ឌថ្នាក់ជាតិ** និង ពិពណ៌នាពីដំណើរការ ដើម្បីឆ្លើយតបនូវគ្រប់កំរិតនិមួយៗ និង ធ្វើការសើរើរៀងរាល់ ៥ឆ្នាំម្តង។ គោលបំណងនៃសារពើភ័ណ្ឌគឺដើម្បីផ្តល់នូវការវាយតម្លៃធនធានព្រៃឈើ និង ចង្អុលបង្ហាញនូវស្ថានភាពព្រៃឈើក្នុងឯកតាខុសៗគ្នា ដែលត្រូវរៀបចំគ្រប់គ្រងឱ្យមាននិរន្តរភាព។

## ២-មធ្យោបាយអនុវត្ត

ការបង្កើតប្លង់ជំរើស ការចំណាយតិចតែមានប្រសិទ្ធិភាព និង វិធីសាស្ត្រធ្វើសារពើភ័ណ្ឌព្រៃឈើជាតិដោយប្រព័ន្ធ ដើម្បីធ្វើការប៉ាន់ស្មាន និងត្រួតពិនិត្យលើធនធានព្រៃឈើជាតិជារៀងរាល់ ៥ឆ្នាំម្តង ដែលទំរង់ទាំងអស់នេះមានដូចខាងក្រោមៈ

- កំណត់នូវភាពជាដៃគូរជាមួយជំនាញការ ក្នុងការរៀបចំប្លង់ជំរើសសារពើភ័ណ្ឌធនធានព្រៃឈើចំរុះ
- បង្កើតថ្មីនូវការចំណាយតិចតែមានប្រសិទ្ធិភាពក្នុងការជ្រើសរើសសំណាក ដើម្បីធ្វើការប៉ាន់ស្មានផលស្តុកព្រៃឈើជាតិ
- បង្កើតនូវការចំណាយតិចតែមានប្រសិទ្ធិភាពក្នុងការជ្រើសរើសវិធីសាស្ត្រ ដើម្បីធ្វើការប៉ាន់ស្មាន បរិមាណ និង គុណភាពនៃអនុផលព្រៃឈើ សេវាកម្មបរិស្ថាន ជំរកស្នាក់នៅ ប្រភេទរងគ្រោះថ្នាក់ ។ល។

- ពិនិត្យសិក្សា និង បង្កើតនូវការចំណាយតិចតែមានប្រសិទ្ធិភាព និង មធ្យោបាយដែលអាចជឿជាក់បាន ដើម្បីអនុវត្តសារពើភ័ណ្ឌកាបូនព្រៃឈើជាតិ
- បង្កើតនូវប្រព័ន្ធដែលមានប្រសិទ្ធិភាព និង អាចជឿជាក់បាន ដើម្បីធ្វើឱ្យត្រឹមត្រូវក្នុងការវិភាគ រៀបចំ និងទុកដាក់នូវគ្រប់ទិន្នន័យសារពើភ័ណ្ឌព្រៃឈើជាតិ
- បង្កើតនូវប្រព័ន្ធដែលប្រាកដថា ការរៀបចំរបាយការណ៍គឺមានទំរង់ច្បាស់លាស់ និងបង្ហាញនៅកំរិតទាក់ទង និង រៀបចំពត៌មានដែលអាចរកបាន នៅក្នុងប្រព័ន្ធអ៊ិនធឺណេត
- បង្កើតនូវប្រព័ន្ធដែលមានលក្ខណះស្តង់ដា ដើម្បីធ្វើការប្រមូល វិភាគទិន្នន័យ និងការរៀបចំរបាយការណ៍ដែលមានទំនាក់ទំនងទៅនឹងការប្រមូលទិន្នន័យសារពើភ័ណ្ឌព្រៃឈើក្នុងទម្រង់បែបបទ ការត្រួតពិនិត្យវាយតម្លៃនិងរាយការណ៍ស្តីពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព (MAR-SFM)

## ៣-លទ្ធផលសង្ឃឹមទុក

- ធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធរៀបចំសារពើភ័ណ្ឌព្រៃឈើជាតិ និងផ្តល់នូវការធ្វើបច្ចុប្បន្នភាពដែលអាចជឿជាក់បាន លើធនធានព្រៃឈើចំរុះរៀងរាល់ ៥ឆ្នាំម្តងដោយផ្អែកតាមការត្រួតពិនិត្យ និង ផែនការនៃការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជា។
- ការប្រមូល វិភាគទិន្នន័យសារពើភ័ណ្ឌជាតិ និង ការរៀបចំរបាយការណ៍ដែលមានលក្ខណៈស្តង់ដា និង ស្ថិតិជាតិដែលអាចជឿជាក់បានលើធនធានព្រៃឈើ គឺអាចរកបានជាសាធារណៈ។ ព្រមទាំងធ្វើឱ្យកាន់តែប្រសើឡើងក្នុងការរៀបចំឯកសារធនធានព្រៃឈើថ្នាក់តំបន់ និង ថ្នាក់ជាតិ។

## ២.២ តាមដានត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៍ ស្តីពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព

១. ការអធិប្បាយ: អនុកម្មវិធីនេះ គឺសកម្មភាពសំខាន់តាមដានត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៍សស្តីពីការគ្រងគ្រងព្រៃឈើប្រកបដោយនិរន្តរភាព សម្រាប់អនុវត្តថ្នាក់ជាតិ និងស្របតាមការវិវត្តបច្ចេកវិទ្យាគ្រប់គ្រងព្រៃឈើសកលលោក។ ទម្រង់នេះផ្តោតលើកត្តាលក្ខខ័ណ្ឌគប់គ្រងព្រៃឈើ វិសាលភាពព្រៃឈើ សុខាមាភាពព្រៃឈើ ផលិតផលព្រៃឈើ ជីវចម្រុះ ការការពារដី និងទឹក និងទស្សនទានសង្គមសេដ្ឋកិច្ច និងវប្បធម៌។

២. មធ្យោបាយអនុវត្ត: រៀបចំលក្ខណៈវិនិច្ឆ័យ និងសូចនាករសម្រាប់កត់ត្រាទិន្នន័យពាក់ព័ន្ធវិស័យព្រៃឈើ សម្រាប់តាមដានត្រួតពិនិត្យ វាយតម្លៃ និងធ្វើរបាយការណ៍ ស្តីពីការគ្រប់គ្រងប្រកបដោយនិរន្តភាព។

៣. លទ្ធផលរំពឹងទុក:ផ្តល់ប្រព័ន្ធតាមដានត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៍ការស្តីពីការគ្រប់គ្រងព្រៃ ឈើសម្រាប់ជាតិ និងកំរិតឯកតាគ្រប់គ្រង ព្រមទាំងជាពត៌មានសម្រាប់ការគ្រប់គ្រង រៀបចំផែនការអនុវត្ត ត្រឹមត្រូវ និងមានប្រសិទ្ធភាព។

## អនុកម្មវិធីទី៣.ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងព្រៃផ្តល់ផលក្រៅព្រៃសហគមន៍

១. ការអធិប្បាយ: ព្រៃបម្រុងទុកអចិន្ត្រៃយ៍ បានចាត់ជាព្រៃផ្តល់ផល ព្រៃការពារ និងព្រៃ សម្រាប់ផ្ទេរទៅជាការអភិវឌ្ឍផ្សេងៗ។ ប្រព័ន្ធគ្រប់គ្រងព្រៃផ្តល់ផលសំខាន់ៗ គឺព្រៃ សហគមន៍ ព្រៃសម្បទាន ព្រៃគុបផ្ទំផលក្រៅពីព្រៃសម្បទាន ការស្តារព្រៃឈើឡើង វិញក្រោយអាជីវកម្ម ព្រៃឈើដៃគូរ និងការការអភិវឌ្ឍដាំឈើ...។ល។ ក្នុងបរិបទអនុកម្មវិធីនេះ គឺអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងព្រៃឈើជាលក្ខណ:ពាណិជ្ជកម្ម ដើម្បីចូលរួមបង្កើន ជីវភាពប្រជាជនមូលដ្ឋាន ការពារនៃសេវាបរិស្ថាន ការពារទីជំរាល និងឥណទាន កាបោន។

២. មធ្យោបាយអនុវត្ត:

- អភិវឌ្ឍការគ្រប់គ្រងព្រៃឈើ ប្រកបដោយនិរន្តភាព: (១) ភាពទទួលខុសត្រូវលើតួនាទី ការគ្រប់គ្រង និងធ្វើផែនការ (២) ការរៀបចំ ផែនការគ្រប់គ្រងព្រៃឈើ ចាំបាច់ត្រូវផ្តោតលើចំណាត់ព្រៃឈើធនធានព្រៃឈើ និង យុទ្ធសាស្រ្តគ្រប់គ្រង។

- ពង្រឹងការគ្រប់គ្រងព្រៃសម្បទាន ដោយបង្កើនការអនុវត្តគ្រប់គ្រងប្រកបដោយនិរន្តភាពឱ្យស្របតាមទស្សន និងបេសកកម្ម នៃកម្មវិធីព្រៃឈើ ដូចជារៀបចំជាសហគមន៍ពាណិជ្ជកម្មព្រៃឈើ, កម្មវិធីឥណទានកាបោន, ព្រៃការពារ និងព្រៃសម្បទានអភិរក្ស ជាដើម។
- អភិវឌ្ឍគំរូការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព ដូចជាបង្កើតព្រៃឈើដៃគូរ ផ្តល់សេវាបរិស្ថានព្រៃឈើ ការពារទីជំរាល និងឥណទានកាបោន។
- ការរៀបចំព្រៃគុបផ្តល់ផលក្រៅពីព្រៃសម្បទាន និងពង្រឹងការត្រួតពិនិត្យ និងអនុវត្ត ដើម្បីធានាបានការប្រមូលផលព្រៃឈើ ដែលរក្សាបានជីវចម្រុះ សេដ្ឋកិច្ច និងសង្គម ព្រមទាំងយន្តការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ។
- កំណត់ និងគ្រប់គ្រងទីតាំងដែលត្រូវស្តារព្រៃឈើឡើងវិញ ដើម្បីបង្កើនធនធានព្រៃឈើ ដោយអនុវត្តការថែរក្សាដំណុះកូនឈើធម្មជាតិ ការដាំបង្កើនធនធាន និងអនុវត្តការងាររុក្ខវប្បកម្ម។

៣.លទ្ធផលរំពឹងទុកៈ

- អនុវត្តការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពក្នុងព្រៃបំរុងទុកអចិន្ត្រៃយ៍ នឹងអាចពិនិត្យកែច្នៃនៃប្រព័ន្ធគ្រប់គ្រងព្រៃសម្បទានដែលនៅមានសុពលភាព និងការគ្រប់គ្រងព្រៃសម្បទានដែលបានលុបចោល ពិសេស នឹងបង្កើតបាននូវប្រព័ន្ធគ្រប់គ្រងព្រៃឈើមានប្រសិទ្ធភាព។

- ការបង្កើតប្រព័ន្ធគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាពសម្រាប់ព្រៃបំរុងទុកអចិន្ត្រៃយ៍ នឹងផ្តល់នូវភាពទទួលខុសត្រូវ និងរក្សាបានកត្តាជីវចម្រុះ សេដ្ឋកិច្ច និងសង្គមប្រកបដោយចេរភាព។

- ប្រព័ន្ធគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព សម្រាប់ព្រៃផ្តលផលស្របតាមគោលបំណងសហគមន៍មូលដ្ឋាន និងផែនការជាតិ។

## អនុកម្មវិធីទី៤. អភិរក្សធនធានសេនេទិច និងបង្កើតប្រភព គ្រាប់ពូជ សម្រាប់កម្មវិធីដាំឈើ

### ១. ការពិពណ៌នា

- មានប្រភេទឈើក្នុងស្រុកជាច្រើន ត្រូវបានរាយឈ្មោះជាប្រភេទងាយរងគ្រោះ ឬ រងគ្រោះ យោងទៅតាមការវិនិច្ឆ័យនៃបញ្ជីក្រហមរបស់សហគមន៍អន្តរជាតិសំរាប់ការអភិរក្សធម្មជាតិ IUCN( International Union for Conservation and Nature) ។

- មានប្រភេទរុក្ខជាតិមានតម្លៃជាច្រើនទៀត ក៏ត្រូវបានរងការគំរាមកំហែង ហើយនឹងអាចឈានទៅរកការបាត់បង់។

- ការបាត់បងប្រភេទឈើគឺជាការចុះថយនៃធនធានសេនេទិក និង គុណភាពគ្រាប់ពូជ ហើយមាន ផលប៉ះពាលអវិជ្ជមានសំរាប់កម្មវិធីដាំឈើ ដូចជា ដាំសំរាប់គោលបំណងជាលក្ខណៈ ពាណិជ្ជកម្ម (ប្រភេទឈើមូល) ដាំសំរាប់គោលបំណងជាលក្ខណៈចិញ្ចឹមជីវិត (ប្រភេទឈើសំរាប់កសិ-រុក្ខកម្ម របងរស់ ច្បារដំណាំក្បែរផ្ទះ ឈើថាមពល។ល។) ឬ ដាំសំរាប់គោលបំណងជាលក្ខណៈបរិស្ថាន (ប្រភេទឈើសំរាប់ការការពារទីជំរាល គ្រប់គ្រងការហូរច្រោះ យន្តការអភិវឌ្ឍស្អាត)។

- រាជរដ្ឋាភិបាលបានផ្តល់សច្ចានុម័តលើអនុសញ្ញាស្តីពី ជីវចំរុះ នៅឆ្នាំ ១៩៩៥ ក្នុងគោលបណង បំពេញ នូវយុទ្ធសាស្រ្តជីវចំរុះថ្នាក់ជាតិ និង ផែនការសកម្មភាព ដែលបានស្វែងរកការ អភិវឌ្ឍ និងការអនុវត្តនៃកម្មវិធីនេះ សម្រាប់ធ្វើឱ្យប្រសើឡើងដល់ប្រភេទរុក្ខជាតិ ដែល បានរងគ្រោះ ក្នុងនោះ រួមមាន ផែនការអភិរក្សក្នុងតំបន់ និង ផែនការអភិរក្សក្រៅតំបន់។
- កម្ពុជាបានអភិវឌ្ឍនូវយុទ្ធសាស្រ្តអភិរក្សហែ្សនព្រៃឈើ ក្នុងនោះបានផ្តល់នូវគម្រោងការ (framework)សំរាប់ការគ្រប់គ្រងនៃប្រភេទរុក្ខជាតិគោលដៅដែលបានស្គាល់អត្ត សញ្ញាណនៅក្នុងបណ្តញការងានៃតំបន់អភិរក្សហែ្សន ដែលបានធ្វើការកំណត់រួច។
- កម្មវត្ថុនៃអនុកម្មវិធីនេះ គឺដើម្បីអភិរក្សធនធានសេនេទិកតាមរយៈការគ្រប់គ្រង ឱ្យមាន និរន្តរភាព និង ប្រយោជន៏ ដែលទទួលបានពីការអនុវត្តតាមរយៈការសហការ ដែលមាន សហគមន៏ មូលដ្ឋានជាដៃគូ។

## ២.មធ្យោបាយអនុវត្ត

- បង្កើតគម្រោងការងារសមស្របសំរាប់ការអភិរក្សហ្សែនព្រៃឈើប្រកបដោយនិរន្តរភាព
- ធ្វើអត្តសញ្ញាណកម្ម និង បង្កើតតំបន់អភិរក្សក្នុង និង តំបន់អភិរក្សក្រៅ ហើយនិង ដាក់ញ្ចូល តាមដាន និង គ្រប់គ្រងនៅក្នុងផែនការគ្រប់គ្រងព្រៃឈើថ្នាក់មូលដ្ឋាន
- បង្កើតឡូតិ៍បង្ហាញនៃការបង្កើនគុណភាពដើមឈើតាមរយៈការប្រើប្រាស់គ្រាប់ពូជឈើ មានគុណភាពចេញពីព្រៃអភិរក្ស
- ផ្តួចផ្តើមបង្កើតការបង្កើនគុណភាពដើមឈើតាមរយៈការបង្កាត់ពូជឈើនៃប្រភេទឈើ ដែល បានជ្រើសរើស
- លើកកំពស់ការយល់ដឹងនៃភាពមានសារៈប្រយោជន៏នៃការប្រើប្រាស់គ្រាប់ពូជឈើ មាន គុណភាពល្អ
- បង្ហាញពីភាពមានតម្លៃនៃការប្រើប្រាស់ និង ភាពមិនមានតម្លៃ នៃប្រើប្រាស់ប្រភេទឈើ ក្នុងស្រុក
- អភិវឌ្ឍប្រព័ន្ធទីផ្សារគ្រាប់ពូជ និង លក់គ្រាប់ពូជឈើ ដើម្បីធ្វើឱ្យប្រសើឡើងពី ការរក ចំណូលនៅមូលដ្ឋាន ដែលបានមកពីប្រភពគ្រាប់ពូជឈើ ។

## ៣. លទ្ធផលសង្ឃឹមទុក

- ប្រភេទរុក្ខជាតិកំរ ឬ ប្រភេទឈើមានតម្លៃបានអភិរក្សប្រកបដោយប្រសិទ្ធភាពនៅក្នុងបណ្តាញការងារនៃព្រៃអភិរក្ស
- គ្រាប់ពូជឈើមានគុណភាពត្រូវបានកើតមាន និង កើនឡើងសំរាប់ការស្តារព្រៃឈើឡើងវិញ និង សកម្មភាពដាំឈើ
- យន្តការនៃការបែកចែកផលប្រយោជន៍ ដែលទទួលបានពីការគ្រប់គ្រង និង ការលក់គ្រាប់ពូជឈើដែលមានការចូលរួមពីសហគមន៍មូលដ្ឋាន
- ការយល់ដឹងនៃតួនាទីអេកូឡូស៊ី និង សេដ្ឋកិច្ចនៃប្រភេទឈើក្នុងស្រុកបានត្រូវបានលើកកំពស់
- ភាពកាន់តែប្រសើឡើងនៃចំការឈើដាំ ដោយសារការប្រើប្រាស់គ្រាប់ពូជឈើមានគុណភាពល្អ ដែលបានមកពីការអភិរក្សហ្សែនព្រៃឈើ ។



# អនុកម្មវិធីទី៥. អភិវឌ្ឍពហុចំការដាំឈើ

## ១.ការពិពណ៌នា

- កម្មវិធីអភិវឌ្ឍថ្នាក់ជាតិនៅកម្ពុជាបានទទួលស្គាល់យ៉ាងច្បាស់នូវភាពមានសារៈសំខាន់នៃធនធានព្រៃឈើ ចំពោះការចិញ្ចឹមជីវិតនៅជនបទ និង ភាពអាច ប្រមូលផលបានលើ ធនធានទាំងនេះ ដោយប្រជាជនមូលដ្ឋាន។
- រដ្ឋបាលព្រៃឈើបានប្រឹងប្រែងបង្កើតនូវបរិយាកាសសមស្រប ដោយបានផ្តោតសំខាន់លើការអភិវឌ្ឍចំការឈើដាំប្រើប្រាស់ច្រើនយ៉ាង ដែលមានសក្តានុពលក្នុងការផ្គត់ផ្គង់ផលិតផលឈើសម្រាប់ការប្រើប្រាស់ក្នុងស្រុក បង្កើនប្រាក់ចំណូលសម្រាប់សហគមន៍មូលដ្ឋាន ហើយនឹង ធ្វើឱ្យប្រសើរឡើងនូវបរិស្ថានតាមរយៈការការពារទីជំរាល និង គ្រប់គ្រងការហូរច្រោះ។

## ២.មធ្យោបាយនៃការអនុវត្ត ៖

- គោលនយោបាយថ្នាក់ជាតិសំរាប់ការអភិវឌ្ឍចំការឈើដាំប្រើប្រាស់ច្រើនយ៉ាង ដើម្បីធានាសិទ្ធិរបស់ប្រជាជនមូលដ្ឋានក្នុងការដាំឈើ ប្រមូលផល និង រកទីផ្សារផលិតផលព្រៃឈើ និង សេវាកម្ម
- ធ្វើអត្តសញ្ញាណកម្មប្រភេទឈើសមស្របសម្រាប់ចំការឈើដាំប្រើប្រាស់ច្រើនយ៉ាង
- អភិវឌ្ឍថ្នាលបណ្តុះ ដើម្បីធានាបានការផ្គត់ផ្គង់កូនឈើ ដែលមានគុណល្អ និង មានស្ថេភាពសម្រាប់សកម្មភាពចំការដាំឈើប្រើប្រាស់ច្រើនយ៉ាង
- កំណត់ទីតាំងចំការឈើដាំប្រើប្រាស់ច្រើនយ៉ាង ហើយចំការឈើនេះត្រូវបានគាំទ្រដោយផែនការគ្រប់គ្រងថ្នាក់ជាតិ ហើយដាក់បញ្ចូល និង គាំទ្រក្នុងរង្វង់ផែនការគ្រប់គ្រងព្រៃឈើថ្នាក់មូលដ្ឋាន

- បង្កើតចំការបង្ហាញនៃចំការឈើប្រើប្រាស់ច្រើនយ៉ាងនៅក្នុងខណ្ឌរដ្ឋបាលព្រៃឈើនីមួយៗ ដើម្បីសាកល្បងបង្ហាញនូវការកើតមានបរិស្ថានសមស្របតាមរយៈការបង្កើតចំការឈើនេះ ដល់ប្រជាជនមូលដ្ឋាន
- អភិវឌ្ឍសេវាកម្មផ្សព្វផ្សាយ និង លើកកំពស់ការយល់ដឹងដើម្បីគាំទ្រសកម្មភាពដាំឈើ ទាំង បច្ចេកទេស និង ផ្លូវច្បាប់
- អភិវឌ្ឍនូវកិច្ចសហការលើការបង្កើតចំការឈើ រវាងសហគមន៍ និង រដ្ឋបាលព្រៃឈើ តាមរយៈការអភិវឌ្ឍនៃគំរូកិច្ចព្រមព្រៀងស្ដីពីកាគ្រប់គ្រង និងបែកចែកផលប្រយោជន៍។ គំរូកិច្ចព្រមព្រៀងនេះត្រូវបានធ្វើយុត្តិកម្មនៅក្នុងអនុក្រឹត្យស្ដីពី វិធាននៃការផ្ដល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ការដាំឈើ។

# ៣.លទ្ធផលសង្ឃឹមទុក ៖

- មានបរិយាកាសសមស្របសម្រាប់ការវិនិយោគនៅមូលដ្ឋាន តាមរយៈការបន្តនូវការកែទំរង់ព្រៃឈើ ដើម្បីធានាសិទ្ធិរបស់ប្រជាជនមូលដ្ឋានចំពោះផលប្រយោជន៍ ដែលទទួលបានពីគ្រប់ទិដ្ឋភាពនៃចំការឈើដាំប្រើប្រាស់ច្រើនយ៉ាង
- ប្រជាជនមូលដ្ឋានចូលរួមយ៉ាងខ្ជាប់ខ្ជួនក្នុងការបង្កើនចំការឈើដាំប្រើប្រាស់ច្រើនយ៉ាង ហើយជាលទ្ធផលនៃការចូលរួមនេះ បានធ្វើឱ្យប្រាក់ចំណូល និង ការចិញ្ចឹមជីវិតកាន់តែប្រសើរឡើង
- បានកាត់បន្ថយការហូរច្រោះ និង ការពារទីជំរាលនៅក្នុងតំបន់ប្រមូលផ្តុំនៃការបង្កើតចំការឈើដាំប្រើប្រាស់ច្រើនយ៉ាង
- ការផ្គត់ផ្គង់ឈើមូល និង ឈើបង្គោលតាមរយៈផលិតផលនៃការផលិតឈើនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិកាន់មាននិរន្តភាព និង ប្រសើរឡើង ។



# អនុកម្មវិធីទី៦. ការរៀបចំប្រព័ន្ធគ្រប់គ្រងព្រៃការពារដែល រួមមានការអភិរក្សធនធានជីវចម្រុះ និងការអភិវឌ្ឍន៍ទេស ចរណ៍ធម្មជាតិ

## សេចក្តីផ្តើម

ព្រៃឈើ តំបន់ដីសើម និងវាលស្មៅនៅក្នុងប្រទេសកម្ពុជា មានជីវចម្រុះសំបូរបែបដែលរួមមានប្រភេទសត្វព្រៃ និងរុក្ខជាតិដែលកំពុងទទួលរងការគំរាមកំហែងជិតផុតពូជ។ ធនធានជីវចម្រុះមានសារៈសំខាន់សម្រាប់ទ្រទ្រង់ការរស់នៅរបស់សហគមន៍មូលដ្ឋាន និងផ្តល់ធនធានហ្សែនមានតម្លៃសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម និងឱសថបុរាណ។ អនុលោមតាមយុទ្ធសាស្ត្រនៃការអភិរក្សជីវចម្រុះ និងផែនការសកម្មភាពជាតិ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយ និងគោលបំណងសំខាន់៧សម្រាប់អភិរក្សជីវចម្រុះ។ គោលបំណងសំខាន់៧ដែលដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជាមានគោលដៅបំពេញកាតព្វកិច្ចអន្តរជាតិរបស់ប្រទេសកម្ពុជា ក្នុងនាមជាប្រទេសហត្ថលេខីអនុសញ្ញាសាយតេស្ត (CITES) និងរ៉ាមសារ (Ramsar)។ គោលបំណងទាំងនេះមានចែងនៅក្នុងបរិបទនៃច្បាប់ស្តីពីព្រៃ ឈើ និងប្រកាសស្តីពីការចាត់ថ្នាក់ក្រុមប្រភេទសត្វព្រៃនៅក្នុងប្រទេសកម្ពុជា ហើយកំពុងអនុវត្តតាមរយៈការគ្រប់គ្រងតំបន់ការពារដែលស្ថិតក្រោមយុត្តាធិការរបស់ក្រសួងបរិស្ថាន ព្រមទាំងព្រៃការពារ និងតំបន់អភិរក្សផ្សេងទៀតស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើ។ គោលបំណងនៃការគ្រប់គ្រងព្រៃការពារគឺសំដៅកាត់បន្ថយផលប៉ះពាល់ទៅលើទីជម្រក និងប្រទេសត្វព្រៃដែលកំពុងទទួលរងការគំរាមកំហែង។ ម្យ៉ាងទៀត ការជួញដូរប្រភេទសត្វព្រៃ និងរុក្ខជាតិកំពុងទទួលរងការគំរាមកំហែងដោយខុសច្បាប់ គួរតែធ្វើការត្រួតពិនិត្យនៅទូទាំងប្រទេសកម្ពុជា។ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ កំពុងផ្តល់ការស្រាវជ្រាវវិទ្យាសាស្ត្រ និងអប់រំទាក់ទងនឹងការអភិរក្ស និងស្តារលទ្ធភាព សត្វព្រៃ។

# យុទ្ធសាស្ត្រនៃការអនុវត្ត

- **កំណត់សកម្មភាពជាអាទិភាពជាតិសម្រាប់ការអភិរក្សនៅក្នុងសម្បត្តិព្រៃឈើអចិន្ត្រៃយ៍**

  រដ្ឋបាលព្រៃឈើនឹងធ្វើការសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ ដៃគូរអភិវឌ្ឍន៍នានា និងភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីពិនិត្យ និងវាយតម្លៃធនធានព្រៃឈើរបស់ប្រទេសកម្ពុជាឡើងវិញ និងកំណត់សកម្មភាពអាទិភាពជាតិសម្រាប់ការអភិរក្សនៅក្នុងសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ហើយត្រូវធានាថា ការអភិរក្សធនធានព្រៃឈើដែលសំបូរជីវចម្រុះមានតម្លៃត្រូវចាត់ទុកជាអាទិភាពនៅពេលបង្កើតឡើង ។

# យុទ្ធសាស្ត្រនៃការអនុវត្ត

- **ធានាបានការគ្រប់គ្រងព្រៃការពារ និងតំបន់អភិរក្សផ្សេងទៀតប្រកបដោយប្រសិទ្ធភាព**

រដ្ឋបាលព្រៃឈើនឹងរៀបចំផែនការគ្រប់គ្រងព្រៃការពារ និងតំបន់អភិរក្សផ្សេងទៀតនៅក្នុងសម្បត្តិព្រៃឈើ អចិន្ត្រៃយ៍ ។ កំណត់សក្តានុពល និងបង្កើតតំបន់អភិរក្សបន្ថែមទៀតដើម្បីធានាថា ប្រព័ន្ធគ្រប់គ្រប់គ្រង និងអភិរក្សព្រៃការពារ និងតំបន់អភិរក្សផ្សេងទៀតមានវិសាលភាពទំលំទូលាយ ។ ធ្វើការអភិវឌ្ឍន៏សហគមន៏មូលដ្ឋាន និង ជុំរុញសហគមន៏មូលដ្ឋាន ចូលរួមនៅក្នុងការងារអភិរក្ស ។ រៀបចំផែនការគ្រប់គ្រងទេសចរណ៏ធម្មជាតិ ។ ធានាយន្តការ និរន្តរភាពហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងព្រៃការពារ និងតំបន់អភិរក្សផ្សេងទៀត ។

# យុទ្ធសាស្ត្រនៃការអនុវត្ត

- **ការគ្រប់គ្រង និងអភិរក្សធនធានជីវចម្រុះ និងសត្វព្រៃ**

  - **ការពារ និងអភិរក្សធនធានជីវចម្រុះ និងសត្វព្រៃ**

ជំរុញការត្រួតពិនិត្យ និងគ្រប់គ្រងព្រំប្រទល់សម្បត្តិព្រៃឈើ និងការការពារទីជម្រកសំខាន់ៗ សត្វព្រៃ រុក្ខជាតិ និងត្រួតពិនិត្យជម្ងឺសត្វព្រៃ។

  - **គ្រប់គ្រងធនធានជីវចម្រុះ និងសត្វព្រៃ**

កម្មវិធីគ្រប់គ្រងសត្វព្រៃរួមមាន ការគ្រប់គ្រងសត្វព្រៃ និងទីជម្រករបស់វា។ យុទ្ធសាស្ត្រគ្រប់គ្រងសត្វព្រៃត្រូវ រួមបញ្ចូលការគ្រប់គ្រងទាំងនៅក្នុងតំបន់ព្រៃការពារ និងក្រៅតំបន់ព្រៃការពារ។

# យុទ្ធសាស្ត្រនៃការអនុវត្ត

- **ការគ្រប់គ្រងតំបន់លំហែកំសាន្ត និងទេសចរណ៍ធម្មជាតិ**

កម្មវិធីគ្រប់គ្រងតំបន់លំហែកំសាន្ត និងទេសចរណ៍ធម្មជាតិមានគោលដៅគ្រប់គ្រងធនធាន និងសកម្មភាពទេស ចរណ៍ធម្មជាតិ ទីផ្សារទេសចរណ៍ធម្មជាតិ និងកម្មវិធីមគ្គុទ្ទេសទេសចរណ៍ ការគ្រប់គ្រងសេវាកម្មដើម្បីបង្កើត និងធានា បានយន្តការហិរញ្ញវត្ថុនិរន្តរភាពសម្រាប់គ្រប់គ្រង និងអភិរក្សតំបន់ព្រៃការពារ និងតំបន់អភិរក្សផ្សេងទៀត និងជួយលើកកំពស់ជីវភាពរបស់សហគមន៏មូលដ្ឋាន។ រៀបចំវិធាន បទដ្ឋានច្បាប់ និងគោលការណ៏ណែនាំបច្ចេកទេសសម្រាប់ ជុំរុញសកម្មភាពទេសចរណ៏ធម្មជាតិ និងលើកទឹកចិត្តវិស័យឯកជន ការចូលរួមរបស់សហគមន៏មូលដ្ឋាន និងការវិនិយោគទេសចរណ៏ធម្មជាតិដោយអនុលោមតាមស្តង់ដាជាតិ និងអន្តរជាតិដើម្បីលើកស្ទួយវិស័យសេដ្ឋកិច្ចជាតិ និងសហគមន៏ ព្រមទាំងឆ្លើយតបនឹងគោលដៅអភិរក្សជីវចម្រុះ។

# យុទ្ធសាស្ត្រនៃការអនុវត្ត

- **កីឡាប្រមាញ់កំសាន្ត**

កម្មវិធីកីឡាប្រមាញ់បែបកំសាន្តមានគោលដៅណែនាំ យន្តការប្រើប្រាស់ធនធានសត្វព្រៃដោយនិរន្តរភាព គ្រប់គ្រងការបរបាញ់ និងលុបបំបាត់ ការបរបាញ់សត្វព្រៃខុសច្បាប់ ។ រៀបចំវិធាន និងបទដ្ឋានច្បាប់ទាក់ទងនឹងរដូវ បរបាញ់ កូតាដកហូត ប្រភេទសត្វព្រៃគោលដៅ ទីតាំង តម្លៃជ័យភ័ណ្ឌ ថ្លៃសួយសារ ថ្លៃពន្ធនិងបុព្វលាភ សម្ភារៈ ប្រមាញ់ ដោយអនុលោមតាមស្តង់ដាជាតិ និងអន្តរជាតិដើម្បីលើកស្ទួយវិស័យសេដ្ឋកិច្ចជាតិ ព្រមទាំងជួយរក្សា លំនឹងសត្វព្រៃ នៅក្នុងតំបន់ ។

# យុទ្ធសាស្ត្រនៃការអនុវត្ត

- **សមាហរណកម្មការអភិវឌ្ឍន៍សហគមន៍ និងកិច្ចសហប្រតិបត្តិការ**

កម្មវិធីសមាហរណកម្មការអភិវឌ្ឍន៍សហគមន៍ និងកិច្ចសហប្រតិបត្តិការ មានគោលដៅកាត់បន្ថយការពឹងផ្អែក ទៅលើធនធានធម្មជាតិតាមរយៈការផ្តល់ប្រាក់ចំណូលសម្រាប់សហគមន៍តាមមូលដ្ឋានដោយផ្តល់ការងារដល់សហគមន៍នៅក្នុងការគ្រប់គ្រង និងអភិរក្សព្រៃការពារ និងតំបន់អភិរក្សផ្សេងទៀត និងលើកទឹកចិត្តការប្រើប្រាស់សេវាកម្មទេសចរណ៍ធម្មជាតិរបស់ពួកគេ ។ ដោះស្រាយជម្លោះការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់ព្រៃការពារ និងតំបន់អភិរក្សផ្សេងទៀត លើកកំពស់កិច្ចសហប្រតិបត្តិការរបស់សហគមន៍នៅក្នុងការគ្រប់គ្រង និងការអប់រំផ្សព្វផ្សាយ ។ ផ្តល់ការបណ្តុះបណ្តាលដល់ប្រជាសហគមន៍មូលដ្ឋាន ដើម្បីពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការទាញយកផលប្រយោជន៍ពីការបណ្តុះបណ្តាលនេះព្រមទាំងការកែលម្អជីវភាពប្រកបដោយចិរភាពផ្សេងទៀត ។ ធ្វើការណែនាំអំពីជម្រើសនៃការប្រើប្រាស់ដីជាក់ស្តែងដល់សហគមន៍មូលដ្ឋានដើម្បីធ្វើការសម្របសម្រួល និងលើកកំពស់ការធ្វើកសិកម្មដោយនិរន្តរភាព និងកសិ-រុក្ខវប្បកម្មនៅក្នុងព្រៃសហគមន៍ ព្រមទាំងនៅតំបន់ដែលកំណត់ទុកសម្រាប់ធ្វើកសិកម្មផ្សេងទៀតនៅក្នុងតំបន់ព្រៃការពារ និងតំបន់អភិរក្សផ្សេងទៀត ។ រៀបចំបទដ្ឋានច្បាប់ និងលក្ខណៈវិនិច្ឆ័យសមស្របក្នុងការចូលប្រមូលផល-អនុផលព្រៃឈើសម្រាប់ប្រើប្រាស់ជាប្រពៃណីនៅក្នុងព្រៃការពារ និងតំបន់អភិរក្សផ្សេងទៀតដើម្បីជួយគាំទ្រជីវភាពសហ គមន៍ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ។

# យុទ្ធសាស្ត្រនៃការអនុវត្ត

- **ការពង្រឹងស្ថាប័ន  និងអភិវឌ្ឍធនធានមនុស្ស**

  កម្មវិធីពង្រឹងស្ថាប័ន និងអភិវឌ្ឍធនធានមនុស្សសំដៅធ្វើឱ្យប្រសើរឡើងដល់ការគ្រប់គ្រងស្ថាប័ន ការ អភិវឌ្ឍន៍  ធនធានមនុស្ស និងកិច្ចសហប្រតិបត្តិការដើម្បីលើកកំពស់អភិបាលកិច្ចល្អនៅក្នុងការគ្រប់គ្រងព្រៃឈើ សត្វព្រៃ និងការ អភិរក្សជីវចម្រុះ។

# យុទ្ធសាស្ត្រនៃការអនុវត្ត

- **ការស្រាវជ្រាវ អង្កេត និងអប់រំផ្សព្វផ្សាយ**

  កម្មវិធីស្រាវជ្រាវ អង្កេត និងអប់រំផ្សព្វផ្សាយមានគោលដៅសម្រាប់រៀបចំប្រព័ន្ធ ទិន្នន័យ ព័ត៌មានភូមិសាស្ត្រស្ដីពី សត្វព្រៃ ជីវចម្រុះ ធនធានធម្មជាតិ ការគ្រប់គ្រង តំបន់លំហែកំសាន្ត និងទេសចរណ៍ធម្មជាតិ សហគមន៍មូលដ្ឋាន ជីវសាស្ត្រ និងការអភិរក្សប្រភេទសត្វព្រៃអាទិភាព ការប្រើប្រាស់ធនធានធម្មជាតិនៅ ក្នុងតំបន់ដែលមានសារៈសំខាន់ សម្រាប់អភិរក្សជីវចម្រុះ ព្រមទាំងធ្វើការអប់រំផ្សព្វផ្សាយស្ដីពីសារៈសំខាន់ព្រៃឈើ សត្វព្រៃ និងជីវចម្រុះ។

# យុទ្ធសាស្ត្រនៃការអនុវត្ត

- **អនុសញ្ញាក្នុងតំបន់  និងអន្តរជាតិ**

កម្មវិធីអនុសញ្ញាក្នុងតំបន់ និងអន្តរជាតិមានគោលដៅអនុវត្ត អនុសញ្ញាក្នុងតំបន់ និងអន្តរជាតិដែលផ្តល់សច្ចាប័ន ដោយរាជរដ្ឋាភិបាលកម្ពុជា កិច្ចព្រមព្រៀង កិច្ច សហប្រតិបត្តិការទ្វេភាគី និងពហុភាគីទាក់ទងនឹងការអភិរក្សព្រៃឈើ សត្វព្រៃ និងជីវចម្រុះ។

## ៣. លទ្ធផលរំពឹងទុក

- មានប្រព័ន្ធគ្រប់គ្រងដោយប្រសិទ្ធភាពទាក់ទងការបរបាញ់បែបកីឡាកំសាន្ត ទេសចរណ៍ធម្មជាតិ ទេសចរណ៍ធម្មជាតិដោយសហគមន៍ ព្រៃការពារ និងតំបន់អភិរក្សផ្សេងទៀត ។
- កាត់បន្ថយជាអប្បរមារាល់រូបភាពនៃការជួនដូរសត្វព្រៃនៅទូទាំងប្រទេសកម្ពុជា
- មានចំណេះដឹងគ្រប់គ្រាន់សម្រាប់គ្រងគ្រងប្រភេទសត្វព្រៃជាអាទិភាព និងទីជម្រករបស់វា
- ឥរិយាបទរបស់សាធារណៈជនបានប្រសើរឡើងទាក់ទងនឹងការការពារ និងអភរក្សជីវចម្រុះ
- វិស័យឯកជន និងសាធារណៈនឹងធ្វើការវិនិយោគកីឡាបរបាញ់កំសាន្ត និងទេសចរណ៍ធម្មជាតិ
- ស្តារលទ្ធភាពសត្វព្រៃសំខាន់ៗនៅក្នុងព្រៃធម្មជាតិ
- មានយន្តការនិរន្តរភាពហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងព្រៃការពារ និងតំបន់អភិរក្សផ្សេងទៀត និងគាំទ្រដល់ជីវភាពប្រជាពលរដ្ឋដែលទទួលបានពីទេសចរណ៍ធម្មជាតិ ឥណទានកាបូន វារីអគ្គិសនី និងការបរបាញ់បែបកីឡាកំសាន្ត
- មានអភិបាលកិច្ចល្អ តម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវប្រកបដោយសហប្រតិបត្តិការនៅក្នុងការគ្រប់គ្រង និងអភិរក្សព្រៃឈើ និងសត្វព្រៃ ព្រមទាំងការអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ ។

# អនុកម្មវិធីទី៧.ការកែច្នៃផលិតផលឈើ និងទីផ្សារ

## Justification and Objectives
## ឯកសារយុត្តិកម្ម និងគោលបំណង

- សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្តីពី គោលនយោបាយវិស័យព្រៃឈើជាតិ ឆ្នាំ ២០០២ ជម្រុញលើកទឹកចិត្តដល់ផ្នែកឯកជន និងសហគមន៍មូលដ្ឋានចូលរួមក្នុងការអភិវឌ្ឍផលិតផលព្រៃឈើសំរាប់ទីផ្សារក្នុងស្រុក និងការនាំចេញ
- គោលបំណងនៃកម្មវិធី គឺជម្រុញសកម្មភាពកែច្នៃអភិវឌ្ឍផលិតផលព្រៃឈើ និងរកទីផ្សារសំរាប់ផលិតផល

# Means of Implementation
# មធ្យោបាយអនុវត្ត

- បង្កើតក្រុមការងារថ្នាក់ជាតិដើម្បីដំណើរការអភិវឌ្ឍគុណភាពផលិតផលព្រៃឈើ
  - រៀបចំយុទ្ធសាស្ត្រថ្នាក់ជាតិ និងគោលការណ៍ណែនាំទ្រទ្រង់ដល់ការបង្កើនតម្លៃបន្ថែម ផលិតផលព្រៃឈើ
  - រៀបចំលិខិតបទដ្ឋានច្បាប់ទ្រទ្រង់ដល់ការកែច្នៃបង្កើនគុណភាពផលិតផល ជួយដល់សហគមន៍មូលដ្ឋាន និងផ្នែកឯកជនក្នុងការកែច្នៃផលិតផល និងរកទីផ្សារ
  - បង្កើតមូលដ្ឋានប្រព័ន្ធផ្តល់វិញ្ញាបនប័ត្រលើផលិតផលឈើ
- ពង្រឹងការងារស្រាវជ្រាវ និងអភិវឌ្ឍន៍
  - ការងារស្រាវជ្រាវត្រូវផ្សាភ្ជាប់ទៅនឹងគោលដៅអភិវឌ្ឍន៍ផលិតផលដើម្បីតម្រូវតាមទីផ្សារក្នុងស្រុក និងនាំចេញ

# Expected Results

# លទ្ធផលរំពឹងទុក

- បង្កើតបានប្រព័ន្ធផលិតកម្មស្របច្បាប់សំរាប់ការវិនិយោគនៃវិស័យឯកជន និងសហគមន៍មូលដ្ឋានលើអាជីវកម្មកែច្នៃបង្កើនគុណភាពផលិតផល
- ផលិតផលព្រៃឈើក្នុងស្រុកទទួលបានឱកាសស្រាវជ្រាវ និងអភិវឌ្ឍន៍តាមតម្រូវការទីផ្សារ
- ឧស្សាហកម្មកែច្នៃក្នុងស្រុក សហគមន៍មូលដ្ឋានទទួលបានការអភិវឌ្ឍបច្ចេកវិជ្ជាកែច្នៃបង្កើនគុណភាពផលិតផល និងការរកទីផ្សារ
- លើកកំពស់ជីវភាពសហគមន៍មូលដ្ឋានតាមរយៈផលិតផលថ្មីៗ និងការធានាទីផ្សារ

# អនុកម្មវិធីទី៨.ការអភិវឌ្ឍន៍បច្ចេកវិជ្ជាឈើ និងការកែច្នៃ

## ឯកសារយុត្តិកម្ម និងគោលបំណង

- អនុក្រឹត្យលេខ ១៣១ ស្តីពី យថាប្រភេទផល អនុផលព្រៃឈើអនុញ្ញាត អោយនាំចេញ នាំចូល បានហាមឃាត់ការនាំចេញឈើហ៊ុបមូល ឈើអារ ក្នុងគោលបំណងដើម្បីលើកទឹកចិត្តការកែច្នៃឈើក្នុងស្រុក បង្កើនតម្លៃបន្ថែម
- គោលបំណងនៃអនុកម្មវិធីនេះ គឺដើម្បីជម្រុញការអភិវឌ្ឍបច្ចេកវិជ្ជាឈើ និងការកែច្នៃផលិតផលព្រៃឈើដើម្បីធានានិរន្តភាព តម្លាភាពប្រភពផ្គត់ផ្គង់

# Means of Implementation
# វិធានការអនុវត្ត

- វិភាគសក្តានុពលនៃការផ្គត់ផ្គង់ឈើពីប្រភពស្របច្បាប់ក្រោមការគ្រប់គ្រង ប្រកបដោយនិរន្តភាព
- អនុវត្តវិធានការផ្តល់វិញ្ញាបនប័ត្រលើផលិតផលព្រៃឈើ
- ជម្រុញការងារស្រាវជ្រាវដោយផ្សាភ្ជាប់ទៅនឹងការអភិវឌ្ឍន៍ ផលិតផល

# Expected Results

# លទ្ធផលរំពឹងទុក

- បង្កើតបាននូវប្រព័ន្ធផលិតកម្មកែច្នៃឈើដែលធានាបាននូវតុល្យភាព រវាង ការផ្គត់ផ្គង់ឈើដោយចីរភាព និងការកែច្នៃផលិតផល ធ្វើពាណិជ្ជកម្មឈើ ក្រោមប្រព័ន្ធផ្តល់វិញ្ញាបនប័ត្រផលិតផលឈើ
- ទទួលបាននូវបច្ចេកទេសថ្មីៗបន្ថែមទៀតសម្រាប់ឧស្សាហកម្មកែច្នៃ ឈើនៅ កម្ពុជា

  បង្កើតបាននូវស្តង់ដាផលិតផលឈើសំរាប់ទីផ្សារក្នុងស្រុក និង ទីផ្សារនាំចេញ

# សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់របស់លោកអ្នក

# កម្មវិធីពង្រឹងការអនុវត្តច្បាប់ ស្តីពីព្រៃឈើ និងអភិបាលកិច្ច

(Forest Law Enforcement and Governance Program)

**សិក្ខាសាលាពិគ្រោះយោបល់ស្តីពី**

**កម្មវិធីព្រៃឈើជាតិ**

**ថ្ងៃទី ២៥-២៦ ខែ មីនា ឆ្នាំ ២០០៩**

**ខេត្តក្រចេះ**

**លោក សួន សុវណ្ណ ប្រធានការិយាល័យនីតិកម្ម-វិវាទ នៃរដ្ឋបាលព្រៃឈើ**

# មាតិកានៃបទបង្ហាញ

១.	ប្រវត្តិនៃដំណើរការរៀបចំកម្មវិធី

២-	បញ្ហាប្រឈមនៃការថយចុះធនធានព្រៃឈើ

៣-	គោលបំណងនៃកម្មវិធី

៤-	យុទ្ធសាស្ត្រអនុវត្តកម្មវិធី

៥-	អនុកម្មវិធីកំណែទំរង់ច្បាប់ និងរដ្ឋបាល

៦-	អនុកម្មវិធីពង្រឹងការអនុវត្តច្បាប់ និងការតាមដាននិងរាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើ

៧-	អនុកម្មវិធីការឆ្លើយតបរហ័សចំពោះពតិមានបទល្មើសព្រៃឈើ

៨-	សន្និដ្ឋាន

# I- ប្រវត្តិនៃដំណើរការរៀបចំកម្មវិធី

- ការបង្កើតអនុក្រុមកម្មវិធី និងកម្មវិធីពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ច យោងតាមអនុសាសន៍របស់ក្រុមការងារកម្មវិធីព្រៃឈើជាតិ
- អនុក្រុមកម្មវិធីបង្កើតឡើងដោយសេចក្តីសំរេចលេខ ៨០៨ រព.ករស ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៨
- សមាសភាពអនុក្រុមកម្មវិធីៈ រដ្ឋបាលព្រៃឈើ អង្គការដានីដា និង ធនាគារពិភពលោក
- សេចក្តីព្រាងកម្មវិធីនេះឆ្លងកាត់កិច្ចប្រជុំអនុក្រុមកម្មវិធី កិច្ចប្រជុំក្រុមការងារកម្មវិធីព្រៃឈើជាតិ កិច្ចប្រជុំរដ្ឋបាលព្រៃឈើ ការពិនិត្យនិងផ្តល់អនុសាសន៍របស់ភ្នាក់ងារទេសភាពព្រៃឈើដាណឺម៉ាក (Forest Landscape Denmark-FLD) និងធ្វើការកែសំរួលជាច្រើនលើក ។

# I- ប្រវត្តិនៃដំណើរការរៀបចំកម្មវិធី (ត)

**កម្មវិធីពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ច**

- អនុកម្មវិធីកំណែទំរង់ច្បាប់ និងរដ្ឋបាល
- អនុកម្មវិធីការពង្រឹងការអនុវត្តច្បាប់ និងការតាមដាននិងរាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើ (រួមបញ្ចូលបទល្មើសកាប់រានដីព្រៃ)
- អនុកម្មវិធីការឆ្លើយតបរហ័សចំពោះពតិមានបទល្មើសព្រៃឈើ

# II- បញ្ហាប្រឈមនៃការថយចុះធនធានព្រៃឈើ

ធនធានព្រៃឈើថយចុះ

↑

សកម្មភាពបទល្មើសព្រៃឈើ សត្វព្រៃ និងការកាប់រានដីព្រៃ

↑

អភិបាលកិច្ចព្រៃឈើ និងការពង្រឹងការអនុវត្តច្បាប់នៅមានកំរិត

↑

- ការតាមដាន និងធ្វើសេចក្ដីរាយការណ៍ មិនដិតដល់
- ការបង្ក្រាបបទល្មើសព្រៃឈើនៅមានកំរិត
- មធ្យោបាយសំភារៈមិនគ្រប់គ្រាន់
- មន្ត្រីមានសមត្ថភាពមានមិនគ្រប់គ្រាន់
- សហប្រតិបត្តិការជាមួយប្រទេសជិតខាង និងអន្តរជាតិនៅមានកំរិត
- នីតិវិធីតុលាការមិនទាន់មានប្រសិទ្ធភាព
- ការចូលរួមជាសាធារណៈនៅមានក្រិត

# III- គោលបំណងនៃកម្មវិធី

- គោលបំណងទូទៅនៃកម្មវិធី: អភិបាលកិច្ចព្រៃឈើ និងការពង្រឹងការអនុវត្តច្បាប់ត្រូវមានតម្លាភាព ត្រឹមត្រូវ និងអនុវត្តមានប្រសិទ្ធភាព
- គោលបំណងជាក់លាក់នៃកម្មវិធី:
  - ធ្វើឱ្យមានការអភិវឌ្ឍន៍ និងការអនុវត្តច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋាននានា
  - អនុវត្តអភិបាលកិច្ចព្រៃឈើល្អ និងដោះស្រាយទំនាស់
  - ធ្វើឱ្យប្រសើរការប្រើប្រាស់ឈើប្រកបដោយនិរន្តរភាព គោរពសិទ្ធិ និងកម្មសិទ្ធិសាធារណៈ
  - ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ច
  - រៀបចំវិធានការឱ្យមានប្រសិទ្ធភាពដើម្បីតាមដាន ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ
  - លុបបំបាត់បទល្មើសព្រៃឈើគ្រប់ប្រភេទ
  - បង្កើនចំណេះដឹងសាធារណៈអំពីច្បាប់ និងលិខិតបទដ្ឋាននានាដើម្បីឱ្យមានការគោរពច្បាប់

# IV-យុទ្ធសាស្ត្រអនុវត្តកម្មវិធី

- បង្កើនកិច្ចសហការរវាងអង្គភាពពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាល
- បង្កើនការដោះស្រាយទំនាស់ បង្កើនតម្លាភាព និងភាពទទួលខុសត្រូវក្នុងវិស័យព្រៃឈើ
- ធ្វើការសំរបសំរួលអនុវត្តការងាររួមគ្នាក្នុងក្របខ័ណ្ឌអន្តរអង្គភាព
- បង្កើនអភិបាលកិច្ចការនាំចេញផល អនុផលព្រៃឈើទៅកាន់ទីផ្សារអន្តរជាតិ
- បង្កើតលិខិតបញ្ជាក់សំរាប់អ្នកផលិតផល អនុផលព្រៃឈើ
- បង្កើនកិច្ចសហប្រតិបត្តិការជាមួយអន្តរជាតិ និងប្រទេសជិតខាងក្នុងការទប់ស្កាត់ និងបង្ក្រាបពាណិជ្ជកម្មឈើ និងសត្វព្រៃខុសច្បាប់

# V-អនុកម្មវិធីកំណែទម្រង់ច្បាប់ និងរដ្ឋបាល

- បង្កើតក្រុមការងាររៀបចំ និងពិនិត្យលិខិតបទដ្ឋាន
- បង្កើតក្រុមការងារស៊ើបអង្កេត និងអធិការកិច្ចបទល្មើសព្រៃឈើ
- បង្កើតគណៈកម្មការវាយតំលៃការងារ និងដាក់វិន័យមន្ត្រីរដ្ឋបាលព្រៃឈើ
- ធ្វើឱ្យប្រសើរនូវរចនាសម្ព័ន្ធអង្គភាពរដ្ឋបាលព្រៃឈើ
- ធ្វើឱ្យប្រសើរនូវសមត្ថភាពគ្រប់គ្រង និងការដោះស្រាយទំនាស់ធនធានព្រៃឈើ
- ធ្វើឱ្យប្រសើរនូវការងារទំនាក់ទំនងរបស់រដ្ឋបាលព្រៃឈើ ។

# V-អនុកម្មវិធីកំណែទម្រង់ច្បាប់ និងរដ្ឋបាល (ត)

- ធ្វើឱ្យប្រសើរនូវអភិបាលកិច្ចព្រៃឈើល្អ ៖
  - លើកទឹកចិត្តឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធដូចជាក្រសួងផ្សេងៗ ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិលក្នុងដំណើរការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព
  - អភិវឌ្ឍន៍វិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើឱ្យមានប្រសិទ្ធភាព ៖
    - ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរក្រសួងតាមរយៈក្រុមការងារបច្ចេកទេសស្តីពីព្រៃឈើ និង បរិស្ថាន (TWG-F&E) ដែលមានការចូលរួមពីក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល
    - សហប្រតិបត្តិការជាមួយគណៈកម្មាធិការជាតិ និងអនុគណៈកម្មាធិការខេត្តដើម្បីទប់ស្កាត់ និងបង្ក្រាបការកាប់រាន និងហ៊ុមព័ទ្ធយកដីព្រៃឈើ
    - សហប្រតិបត្តិការជាមួយអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
    - លើកទឹកចិត្តឱ្យមានវិមជ្ឈការព្រៃឈើដើម្បីឱ្យមានការចូលរួមពីប្រជាពលរដ្ឋ រដ្ឋបាលព្រៃឈើ និងអ្នកអភិរក្សនៅមូលដ្ឋាន។

# V-អនុកម្មវិធីកំណែទម្រង់ច្បាប់ និងរដ្ឋបាល (ត)

- ធ្វើឱ្យប្រសើរនូវការអនុវត្តច្បាប់ ៖
  - មនុស្សគ្រប់ស្រទាប់វណ្ណៈក្នុងសង្គមត្រូវគោរពច្បាប់
  - ធ្វើឱ្យកាន់តែល្អនូវប្រព័ន្ធតុលាការដើម្បីប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់
  - រៀបចំឱ្យមានកិច្ចប្រជុំប្រចាំឆ្នាំជាមួយព្រះរាជអាជ្ញារាជធានី ខេត្ត ដើម្បីដោះស្រាយករណីបទល្មើសព្រៃឈើដែលបានបញ្ជូនទៅសាលាដំបូង
- ធ្វើឱ្យប្រសើរនូវតម្លាភាព ៖
  - បន្តផ្សព្វផ្សាយជាសាធារណៈនូវទិន្នន័យ ស្ថិតិ និងពត៌មានបទល្មើសព្រៃឈើ តាមរយៈទស្សនាវដ្ដីព្រៃឈើ ស្ថិតិវិស័យព្រៃឈើ និងគេហទំព័ររដ្ឋបាលព្រៃឈើ
  - បង្កើតផ្នែកទំនាក់ទំនងសាធារណៈដើម្បីផ្ដល់ពត៌មាន ឯកសារ និងលិខិតបទដ្ឋានច្បាប់ក្នុងវិស័យព្រៃឈើ
  - បន្តចូលរួម និងចែករំលែកពត៌មាន និងបទពិសោធន៍នៅវេទិកាជាតិ តំបន់ និងអន្តរជាតិដូចជា EA FLEG, EU FLEGT, ASEAN FLEG, ASEAN-WEN
- ធ្វើឱ្យប្រសើរនូវភាពទទួលខុសត្រូវ ។


DENR
SECOND WORKING MEETING
OF THE ASIA FLEG TASK FORCE
AND ADVISORY GROUP
WORLD BANK
March 7-9, 2006
HYATT HOTEL and CASINO MANILA
Manila, Philippines
CHAIR
EU


BRUNEI
DARUSSALAM


Inaugural Meeting
ASEAN Regional Knowledge Network on
Forest Law Enforcement and Governance (FLEG)
gtz


The 3rd Meeting of The ASEAN
Wildlife Enforcement Network
USAID

# VI-អនុកម្មវិធីពង្រឹងការអនុវត្តច្បាប់ និង ការតាមដាន និងរាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើ

- ផ្តល់មធ្យោបាយ និងសំភារៈបរិក្ខារឱ្យបានគ្រប់គ្រាន់ដល់មន្ត្រីពង្រឹងការអនុវត្តច្បាប់នៃរដ្ឋបាលព្រៃឈើ
- បង្កើនប្រសិទ្ធភាពនៃយន្តការតាមដាន និងធ្វើសេចក្តីរាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើ
- បង្កើនប្រសិទ្ធភាពប្រព័ន្ធតុលាការពាក់ព័ន្ធនឹងរឿងក្តីបទល្មើសព្រៃឈើ
- ធ្វើឱ្យប្រសើរនូវកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាងក្នុងការប្រយុទ្ធប្រឆាំងពាណិជ្ជកម្មឈើ និងសត្វព្រៃខុសច្បាប់
- ធ្វើកិច្ចសហការឱ្យមានប្រសិទ្ធភាពជាមួយអង្គភាពពង្រឹងការអនុវត្តច្បាប់ផ្សេងៗ ដូចជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស នាយកដ្ឋានប្រឆាំងបទល្មើសសេដ្ឋកិច្ច និងកងយោធពលខេមរភូមិន្ទ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ ។














# VI-អនុកម្មវិធីពង្រឹងការអនុវត្តច្បាប់ និង ការតាមដាន និងរាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើ (ត)

- អនុវត្តវិធានការឱ្យមានប្រសិទ្ធភាពដើម្បីប្រយុទ្ធប្រឆាំងនឹងការកាប់រាន និងហ៊ុមព័ទ្ធដីព្រៃ ៖
  - ពង្រឹងយន្តការ និងបង្កើនសមត្ថភាពអនុគណៈកម្មាធិការខេត្ត ដើម្បីដកហូតដីព្រៃដែលបានកាប់រាន និងហ៊ុមព័ទ្ធដោយខុសច្បាប់
  - បង្កើតវេទិកាដោះស្រាយទំនាស់ដីធ្លីនៅមូលដ្ឋានតាមរយៈការចរចារ
  - ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានទាក់ទងនឹងការកាប់រាន និងហ៊ុមព័ទ្ធដីព្រៃឈើខុសច្បាប់ ដល់អ្នកពាក់ព័ន្ធ
  - ស្វែងរក និងផ្តល់ថវិកាដល់អនុគណៈកម្មាធិការខេត្តដើម្បីត្រួតពិនិត្យ ស្រាវជ្រាវផ្ទៀងផ្ទាត់ ស្រង់ស្ថិតិ ចេញដីកាដកហូតដីព្រៃ ការផ្សព្វផ្សាយ ការរៀបចំផែនទី ។ល ។

# VII-អនុកម្មវិធីការឆ្លើយតបចំពោះពត៌មានបទល្មើសព្រៃឈើ

- បង្កើតក្រុមការងារឆ្លើយតបពតិមានបទល្មើសព្រៃឈើនៅថ្នាក់កណ្តាល ៖
  - ពិនិត្យគ្រប់របាយការណ៍ពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងរៀបចំរបាយការណ៍ឆ្លើយតបជូនរដ្ឋបាលព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធករណីចាំបាច់
  - ទំនាក់ទំនងជាមួយគ្រប់ក្រសួង និងអង្គភាពពាក់ព័ន្ធទាក់ទងនឹងពតិមានបទល្មើសចុះផ្សាយក្នុងសារពតិមាន
  - ចុះពិនិត្យផ្ទៀងផ្ទាត់ជាក់ស្តែងដើម្បីប្រាកដថារបាយការណ៍បំភ្លឺពិត និងមានតម្លាភាពក្នុងករណីចាំបាច់
  - បញ្ចូលពតិមានបទល្មើសព្រៃឈើ និងការឆ្លើយតបក្នុងប្រព័ន្ធកុំព្យូទ័រ
  - បញ្ចូលពតិមានបទល្មើសព្រៃឈើ និងការឆ្លើយតប តាមគេហទំព័ររដ្ឋបាលព្រៃឈើក្នុងករណីចាំបាច់ ។

## VII- អនុកម្មវិធីការឆ្លើយតបរហ័សចំពោះពត៌មានបទល្មើសព្រៃឈើ (ត)

- បង្កើតក្រុមការងារឆ្លើយតបពតិមានបទល្មើសព្រៃឈើនៅថ្នាក់មូលដ្ឋាន :
    - ពិនិត្យពតិមានបទល្មើសព្រៃឈើផ្សាយតាមសារពតិមាន
    - ចុះពិនិត្យ ផ្ទៀងផ្ទាត់ជាក់ស្តែង និងចាត់វិធានការដោយសហការជាមួយអ្នកពាក់ព័ន្ធ
    - រៀបចំរបាយការណ៍បំភ្លឺសារពតិមានជូនរដ្ឋបាលព្រៃឈើ
    - បញ្ចូលពតិមានបទល្មើសព្រៃឈើ និងការឆ្លើយតបក្នុងប្រព័ន្ធកុំព្យូទ័រ ។

# VII- អនុកម្មវិធីការឆ្លើយតបចំពោះពត៌មានបទល្មើសព្រៃឈើ (ត)

- បង្កើនកិច្ចសហការល្អជាមួយអ្នកសារពត៌មាន និងអ្នកផ្តល់ពត៌មាន :
  - រៀបចំកិច្ចប្រជុំរវាងរដ្ឋបាលព្រៃឈើ និងអ្នកសារពត៌មានដើម្បីរកវិធីសហការឱ្យបានល្អ
  - ធ្វើការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានដល់អ្នកសារពត៌មាន
  - រៀបចំការបណ្តុះបណ្តាលអំពីប្រភេទបទល្មើសព្រៃឈើ និងការស៊ើបអង្កេត
  - រៀបចំទស្សនកិច្ចសិក្សាសំរាប់អ្នកសារពត៌មាននៅទីតាំងកើតមានបទល្មើសព្រៃឈើ
  - ប្រតិបត្តិការរួមគ្នាក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ
  - បង្កើតបណ្តាញផ្តល់ពត៌មានបទល្មើសព្រៃឈើរវាងរដ្ឋបាលព្រៃឈើ និងអ្នកសារពត៌មាន
  - រកថវិកាសំរាប់អ្នកសារពត៌មាន អ្នកផ្តល់ពត៌មាន ការចុះផ្សាយការយល់ដឹងជាសាធារណៈអំពីបទល្មើសព្រៃឈើ និងការចាត់វិធានការរបស់រាជរដ្ឋាភិបាល
  - បង្កើតប្រព័ន្ធផ្ញើសារ (SMS) ដែលអាចឱ្យសាធារណៈជនផ្តល់ពត៌មានបទល្មើសព្រៃឈើ ។

# VIII - សន្និដ្ឋាន

- សេចក្តីព្រាងកម្មវិធីនេះបានរៀបចំ ពិនិត្យ និងផ្តល់មតិយោបល់នៅថ្នាក់កណ្តាល ដោយមានការចូលរួមពីរដ្ឋបាលព្រៃឈើ អង្គការដានីដា ធនាគារពិភពលោក និងភ្នាក់ងារទេសភាពព្រៃឈើប្រទេសដាណឺម៉ាក និងបានធ្វើការកែសំរួលជាច្រើនលើកច្រើនសារ

- សេចក្តីព្រាងនេះត្រូវការអនុសាសន៍ និងការកែលំអពីថ្នាក់មូលដ្ឋានពិសេសអង្គសិក្ខាសាលានេះ
- អនុក្រុមការងារកម្មវិធីនឹងបញ្ចូលអនុសាសន៍ និងមតិយោបល់ពីអង្គសិក្ខាសាលាដែលមានលក្ខណៈសមស្រប ដើម្បីឱ្យកម្មវិធីនេះមានតម្លាភាព ត្រឹមត្រូវ និងអនុវត្តមានប្រសិទ្ធភាពខ្ពស់ ។


សូមអរគុណ!

# កម្មវិធីសហគមន៍ព្រៃឈើ

## កិច្ចប្រជុំពិគ្រោះយោបល់កម្មវិធីព្រៃឈើជាតិ

## ថ្ងៃទី ២៥-២៦ ខែមិនា ឆ្នាំ២០០៩

## ខេត្តក្រចេះ

ដោយ ឡាវ សេដ្ឋាផល

# មាតិកា

- ប្រវត្តិនៃការរៀបចំកម្មវិធីសហគមន៍ព្រៃឈើ
- ប្រវត្តិនៃការកកើតសហគមន៍ព្រៃឈើ
- ការចូលរួមគ្រប់គ្រងព្រៃឈើ
- គោលបំណងកម្មវិធី
- អនុកម្មវិធីទាំង ៣ (សកម្មភាព និងលទ្ធផលរំពឹងទុក)

# ប្រវត្តិនៃការរៀបចំកម្មវិធីសហគមន៍ព្រៃឈើ

- ប្រមូលឯកសារពាក់ព័ន្ធ និងរៀបចំឯកសារបឋម
- ពិភាក្សាក្នុងគណៈកម្មការសំរបសំរួលកម្មវិធីស/ពជាតិ ដើម្បីពិនិត្យ និងកែសំរួល
- ប្រជុំរួមក្រុមរៀបចំកម្មវិធីព្រៃឈើជាតិ
- សិក្ខាសាលាលើកទី១ នៅខេត្តព្រះសីហនុ
- ផ្ញើជូនក្រុម Forest & Landscape, Denmark ពិនិត្យ និងផ្តល់យោបល់
- ពិនិត្យកែសំរួលដោយក្រុមការងារ
- ដាក់ជូនពិនិត្យ ពិភាក្សាក្នុងសិក្ខាសាលានាពេលនេះ។

# ប្រវត្តិនៃការកកើតសហគមន៍ព្រៃឈើ

- ស/ពបានបង្កើតឡើងក្នុងអំឡុងពាក់កណ្តាលទសវត្សឆ្នាំ៩០ តាមរយៈគំរោងសាកល្បង ដែលគាំទ្រដោយរាជរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ បានបង្ហាញអោយឃើញថា ស/ពមានសក្តានុពលក្នុងការការពារព្រៃឈើ ការការពារទីជំរាល ជីវចំរុះ និងការបង្កើនជីវភាព។
- ក្រុមវាយតំលៃវិស័យព្រៃឈើឯករាជ្យ បានផ្តល់អនុសាសន៍ គឺត្រូវ**បន្តគាំទ្រ**ដល់ការអនុវត្តន៍ស/ព ជាពិសេសធ្វើយ៉ាងណាអោយស/ពអាចដំណើរការបានដោយខ្លួនឯង ហើយក៏បានសំណូមពរអោយធ្វើការ**សាកល្បង**អនុវត្តព្រៃឈើដៃគូ។

# ការចូលរួមគ្រប់គ្រងព្រៃឈើ

## ១. សហគមន៍ព្រៃឈើ

- **អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ** (២០០៣) បានផ្តល់នូវភាពស្របច្បាប់ដល់**ការអនុវត្តន៍សហគមន៍ព្រៃឈើ** នៅក្នុងព្រៃផ្តល់ផល និងស្ថិតនៅក្រោមយុត្តាធិការរបស់ រ.ព។
- **ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ** (២០០៦) បានពន្យល់ណែនាំអំពីនីតិវិធីនៃការ**រៀបចំ** និង**បង្កើត**សហគមន៍ព្រៃឈើ។

# ការចូលរួមគ្រប់គ្រងព្រៃឈើ

## ២. ព្រៃឈើដៃគូ

- **ព្រៃឈើដៃគូ** គឺបានផ្តល់ការទទួលខុសត្រូវក្នុងការចូលរួមគ្រប់គ្រងព្រៃឈើទៅអោយ**ក្រុមប្រឹក្សាឃុំ**។ ផលប្រយោជន៍ដែលទទួលបានពីការចូលរួមនេះ ក្រុមប្រឹក្សាឃុំនឹងយកទៅប្រើប្រាស់សំរាប់ការអភិវឌ្ឍន៍ឃុំរបស់ខ្លួនអោយមានភាពរីកចំរើន។

# ការចូលរួមគ្រប់គ្រងព្រៃឈើ (ត)

## ៣. សហគមន៍ព្រៃផ្តល់ផល

- **សហគមន៍ព្រៃផ្តល់ផល**គឺផ្តោតសំខាន់ដល់ការប្រមូលផលឈើប្រកបដោយនិរន្តរភាពដោយសហគមន៍មូលដ្ឋាន។ ការរៀបចំសហគមន៍នេះ គឺត្រូវពិនិត្យមើល**ធនធានព្រៃឈើ ទំហំព្រៃ លទ្ធភាពនៃការប្រមូលផលឈើ ទីផ្សារផលិតផលឈើ** និងការ**វិនិយោគបច្ចេកវិទ្យា** ។ល។

# ការចូលរួមគ្រប់គ្រងព្រៃឈើ (ត)

## ៤. សហគមន៍ព្រៃការពារ

- **សហគមន៍ព្រៃការពារ** ត្រូវបានបង្កើតឡើងក្នុង**តំបន់ព្រៃការពារ**។ ការរៀបចំគឺផ្អែកទៅលើលិខិតបទដ្ឋានដែលមានស្រាប់ក្នុងការបង្កើតសហគមន៍ព្រៃឈើ។ ការបង្កើតសហគមន៍ព្រៃការពារ **ក្នុងគោលបំណងធ្វើការការពារ** និង**អភិរក្សជាសំខាន់**។ ហេតុនេះសមាជិកសហគមន៍នឹងទទួលបាននូវការ**កសាងសមត្ថភាព**ជាចាំបាច់ ដើម្បី**ទប់ស្កាត់** និង**បង្ក្រាបបទ**ល្មើសព្រៃឈើ និងសត្វព្រៃក្នុងតំបន់ព្រៃសហគមន៍។

# គោលបំណងនៃកម្មវិធី

- ដើម្បីធានាដល់**ការប្រើប្រាស់**ធនធានព្រៃឈើប្រកបដោយ**សមធម៌** ។
- **ផ្តល់ឱកាស**ដល់សហគមន៍មូលដ្ឋាន បាន**ចូលរួមរៀបចំបង្កើត** និង**គ្រប់គ្រង**ព្រៃសហគមន៍ ព្រមទាំងចូលរួម**ធ្វើសេចក្តីសំរេចចិត្ត**។
- ផ្តល់ការ**កសាងសមត្ថភាព** និង**គាំទ្រ**ដល់មន្ត្រីរដ្ឋបាលព្រៃឈើ ដើម្បីអោយ**មានសមត្ថភាព**គ្រប់គ្រាន់ក្នុងការ**ជួយគាំទ្រ** និង**ផ្តល់សេវាកម្ម**ដល់ស/ព។
- **បង្កើនការចូលរួម**របស់សមាជិកសហគមន៍ព្រៃឈើ ជាពិសេស**ស្ត្រី** ដើម្បីអោយមាន**តម្លាភាព អភិបាលកិច្ចល្អ** និងការបែងចែក**ផលប្រយោជន៍**ប្រកបដោយសមធម៌។

# គោលបំណងនៃកម្មវិធី (ត)

- **ពង្រឹង** និង**ជំរុញ**ការគ្រប់គ្រងព្រៃសហគមន៍ប្រកបដោយនិរន្តរភាព ក្នុងគោលបំណង**ពាណិជ្ជកម្ម** និងការ**បង្កើនជីវភាព** តាមរយៈការ**បង្កើនផលិតផលឈើ អនុផលព្រៃឈើ ការអភិរក្សជីវចំរុះ** និង**ការលក់ឥណទានកាបូនព្រៃឈើ** ទៅទីផ្សារអន្តរជាតិ ដែលធ្វើអោយសហគមន៍ព្រៃឈើ**មានលទ្ធភាព** និង**សមត្ថភាព**គ្រប់គ្រងព្រៃសហគមន៍បានដោយ**ខ្លួនឯង**
- **ធ្វើការពិនិត្យ** និង**កែសំរួលឡើងវិញ**ក្នុងករណីចាំបាច់នូវលិខិតបទដ្ឋាននានា ដែលគាំទ្រដល់ការអនុវត្តសហគមន៍ព្រៃឈើ ដើម្បីឆ្លើយតបទៅនឹង**តំរូវការ** និង**ដោះស្រាយបញ្ហា**នានា។

# អនុកម្មវិធីចំនួន ៣ រួមមានៈ



# អនុកម្មវិធី១~

## ការកំណត់តំបន់ និង ការបង្កើតសហគមន៍ព្រៃឈើ













# អនុកម្មវិធី១_ ការកំណត់តំបន់ និង ការបង្កើតសហគមន៍ព្រៃឈើ

## វិធីសាស្ត្រអនុវត្ត :

**ជំហាន ០** _ ការកំណត់តំបន់សក្តានុពលសំរាប់បង្កើតសហគមន៍ព្រៃឈើ

**ជំហាន ១** _ ការសុំបង្កើតសហគមន៍ព្រៃឈើ ទៅឯកឧត្តមអភិបាលខេត្ត

**ជំហាន ២** _ ការប្រមូលពត៌មាន

**ជំហាន ៣** _ ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍ព្រៃឈើ

**ជំហាន ៤** _ ការរៀបចំបទបញ្ញត្តិផ្ទៃក្នុងរបស់គណៈកម្មការគ្រប់គ្រងស/ព

**ជំហាន ៥** _ ការកំណត់ព្រំប្រទល់ព្រៃសហគមន៍ និងធ្វើផែនទីព្រៃសហគមន៍។

# អនុកម្មវិធី១៖ ការកំណត់តំបន់ និងការបង្កើតសហគមន៍ព្រៃឈើ

## វិធីសាស្ត្រអនុវត្ត (ត) ៖

**ជំហាន ៦** ៖ ការរៀបចំលក្ខន្តិកៈសហគមន៍ព្រៃឈើ

**ជំហាន ៧** ៖ ការរៀបចំកិច្ចព្រមព្រៀងព្រៃសហគមន៍

**ជំហាន ៨** ៖ ការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍

**ជំហាន ៩** ៖ ការអភិវឌ្ឍន៍សហគ្រាសសហគមន៍ព្រៃឈើ

**ជំហាន ១០** ៖ ការអនុវត្តន៍

**ជំហាន ១១** ៖ ការត្រួតពិនិត្យ និងវាយតំលៃ

## អនុកម្មវិធី១៖ ការកំណត់តំបន់ និងការបង្កើតសហគមន៍ព្រៃឈើ

**លទ្ធផលរំពឹងទុក** :

- **សហគមន៍មូលដ្ឋាន**ដែលរស់នៅក្នុង និងក្បែរតំបន់ព្រៃ **មានឱកាសក្នុងការចូលរួម**កំណត់តំបន់សក្តានុពល និងការរៀបចំបង្កើតសហគមន៍ព្រៃឈើ។
- **កិច្ចសហការ**រវាងរដ្ឋបាលព្រៃឈើ សហគមន៍មូលដ្ឋាន និងក្រុមប្រឹក្សាឃុំ **ត្រូវបានពង្រឹង** និង **ពង្រីក**។
- **កាត់បន្ថយទំនាស់**ក្នុងការប្រើប្រាស់ធនធានព្រៃឈើ។
- **បទពិសោធន៍** និង**មេរៀនដែលទទួលបានពីការអនុវត្តន៍** ត្រូវបានចងក្រងជាឯកសារសំរាប់ការរៀបចំ និងកែលំអគោលនយោបាយគាំទ្រដល់ការអនុវត្តន៍សហគមន៍។

# អនុកម្មវិធី២៖

## ការពង្រឹងសហគមន៍ និងការបង្កើនជីវភាព













# អនុកម្មវិធី២៖ ការពង្រឹងសហគមន៍ និងការបង្កើនជីវភាព

## វិធីសាស្ត្រអនុវត្ត :

- **ធ្វើការសិក្សា**ទៅលើសហគមន៍ព្រៃឈើ សំរាប់ការ**បង្កើនជីវភាព**
- **ធ្វើការកសាងសមត្ថភាព**ដល់សមាជិកសហគមន៍ និងគណៈកម្មការ ដើម្បីអោយ**មានសមត្ថភាព**ក្នុងការ**គ្រប់គ្រង**ព្រៃសហគមន៍ និង**អនុវត្ត**កម្មវិធីបង្កើនជីវភាព
- **ធ្វើការកសាងសមត្ថភាព**ដល់មន្ត្រីរ/ព និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអោយ**មានសមត្ថភាព**ក្នុងការ**ផ្តល់សេវាកម្ម** ប្រកបដោយ**គុណភាព** និង**ប្រសិទ្ធភាព**
- **ធ្វើការគាំទ្រ ណែនាំ** និង**បង្ហាត់បង្ហាញ** ដើម្បី**បង្កើន**សមត្ថភាព និងការ**យល់ដឹង**ដល់សមាជិកសហគមន៍ព្រៃឈើ **ស្តីពីការបង្កើនជីវភាព**។

# អនុកម្មវិធី២ ការពង្រឹងសហគមន៍ និងការបង្កើនជីវភាព

## វិធីសាស្ត្រអនុវត្ត (ត) ៖

- រៀបចំអោយមាន**ទស្សនកិច្ចសិក្សា** **បណ្តាញការងារ**សហគមន៍ព្រៃឈើ ដើម្បីផ្តល់ឱកាសដល់សមាជិកសហគមន៍ព្រៃឈើ បានធ្វើការ**ចែករំលែក**បទពិសោធន៍ និង**រៀនសូត្រ**ពីគ្នាទៅវិញទៅមក
- ធ្វើការ**លើកទឹកចិត្ត**ដល់សហគមន៍ក្នុងការរៀបចំអោយមានវិធីសាស្ត្រផ្សេងៗក្នុងការបង្កើនជីវភាព និងការ**ស្វែងរកថវិកា**សំរាប់ដំណើរការមុខរបរទាំងនោះ
- រៀបចំសកម្មភាព បច្ចេកទេស វិធីសាស្ត្រ និងឧបករណ៍សមស្រប សំរាប់អនុវត្តកម្មវិធីបង្កើនជីវភាព ។

## អនុកម្មវិធី២៖ ការពង្រឹងសហគមន៍ និងការបង្កើនជីវភាព

### លទ្ធផលរំពឹងទុក ៖

- **និរន្តរភាព** និង**ភាពរឹងមាំ**នៃការគ្រប់គ្រងប្រកបដោយសមត្ថភាព និងប្រសិទ្ធិភាព របស់សហគមន៍នីមួយៗ
- **វិធីសាស្រ្ត** និង**បច្ចេកទេស**សមស្របដែលបានអនុវត្ត ត្រូវបានប្រើប្រាស់ដោយ អ្នកពាក់ព័ន្ធ
- សហគមន៍ព្រៃឈើនឹងបង្កើនការ**ផ្គត់ផ្គង់ផលិតផលឈើស្របច្បាប់** សំរាប់ការប្រើប្រាស់ក្នុងស្រុក និងនាំចេញ
- ការគ្រប់គ្រងសហគមន៍**ត្រូវបានពង្រឹង** ដើម្បីបង្កើនគុណភាពផលិតផលឈើ-អនុផលព្រៃឈើ និងទីផ្សារ សំដៅបង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍។

# អនុកម្មវិធី៣-

## ការគាំទ្រដល់ការអភិវឌ្ឍន៍សហគមន៍ព្រៃឈើ













# អនុកម្មវិធី៣៖ ការគាំទ្រដល់ការអភិវឌ្ឍន៍សហគមន៍ព្រៃឈើ

## វិធីសាស្ត្រអនុវត្ត ៖

- **ការផ្តល់ចំណេះដឹង/ការផ្សព្វផ្សាយ:** លិខិតបទដ្ឋានច្បាប់ បច្ចេកទេស ដំណើរការបង្កើត និងការគ្រប់គ្រងសហគមន៍ព្រៃឈើ អភិបាលកិច្ច ...
- **ការបង្កើនសមត្ថភាព:** រៀបចំកម្មវិធីបណ្តុះបណ្តាល ទស្សនកិច្ចសិក្សា ...
- **ការគ្រប់គ្រងព័ត៌មាន:** ប្រមូល វិភាគ គ្រប់គ្រង និងចែកចាយព័ត៌មានអំពីស/ព ទៅឱ្យអ្នកពាក់ព័ន្ធ
- **ការដោះស្រាយទំនាស់:** មន្ត្រីរដ្ឋបាលព្រៃឈើធ្វើការសម្រុះសម្រួលដោះស្រាយទំនាស់ ដើម្បីកាត់បន្ថយផលប៉ះពាល់ក្នុងការអនុវត្តស/ព។

# អនុកម្មវិធី៣៖ ការគាំទ្រដល់ការអភិវឌ្ឍន៍សហគមន៍ព្រៃឈើ

## វិធីសាស្ត្រអនុវត្ត (ត) ៖

- **ការរៀបចំបណ្តាញសហគមន៍ព្រៃឈើ** ៖ រៀបចំបណ្តាញស/ពថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ព្រមទាំងមានការទទួលស្គាល់ដោយស្របច្បាប់
- **ការសិក្សាស្រាវជ្រាវ** ៖ រៀបចំកម្មវិធីសិក្សាស្រាវជ្រាវពីការគ្រប់គ្រងស/ព ប្រកបដោយនិរន្តរភាព ទីផ្សារ និងការប្រកបរបរចិញ្ចឹមជីវិត ...
- **សម្របសម្រួល និងកិច្ចសហការ** ៖ បង្កើនការទំនាក់ទំនងរវាងស្ថាប័នពាក់ព័ន្ធ
- **កែសម្រួលគោលនយោបាយ និងលិខិតបទដ្ឋាននានា** ៖ ធ្វើការពិនិត្យឡើងវិញពីប្រសិទ្ធិភាពនៃការអនុវត្តលិខិតបទដ្ឋាននានាពាក់ព័ន្ធសហគមន៍ព្រៃឈើ ដើម្បីឆ្លើយតបទៅនឹងការអនុវត្តជាក់ស្តែង។

# អនុកម្មវិធី៣៖ ការគាំទ្រដល់ការអភិវឌ្ឍន៍សហគមន៍ព្រៃឈើ

## វិធីសាស្ត្រអនុវត្ត (ត) ៖

- **ថ្លៃសួយសារ និងបុព្វលាភ ៖** រៀបចំប្រព័ន្ធឱ្យមានតម្លាភាពក្នុងការកំណត់ថ្លៃសួយសារ និងបុព្វលាភ សំរាប់សហគមន៍ព្រៃឈើ
- **ការត្រួតពិនិត្យ និងវាយតម្លៃ ៖** ត្រួតពិនិត្យការអនុវត្តន៍គោលនយោបាយលិខិតបទដ្ឋានច្បាប់ និងកម្មវិធីសហគមន៍ព្រៃឈើជាតិ ។

# អនុកម្មវិធី៣៖ ការគាំទ្រដល់ការអភិវឌ្ឍន៍សហគមន៍ព្រៃឈើ

## លទ្ធផលរំពឹងទុក ៖

- **ចំណេះដឹង**ផ្នែកសហគមន៍ព្រៃឈើ **ត្រូវបានបង្កើន**
- **សមត្ថភាព**របស់អ្នកពាក់ព័ន្ធនឹងការងារសហគមន៍ព្រៃឈើ **ត្រូវបានបង្កើន**
- **ព័ត៌មាន**ពាក់ព័ន្ធនឹងការអនុវត្តសហគមន៍ព្រៃឈើ **ត្រូវបានការប្រមូល** គ្រប់គ្រង និង**ធ្វើការចែកចាយ**ដល់អ្នកពាក់ព័ន្ធទាំងអស់តាមរយៈគេហទំព័រ
- **ទំនាស់**ក្នុងការគ្រប់គ្រងព្រៃសហគមន៍ **ត្រូវបានកាត់បន្ថយ**
- **បណ្តាញ**សហគមន៍ព្រៃឈើនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន **ត្រូវបានបង្កើតឡើង**។

## **អនុកម្មវិធី៣៖ ការគាំទ្រដល់ការអភិវឌ្ឍន៍សហគមន៍ព្រៃឈើ**

**លទ្ធផលរំពឹងទុក (ត) :**

- **គំរោងឥណទានការប្ញូន**សហគមន៍ព្រៃឈើ **ត្រូវបានរៀបចំ**
- **ការគ្រប់គ្រង**ព្រៃសហគមន៍ ការបែងចែកផលប្រយោជន៍ អភិបាលកិច្ច ទីផ្សារ និងការបង្កើនជីវភាព **ត្រូវបានធ្វើឱ្យប្រសើរឡើង**
- **កិច្ចសហការ**រវាងអ្នកពាក់ព័ន្ធ **ត្រូវបានធ្វើអោយប្រសើរឡើង**
- **លិខិតបទដ្ឋានច្បាប់**ពាក់ព័ន្ធសហគមន៍ព្រៃឈើ **ត្រូវបានកែសម្រួល** ដោយយោងទៅលើបទពិសោធន៍ដែលទទួលបានពីការអនុវត្ត និងយុទ្ធសាស្ត្រថ្មីៗ
- **ប្រកាសស្តីពីការកំណត់ថ្លៃសួយសារ** និង**បុព្វលាភ**សំរាប់សហគមន៍ព្រៃឈើ **ត្រូវបានអនុម័ត** និង**អនុវត្ត** ។


សូមអរគុណ
ចំពោះការយកចិត្តទុកដាក់ស្តាប់

# សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈ
# ស្តីពីកម្មវិធីព្រៃឈើជាតិ

## កម្មវិធីទី៥

## អភិវឌ្ឍសមត្ថភាព និង ការស្រាវជ្រាវ

# បញ្ហា និង គោលបំណងនៃកម្មវិធី

- **បញ្ហា**

  -ព្រៃឈើកម្ពុជាកំពុងរងគ្រោះដោយភាពរេចរិល និងកំពុងប្រែក្លាយជាដីមិនមែនព្រៃ ហើយរដ្ឋបាលព្រៃឈើ/វិទ្យាស្ថានស្រាវជ្រាវពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការស្រាវជ្រាវជាមូលដ្ឋាន ។ ដោយឡែកការស្រាវជ្រាវក្នុងវិស័យព្រៃឈើដែលបានធ្វើកន្លងមកនៅមានកំរិត និងមិនទាន់បានរួមចំណែកពេញលេញដល់ការអនុវត្តផែនការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពនៅឡើយ ។

- **គោលបំណង**

  -ដើម្បីឆ្លើយតបទៅនឹងកង្វះខាតធនធានមនុស្សក្នុងវិស័យព្រៃឈើ ទាំងផ្នែកទ្រឹស្តីនិងការអនុវត្តនាំឆ្ពោះទៅរកការអភិវឌ្ឍន៍សេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និងការអភិរក្សបរិស្ថាន ។

  -អភិវឌ្ឍសមត្ថភាពនៃអ្នកដែលពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃឈើ និងធ្វើអោយប្រសើរឡើងនូវសមត្ថភាពស្រាវជ្រាវព្រៃឈើ ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីព្រៃឈើជាតិ ។

# មាតិកាបទបង្ហាញ

- បញ្ហា និង គោលបំណងនៃកម្មវិធី
- អនុកម្មវិធីទី១: ការអភិវឌ្ឍស្ថាប័ន និង ធនធានមនុស្ស ( ប៊ុន វ៉ាថា)
- អនុកម្មវិធីទី២: ការផ្សព្វផ្សាយ និងការបង្កើនការយល់ដឹងជាសាធារណៈ ( នុព សុធា)
- អនុកម្មវិធីទី៣: ការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ ( ចាន់ សុផល)
- អនុកម្មវិធីទី៤: វិញ្ញាបនប័ត្រព្រៃឈើ ( សរិត វណ្ណា)

# អនុកម្មវិធីទី១

# ការអភិវឌ្ឍស្ថាប័ន និង ធនធានមនុស្ស

- ស្ថានភាពបច្ចុប្បន្ន
- មធ្យោបាយសំរាប់អនុវត្ត
- លទ្ធផលរំពឹងទុក

# ស្ថានភាពបច្ចុប្បន្ន

- មន្ត្រីរដ្ឋបាលព្រៃឈើសរុប ១.៦៦៧នាក់, (៦០០នាក់ មានជំនាញខាងវិស័យព្រៃឈើ)
- ត្រូវជ្រើសរើសមន្ត្រីបន្ថែម និងធ្វើការបង្វឹក ដើម្បីបំពេញការងារតាមតួនាទីដែលនឹងផ្តល់ជូន
- ផ្តល់ការបណ្តុះបណ្តាល និងលើកទឹកចិត្ត ដល់មន្ត្រីជ្រើសរើសថ្មី និង មន្ត្រីកំពុងបម្រើការងារ ដើម្បីអាចបំពេញការងារតាមតួនាទីថ្មី និងភាពទទួលខុសត្រូវរបស់ពួកគេ
- តម្រូវការសមត្ថភាពនៃអ្នកពាក់ព័ន្ធ ទាំងស្ថាប័នរដ្ឋ និងអង្គការក្រៅរដ្ឋាភិបាល ក៏នឹងត្រូវលើកយកមកបញ្ចូលមួយចំនួនផងដែរនៅក្នុងអនុកម្មវិធីនេះ ដើម្បីអនុវត្តកម្មវិធីព្រៃឈើជាតិប្រកបដោយជោគជ័យ ។

# មធ្យោបាយសំរាប់អនុវត្ត

- ធ្វើឱ្យប្រសើរឡើងនូវរចនាសម្ព័ន្ធរដ្ឋបាលព្រៃឈើ
- បង្កើតប្រព័ន្ធអប់រំមួយ ដើម្បីធានានូវគុណភាពមន្ត្រី (សមត្ថភាព)
- ជ្រើសរើសមន្ត្រីថ្មី និងអភិវឌ្ឍធនធានមនុស្ស នៅក្នុងរដ្ឋបាលព្រៃឈើ
- បង្កើតកម្មវិធីបណ្តុះបណ្តាល ដើម្បីបំពេញបន្ថែមតម្រូវការសមត្ថភាព :

- ការធ្វើព្រំប្រទល់ ធ្វើចំណាត់ថ្នាក់ និងចុះបញ្ជិកា សម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- ការអភិរក្សនិងគ្រប់គ្រងធនធានព្រៃឈើ
- ពង្រឹងការអនុវត្តន៍ច្បាប់ និងអភិបាលកិច្ច
- ការគ្រប់គ្រងព្រៃឈើជាតិដោយមានការចូលរួម
- យន្តការនិរន្តរភាពហិរញ្ញវត្ថុសំរាប់វិស័យព្រៃឈើ ។

# លទ្ធផលរំពឹងទុក

☞ **រចនាសម្ព័ន្ធរដ្ឋបាលព្រៃឈើ ត្រូវបានធ្វើឱ្យប្រសើរឡើង**

- តួនាទីនិងការទទួលខុសត្រូវ មានភាពច្បាស់លាស់សំរាប់មន្ត្រីរដ្ឋបាលព្រៃឈើ ត្រូវបានកំណត់ត្រឹមឆ្នាំ ២០១០
- ប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃ ត្រូវបានបង្កើតឡើងត្រឹមឆ្នាំ ២០១០
- កម្មវិធីប្រាក់ឧបត្ថម្ភលើកទឹកចិត្តនិងគ្រប់គ្រងការអនុវត្តការងារ ត្រូវបានអនុវត្តត្រឹមឆ្នាំ ២០១៥
- ប្រព័ន្ធទាក់ទង និងចែករំលែកពិត៌មាន មានប្រសិទ្ធភាព ត្រូវបានបង្កើតឡើងត្រឹមឆ្នាំ ២០១៣ ។

# លទ្ធផលរំពឹងទុក (ត)

☞ **សមត្ថភាពនៃរដ្ឋបាលព្រៃឈើ និង អ្នកពាក់ព័ន្ធវិស័យព្រៃឈើផ្សេងទៀត ត្រូវបានធ្វើឱ្យប្រសើរឡើង**

- ➢ មន្ត្រីមានសមត្ថភាពដែលសមស្របនឹងតម្រូវការថ្មីនៃរចនាសម្ព័ន្ធការងាររបស់រដ្ឋបាលព្រៃឈើ ត្រូវបានជ្រើសរើសនិងបណ្តុះបណ្តាល ត្រឹមឆ្នាំ ២០១៥
- ➢ ផែនការអភិវឌ្ឍន៍ធនធានមនុស្សនឹងត្រូវរួមបញ្ចូលគ្នាជាផែនការរួមមួយនៃការពង្រឹងសមត្ថភាពរបស់មន្ត្រីរដ្ឋបាលព្រៃឈើ
- ➢ សមត្ថភាពរបស់មន្ត្រីរដ្ឋបាលព្រៃឈើ នឹងបានធ្វើឱ្យប្រសើរឡើង ត្រឹមឆ្នាំ ២០១៥ ។

# លទ្ធផលរំពឹងទុក (ត)

- ក្នុងកិច្ចសហការជាមួយរដ្ឋបាលព្រៃឈើ អាជ្ញាធរមូលដ្ឋាន គណៈកម្មាធិការ និងសមាជិកគ្រប់គ្រងព្រៃឈើមូលដ្ឋាន ភាគីឯកជនទាំងអស់ និង ដៃគូអង្គការក្រៅរដ្ឋាភិបាល នឹងត្រូវបានបណ្តុះបណ្តាល
- ប្រព័ន្ធអប់រំនឹងត្រូវបានបង្កើតឡើង ដើម្បីធានាថាជំនាញគ្រប់គ្រងព្រៃឈើមានស្តង់ដារទាំងអស់ ដែលត្រូវការសំរាប់អនុវត្តកម្មវិធីព្រៃឈើជាតិ គឺត្រូវបានទទួលជោគជ័យក្នុងអំឡុងពេលធ្វើការបណ្តុះបណ្តាលមុខវិជ្ជាព្រៃឈើជាមូលដ្ឋាន ។

# អនុកម្មវិធីទី២

# ការផ្សព្វផ្សាយព្រៃឈើ និង ការបង្កើនការយល់ដឹងជាសាធារណៈ

- សេចក្តីផ្តើម
- ចម្លោះយសំរាប់អនុវត្ត
- លទ្ធផលរំពឹងទុក

## ១.សេចក្តីផ្តើម

-ព្រៃឈើមានសារសំខាន់ច្រើនយ៉ាងដូចជា : គ្រឿងសំណង់អុសសម្រាប់ដុត

ជាផលិតផលសម្រាប់ប្រើប្រាស់ច្រើនយ៉ាងក្នុងជីវភាពរស់នៅ ជាជម្រកសត្វព្រៃគ្រប់ប្រភេទ បង្កើនជីជាតិដល់ដី ទប់ទល់ការហូរច្រោះ និង កែសម្រួលធាតុអាកាស ។ល ។

-កម្មភាពផ្សព្វផ្សាយអាចជួយជួយដល់គំនិតផ្តួចផ្តើមក្នុងការសំរបសំរួលពិភាក្សាដើម្បីកំណត់បញ្ហា និង តម្រូវការផ្សេងៗនៅក្នុងស្ថានភាពជាក់ស្តែង ។

# សេចក្តីផ្តើម (ត)

-ជួយតម្រង់ទិសនៃការអភិវឌ្ឍដើម្បីជំរុញការចូលរួមគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។

-ជួយបង្ហាញនូវគំរូនៃការគ្រប់គ្រងព្រៃឈើបកបដោយនិរន្តរភាព និង ភាពជោគជ័យនៃការដាំឈើឡើងវិញ ។

-បញ្ច្រៀបចំណេះដឹងក្នុងវិស័យព្រៃឈើទៅក្នុងកម្មវិធីអប់រំតាមបណ្តាសាលារៀន មហាវិទ្យាល័យ និង វិទ្យាស្ថានបណ្តុះបណ្តាលផ្សេងៗ ។ល ។

## ២_មធ្យោបាយនៃការអនុវត្តសំខាន់ៗ

### ២.១.លើកកំពស់ការយល់ដឹងសម្រាប់ក្មេងជំនាន់ក្រោយ

-ធ្វើឱ្យប្រសើរឡើងនូវសកម្មភាពទំនាក់ទំនងចែករំលែក និង ផ្លាស់ប្តូរព័ត៌មានព្រៃឈើក្នុងកម្មវិធីអប់រំ ។

-រៀបចំកម្មវិធី និង បង្កើតសំភារៈផ្សព្វផ្សាយព្រៃឈើឱ្យបានសមស្របដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីអប់រំ ។

-បង្កើនសកម្មភាពផ្សព្វផ្សាយដល់ គ្រូបង្រៀន សិស្សសាលា និង និស្សិតជាដើម ។ល។

## ២.២.បង្កើនការផ្សព្វផ្សាយក្នុងការអនុវត្តកម្មវិធីព្រៃឈើជាតិ

-គោលបំណងនៃកម្មវិធីព្រៃឈើជាតិ

-ឱកាសនៃការចូលរួមគ្រប់គ្រងធនធានព្រៃឈើនៅមូលដ្ឋាន

-គោលបំណងនៃការកំណត់ព្រំប្រទល់ព្រៃ និង និតិវិធី

-ផែនការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព

-ច្បាប់ លិខិតបទដ្ឋានច្បាប់ បទបញ្ជា ...។ល។

# ២.៣.ការធ្វើឱ្យប្រសើរនូវមជ្ឈមណ្ឌលផ្សព្វផ្សាយព័ត៌មានព្រៃឈើ

-រៀបចំឯកសារជាភាសាខ្មែរ  និង អង់គ្លេស និង ធ្វើបច្ចុប្បន្នភាពឯកសារនៅក្នុងគេហទំព័រព្រៃឈើ ។

-រៀបចំផលិតសំភារៈផ្សព្វផ្សាយព្រៃឈើថ្មីៗដែលជាលទផលនៃការស្រាវជ្រាវ និង បទពិសោធន៏ ។

-រៀបចំទុកដាក់ឯកសារទៅតាមប្រភេទនីមួយៗក្នុងប្រព័ន្ធទិន្នន័យកំព្យូទ័រ

-ដាក់តាំងបង្ហាញនូវឯកសារសំខាន់ៗសម្រាប់ការចូលទស្សនា

## ២.៤.យុទសាស្រ្តទំនាក់ទំនង

-បង្កើនទំនាក់ទំនងជាមួយ សហគមន៏មូលដ្ឋាន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍនានា និង ស្ថាប័នពាក់ព័នផ្សេងៗ ដើម្បីបង្កើនប្រសិទិភាពនៃការ ផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយ និង មាននិរន្តរភាព។

## ២.៥.ការវាយតម្លៃពីតម្រូវការសមត្ថភាព

-សិក្សាវាយតម្លៃពីតម្រូវការកសាងសមត្ថភាព ដើម្បីអភិវឌ្ឍនូវសេវាកម្មផ្សព្វ ផ្សាយឱ្យមានគុណភាព និង ប្រសិទិភាពដើម្បីជួយគាំទ្រការគ្រប់គ្រងព្រៃឈើ នៅមូលដ្ឋានឱ្យមាននិរន្តរភាព។

## ២.៦.សេវាកម្មផ្សព្វផ្សាយព្រៃឈើនៅមូលដ្ឋាន

-រៀបចំសេវាកម្មផ្សព្វផ្សាយដែលមានជំនាញចាំបាច់ រឹងមាំ ងាយស្រួល និង មានកិច្ចសហការល្អជាមួយដៃគូអភិវឌ្ឍនានា និងស្ថាប័នពាក់ព័ន ដើម្បីជួយដល់ការគ្រប់គ្រងព្រៃឈើនៅមូលដ្ឋាន។

-ផ្តល់សេវាកម្មបណ្តុះបណ្តាលនូវបច្ចេកទេស និង ជំនាញចាំបាច់ដែលអាចជួយដល់សហគមន៍មូលដ្ឋាន ក្រុមប្រឹក្សាឃុំ ដៃគូអភិវឌ្ឍនាន និង វិស័យឯកជនដែលពាក់ព័នក្នុងសកម្មភាពព្រៃឈើ។

## ២.៧.ការត្រួតពិនិត្យ និង វាយតម្លៃ

-សហការជាមួយ សហគមន៍មូលដ្ឋាន អាជ្ញាធរដែនដី សង្គមស៊ីវិល ស្ថាប័នបណ្តុះបណ្តា និង ដៃគូអភិវឌ្ឍនានា ដើម្បីត្រួតពិនិត្យ និងវាយតម្លៃនូវលទ្ធផលនៃការអនុវត្តសកម្មភាពផ្សព្វផ្សាយព្រៃឈើ និង សំភារៈផ្សព្វផ្សាយព្រៃឈើ ដើម្បីកែសម្រួល និង ធ្វើឱ្យប្រសើរឡើង។

# ៣_លទផលរំពឹងទុក

-សេវាកម្មផ្សព្វផ្សាយព្រៃឈើនឹងត្រូវបានរៀបចំដើម្បីផ្តល់ជូនដល់សហគមន៍មូលដ្ឋាន ក្រុមប្រឹក្សាឃុំ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និង ស្ថាប័នពាក់ព័នផ្សេងទៀតឱ្យបានពេញលេញនៅឆ្នាំ ២០១៥។

-ការយល់ដឹងស្តីពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពនឹងធ្វើឱ្យកាន់តែប្រសើរឡើងតាមរយៈកម្មវិធីអប់រំ ។

## ៣_លទ្ធផលរំពឹងទុក (ត)

- ព័ត៌មាន និង សំភារៈផ្សព្វផ្សាយព្រៃឈើនឹងត្រូវបានធ្វើឱ្យប្រសើរឡើងតាមរយៈការបោះពុម្ពផ្សាយជាប្រចាំនូវលទ្ធផលស្រាវជ្រាវព្រៃឈើ និងបទពិសោធន៏ថ្មីៗ ។

-ចំណេះដឹងស្តីពី ការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាពនឹងត្រូវបានធ្វើឱ្យប្រសើរឡើងតាមរយៈការបង្កើនសកម្មភាពផ្សព្វផ្សាយជាប្រចាំ ។

-សេវាកម្មផ្សព្វផ្សាយនឹងត្រូវបានពង្រឹង និង ធ្វើប្រសើរឡើងនូវកម្មវិធីអភិវឌ្ឍដើម្បីជួយការគ្រប់គ្រងព្រៃឈើនៅមូលដ្ឋានប្រកបដោយប្រសិទ្ធិភាព ។

# អនុកម្មវិធីទី៣

# អភិវឌ្ឍសមត្ថភាពការស្រាវជ្រាវ

- ស្ថានភាពបច្ចុប្បន្ន
- ចម្មោបាយសំរាប់អនុវត្ត
- លទ្ធផលរំពឹងទុក

# អ្វីទៅជាការស្រាវជ្រាវ?

# ហេតុអ្វីត្រូវស្រាវជ្រាវ?

# ហេតុអ្វីចាំបាច់អភិវឌ្ឍការស្រាវជ្រាវ?

# ស្ថានភាពបច្ចុប្បន្ន

- វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ-សត្វព្រៃនៅមានការខ្វះខាតមន្ត្រីជំនាញដែលមានសមត្ថភាពក្នុងសិក្សាស្រាវជ្រាវ ពុំទាន់ប៉ិនប្រសប់ក្នុងការរៀបចំគំរោងសំណើសំរាប់ការងារស្រាវជ្រាវទៅកាន់ស្ថាប័នផ្តល់ជំនួយនានា ។
- មានការសិក្សាស្រាវជ្រាវមួយចំនួនដែលបានធ្វើឡើងដោយវិទ្យាស្ថានស្រាវជ្រាវព្រៃឈើដែរ តែលទ្ធផលនៅមានកំរិត និងមិនទាន់បានផ្សព្វផ្សាយអោយបានទូលំទូលាយនៅឡើយ ។

# ស្ថានភាពបច្ចុប្បន្ន ( ត )

- លទ្ធផលនៃការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងវិស័យព្រៃឈើដែលបានធ្វើកន្លងមក នៅមិនទាន់បានទាក់ទាញចំណាប់អារម្មណ៍អោយបានខ្លាំងក្លាពីថ្នាក់ដឹកនាំនៅឡើយ ។
- អនុកម្មវិធីនេះនឹងនឹងអភិវឌ្ឍសមត្ថភាពនៃការស្រាវជ្រាវព្រៃឈើដើម្បីអោយប្រាកដថា ការស្រាវជ្រាវនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តកម្មវិធីព្រៃឈើជាតិ ។

# មធ្យោបាយសំរាប់អនុវត្ត

- ត្រូវមានគណៈកម្មាធិការតម្រង់ទិសសំរាប់វិស័យស្រាវជ្រាវព្រៃឈើជាតិមួយ ដែលនឹងផ្តោតទៅលើផ្នែកសេដ្ឋកិច្ច សង្គម បរិស្ថាន និង ទិដ្ឋភាពច្បាប់ក្នុងវិស័យព្រៃឈើដើម្បីអោយប្រាកដថាទៅអនាគតការស្រាវជ្រាវក្នុងវិស័យព្រៃឈើ នឹងគាំទ្រដល់កម្មវិធីព្រៃឈើជាតិ ។
- ត្រូវមានវិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍព្រៃឈើ-សត្វព្រៃ ដែលមានសមត្ថភាពពេញលេញទាំងធនធានមនុស្ស និងសំភារៈ-បរិក្ខាពិសោធន៍ដែលអាចឆ្លើយតបទៅនឹងតំរូវការស្រាវជ្រាវជាពិសេសការទាក់ទាញរកថវិកាស្រាវជ្រាវពីស្ថាប័នផ្តល់ជំនួយនានា ។

# មធ្យោបាយសំរាប់អនុវត្ត (ត)

- ត្រូវពង្រឹងសមត្ថភាពដល់វិទ្យាស្ថានស្រាវជ្រាវព្រៃឈើ ក៏ដូចជាសាកលវិទ្យាល័យព្រៃឈើនានាក្នុងការបណ្តុះបណ្តាលធនធានមនុស្សជំនាន់ក្រោយក្នុងវិស័យព្រៃឈើ ដើម្បីអោយមនុស្សថ្មីទាំងនោះមានសមត្ថភាពពេញលេញក្នុងការស្រាវជ្រាវពីវិស័យព្រៃឈើ ធានាបាននូវការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។
- បង្កើតបណ្តាញស្រាវជ្រាវព្រៃឈើជាមួយបណ្តាស្ថាប័នស្រាវជ្រាវព្រៃឈើនានាទាំងនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងសកលលោក ដើម្បីអភិវឌ្ឍការងារស្រាវជ្រាវ ផ្លាស់ប្តូរបទពិសោធន៍ និងរៀនសូត្រពីបទពិសោធន៍ជោគជ័យនានាដែលគេបានធ្វើកន្លងមក ។
- ស្រាវជ្រាវដើម្បីគាំទ្រការអនុវត្តកម្មវិធីព្រៃឈើជាតិ ដែលផ្តោតសំខាន់លើការគ្រប់គ្រងធនធានព្រៃឈើ ការអភិរក្សព្រៃឈើ ការពង្រឹងការអនុវត្តច្បាប់និងអភិបាលកិច្ច និង វិមជ្ឈការក្នុងការគ្រប់គ្រងព្រៃឈើ ។

# លទ្ធផលរំពឹងទុក

- ប្រព័ន្ធការងារស្រាវជ្រាវព្រៃឈើជាតិមួយត្រូវបានអភិវឌ្ឍ ដើម្បីធ្វើការងារស្រាវជ្រាវព្រៃឈើ ដើម្បីគាំទ្រការអនុវត្តកម្មវិធីព្រៃឈើជាតិ ។
- ស្ថាប័នរដ្ឋាភិបាល និងស្ថាប័នស្រាវជ្រាវដទៃទៀតដែលមិនមែនរដ្ឋាភិបាល នឹងដើរតួនាទីសំខាន់ក្នុងការតាមដាន និងអនុវត្តកម្មវិធីព្រៃឈើជាតិ ។
- វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ-សត្វព្រៃមួយដែលធ្វើការស្រាវជ្រាវដើម្បីគាំទ្រយ៉ាងសកម្មនូវការអនុវត្តកម្មវិធីព្រៃឈើជាតិ តាមរយៈការរៀបចំ ការគ្រប់គ្រង និងការអនុវត្តកម្មវិធីស្រាវជ្រាវស្តីពីព្រៃឈើមូលដ្ឋាន ។

# លទ្ធផលរំពឹងទុក ( ត)

- ស្ថាប័នស្រាវជ្រាវ និងសាកលវិទ្យាល័យព្រៃឈើនៅកម្ពុជា នឹងចូលរួមក្នុងសកម្មភាពការងារព្រៃឈើជាតិ និងការស្រាវជ្រាវពិសោធន៍ដែលមានទំនាក់ទំនងដល់ការអនុវត្តកម្មវិធីព្រៃឈើជាតិ។
- ទិន្នន័យព្រៃឈើ និងព័ត៌មានស្តីពីព្រៃឈើត្រូវបានផ្តល់ជាចំហរដល់ស្ថាប័នរដ្ឋាភិបាល និងស្ថាប័នស្រាវជ្រាវមិនមែនរដ្ឋាភិបាលក្នុងគោលបំណងនៃការស្រាវជ្រាវ ។
- ការចូលរួមរបស់ស្ថាប័នស្រាវជ្រាវកម្ពុជាក្នុងបណ្តាញស្រាវជ្រាវថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិត្រូវបានពង្រឹង ហើយស្ថាប័នស្រាវជ្រាវព្រៃឈើ កម្ពុជាអាចមានលទ្ធភាពក្នុងការស្វែងរកឱកាសសំរាប់ការបណ្តុះបណ្តាល និងស្វែងរកថវិកាសំរាប់ការងារស្រាវជ្រាវ ។

# អនុកម្មវិធីទី ៤
# វិញ្ញាបនប័ត្រព្រៃឈើ

១_ស្ថានភាពបច្ចុប្បន្ន

_អ្វីទៅជាវិញ្ញាបនប័ត្រ? អ្វីទៅជាវិញ្ញាបនប័ត្រព្រៃឈើ?

_ឱកាសរៀបចំវិញ្ញាបនប័ត្រព្រៃឈើនៅកម្ពុជា

_ប្រព័ន្ធវិញ្ញាបនប័ត្រព្រៃឈើ

២_តើមធ្យោបាយអនុវត្តយ៉ាងដូចម្តេច?

៣_លទ្ធផលរំពឹងទុក

# ១_ស្ថានភាពបច្ចុប្បន្ន

- ព្រៃឈើលើពិភពលោកប្រមាណ ៨% បានផ្តល់វិញ្ញាបនប័ត្រព្រៃឈើ
- ប្រទេសកំពុងអភិវឌ្ឍន៍ប្រមាណ ៧%
- ឆ្នាំ ២០០២ ការពិចារណាលើការផ្តល់វិញ្ញាបនប័ត្រព្រៃឈើកើនឡើងខណះ ដែលព្រៃឈើប្រមាណ ២,៨% បានផ្តល់វិញ្ញាបនប័ត្រព្រៃឈើ
- បច្ចុប្បន្ន ប្រទេសកំពុងអភិវឌ្ឍន៍កំពុងសកម្មលើការងារវិញ្ញាបនប័ត្រព្រៃឈើ
- ៣២ ប្រទេស មាន National certification schemes
- Schemes ចំនួន ០២ FSC & PEFC កំពុងប្រកួតប្រជែងគ្នាលើពិភពលោក

# ~អ្វីទៅជាវិញ្ញាបនប័ត្រ ? អ្វីទៅជាវិញ្ញាបនប័ត្រព្រៃឈើ ?

- វិញ្ញាបនប័ត្រ : គឺជាដំណើការបញ្ជាក់ដល់ភាគីមួយទៀត ដែលភាគីនោះសម្រេចបានតាមកំរិតស្តង់ដាកំណត់ទុកជាមុន
- វិញ្ញាបនប័ត្រព្រៃឈើ : គឺជាដំណើការវាយតម្លៃការងាររៀបចំគ្រប់គ្រងព្រៃឈើ ផ្សារភ្ជាប់ជាមួយសង្វាក់ផលិតកម្មឈើ ដែលសម្រេចបានតាមកំរិតស្តង់ដាកំណត់ទុកជាមុន

# ១.ស្ថានភាពបច្ចុប្បន្ន (ត)

- អ្វីទៅជា FSC(1993) ? Forest Stewardship Council ។ ធាតុសំខាន់ៗ ពាក់ព័ន្ធនឹងវិញ្ញាបនប័ត្រព្រៃឈើ ធ្វើមជ្ឈការសម្រេចចិត្តដែលមានលក្ខណៈស្តង់ដា និង មានភាពជឿជាក់ ។ ប្រទេសចំនួន ៧៨ ស្មើនឹង ២៨% បានអនុវត្តប្រព័ន្ធវិញ្ញាបនប័ត្រព្រៃឈើ FSC
- អ្វីទៅជា PEFC (1999) ? Programme for the Endorsement of Forest Certification ។ ប្រព័ន្ធរបស់វា មានភាពជឿជាក់ ហើយក៏ទទួលស្គាល់ប្រព័ន្ធវិញ្ញាបនប័ត្រព្រៃឈើឯករាជ្យផ្សេងៗផងដែរ ។ ប្រទេសចំនួន ២២ បានអនុវត្តប្រព័ន្ធវិញ្ញាបនប័ត្រព្រៃឈើ PEFC

# ប្រព័ន្ធវិញ្ញាបនប័ត្រព្រៃឈើ(Certificate systems)

- ប្រព័ន្ធវិញ្ញាបនប័ត្រព្រៃឈើលើពិភពលោក មានចំនួន ៥ គឺ

  - FSC : Forest Stewardship Council
  - PEFC : Programm Endorsement
  - CERFLOR : (Programa Brasileiro de Certificacao Forestal
  - LEI : Lembaga Ekolabel Indonesia (Indonesian Ecolabelling Institute)
  - MTCC : Malaysian Timber Certification Council



- បទពិសោធន៏កន្លងមក ការរៀបចំប្រព័ន្ធវិញ្ញាបនប័ត្រព្រៃឈើ ត្រូវចំណាយពេលវែង សោហ៊ុយចំណាយខ្ពស់ និង ល្គឹកណាការលក់ឈើចេញប្រទេសដែលទិញតម្រូវឱ្យមានវិញ្ញាបនប័ត្រព្រៃឈើបញ្ជាក់ ទើបប្រើប្រាស់វិញ្ញាបនប័ត្រព្រៃឈើ



FSC International Center, Bonn, Germany
FSC Europe RO, Central Europe
FSC Russia
FSC China
FSC Asia RO, SE Asia
FSC Americas RO, Oaxaca, Mexico
FSC Africa RO, Central Africa

# ឱកាសរៀបចំវិញ្ញាបនប័ត្រព្រៃឈើនៅកម្ពុជា

- ប្រទេសកម្ពុជា ក៏ដូចប្រទេសដ៏ទៃទៀតដែរ ចាប់អារម្មណ៍លើការរៀបចំប្រព័ន្ធវិញ្ញាបនប័ត្រព្រៃឈើថ្នាក់ជាតិ
- វិញ្ញាបនប័ត្រព្រៃឈើនាំមកនូវផលចំណេញច្រើន ជាពិសេស ជួយពង្រីកទីផ្សារឈើរបស់កម្ពុជា រហូតដល់ទីផ្សារអឺរ៉ុប

## ២_តើមធ្យោបាយអនុវត្តយ៉ាងដូចម្តេច?

១_បង្កើតមជ្ឈមណ្ឌលវិញ្ញាបនប័ត្រព្រៃឈើមួយក្នុងរដ្ឋបាលព្រៃឈើ

២_បង្កើតក្រុមការងារថ្នាក់ជាតិ ស្ថិតនៅក្រោមអង្គភាពវិញ្ញាបនប័ត្រព្រៃឈើ

- ជ្រើសរើស certification scheme ដែលសមស្របជាមួយនឹងលក្ខខណ្ឌកម្ពុជា និង មានការទទួលស្គាល់ពីសំណាក់អន្តរជាតិផងដែរ
- បង្កើតលក្ខណៈវិនិច្ឆ័យ និងសូចនាករ កំរិតជាតិ សម្រាប់ផ្តល់វិញ្ញាបនប័ត្រព្រៃឈើ លើការងារគ្រប់គ្រងព្រៃឈើ
- បង្កើតលក្ខណៈវិនិច្ឆ័យ និងសូចនាករ កំរិតជាតិ សម្រាប់ផ្តល់វិញ្ញាបនប័ត្រព្រៃឈើ លើសង្វាក់ផលិតកម្មឈើ

## ២.តើមធ្យោបាយអនុវត្តយ៉ាងដូចម្តេច? (ត)

- រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា ផ្សព្វផ្សាយចំណេះដឹងអំពីវិញ្ញាបនប័ត្រព្រៃឈើ បង្កើនការយល់ដឹងអំពីរចនាសម្ព័ន្ធ បង្កើតគោលការណ៍បច្ចេកទេសនានា ស្វែងយល់អំពីព័ត៌មានព្រៃឈើថ្នាក់ជាតិ របៀបកំណត់បញ្ហា និង វិធានការដោះស្រាយពាក់ព័ន្ធទៅនឹងវិញ្ញាបនប័ត្រព្រៃឈើ
- បង្កើតតំបន់សាកល្បងគោលការណ៍បច្ចេកទេសពាក់ព័ន្ធក្នុងព្រៃធម្មជាតិ ព្រៃដាំ ព្រៃឯកជន ព្រៃការពារ ដើម្បីពិនិត្យផលប៉ះពាល់មកលើវិញ្ញាបនប័ត្រព្រៃឈើ

## ២.តើមធ្យោបាយអនុវត្តយ៉ាងដូម្តេច? (ត)

៣.ក្រុមការងារជម្រុញការផ្តួចផ្តើមគំនិតពាក់ព័ន្ធនឹង FSC Schemes សម្រាប់ប្រទេសកម្ពុជា លើកទឹកចិត្តអ្នកពាក់ព័ន្ធនឹងវិស័យព្រៃឈើ អ្នកនយោបាយ លើការងាររៀបចំលក្ខណៈវិនិច្ឆ័យ និង សូចនាករ កំរិតជាតិ សំរាប់ផ្តល់វិញ្ញាបនប័ត្រព្រៃឈើនៅកម្ពុជា

៤.វិញ្ញាបនប័ត្រព្រៃឈើកម្ពុជា ត្រូវអនុវត្តឱ្យស្របទៅ FSC Schemes

៥.មជ្ឈមណ្ឌលវិញ្ញាបនប័ត្រព្រៃឈើ លើកទឹកចិត្តអ្នកពាក់ព័ន្ធនឹងឧស្សាហកម្មឈើ សហគ្រាសកែច្នៃឈើ ដើម្បីផ្តល់វិញ្ញាបនប័ត្របញ្ជាក់លើសង្វាក់ផលិតកម្ម និង បង្ហាញអំពីភាពជឿនលឿនលើការងារវិញ្ញាបនប័ត្រព្រៃឈើ។

## ៣_លទ្ធផលរំពឹងទុក

១_នឹងមានមជ្ឈមណ្ឌលផ្តល់វិញ្ញាបនប័ត្រព្រៃឈើមួយ ត្រូវបានបង្កើតឡើងក្នុងរដ្ឋបាលព្រៃឈើ ដែលផ្តួមផ្តើមគំនិតចេញពី FSC Schemes

២_មន្ត្រី និង អ្នកពាក់ព័ន្ធនឹងវិស័យព្រៃឈើ មានការយល់ដឹងអំពីសារៈសំខាន់ របស់វិញ្ញាបនប័ត្រព្រៃឈើ

៣_តាមរយៈក្រុមការងារមជ្ឈមណ្ឌលផ្តល់វិញ្ញាបនប័ត្រព្រៃឈើ សេចក្តីព្រាងលក្ខណៈវិនិច្ឆ័យ និង សូចនាករ កំរិតជាតិ សម្រាប់ផ្តល់វិញ្ញាបនប័ត្រព្រៃឈើ ត្រូវបានរៀបចំ និង មានការទទួលស្គាល់ពីស្ថាប័ន FSC។



# កម្មវិធីទី៦

# ការប្រើប្រាស់ហិរញ្ញប្បទានប្រកបដោយនិរន្តរភាព

# Sustainable Forest Financing

ម៉ា សុខថា

# I- សេចក្តីផ្តើម

- ព្រៃឈើនៅប្រទេសកម្ពុជាគឺបានគ្រប់គ្រងដោយច្បាប់ស្តីពីព្រៃឈើនិងមានយុទ្ធសាស្រ្តផែទាំការពារបរិស្ថានព្រៃឈើដែលបានដាក់បញ្ចូលនៅក្នុងយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល( ដំណាក់កាលទី២ឆ្នាំ២០០៨) ចតុកោណទី១ បានកំណត់ពី ការលើកស្ទួយវិស័យកសិកម្មហើយក្នុងនោះមុំទី៤បានលើកឡើងពី កំណែទម្រង់ព្រៃឈើ ដើម្បីថែរក្សារក្សាគំរបព្រៃឈើឱ្យបាន៦០%នៅឆ្នាំ២០១៥ ។
- គោលនយោបាយរាជរដ្ឋាភិបាលគឺការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងការប្រើប្រាស់ធនធានព្រៃឈើសម្រាប់លើកកំពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជននៅជនបទ និងចូលរួមក្នុងកំណើនសេដ្ឋកិច្ចជាតិ ។

• រដ្ឋបាលព្រៃឈើបានគ្រប់គ្រង និង គាំទ្រនូវការរៀបចំតំបន់សាកល្បងយន្តការ REDD ដែលកាត់បន្ថយការបញ្ចេញ ឧស្ម័នផ្ទះកញ្ចក់ពីការរេចរឹលព្រៃឈើដែលមានការផ្តួចផ្តើមនៅតំបន់ព្រៃសហគមន៍នៅក្នុងខេត្តឧត្តរមានជ័យភាគខាងជើងនៃប្រទេស។ នៅទីនោះរដ្ឋបាលព្រៃឈើ និងសហគមន៍ព្រៃឈើនឹងបង្កើតនូវគំរូហិរញ្ញប្បទានកាបូន（ Carbon financing model）ដើម្បីជាគំរូណែនាំនៃការគ្រប់គ្រងហិរញ្ញវត្ថុ និង ប្រពន្ធ័គ្រប់គ្រងរួមគ្នា។ ជាងនេះទៅទៀត ពាណិជ្ជកម្មចំការឈើដាំ អេកូទេសចរណ៍ គម្រោងសហប្រតិបត្តិការទទួលខុសត្រូវចំពោះសង្គមនៅក្នុងវិស័យឧស្សាហកម្ម（ដូចជា ផលិតកម្មវារីអគ្គីសនី ផលិតកម្មទឹកស្អាត ថ្មផដ្ឋ ឡ）។

- ព្រៃឈើសំរាប់ការផ្គត់ផ្គង់ថាមពលនិងជីវម៉ាស់ គឺជាធនធានសក្តានុពលនៃគំរូហិរញ្ញប្បទាន ដែលរដ្ឋបាលព្រៃឈើ ត្រូវយកទៅ ប្រើសំរាប់ការចេញបទបញ្ញត្តិ ក្នុងការលើកទឹកចិត្តពួកគេ ឱ្យមានកាតព្វកិច្ចទៅលើការទូទាត់សំរាប់សេវាកម្មប្រពន្ធ័អេកូឡូស៊ី ហើយរដ្ឋបាលព្រៃឈើ អាចបំរើសេវាកម្មថែរក្សាសេដ្ឋកិច្ចសង្គមរបស់ប្រទេស ប្រព័ន្ធអេកូឡូស៊ីព្រៃឈើ និងប្រពន្ធ័ ធារាសាស្រ្តនៅតាមតំបន់នានា ក៏ដូចជា ជួយសម្រាលការឡើងកំដៅភពផែនដីផងដែរ ។

- ក្នុងរយៈពេលកន្លងមកនេះមានការរីកចំរើនសំខាន់ៗជាច្រើននៅក្នុងការងារដាំដុះព្រៃឈើ ឡើងវិញ ការគ្រប់គ្រងព្រៃឈើដោយសហគមន៍ព្រៃឈើ និងបណ្តាសកម្មភាពផ្សេងៗដែល មកពីការប្រើប្រាស់និងគ្រប់គ្រងព្រៃឈើព្រមទាំងការរចនា នូវឧបករណ៏សេដ្ឋកិច្ច សំរាប់ និរន្តភាពនៃការគ្រប់គ្រងព្រៃឈើ ។

# II- គោលបំណង

- ធ្វើឱ្យមានចលនាហិរញ្ញប្បទាន សំរាប់ការគ្រប់គ្រងព្រៃឈើដោយនិរន្តភាព
- ចល័តហិរញ្ញប្បទានសំរាប់ការកាត់បន្ថយភាពក្រីក្រតាមរយៈគំរោងព្រៃឈើនានា
- លើកទឹកចិត្តវិធីសាស្ត្រផ្តួចផ្តើមឱ្យកើតមានប្រភពហិរញ្ញប្បទាន
- ផ្តួចផ្តើមជំរុញការគាំទ្រ សក្តានុពលលើយន្តការ Aff-Re/CDM និង ការបង់ប្រាក់លើសេវាប្រព័ន្ធអេកូឡូស៊ីផ្សេងៗដែលបានមកពីការថែទាំប្រើប្រាស់ធនធានព្រៃឈើ
- កាត់បន្ថយនូវការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលកើតមកពីការរេចរឹលព្រៃឈើ និងការបង្កើនថែមទៀតនូវកាបូនស្តុក ដោយការគ្រប់គ្រងព្រៃឈើដោយចីរភាព

# អនុកម្មវិធីនេះរួមមាន

- ហិរញ្ញប្បទានពីរាជរដ្ឋាភិបាល
- ហិរញ្ញប្បទានផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាល និង ប្រទេសផ្តល់ជំនួយ
- ហិរញ្ញប្បទានបានមកពីប្រភពធនធានព្រៃឈើ( ចំណូលពីលក់ផលិតផលឈើ និង ការប្រើប្រាស់ធនធានបរិស្ថានព្រៃឈើ
- សេវាកម្មរបស់ក្រុមហ៊ុនឯកជន ។

## ១.ហិរញ្ញប្បទានពីរាជរដ្ឋាភិបាល

- រាជរដ្ឋាភិបាលបានវិភាជន៍ថវិកាដល់រដ្ឋបាលព្រៃឈើ តាមរយៈកញ្ចប់ថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ថវិកានេះបានប្រើប្រាស់ទៅលើសកម្មភាពនានា ដូចជា ការដាំដើមឈើ ការគ្រប់គ្រងសម្បត្តិព្រៃឈើអចិន្ត្រៃយ៍តាមរយៈការបោះបង្គោលព្រំដែនព្រៃឈើ ការផ្តល់មធ្យោបាយ និងសំភារៈសំរាប់បំពេញការងាររបស់មន្ត្រីរដ្ឋបាលព្រៃឈើ...។ល។
- តាមរយៈការផ្តល់ហិរញ្ញប្បទាននេះនៅមានកំរិតនៅឡើយដើម្បីឆ្លើយតបនូវការធានាក្នុងការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ។

# ២.ហិរញ្ញប្បទានផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាល និងប្រទេសផ្តល់ជំនួយ

- អង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានទទួលជំនួយផ្នែកហិរញ្ញវត្ថុដោយផ្ទាល់ ពីប្រទេសផ្តល់ជំនួយ ដើម្បីដំណើរគំរោង ដូចជាធ្វើការអភិរក្សព្រៃឈើ និង ការគ្រប់គ្រង់តំបន់ការពារសត្វព្រៃ ការបង្កើតសហគមន៍ព្រៃឈើ ការបណ្តុះបណ្តាលធនធាមនុស្ស ។ល។
- ការផ្តល់ជំនួយទៅលើការពារធនធានធម្មជាតិបានធ្វើឱ្យព្រៃឈើ និង ដីព្រៃ និងប្រពន្ធ័ផលិតកម្មកសិកម្ម មានគុណភាពកាន់តែប្រសើរឡើង ។

## ៣. ហិរញ្ញប្បទានផ្តល់ពីប្រភពធនធានព្រៃឈើ (ចំណូលពីលក់ផលិតផលឈើ និងប្រើប្រាស់ធនធានបរិស្ថានព្រៃឈើ )

- ព្រៃឈើបានផ្តល់អុកស៊ីហ្សែន និង បំបាត់កាបូនឌីអុកស៊ីតពីបរិយាកាស ធ្វើឱ្យផ្ទៃខាងលើ និងខាងក្រោមមានលំហូរទឹកទៀងទាត់ និង ផ្តល់នូវការចំរោះទឹកបានកាន់តែល្អ ។ ព្រៃឈើក៏អាចក៏អាចជួយដល់ពពួកភូតគាមនិងសត្វព្រៃនៅតាមតំបន់និងផ្តល់នូវទំនិញនិង សេវាកម្មដ៏មានតម្លៃរាប់តាំងពីឈើហ៊ុបរហូតដល់ផ្នែកទេសភាព ។

## ៣.១ ការលើកទឹកចិត្តសាធារណៈ និង អេកូទេសចរណ៍

- កម្មវិធីទូទាត់សំរាប់សេវាកម្មបរិស្ថាន គឺជាវិធីសាស្ត្រជំរើសមួយ ដើម្បីបញ្ឈប់ការអន់ថយរបស់បរិស្ថាន ដែលមានប្រភពមកពីការកាប់បំផ្លាញព្រៃឈើនៅក្នុងប្រទេសដែលបានចំណូលទាប ។
- ទេសចរណ៍អេកូឡូស៊ីគឺជាសកម្មភាពសេដ្ឋកិច្ចដែលទាក់ទងនិងព្រៃឈើសំខាន់មួយផ្សេងទៀត ។
- ការផ្សព្វផ្សាយជាអន្តរជាតិអំពី តំបន់ឧទ្យានជាតិ ជំរកសត្វព្រៃ ។ល ។
- បានធ្វើឱ្យព្រៃក្លាយជាតំបន់ទាក់ទាញទេសចរណ៍ទៅទស្សនាកំសាន្ត ។
- ម្ចាស់ព្រៃឈើ(រដ្ឋ សហគមន៍គ្រួសារ) ត្រូវបានទូទាត់ឱ្យសំរាប់សេវាកម្មបរិស្ថានដែលពួកគេផលិតបាន ពេលពួកគេប្រើប្រាស់ដី និងសកម្មភាពគ្រប់គ្រងព្រៃឈើផ្សេងៗដែលអាចការពារព្រៃនិងជីវៈចំរុះដោយបានថែរក្សាលើកកំពស់គុណភាពជីវភាពមនុស្ស ។
- មុខងាររបស់កម្មវិធីនេះដូចជាប្រព័ន្ធផ្ទេរមូលនិធិពីអ្នកដែលទទួលបានផលពីសេវាកម្មបរិស្ថានទៅអ្នកដែលបានផលិតសេវាកម្មបរិស្ថានវាជាយន្តការហិរញ្ញវត្ថុមួយដើម្បីធ្វើការផ្សព្វផ្សាយការអភិរក្សធនធានព្រៃឈើរបស់ប្រទេស

## ៣.២-ការដាំដើមឈើ

- ការប្រើប្រាស់ដីសំរាប់ការដាំដើមឈើឡើងវិញជាលក្ខណៈពាណិជ្ជកម្មក៏ដូចជាការអភិរក្សព្រៃឈើ ដែលការទូទាត់សំរាប់សេវាកម្មបរិស្ថាន គឺជាការបន្ថែមទៅចំណូលដែលបានមកពីការលក់ផលិតផលព្រៃឈើដោយផ្ទាល់ និងប្រយោលដល់ប្រជាជន និងចំណូលថវិកាជាតិ ។
- ជួយគាំពារផ្នែកបរិស្ថានជាច្រើនទៀតដូចជា ការពារទីជំរាល ទប់ស្កាត់ការហូរច្រោះដី ការធ្វើប្រសើរឡើងនៃគុណភាពដី និង ធ្វើឱ្យមាននិរន្តរភាពព្រៃឈើ ។

## ៣.៣-ការអភិរក្សជីវៈចំរុះ

- ការអភិរក្សជីវៈចំរុះអាចជាមុខងារនិយត័ករមួយនៃប្រពន្ធ័អេកូឡូស៊ីធម្មជាតិ ដែលបានជួយថែរក្សា ឬធ្វើឱ្យបរិស្ថាននិងគុណភាពជីវិតរបស់មនុស្សមានការប្រសើរឡើង ។
- មុខងារប្រពន្ធ័អេកូឡូស៊ី(Ecosystem function)គឺជាសមត្ថភាពនៃដំណើរការធម្មជាតិ និង ធាតុផ្សំដែលផ្តល់ទំនិញ និងសេវាកម្មដើម្បីបំពេញតំរូវការរបស់មនុស្ស ទាំងដោយផ្ទាល់ និងប្រយោល ។ ឧ. យន្តការ REDD តាមរយៈការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ គេអាចលក់វិញ្ញាបនប័ត្រ ទៅទីផ្សារអន្តរជាតិ ។

## ៤. សេវាកម្មរបស់ក្រុមហ៊ុនឯកជន

- សេវាកម្មផ្ដល់ទឹកស្អាត និង ផលិតកម្មវារីអគ្គីសនី ជាវិធីសាស្ត្រមួយផ្សេងទៀត សំរាប់លើកទឹកចិត្តដល់ការអភិរក្ស និង ការការពារប្រពន្ធ័អេកូឡូស៊ីព្រៃឈើ គឺជាការទូទាត់ ដោយផ្ទាល់រវាងក្រុមហ៊ុនឯកជនដែលប្រើប្រាស់ដីព្រៃឈើសំរាប់ផលិតកម្មទឹកស្អាត និង ផលិតកម្មថាមពលវារីអគ្គីសនី ជាមួយនឹង រដ្ឋបាលព្រៃឈើ ។
- ហេតុដូច្នេះវាអាចជួយធ្វើឱ្យលំហូរសាច់ប្រាក់ ដែលមានមិនទៀងទាត់និង តែងតែគេឧស្សាហ៍ឃើញនៅក្នុងប្រពន្ធ័ផលិតកម្មព្រៃឈើនោះមានការប្រសើរឡើង ។

- ដើម្បីអនុវត្តនូវអនុកម្មវិធីនេះ គេគួរមានគោលដៅយុទ្ធសាស្ត្រហិរញ្ញប្បទាន ព្រៃឈើជាតិដែលអាចអនុវត្តនូវការគ្រប់គ្រង់ ថែរក្សា ការពារ និង ការអភិរក្សធនធានព្រៃឈើ និង ផលិតកម្មឧស្សាហកម្មព្រៃឈើរបស់ប្រទេសដែលឆ្លោះទៅតាមគោលការណ៍នៃការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តភាព។
- បន្ថែមពីនេះវានឹង អាចបង្កើនភាពមានការងារធ្វើ និងធ្វើឱ្យស្តង់ដារ នៃការរស់នៅមានភាពរីកចំរើន សំរាប់ប្រជាជននៅជនបទតាមរយៈការរួមបញ្ចូលគ្នានៃសកម្មភាពព្រៃឈើនានា ។

# III- មធ្យោបាយអនុវត្ត

**កម្មវិធីសេវាកម្មបរិស្ថានព្រៃឈើគឺជាសមាសធាតុមួយយ៉ាងសំខាន់នៅក្នុងយុទ្ធសាស្រ្តហិរញ្ញប្បទាន ព្រៃឈើជាតិ ។ យុទ្ធសាស្រ្តនេះ គឺជាកត្តាប្រឈមយ៉ាងសំខាន់ក្នុងការគ្រប់គ្រងដោយនិរន្តភាពព្រៃឈើ ក្នុងនោះរួមមានគោលការណ៏ចំនួន៥ ដូចខាងក្រោមនេះ**

**១- រចនាសម្ព័ន្ធច្បាប់** : បទបញ្ញត្តិច្បាប់ និង គោលការណ៏ច្បាស់លាស់ដែលអាចឱ្យមានការអភិវឌ្ឍន៏ជា លក្ខណៈប្រពន្ធ័ជារួម មានៈ

- អន្តរគូបនីយកម្មនៃតំលៃក្នុងពន្ធនាំចូលនាំចេញ សេវាកម្មសាធារណៈ បំលាស់ប្តូរបទបញ្ញត្តិ ការប្រើប្រាស់ដី និង ទស្សនទានព្រៃឈើ

- ការទូទាត់សេវាកម្មបរិស្ថានព្រៃឈើ និង ប្រភពមូលនិធិដែលទទួលបាន
- ទំនាក់ទំនងជាមួយកិច្ចព្រមព្រៀងអន្តរជាតិដើម្បីពង្រឹងសេវាកម្មព្រៃឈើផ្សេងៗ

**២- ស្ថាប័ន** ៖ រចនាសម្ព័ន្ធរដ្ឋបាលគ្រប់គ្រាន់សំរាប់បំពេញនូវគោលដៅរបស់កម្មវិធី និង សមាហរណកម្មគ្រប់គ្រងរបស់ខ្លួន និង រដ្ឋបាលនៃធនធានហិរញ្ញវត្ថុ ។

**៣- ហិរញ្ញវត្ថុ** ៖ បង្កើតប្រភពមូលនិធិសាធារណៈឯកជន និង លាយចំរុះខុសៗគ្នាដោយប្រើប្រភព ខាងក្នុង និង ខាងក្រៅ និង យន្តការណែនាំតាមទីផ្សារ ។

**៤- គោលនយោបាយ** ៈ រួមមានៈ

- ដំណើរការ និង ឧបករណ៍សំរាប់កំណត់គោលនយោបាយព្រៃឈើ ( ទិសដៅនិងគោលដៅ)ៈ

ផែនការអភិវឌ្ឍន៍ព្រៃឈើជាតិ  យុទ្ធសាស្រ្តគ្រប់គ្រងការកាប់ឈើ និង ការកាន់កាប់ដីព្រៃខុសច្បាប់ ... ។ល ។

- គោលនយោបាយផ្សេងៗសំរាប់ផ្សព្វផ្សាយការគ្រប់គ្រង ការអភិរក្ស និង ការអភិវឌ្ឍធនធានព្រៃឈើដោយនិរន្តភាព

- ផលប្រយោជន៏នៃរបស់ការទូទាត់សេវាកម្មព្រៃឈើ

- ការផ្សារភ្ជាប់ជាមួយយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល

## ៥- តម្លាភាព និង គណនេយ្យភាព :

- ការត្រួតពិនិត្យ និង បង្កើប្រព័ន្ធតាមដាន វាយតម្លៃ និងធ្វើសវនកម្មលើផលរបរប្រកប សេវាកម្ម និងផលិតកម្មដែលពាក់ព័ន្ធ និងវិស័យព្រៃឈើ
- ភ្នាក់ងារព្រៃឈើ( ដើម្បីសំរបសំរួលការគ្រប់គ្រងគម្រោងនៅក្នុងតំបន់)
- បទបញ្ញត្តិចុះឈ្មោះទ្រព្យសម្បត្តិ ( ការចុះឈ្មោះកិច្ចសន្យាដើម្បីធានាការការពារនៃផលប្រយោជន៏ និង ការទទួលខុសត្រូវរបស់កម្មវិធីទូទាត់សេវាកម្មព្រៃឈើផ្សេងៗ)
- បន្តការបណ្តុះបណ្តាល ។

# IV- លទ្ធផលរំពឹងទុក

ដើម្បីឱ្យសំរេចបាននូវគោលដៅជាយុទ្ធសាស្ត្រហិរញ្ញប្បទានព្រៃឈើជាតិ រួមមានៈ

១-ការវិនិយោគផ្នែកឯកជន និង វិស័យព្រៃឈើ មានការសហប្រត្តិបការរឹងមាំ ដើម្បីធ្វើឱ្យសុខភាពព្រៃឈើមានការធូរស្រាល ឆ្ពោះទៅការបង្កើនទ្រព្យសម្បត្តិព្រៃជាអចិន្ត្រៃយ៍ ។

២-ផលិតផល-អនុផលព្រៃឈើ និងគ្រប់សេវាកម្មបរិស្ថានព្រៃឈើ ត្រូវមានការចុះសារពើភ័ណ្ឌសំរាប់ស្រង់យកទិន្នផលតាមបណ្តាតំបន់ និង ទីផ្សារ ដោយរដ្ឋបាលព្រៃឈើផ្តល់សេវាកម្មដើម្បីបង្កើនផលិតផល និង ការប្រើប្រាស់មានប្រសិទ្ធិភាព ។

៣-មានដៃគូរឹងមាំ ដើម្បីបង្កើតព្រៃ ទៅតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា  រៀបចំបទបញ្ញត្តិថ្មីៗដូចជា “កាតព្វកិច្ចរបស់បុគ្គល និង និតិបុគ្គលដែលវិនិយោគលើធនធានព្រៃឈើកម្ពុជា ” ... ។

៤-កម្មវិធីលើកទឹកចិត្តនឹងត្រូវអនុវត្តលើបុគ្គល និង និតិបុគ្គលដែលមានហិរញ្ញវត្ថុរឹងមាំសំរាប់ការវិនិយោគផ្ទាល់ និងនាំមកបច្ចេកវិទ្យាថ្មីៗដើម្បីឱ្យមុខងារដាំព្រៃឈើឡើងវិញកាន់តែល្អប្រសើរក្នុងប្រទេសកម្ពុជា ។

# សូមអរគុណ

# សំនួរ ចម្លើយ ពីកម្មវិធីព្រៃឈើជាតិ

## • កម្មវិធីទី១: ការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍

*សំនួរទី ១* ( ភិក្ខុ **ជឹម ពាន់** គង់នៅវត្តសិរីសុទ្ធាវង្ស ភូមិវត្ត ឃុំក្រចេះ ស្រុកចិត្របុរី ខេត្តក្រចេះ): បន្ទាប់ពីកំណត់ព្រំប្រទល់រួច ហើយព្រៃនៅមានឈើដែលមានអាយុអាចកាប់ដកហូតយកបាន តើប្រជាជនអាចស្នើសុំកាប់យកឈើទាំងនោះមកប្រើប្រាស់បានទេ?

*ចម្លើយទី ១* ( លោក **ប៉ក់ ជាលី**): យើងមានច្បាប់ព្រៃឈើដែលចែងថា ការប្រើប្រាស់ព្រៃឈើជាប្រពៃណីរបស់បងប្អូនសហគមន៍មូលដ្ឋាននឹងត្រូវបានគោរព ដូចនេះពួកគាត់អាចដកហូតព្រៃឈើទាំងនោះមកប្រើប្រាស់បាន តែមិនមែនដើម្បីធ្វើអាជីវកម្មទេ។

*សំនួរទី ២* ( លោក **ស៊ុន យូរ៉ា** តំណាងអង្គការ MVI ខេត្តស្ទឹងត្រែង): យើងបានលើកយកបញ្ហាធំៗរបស់កម្មវិធីមកធ្វើបទបង្ហាញនៅថ្ងៃនេះ តែនៅពេលពិភាក្សាតាមក្រុមមានលើកយកបញ្ហាទាំងនេះមកពិភាក្សាដែរឬទេ?

*ចម្លើយទី ២* ( លោក **ប៉ក់ ជាលី**): ស្អែកយើងនឹងលើកយកបញ្ហាទាំងនេះមកពិភាក្សា។

*សំនួរទី ៣* ( លោក **ថៃ ប៊ុនលាង** តំណាងសហគមន៍ខេត្តក្រចេះ): បន្ទាប់ពីកំណត់ដីព្រៃរួចហើយ តើយើងត្រូវបែងចែកដីទាំងនោះឱ្យទៅជាដីសម្បទានសេដ្ឋកិច្ចឬយ៉ាងណា?

*ចម្លើយទី ៣* ( លោក **ប៉ក់ ជាលី**): បន្ទាប់ពីកំណត់ដីព្រៃរួច យើងនឹងដឹងថាកន្លែងណាអាចធ្វើការអភិវឌ្ឍន៍ជាដីសម្បទានសង្គមកិច្ច និងកន្លែងណាគួរលៃទុកជាតំបន់អភិរក្ស គឺអាស្រ័យទៅនឹងទីតាំងជាក់ស្តែង។

## • កម្មវិធីទី២: ការគ្រប់គ្រងធនធានព្រៃឈើ និងការអភិរក្ស

*សំនួរទី ១* ( លោក **ហ៊ុន ណាវ៉ែន** មន្ត្រីខណ្ឌរដ្ឋបាលព្រៃឈើរតនគិរី): ចំពោះកីឡាប្រមាញ់ តើគួរធ្វើដូចម្តេច ដើម្បីធានានិរន្តរភាពសត្វព្រៃ?

*ចម្លើយទី ១* ( លោក **ឈុំ សំណាង**) ៖ យើងនឹងសិក្សាតំបន់សម្រាប់កីឡាប្រមាញ់ និងធ្វើការចាត់ថ្នាក់សត្វព្រៃស្របតាមលក្ខណៈជាតិនិងអន្តរជាតិ ។ យើងនឹងសិក្សាពីលក្ខណៈជីវសាស្ត្រ និងដង់ស៊ីតេរបស់វា រួចយើងនឹងរៀបចំ ផែនការយុទ្ធសាស្ត្រដើម្បីគ្រប់គ្រងកីឡាប្រមាញ់ រៀបចំកូតាដកហូត និងធ្វើការតាមដានឱ្យបានជាប្រចាំ ដើម្បីទទួលបានព័ត៌មានពីមូលហេតុផ្សេងៗ ដែលអាចកើតមានឡើងចំពោះសត្វព្រៃ ។

*សំនួរទី ២* ( អ្នកស្រី **មុំ សាគីន** តំណាងបណ្តាញ CPN ខេត្តក្រចេះ) ៖ តាមបទបង្ហាញ យើងនឹងសម្រេចឱ្យបានគម្របព្រៃឈើចំនួន៦០%លើផ្ទៃប្រទេស តើយើងត្រូវមានយន្តការអ្វីខ្លះ ដើម្បីសម្រេចការងារនេះ?

*ចម្លើយទី ២* ( លោក **ឃន សាវ៉េត**) ៖ ដើម្បីធានាគម្របព្រៃឱ្យបាន៦០%នៅឆ្នាំ២០១៥ យើងមានអនុកម្មវិធីចំនួន៦ ដែលបញ្ជាក់ពីការការពារ និងថែរក្សាព្រៃឈើ ។ យើងនឹងកំណត់ព្រំប្រទល់ និងទីកន្លែងដែលត្រូវស្តារព្រៃឡើងវិញ ។ កម្មវិធីទាំងនេះ នឹងនាំឱ្យយើងសម្រេចបានគម្របព្រៃ៦០% នៅឆ្នាំ២០១៥ ។

*សំនួរទី ៣* ( លោក **ឡុង យិន** តំណាងសហគមន៍ស្រុកឆ្លូង ខេត្តក្រចេះ) ៖ តាមរយៈការចូលរួម តើយើងទទួលផលក្នុងភាពជាម្ចាស់ ឬជាកម្មករ?

*ចម្លើយទី ៣* ( លោក **អួន សំអុល**) ៖ យើងមានលិខិតបទដ្ឋានមួយចំនួនស្តីពីការដាំឈើដោយឯកជនគ្រួសារ... ។ បើប្រជាជនចូលរួមដាំឈើក្នុងចំការដាំឈើរបស់រដ្ឋ ឬរបស់ក្រុមហ៊ុន នោះពួកគាត់នឹងទទួលបានកម្រៃពីការងារនេះ ។ តែបើប្រជាជនចុះកិច្ចសន្យាជាមួយរដ្ឋបាលព្រៃឈើ ដើម្បីធ្វើការដាំដុះព្រៃឈើលើដីរបស់រដ្ឋ នោះពួកគាត់នឹងទទួលផលប្រយោជន៍ក្នុងភាពជាម្ចាស់ ។

- **កម្មវិធីទី៣៖ ពង្រឹងការអនុវត្តន៍ច្បាប់ និងអភិបាលកិច្ច**

*សំនួរទី ១* ( លោក **ស៊ុន យូរ៉ា** តំណាងអង្គការ MVI ខេត្តស្ទឹងត្រែង ) ៖ នៅក្នុងកម្មវិធីនេះ គួរឱ្យមានការចូលរួមពីសហគមន៍ផង ដើម្បីឱ្យមានអភិបាលកិច្ចល្អលើវិស័យព្រៃឈើ ។

*ចម្លើយទី១* ( លោក **សួន សុវណ្ណ**) ៖ ចំពោះការចូលរួមរបស់សហគមន៍ព្រៃឈើ មានចែងក្នុងកម្មវិធីសហគមន៍ព្រៃឈើរួចហើយ ។

*សំនួរទី ២* (លោក **ថៃ ប៊ុនលាង** តំណាងសហគមន៍ខេត្តក្រចេះ): បេមានទំនាស់រវាងអ្នកមាន និងអ្នកក្រ ស្តីពីបញ្ហាដីធ្លី តើយើងត្រូវដោះស្រាយដូចម្តេច?

*ចម្លើយទី២* (លោក **សួន សុវណ្ណ**): អ្នកមាន និងអ្នកក្រត្រូវមានការទទួលខុសត្រូវស្មើគ្នាចំពោះមុខច្បាប់។

*សំនួរទី ៣* (លោក **សា ខួយ** តំណាងសហគមន៍ខេត្តក្រចេះ): តើការនាំចេញផល អនុផលព្រៃឈើមាន សារៈសំខាន់ យ៉ាងណាដែរ ចំពោះសហគមន៍ និងរាជរដ្ឋាភិបាល?

*ចម្លើយទី ៣* (លោក **សូ លន**): នៅក្នុងការនាំចេញផល អនុផលព្រៃឈើ ប្រជាជនក្នុងសហគមន៍ទទួល បានផលប្រយោជន៍ច្រើន ដោយរដ្ឋមិនបានយកថ្លៃសួយសារពិសហគមន៍ឡើយ តែត្រូវបំពេញបែបបទតាមនិតិវិធី។ រីឯរដ្ឋាភិបាលទទួលបានផលប្រយោជន៍ដោយប្រយោល ដោយមានការចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រ ពីសហគមន៍មូលដ្ឋាន។

*សំនួរទី ៤* (អ្នកស្រី **មុំ សាគីន** តំណាងបណ្តាញ CPN ខេត្តក្រចេះ): តើបណ្តាញព័ត៌មានរបស់កម្មវិធី មានប្រសិទ្ធភាពដូចម្តេចក្នុងការគ្រប់គ្រងព្រៃឈើ?

*ចម្លើយទី ៤* (លោក **សួន សុវណ្ណ**) រដ្ឋបានផ្តល់អំណាចដល់គ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ ក្នុងការរាយ ការណ៍ និងចាប់ឃាត់វត្ថុតាងល្មើសច្បាប់ តែត្រូវបញ្ជូនវត្ថុតាងទាំងនេះមករដ្ឋបាលព្រៃឈើ ដើម្បីមាន វិធានការណ៍ តាមផ្លូវ ច្បាប់។ អ្នករាយការណ៍អាចទូរស័ព្ទមកអង្គាធរ ហើយអង្គាធរនឹងរាយការណ៍បន្តមករដ្ឋបាលព្រៃឈើ។

● **កម្មវិធីទី៤: សហគមន៍ព្រៃឈើ**

*សំនួរទី ១* (លោក **សែ សុភី** តំណាងអង្គការ DPA រតនគីរី): តើកម្មវិធិសហគមន៍ព្រៃឈើមានភាព ប្រទាំងប្រទើសជាមួយនិងការអនុវត្តន៍ជាក់ស្តែងយ៉ាងណា?

*ចម្លើយទី១* (លោក **ឡាវសេដ្ឋាផល**): មិនមានការប្រទាំប្រទើសអ្វីឡើយ។ បច្ចុប្បន្នយើងមានសហគមន៍ ជាង៣00 តែក្នុងនោះមានតែ១២៤ប៉ុណ្ណោះ ដែលមានការទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ យើងនឹងជម្រុញឱ្យសហគមន៍ទាំងអស់ទទួលស្គាល់បានតាមផ្លូវច្បាប់ពេញលេញពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាពេលឆាប់ៗខាងមុខ។

*សំនួរទី ២* ( លោក **សោម ផល្លា** តំណាងសហគមន៍នៅខេត្តក្រចេះ ) : រដ្ឋាភិបាលបានផ្តល់ដីព្រៃសម្រាប់ធ្វើសម្បទានសេដ្ឋកិច្ច តើឱ្យសហគមន៍ព្រៃឈើកើតឡើងដូចម្តេច?

*ចម្លើយទី ២* ( លោក **ឡាវ សេដ្ឋាផល** ) : សហគមន៍កន្លងមកមិនមានកិច្ចសហការជាមួយរដ្ឋបាលព្រៃឈើក្នុងការបង្កើតសហគមន៍ព្រៃឈើទេ ។ ពេលរាជរដ្ឋាភិបាលប្រគល់ដីទៅឱ្យក្រុមហ៊ុនរួចហើយ ទើបសហគមន៍នាំគ្នាចង់បង្កើតសហគមន៍ព្រៃឈើ ។ ដូចនេះវាជាការលំបាកក្នុងការទាមទារយកដីនេះមកវិញដើម្បីបង្កើតសហគមន៍ ។ នេះក៏ជាការខ្វះខាតការផ្តល់ព័ត៌មានរបស់អង្គាធរមូលដ្ឋានក្នុងការលៃទុកដីទាំងនេះទុកជូនសហគមន៍ផងដែរ ។

*សំនួរទី ៣* ( លោក **ប៉ៃ គីមហាន** អភិបាលរងស្រុកស្នួល ខេត្តក្រចេះ ) សូមបំភ្លឺពីពាក្យឥណទានកាបូន ។ ម្យ៉ាងទៀតនៅក្នុងកម្មវិធី មានលើក ឡើងពីលទ្ធផលរំពឹងទុក តែពុំឃើញមានការលើកឡើងពីហានិយភ័យ ។ គួរលើកពីបញ្ហានេះផង ។

*ចម្លើយទី ៣* ( លោក **ឡាវ សេដ្ឋាផល** ) : គម្រោងឥណទានកាបូនគឺការលក់ខ្យល់អាកាសបរិសុទ្ធជូនប្រជាជនលើសាកលលោក ។ បណ្តាប្រទេសឧស្សាហកម្ម បានបំផ្លាញបរិស្ថានយ៉ាងធ្ងន់ធ្ងរ ដូចនេះគេយកប្រាក់មកឱ្យយើងដើម្បី ឱ្យយើងដាំដើមឈើ និងថែរក្សាព្រៃទុកខ្យល់បរិសុទ្ធជូនពិភពលោក ។ បច្ចុប្បន្ន យើងមានគម្រោងសាកល្បងពីឥណទានកាបូនរួចហើយ នៅខេត្តឧត្តរមានជ័យ ។

● **កម្មវិធីទី៥: ការកសាងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្ស**

*សំនួរទី ១* ( ភិក្ខុ **ជឹម ពាន់** គង់នៅវត្តសិរីសុទ្ធរង្ស ភូមិវត្ត ឃុំក្រចេះ ស្រុកចិត្របុរី ខេត្តក្រចេះ ) : បើការស្រាវជ្រាវមិនច្បាស់លាស់ តើមានផលប៉ះពាល់ដល់ការអនុវត្តន៍យ៉ាងដូចម្តេច? តើត្រូវធ្វើយ៉ាងណាដើម្បីឱ្យការស្រាវជ្រាវមិនភ្លាំងភ្លាត់?

*ចម្លើយទី ១* ( លោក **ចាន់ សុផល** ) : បើយើងមានសមត្ថភាពពេញលេញ នោះការស្រាវជ្រាវរបស់យើងមិនភ្លាំងភ្លាត់ទេ ។ តែបច្ចុប្បន្នការស្រាវជ្រាវរបស់យើងនៅមិនទាន់ល្អនៅឡើយទេ ដូចនេះយើងចាំបាច់ត្រូវពង្រឹងបន្ថែម ។

*សំនួរទី ២* ( លោក **វុទ្ធារ៉ា** តំណាងសហគមន៍មកពីខេត្តរតនគីរី ) : នៅក្នុងកម្មវិធីមានការប្រើពាក្យមជ្ឈមណ្ឌលផ្សព្វផ្សាយផង និងវិទ្យាស្ថានស្រាវជ្រាវផង ។ តើយើងចង់បង្កើតសាកលវិទ្យាល័យទៀត ឬយ៉ាងណា?

*ចម្លើយទី ២* ( លោក **ប៊ុន រ៉ាដា** ) ៖ បច្ចុប្បន្នយើងមានសាលាពីររួចហើយគឺ៖ សាកលវិទាល័យភូមិន្ទចំការដូង និងសាលាជាតិកសិកម្មព្រែកលៀប ដូចនេះយើងមិនចង់បង្កើតសាកលវិទ្យាល័យទៀតទេ តែយើងចង់ដាក់បញ្ចូលកម្មវិធីព្រៃឈើទៅក្នុងប្រព័ន្ធអប់រំ ។

*សំនួរទី ៣* ( អ្នកស្រី **ឡុង ធី** តំណាងសហគមន៍មកពីខេត្តក្រចេះ ) ៖ តើត្រូវធ្វើដូចម្តេចដើម្បីឱ្យគម្របព្រៃឈើរបស់យើងកើនដល់៦០% នៅឆ្នាំ២០១៥?

*ចម្លើយទី ៣* ( លោក **ប៉ក់ ជាលី** ) ៖ បច្ចុប្បន្នយើងមានគម្របព្រៃឈើ៥៩,១៥%រួចហើយ យើងនឹងបន្តធ្វើការ ដាំដុះព្រៃឈើនៅគ្រប់ទីកន្លែងទៀត ។ ដូចនេះគម្របព្រៃឈើរបស់យើងនឹងកើនដល់៦០%នៅឆ្នាំ២០១៥ ។

**សំនួរទូទៅពាក់ព័ន្ធនឹងកម្មវិធីព្រៃឈើជាតិ បន្ទាប់ពីបទបង្ហាញកម្មវិធីទាំង៦ បានបញ្ចប់៖**

*សំនួរទី ១* ( លោក **ហ៊ុល សឿង** មេឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ ) ៖ តើយើងត្រូវការពេលវេលាប៉ុន្មានសម្រាប់ការអនុវត្តន៍កម្មវិធីនេះ? នៅក្នុងការអនុវត្តន៍កម្មវិធី តើនៅមានការរាំងស្ទះនៅចំណុចណា ហើយគួរដោះស្រាយដូចម្តេច?

*ចម្លើយទី ១* ( លោក **សួន សុវណ្ណ** ) ៖ នេះមិនមែនតែជាការងាររបស់រដ្ឋបាលព្រៃឈើតែម្នាក់ឯងទេ វាជាការទទួលខុសត្រូវរបស់យើងទាំងអស់គ្នា ។

*សំនួរទី ២* ( កសិករ មកពី ខេត្តកំពង់ចាម ) ៖ យើងបានផ្តល់ដីឱ្យក្រុមហ៊ុនអស់ហើយ តើប៉ះពាល់ដល់ការអភិរក្សដែរឬទេ? កសិករត្រូវការលែងសត្វពាហនៈនៅលើដីវេចរិល តែរដ្ឋាភិបាលប្រគល់ដីនេះទៅឱ្យក្រុមហ៊ុនអស់ហើយសម្រាប់ជាដីសម្បទានសេដ្ឋកិច្ច ។ តើនេះជាការប៉ះពាល់ឬទេ? ហើយតើកូនចៅជំនាន់ក្រោយបានអ្វី?

*ចម្លើយទី ២* ( លោក **ប៉ក់ ជាលី** ) ៖ រាជរដ្ឋាភិបាលមានគោលការណ៍អភិវឌ្ឍន៍ប្រទេសជាតិ បើយើងទុកដីសម្រាប់តែ ការលែងគោ នោះវានឹងមិនមានការអភិវឌ្ឍន៍ឡើយ ។ តែបើយើងយកដីនេះទៅដាំដុះព្រៃឈើ ឬធ្វើជាដីសម្បទានសេដ្ឋកិច្ចវាប្រសើរជាង ។ ម្យ៉ាងទៀត មុននឹងរដ្ឋាភិបាលប្រគល់ដីឱ្យក្រុមហ៊ុន តែងតែមានការវាយតម្លៃប្រសិទ្ធភាពសេដ្ឋកិច្ចជាមុន បន្ទាប់មកយើងនឹងពិចារណារកភាពចំណេញ សម្រាប់ការអភិវឌ្ឍន៍ប្រទេសជាតិ ។

*សំនួរទី ៣* (លោក **ឡុង យិន** តំណាងសហគមន៍ស្រុកឆ្លូង ខេត្តក្រចេះ) ការផ្តល់សិទ្ធទៅឱ្យក្រុមហ៊ុនឯកជន ទទួលបានការចាប់អារម្មណ៍ពីរដ្ឋ ហើយការផ្តល់សិទ្ធនេះមានល្បឿនលឿន តែបើប្រជាជនសុំបង្កើតព្រៃសហគមន៍ បែរជាមានល្បឿនយឺតទៅវិញ។ តើហេតុអ្វី? តើការផ្តល់សម្បទានដីព្រៃឱ្យក្រុមហ៊ុនឯកជន និងផ្តល់ដីព្រៃឱ្យប្រជាជនប្រើប្រាស់ មួយណាសំខាន់ជាង?

*ចម្លើយទី ៣* (លោក **អួន សំអុល**): កន្លងមកសហគមន៍មិនដែលស្នើសុំដីព្រៃសម្រាប់ធ្វើសហគមន៍ទេ។ ពេលមានក្រុមហ៊ុនមកវិនិយោគ រដ្ឋក៏បានប្រគល់ដីឱ្យក្រុមហ៊ុនដើម្បីដាំដុះ និងបែងចែកផលប្រយោជន៍។ ដូចនេះសហគមន៍ គួរស្នើរសុំដីឱ្យបានមុនក្រុមហ៊ុន។

*សំនួរទី ៤* (លោក **ហួត វុទ្ធី** តំណាងអង្គការ DPA ខេត្តស្ទឹងត្រែង): ពីមុនការបង្កើតសហគមន៍ព្រៃឈើមានតែ ៨ជំហាន តែឥឡូវមាន១២ជំហាន។ តើហេតុអ្វី?

*ចម្លើយទី ៤* (លោក **ឡាវ សេដ្ឋាផល**): ជំហានសម្រាប់ការបង្កើតសហគមន៍ថ្មីទាំង១២នេះ គឺចេញពីជំហានចាស់ទាំង៨មុន។ យើងគ្រាន់តែបំបែកដើម្បីឱ្យងាយស្រួលក្នុងការអនុវត្តន៍ និងបង្កើនជីវភាពសហគមន៍តែប៉ុណ្ណោះ។

*សំនួរទី ៥* (អ្នកស្រី **ម៉ុំ សាតីន** បណ្តាញ CPN ខេត្តក្រចេះ): ការអនុវត្តន៍កម្មវិធីមានរយៈពេល ២០ឆ្នាំ តែការពិគ្រោះយោបល់មានតែ២ថ្ងៃប៉ុណ្ណោះ។ ដូចនេះសូមឱ្យកម្មវិធីទាំង៦ ធ្វើការផ្ទៀងផ្ទាត់យ៉ាងណា ដើម្បីធានាដល់ការប្រើប្រាស់ព្រៃឈើរបស់សហគមនផង៏។

*ចម្លើយទី ៥*: នេះជាការដឹងទុក្ខកង្វល់របស់យើង ចំពោះសហគមន៍ ដែលទើបនាំឱ្យមានសិក្ខសាលាថ្ងៃនេះ។ ដូចនេះសូមបងប្អូន បញ្ចេញយោបល់ក្នុងការពិភាក្សា ដើម្បីឱ្យយើងដាក់បញ្ចូលបញ្ហាទាំងនេះ ក្នុងកម្មវិធីព្រៃឈើជាតិ។

# សំនួរ ចម្លើយ ពីលទ្ធផលពិភាក្សាតាមក្រុម

## ● ក្រុម១: ការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍

*សំនួរ* ( លោក **ឡុង ប៊ុង** មន្ត្រីសម្របសម្រួលក្រុមពិភាក្សា): តើក្រុមការពារបង្គោលព្រំយ៉ាងដូចម្តេច?

*ចម្លើយ* ( អ្នកស្រី **កែវ ស៊ីយ៉ា** មកពីសហគមន៍ស្រុកស្នួល ខេត្តក្រចេះ): យើងនឹងសហការគ្នាយាមល្បាត ជាប្រចាំ ដើម្បីការពារបង្គោលព្រំ។

## ● ក្រុម២: ការគ្រប់គ្រងធនធានព្រៃឈើ និងការអភិរក្ស

ពុំមានសំនួរទេ បន្ទាប់ពីបទបងាញ។

## ● ក្រុម៣: ពង្រឹងការអនុវត្តន៍ច្បាប់ និងអភិបាលកិច្ច

ពុំមានសំនួរទេ បន្ទាប់ពីបទបងាញ។

## ● ក្រុម៤: សហគមន៍ព្រៃឈើ

*សំនួរ* ( លោកស្រី **មុំ សាគីន** តំណាងបណ្តាញ CPN ខេត្តក្រចេះ): នៅក្នុងច្បាប់ស្តីពីព្រៃឈើ មានការ ដាក់ ទោសទ័ណ្ឌដល់ជនប្រព្រឹត្តល្មើសច្បាប់ តែយើងឃើញមានការដឹកជញ្ជូនឈើយ៉ាងច្រើននៅមូលដ្ឋាន តើគួរមាន ការដាក់ទោសទ័ណ្ឌយ៉ាងណាដែរ?

*ចម្លើយ* ( លោក **សួន សុវណ្ណ**): នៅក្នុងច្បាប់ស្តីពីព្រៃឈើ មានការដាក់ទោសទ័ណ្ឌដល់មន្ត្រី ដែលប្រព្រឹត្ត ខុស តែនេះជារឿងបុគ្គលតែប៉ុណ្ណោះ។

● **ក្រុម៥: ការកសាងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្ស**

ពុំមានសំនួរទេ បន្ទាប់ពីបទបងាញ។

● **ក្រុម៦: ឯកសារគោលកម្មវិធិព្រៃឈើជាតិ**

*សំនួរ*: គួរដាក់បញ្ចូលការបញ្ជ្រាបយេនឌ័រទៅក្នុងកម្មវិធីណាមួយនៃកម្មវិធីព្រៃឈើជាតិ។

*ចម្លើយ* (លោកបណ្ឌិត **សុខ ហេង**): យើងមានកម្មវិធីយេនឌ័រនៅក្នុងកម្មវិធីទី៣រួចហើយ។

# កម្មវិធីទី ១៖

# ការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍

ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៩

ខេត្ត ក្រចេះ

# ១) តើអ្នកយល់ដូចម្តេចចំពោះកម្មវិធីការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និងការចុះបញ្ជិកា សម្បត្តិព្រៃឈើអចិន្ត្រៃយ៍? គួរបន្ថែមអនុកម្មវិធីអ្វីទៀត?

❖ សារៈសំខាន់របស់កម្មវិធី

- ងាយស្រួលដោះស្រាយទំនាស់
- ងាយស្រួលក្នុងការប្រើប្រាស់ផល-អនុផលព្រៃឈើ
- ទប់ស្កាត់បទល្មើសព្រៃឈើ
- បង្កើតទំនាក់ទំនងល្អរវាងអាជ្ញាធរដែនដី និងមន្ត្រីជំនាញ
- ដឹងពីព្រំប្រទល់របស់សហគមន៍
- មានកម្មសិទ្ធស្របច្បាប់

- គ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព
- ធ្វើផែនទីប្រើប្រាស់ដី និង ដីព្រៃ
- រួមចំណែកក្នុងការអភិវឌ្ឍន៍តាមរយៈការគ្រប់គ្រងធនធានធម្មជាតិ
- ទទួលស្គាល់ដីព្រៃឈើ ដីមិនមែនព្រៃឈើ និង ដីស្រែចំការ
- ងាយស្រួលបែងចែកផល-អនុផលព្រៃឈើ
- មានការបែងចែកព្រំប្រទល់ដីស្រែចំការ លំនៅដ្ឋាន ដីព្រៃឈើ ក្រុមហ៊ុន និងដីសហគមន៍
- ងាយស្រួលក្នុងការស្រាវជ្រាវពីធនធានធម្មជាតិនៅក្នុងព្រៃ

- ស្របតាមច្បាប់ភូមិបាល និងអនុក្រិត្យលេខ ៥៣
- កាត់បន្ថយការទន្ទ្រានដីព្រៃឈើ
- សម្គាល់កម្មសិទសហគមន៍ដែលនៅជិតគ្នា
- ងាយស្រួលក្នុងការយល់ដឹងពីព្រៃត្រូវការពារ និងព្រៃដែលត្រូវអភិវឌ្ឍន៍
- ឆ្លើយតបទៅនឹងចក្ខុវិស័យរបស់កម្មវិធីព្រៃឈើជាតិ
- មិនមានភាពច្របូកច្របល់ក្នុងការអនុវត្ត
- មានសារៈសំខាន់សំរាប់ការការពារទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ

—សំណូមពរៈ

- ការផ្សព្វផ្សាយពីព្រៃឈើ និង ការផ្តល់ចំណេះដឹងជាសាធារណៈ
- ត្រូវមានការព្រមព្រាងពីប្រជាជនសហគមន៍
- បែងចែកដីព្រៃសង្គមកិច្ច និងសេដ្ឋកិច្ចឱ្យបានច្បាស់លាស់
- គួរអនុវត្តច្បាប់ផ្ដន្ទាទោសឱ្យបានម៉ឺងម៉ាត់
- ត្រូវមានការចូលរួមពីតំណាងអាជ្ញាធរមូលដ្ឋាន

# ២) បញ្ហាប្រឈម និង ដំណោះស្រាយ ក្នុងការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ?

បញ្ហាប្រឈម:

- លួចទាយបំផ្លាញបង្គោលព្រំ
- ខ្វះការចូលរួមពីប្រជាពលរដ្ឋក្នុងការថែរទាំបង្គោលព្រំ
- ខ្វះខាតមធ្យោបាយដឹកជញ្ជូនទៅតីតាំងដែលមានស្ថានភាពភូមិសាស្ត្រលំបាក (តំបន់ភ្នំ)
- មានការកាប់រានដីព្រៃថ្មីៗ
- ប៉ះពាក់ជាមួយប្រជាពលរដ្ឋដែលរុករានដីព្រៃធ្វើស្រែចំការ និងលំនៅដ្ឋាន
- មិនមានការផ្សព្វផ្សាយពីសារៈសំខាន់ និងការកំណត់ព្រំប្រទល់ដល់សហគមន៍
- មានទំនាស់រវាងសហគមន៍មួយ និងសហគមន៍មួយទៀត

- មានការគំរាមពីប្រជាជនដែលនៅក្បែរតំបន់កំណត់ព្រំប្រទល់
- ចំណេះដឹងរបស់ប្រជាពលរដ្ឋនៅក្បែរតំបន់ព្រៃនៅមានកំរិត
- មានការប៉ះពាល់ដល់ការដកហូតយកផល-អនុផលព្រៃឈើដែលគាត់ធ្លាប់អាស្រ័យលើ
- កើតមានទំនាស់រវាងម្ចាស់កម្មសិទដែលមានព្រំប្រទល់ជាប់គ្នា
- ហ៊ុំព័ទដីស្រែចំការរបស់ប្រជាពលរដ្ឋដែលកំពុងប្រើប្រាស់
- មានការកាប់រានដីព្រៃដោយខុសច្បាប់
- មានក្រុមហ៊ុនឈ្មូសឆាយយកដីប្រជាពលរដ្ឋក្នុងសហគមន៍

- ចលនានៃការធ្វើពាណិជ្ជកម្មដីធ្លី
- ចំណាក-ចំណូលស្រុក និង ការគ្រប់គ្រងមិនបានច្បាស់លាស់
- មានការពង្រីកដីធ្វើស្រែចំការ
- ការចូលរួមពីប្រជាពលរដ្ឋមានកំរិត
- ការចូលរួមរបស់អាជ្ញាធរមូលដ្ឋានមួយចំនួននៅមានកំរិត

- អាជ្ញាធរមូលដ្ឋានមិនព្រមចូលរួមក្នុងការកំណត់ព្រំប្រទល់
- អាចប៉ះពាល់ជាមួយជនជាតិដើមភាគតិច
- បញ្ហានៅលើផែនទី និង ស្ថានភាពដីជាក់ស្តែង
- ប្រឈមជាមួយអ្នកមានអំណាចដែលមានដីក្នុងដែនព្រៃឈើ

# 🏆 ដំណោះស្រាយ:

- ត្រូវដោះស្រាយដោយយកច្បាប់ជាធំ ដោយទទួលផលប្រយោជន៍ស្មើភាព និងយុត្តិធម៌
- មន្ត្រីជំនាញគួរតែអនុវត្តឱ្យបានច្បាស់ ជាពិសេសធ្វើផែនការសកម្មភាព ដូចជាធ្វើសារពើភ័ណ្ឌនឹងផែនការប្រើប្រាស់ព្រៃឈើដោយមានការចូលរួម
- ផ្សព្វផ្សាយច្បាប់ព្រៃឈើ បច្ចេកទេស និងបទដ្ឋានផ្សេងៗ ដែលពាក់ព័ន្ធពីព្រៃឈើដល់ប្រជាជនឱ្យបានយល់ទូលំទូលាយ និងជាសាធារណៈ
- ដោះស្រាយគោលនយោបាយ
- តាមដានត្រួតពិនិត្យ តើគ្រួសារដែលកាប់រានថ្មីនោះគាត់មានដីហើយ រឺនៅ? បើគ្មានគួរតែដោះស្រាយ រកដីជូនគាត់

- មានការចូលរួមពីអាជ្ញាធរមូលដ្ឋាន  អង្គការពាក់ព័ន្ធ ប្រជាពលរដ្ឋត្រូវចូលរួមឱ្យបាន  ច្រើន
- ការចូលរួមត្រូវមានឆន្ទៈ
- ឯកភាពពីប្រជាពលរដ្ឋ
- អនុវត្តច្បាប់ព្រៃឈើឱ្យបានតឹងរឹងចំពោះអ្នកប្រព្រឹត្តបទល្មើស
- ត្រូវរៀបចំបង្កើតផែនទីឱ្យបានរហ័ស
- ធ្វើការសម្របសម្រួលគ្រប់ភាគីពាក់ព័ន្ធ

- ចុះទប់ស្កាត់ឱ្យបានទាន់ពេលវេលាចំពោះការកាប់រានដីព្រៃឈើដោយខុសច្បាប់ និង ធ្វើការអប់រំដល់ពួកគាត់
- ពេលចុះកំណត់ព្រំប្រទល់ ត្រូវឱ្យមានការចូលរួមគ្រប់ភាគីពាក់ព័ន្ធទាំងអស់

## ៣) តើត្រូវធ្វើដូចម្តេច ដើម្បីបង្កើនការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ សម្រេចបានឆាប់រហ័ស ?

- ត្រូវមានការផ្សព្វផ្សាយពីសារៈសំខាន់នៃការបោះព្រំ
- ឧបករណ៍មធ្យោបាយ ថវិកាឱ្យបានគ្រប់គ្រាន់
- មានការឯកភាពគ្នា
- សហការណ៍ និងទំនាក់ទំនងល្អជាមួយអ្នកពាក់ព័ន
- សិក្សាពីផលប៉ះពាល់ជាមុន
- មានធនធានមនុស្ស និងសមត្ថភាពជំនាញ

- មានការចូលរួមពីចាស់ស្រុកនៅក្នុងភូមិ
- ផែនការសកម្មភាពការងារជាក់លាក់
- មានឆន្ទៈក្នុងការចូលរួម

## ៤) តើអាជ្ញាធរដែនដី សហគមន៍ និងប្រជាពលរដ្ឋមូលដ្ឋាន ចូលរួមដូចម្តេច នៅក្នុងការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើ អចិន្ត្រៃយ៍ ?

- គ្រប់ភាគីពាក់ព័ន្ធត្រូវមានឆន្ទៈខ្ពស់ក្នុងការចូលរួម
- គោរពពេលវេលា
- អាជ្ញាធរ ស្ថាប័នពាក់ព័ន្ធ ត្រូវចូលរួមដឹងឮ ទទួលស្គាល់ការផ្តល់យោបល់
- សហគមន៍ត្រូវចូលរួមក្នុងការចង្អុលបង្ហាញ និងកំណត់ទីតាំង ពេលវេលា កំលាំង ពលកម្ម
- ត្រូវចូលរួមទប់ស្កាត់ជំលោះដីធ្លីក្នុងមូលដ្ឋាន
- ស្រុក ឃុំ ភូមិ សហគមន៍ និងប្រជាពលរដ្ឋ ចុះជួបជាមួយគ្នាដល់ទីកន្លែង

- ចូលរួមទទួលខុសត្រូវ និងធ្វើឯកសារក្នុងការកំណត់ទីតាំង
- រក្សាចំនុចដែលត្រូវបោះបង្គោល
- អាជ្ញាធរត្រូវបង្កលក្ខណៈងាយស្រួលដល់មន្ត្រីរដ្ឋបាលព្រៃឈើក្នុងការបោះសបង្គោលព្រំ
- ត្រូវចូលរួមសិក្សាវាយតម្លៃ ចន្ទុលបង្ហាញព្រំប្រទល់
- ចូលរួមធ្វើសេចក្តីសំរេចចិត្ត
- ចូលរួមក្នុងការដោះស្រាយទំនាស់

# ៥)  តើត្រូវមានស្ថាប័នពាក់ព័ន្ធអ្វីខ្លះ ចូលរួមក្នុងការចាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍  ?

- អាជ្ញាធរដែនដីមូលដ្ឋាន
- មន្ទីរកសិកម្ម
- សុរិយោដី
- កងកម្លាំងប្រដាប់អាវុធ
- ចាស់ទុំក្នុងភូមិ
- សហគមន៍
- រដ្ឋបាលព្រៃឈើ
- បរិស្ថាន

- អង្គការ NGOs (ម្ចាស់ជំនួយ)
- មន្ទីរទេសចរណ៍(ស្រាវជ្រាវកន្លែងទេសចរណ៍)
- មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល

## ៦) បន្ទាប់ពីបានការកំណត់ព្រំព្រមលំរួច តើអាជ្ញាធរដែនដី សហគមន៍ និងប្រជាពលរដ្ឋមូលដ្ឋាន ចូលរួមដូចម្តេចក្នុង ការថែរក្សា ?

- សហការរួមកំលាំងគ្នា ទប់ស្កាត់រាល់បទល្មើស
- យកព័ត៌មានប្រមូលភស្តុតាង រាយការណ៍ទៅអាជ្ញាធរ និងស្ថាប័នពាក់ព័ន
- ធ្វើផែនការការពារ
- ទប់ស្កាត់ភ្លើងឆេះព្រៃ
- យាមល្បាតជាប្រចាំ
- រាយការណ៍ពីសកម្មភាពដែលកើតមាន

- ផ្តល់ព័ត៌មានអំពីការរំលោភបំពានព្រំដីព្រៃ
- បំផុសឱ្យប្រជាជនយល់ដឹងពីសារៈសំខាន់ពីការបោះបង្គោលព្រំ
- ទប់ស្កាត់បទល្មើស
- ការពារមិនឱ្យជនទាយបំបាក់បង្គោល

# ការពិភាក្សាពិគ្រោះយោបល់

## កម្មវិធីទី ២:

## ការគ្រប់គ្រងធនធានព្រៃឈើជាតិ

## និងការអភិរក្សជីវចម្រុះ

ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៩

ខេត្ត ក្រចេះ

# ការងារពិភាក្សាពិគ្រោះយោបល់

- សមាជិកចូលរួម មាន ១៧ រូប រួមមានៈ ព្រះសង្ឃ រដ្ឋបាលព្រៃឈើ អាជ្ញាធរដែនដីភូមិ ឃុំ ស្រុក តំណាងសហគមន៍ និងសង្គមស៊ីវិល
- ពិភាក្សាលើអនុកម្មវិធីចំនួន ០៨
- វិធីសាស្រ្តពិភាក្សាមានផ្តល់សំណួរបំផុសគំនិតទាក់ទងនឹងអនុកម្មវិធីនីមួយៗ សមាជិក សមាជិកាក្រុមពិភាក្សាបញ្ចេញយោបល់ដោយការសរសេរ និងផ្ទាល់មាត់ អ្នកសម្របសម្រួល សរុបមតិយោបល់ជូនក្រុមពិភាក្សា និងមានការឯកភាពលើមតិយោបល់របស់ក្រុមពិភាក្សា
- ការពិភាក្សាតាមអនុកម្មវិធីនិមួយៗ
- អ្នកបច្ចេកទេស បានធ្វើការសម្របសម្រួលនិងកត់ត្រាមតិយោបល់ការពិភាក្សា និងរៀបចំ បទបង្ហាញលទ្ធផលរបស់ក្រុមពិភាក្សា

# អនុកម្មវិធីទី១ ៈ ការរៀបចំផែនការគ្រប់គ្រងព្រៃឈើជាតិ

- ការរៀបចំផែនការគ្រប់គ្រងព្រៃឈើជាតិ ត្រូវផ្តោតសំខាន់ទៅលើការគ្រប់គ្រងព្រៃឈើជាតិ និង ផលប្រយោជន៍ប្រជាពលរដ្ឋ ហើយមានរយៈពេល ១០-១៥ ឆ្នាំ
- ដើម្បីឱ្យផែនការនេះមានប្រសិទ្ធិភាពក្នុងការអនុវត្ត គួររៀបចំផែនការមេឱ្យបានច្បាស់ អនុវត្តទៅតាមផែនការ ដែលបានគ្រោងទុក
 រៀបចំគំរោងចំណាយថវិកាឱ្យបានច្បាស់ដើម្បីកុំឱ្យផែនការអាក់ខាននិងមិនបានសំរេចទៅ តាមគោលដៅ
 រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនិងពង្រឹងរចនាសម្ព័ន្ធ ត្រួតពិនិត្យតាមដានព្រៃឈើ បង្ហាត់បង្រៀន ប្រជាពលរដ្ឋឱ្យយល់ច្បាស់ពីកម្មវិធីគ្រប់គ្រងព្រៃឈើជាតិ មានសហការនិងចូលរួមជាមួយអ្នកពាក់ព័ន្ធក្នុង និង ក្រៅស្រុក ធនធានមនុស្សនិងថវិកា បញ្ចូលបន្ថែមការថែរក្សាអត្តសញ្ញាណកម្មព្រៃឈើ
- ការរៀបចំផែនការនេះ ផ្តួចផ្តើមដោយរដ្ឋបាលព្រៃឈើ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធដូចជាៈ កសិកម្ម ស្វូរិយោដី បរិស្ថាន ឧស្សាហកម្ម មហាផ្ទៃ សេដ្ឋកិច្ចហិរញ្ញវត្ថុ អភិវឌ្ឍន៍ជនបទ យុត្តិធម៌ ព្រះសង្ឃ អាជ្ញាធរដែនដី សហគមន៍មូលដ្ឋាន វិស័យឯកជន និងសង្គមស៊ីវិល។

# អនុកម្មវិធីទី២ : សារពើភ័ណ្ឌព្រៃឈើជាតិ

## ២.១ : សារពើភ័ណ្ឌព្រៃឈើជាតិ

- **ផលប្រយោជន៍នៃសារពើភ័ណ្ឌព្រៃឈើជាតិ:**

- ដឹងពីប្រភេទ ចំនួនដើមឈើ អង្កត់ផ្ចិត កំពស់ អាយុ និងគុណភាព ដើម្បីងាយស្រួលក្នុងការដកហូត និងរៀបចំផែនការគ្រប់គ្រង
- អាចធ្វើការវាយតម្លៃសេដ្ឋកិច្ចចំពោះធនធានព្រៃឈើ
- សំរួលជីវភាពប្រជាជនមូលដ្ឋាន និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ
- ជួយដល់បរិស្ថាន ជាជម្រកសត្វព្រៃ សង្គមជាតិយើង
- អភិរក្ស អភិវឌ្ឍន៍ តាមដាន និងការអនុវត្ត។

- **ភាពសមស្របក្នុងការធ្វើសារពើភ័ណ្ឌព្រៃឈើជាតិ ៥ឆ្នាំម្តង** ដោយប្រមូលទិន្នន័យ:
- ចំនួនភាគរយរស់ ដាំព្រៃធម្មជាតិ និងប្រភេទព្រៃផ្សេងទៀត
- អាយុ គុណភាព ទិន្នន័យដើមឈើដកហូត
- កំនើន ឬការបាត់បង់
- ប្រភេទថ្មីដែលទើបរកឃើញ (ត្រូវដាក់ឈ្មោះខ្មែរ អង់គ្លេស និងវិទ្យាសាស្ត្រ)
- ប្រព័ន្ធអេកូឡូស៊ី សត្វ និងបរិស្ថាន
- ផ្ទៃដីស្រែចំការ ព្រៃរិចរិល និងព្រៃបម្រុងទុកអចិន្ត្រៃយ៍

- **ដើម្បីឱ្យការធ្វើសារពើភ័ណ្ឌព្រៃឈើជាតិទទួលបានលទ្ធផលល្អប្រសើរ** យើងត្រូវមានៈ
- វគ្គបណ្តុះបណ្តាលសារពើភ័ណ្ឌដលមន្ត្រីរដ្ឋបាលព្រៃឈើ និងអ្នកពាក់ព័ន្ធ ព្រមទាំងអនុវត្តផ្ទាល់នៅវគ្គបណ្តុះបណ្តាល
- យន្តការបង្កើតនិងពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងឱ្យរឹងមាំ

## ២.២ : ទម្រង់តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៍ស្តីពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព

- **វិធីសាស្ត្រត្រួតពិនិត្យវាយតម្លៃនិងរបាយការណ៍រួមមានៈ**

- ត្រួតពិនិត្យទៅលើចំនួនព្រៃឈើ ទំហំដីព្រៃ គុណភាពព្រៃឈើ
- មានការតាមដានត្រួតពិនិត្យការគ្រប់គ្រងព្រៃឈើ
- ប្រមូលទិន្នន័យឱ្យបានច្បាស់លាស់រាល់គ្រប់របាយការណ៍
- បង្កើតឱ្យមានទំនុកចិត្ត និងលើកទឹកចិត្តដល់ប្រជាជន
- បង្ហាញពីផលប្រយោជន៍របស់ព្រៃឈើ
- ចុះផ្ទៀងផ្ទាត់ជាក់ស្តែងបន្ទាប់ពីរាយការណ៍ និងធ្វើការវិភាគទិន្នន័យ ព្រមទាំងស្វែងរកដំណោះស្រាយលើព្រៃឈើដែលបានបាត់បង់ ឬកំណើនព្រៃឈើមានការលូតលាស់ឃើត
- សិក្សាពីសកម្មភាពរបស់ប្រជាជន និងសុំមតិយោបល់
- ចុះបង្ហាត់បង្រៀនប្រជាពលរដ្ឋឱ្យជួយថែរក្សាព្រៃឈើ
- បង្កើតសហគមន៍ព្រៃឈើដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន។

- **ប្រភពទិន្នន័យដែលអាចយកមកធ្វើការតាមដាន ពិនិត្យ វាយតម្លៃ និងធ្វើរបាយការណ៍រួមមាន:**

- ប្រមូល ត្រួតពិនិត្យ តាមដានទិន្នន័យឱ្យបានច្បាស់លាស់ពីចំនួនព្រៃឈើ ទំហំផ្ទៃដី ប្រភេទឈើ ជីវចំរុះព្រៃដាំ ព្រៃសហគមន៍ ធនធានដី ផលអនុផលព្រៃឈើ និងសត្វព្រៃ
- វាយការណ៍ឱ្យបានជាក់លាក់
- ទិន្នន័យផ្ទៃដីធនធានព្រៃឈើជាក់ស្តែង
- ទិន្នន័យសារពើភ័ណ្ឌ ទិន្នន័យព្រៃសារពើភ័ណ្ឌ ទិន្នន័យព្រៃទើបដាំ

- **ប្រសិទ្ធិភាពនៃការតាមដាន ពិនិត្យ វាយតម្លៃ និងរបាយការណ៍**

- ស្ថាប័នពាក់ព័ន្ធ និងសហគមន៍មូលដ្ឋានចូលរួម
- បណ្តុះស្មារតីឱ្យមានការចូលរួម
- បញ្ចេញមតិរាល់អង្គប្រជុំ និងការពិភាក្សា
- បង្កើតក្រុមដើរល្បាត ដើម្បីត្រួតពិនិត្យការគ្រប់គ្រងព្រៃឈើ
- ប្រើពាក្យសាមញ្ញ និងបំផុសសំណួរដល់អ្នកចូលរួម

# អនុកម្មវិធីទី៣ ៖ ការអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងព្រៃបម្រុងទុកអចិន្ត្រៃយ៍ក្រៅពីព្រៃសហគមន៍

- **ប្រព័ន្ធគ្រប់គ្រងមានសារៈប្រយោជន៍ រួមមានៈ** សេដ្ឋកិច្ច បង្កើនទេសចរណ៍ធម្មជាតិ កាត់បន្ថយភាពក្រីក្រ កាត់បន្ថយបទល្មើសព្រៃឈើ បង្កើនគម្របព្រៃឈើ អភិវឌ្ឍន៍សង្គម សហគមន៍រីកចំរើន បង្កើនជីវភាពប្រជាជន ជម្រកសត្វព្រៃ ការប្រើប្រាស់ឈើតាមបទដ្ឋានច្បាប់ និងអភិវឌ្ឍន៍ព្រៃឈើប្រកបដោយនិរន្តរភាព។
- **វិធីសាស្ត្រក្នុងការអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រង រួមមានៈ**

- ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមឱ្យមានលក្ខណៈសុក្រឹត យុត្តិធម៌ចំពោះការកែប្រែដីព្រៃឈើជាដីសម្បទានក្នុងគោលបំណងអភិវឌ្ឍន៍ផ្សេងៗ

- គួរតែធ្វើសារពើភ័ណ្ឌកំណត់ធនធានព្រៃឈើមុននឹងផ្តល់ដីសម្បទាន និងមិនយកដីពីតំបន់ជិតខាងចូលក្នុងដីតំបន់សម្បទាន ព្រមទាំងជម្រុញម្ចាស់ដីសម្បទានអនុវត្តឱ្យបានត្រឹមត្រូវ

- ត្រូវសហការការពារ និងដាំឈើឡើងវិញ

- ត្រូវមានការបែងចែកផលចំណូលព្រៃឈើឱ្យបានច្បាស់លាស់ និងផ្តល់ឱកាសជូនប្រជាជនបានប្រើប្រាស់ខ្លះ

- ពង្រឹងប្រព័ន្ធច្បាប់ និងមានវិធានការទប់ស្កាត់រាល់បញ្ហាដែលកើតមានឡើង

- ពង្រឹងប្រព័ន្ធគ្រប់គ្រងដីសម្បទាន។

- **ដើម្បីទទួលបានប្រសិទ្ធិភាពនៃប្រព័ន្ធគ្រប់គ្រង យើងគួរអនុវត្តដូចខាងក្រោម:**

- គ្រប់អាជ្ញាធរមូលដ្ឋានត្រូវតែគិតគូរពីផលប្រយោជន៍របស់ប្រជាជនដោយមិនរើសអើង
- ត្រូវបង្កើតកម្មវិធីគាំទ្រជីវភាពប្រជាជន
- កាត់បន្ថយដីសម្បទាន បង្កើតជាតំបន់ទេសចរណ៍ធម្មជាតិ។

# អន្តរកម្មវិធីទី៤ ៖ ការអភិរក្សធនធានសេនេទិច និងបង្កើតប្រភពគ្រាប់ពូជសម្រាប់កម្មវិធីដាំឈើ

- **ជម្រុញ ពង្រឹង និងលើកទឹកចិត្តការអភិរក្សធនធានសេនេទិចព្រៃឈើរួមមាន ៖**

- បង្កើតចំការពូជឱ្យបានច្រើនកន្លែង
- ធ្វើការប្រមូលពូជឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ព្រមទាំងជ្រើសរើសពូជល្អៗសំរាប់បង្កើតចំការដាំ
- លើកទឹកចិត្តប្រជាជនដាំដើមឈើ បង្កើតសហគមន៍ភូមិឱ្យមានការចូលរួមពិភាក្សា
- ផ្សព្វផ្សាយ និងបណ្តុះស្មារតីប្រជាជនមូលដ្ឋានឱ្យយល់ច្បាស់ពីតម្លៃព្រៃឈើ ធនធានសេនេទិច និងផលដែលទទួលបានពីការអភិរក្សធនធានសេនេទិច
- លុបបំបាត់ការបំផ្លាញព្រៃឈើ និងការរុករានដីព្រៃឈើធ្វើជាកម្មសិទ្ធិ
- អភិរក្សព្រៃឈើធម្មជាតិ និងសហគមន៍ចូលរួមជួយអភិរក្ស និងមានសិទ្ធិអាចទាញយកផលប្រើប្រាស់ជាលក្ខណៈគ្រួសារ

- **ស្ថាប័នចូលរួម:**

- រដ្ឋបាលព្រៃឈើ
- ក្រសួងបរិស្ថាន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងអភិវឌ្ឍន៍ជនបទ
- កងកំលាំងប្រដាប់អាវុធ
- អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់
- សហគមន៍មូលដ្ឋាន
- ដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ
- វិស័យឯកជន
- សង្គមស៊ីវិល និង
- ព្រះសង្ឃ។

- **ផលប្រយោជន៍ទទួលបានពីការអភិរក្សធនធានសេនេទិចព្រៃឈើ** ដូចខាងក្រោម:

- រក្សាមិនឱ្យមានការវិនាសហិនហោចប្រភេទព្រៃឈើ និងទទួលបានផលប្រយោជន៍ដល់មនុស្សជំនាន់ក្រោយ
- សំបូរធនធាន និងរក្សាពូជឈើល្អៗ
- អភិរក្សប្រភេទឈើជិតផុតពូជ
- រក្សាបានតម្លៃសេដ្ឋកិច្ចរបស់សហគមន៍ និងជាតិ
- រក្សាលំនឹងបរិស្ថាន គ្មានភាពរាំងស្ងួត ទឹកជំនន់
- មានតម្លៃខ្ពស់សំរាប់នាំចេញទៅក្រៅប្រទេស និងជាកិត្តិយលប្រទេសជាតិ
- កាត់បន្ថយភាពក្រីក្រ

# អនុកម្មវិធីទី៥ : អភិវឌ្ឍពហុចំការដាំឈើ

- **ប្រភេទឈើសំរាប់ដាំជាចំការប្រើប្រាស់ច្រើនយ៉ាង** ដូចជា:

- បេង នាងនួន ធ្នង់ គ្រើល គគីរ ឈើទាល ស្រឡៅ ពពេល សុក្រំ ផ្ចឹក កកោះ ត្រសេក
- កៅស៊ូ កន្ទុំធេត អង្គាដី ខ្លឹមចន្ទន៍ អង្កាញ់ ម៉ៃសាក់ ប្រេងខ្យល់ អាកាស្យា ដើមគរ ខ្លុង ត្បែង
- ក្រូច ស្វាយចន្ទី អំពិលបារាំង ស្វាយ។

- **ការលើកទឹកចិត្តក្នុងការជម្រុញការបង្កើតចំការឈើប្រើប្រាស់ច្រើនយ៉ាង** រួមមាន:

- លើកទឹកចិត្តឱ្យដាំជាលក្ខណៈឯកជន ដោយផ្តល់ដីឱ្យឯកជនឬសហគន៍ចូលរួមដាំ និងការកាត់បន្ថយពន្ធឈើដាំរបស់សហគមន៍មូលដ្ឋាន
- ធ្វើការផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសដាំ និងគ្រប់គ្រងចំការព្រៃឈើដាំដល់សហគមន៍មូលដ្ឋាន
- ជួយស្វែងរកដៃគូអភិវឌ្ឍន៍ និងរកទីផ្សារ

- **ផលប្រយោជន៍នៃចំការឈើដាំប្រើប្រាស់ច្រើនយ៉ាង:**

- បង្កើនគំរបព្រៃ និងជម្រកសត្វព្រៃ
- បង្កឱ្យមានបរិស្ថានល្អ  ដីមានជីជាតិ
- ទទួលបានការប្រើប្រាស់ឈើសំណង់ និងអុសដុត ផ្សេងតាមរយៈការគ្រីមែក
- រក្សាលំនឹងបរិស្ថាន
- ជីធម្មជាតិ និងចំណីសត្វ
- ការពារការហូរច្រោះដី
- ទទួលបានប្រាក់កំរៃពីការចំការឈើដាំ
- កាត់បន្ថយការដកហូតផលពីព្រៃធម្មជាតិ

# អនុកម្មវិធីទី៦ ៖ ការអភិរក្សធនធានជីវៈចម្រុះ និងការអភិវឌ្ឍន៍ទេសចរណ៍

- **ការប្រឈម ចំពោះការអភិរក្សព្រៃឈើ សត្វព្រៃ និងជីវៈចំរុះ** រួមមានៈ

- ខ្វះធនធានព្រៃឈើដើម្បីចិញ្ចឹមជីវិត បង្កឱ្យមានការបរបាញ់ និងដាក់អន្ទាក់ចាប់សត្វ
- ការជួញដូរសត្វព្រៃ
- ការយល់ពីច្បាប់ និងការអនុវត្តនៅមានកំរិត
- ការរុករានដីព្រៃឈើ និង ការកាប់ឈើយ៉ាងអានាធិបតេយ្យ ប៉ះពាល់ដល់ជំរកសត្វព្រៃ
- មិនទាន់មានការចូលរួមរបស់សហគន៍ឱ្យបានទូលំទូលាយ
- ចំណេះដឹងរបស់សហកមន៍ និងការផ្សព្វផ្សាយអប់រំនៅមានកំរិតនៅតាមតំបន់
- ការចង់បានហួសប្រមាណ
- កត្តាសង្គម និងធម្មជាតិ
- ការបង្កដោយជនប្រដាប់អាវុធ និងអ្នកមានអំណាច

- **ជម្រុញ និងពង្រឹងប្រព័ន្ធគ្រប់គ្រង ការពារ អភិរក្សជីវចំរុះ និងទេសចរណ៍ធម្មជាតិឱ្យមាននិរន្តរភាព**

- ត្រូវមើលថែរក្សា ការពារគ្រប់រដូវកាល
- បង្កើតប្រព័ន្ធការពារ និងពង្រឹងការអនុវត្តន៍ច្បាប់ (ការដាក់ពន្ធនាគារ ឬការបង់ថវិកា)
- បង្កើតប្រព័ន្ធផ្សព្វផ្សាយច្បាប់ និងការគ្រប់គ្រងការពារជីវចំរុះ
- បង្កើនកំរិតជីវភាពរស់នៅរបស់ប្រជាជន
- កែច្នៃព្រៃឈើឱ្យមានសោភ័ណភាពល្អ និងត្រូវមានការកែលំអខ្លះៗត្រង់ចំនុចខ្វះខាត
- ចែកឱ្យដាច់ពីគ្នាចំពោះតំបន់សម្រាប់ការពារអភិរក្ស និងតំបន់អភិវឌ្ឍន៍
- បំផុស និងលើកទឹកចិត្តប្រជាជន
- បង្កើតកិច្ចប្រជុំពិភាក្សា និងពិគ្រោះយោបល់
- បង្កើនចំណេះដឹងដល់សហគមន៍មូលដ្ឋានលើការអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ

- **ផលប្រយោជន៍របស់សហគមន៍មូលដ្ឋានទទួលបានពីការការពារ អភិរក្សជីវៈចំរុះ និង ទេសចរណ៍ធម្មជាតិ:**

- ជីវភាពប្រជាជនបានប្រសើរឡើង គឺកាត់បន្ថយភាពក្រីក្រ
- រក្សាជីវចំរុះសម្រាប់កូនចៅជំនាន់ក្រោយ
- មានគម្របព្រៃធម្មជាតិ
- កន្លែងកំសាន្តផ្តល់បរិយាកាសបរិសុទ្ធ
- រកថវិកាបានច្រើន
- អភិវឌ្ឍន៍សហគមន៍មូលដ្ឋាន

# អនុកម្មវិធីទី៧ ៖ ការកែច្នៃផលិតផលឈើ និងទីផ្សារ

- **ពង្រឹងការកែច្នៃផលអនុផលព្រៃឈើ រួមមាន៖**

- ត្រូវបង្កើតរោងចក្រកែច្នៃផលអនុផលព្រៃឈើឱ្យបានច្រើន និងពង្រឹងការកែច្នៃផលអនុផលព្រៃឈើឱ្យមានស្តង់ដា ដើម្បីឱ្យទីផ្សារអាចទទួលយកបាន

- ត្រូវប្រមូលអនុផលឈើមកកែច្នៃ និងឈើដែលមិនមានទីផ្សារត្រូវកែច្នៃឱ្យមានទីផ្សារ ដូចជាដើមគរ

- ត្រូវបង្កើត ឬទាក់ទងអ្នកទិញទាំងក្នុងនិងក្រៅស្រុកឱ្យបានច្រើន ចៀសវាងការសល់ផលិតផលដែលបានកែច្នៃរួច

- បំផុសប្រជាជនឱ្យកែច្នៃផលអនុផលព្រៃឈើ ដូចជា ការធ្វើរូបផ្សោត រូបត្រី រូបក្រពើ រូបដំរី កញ្ជើ កន្ត្រក ចង្អេរ ល្អី ។ល។

- បើកវគ្គបណ្តុះបណ្តាលសហគមន៍ស្តីពីការកែច្នៃ

- ត្រូវមានកម្មករជំនាញ និងមានការសហការជាមួយស្ថាប័នពាក់ព័ន្ធ

- **ពង្រឹងផលិតផលកែច្នៃក្នុងស្រុកនិងរកទីផ្សារៈ**

- ពង្រឹងគុណភាព ហើយឱ្យរដ្ឋាភិបាលទាក់ទងឈ្មួញក្នុងនិងក្រៅស្រុក
- សហគមន៍ត្រូវសហការជាមួយរដ្ឋបាលព្រៃឈើ និងអង្គការនានា ដើម្បីលក់ផលិតផលដែលសហគមន៍បាន កែច្នៃ
- មិននាំចូលរបស់បរទេស (ករណីមិនចាំបាច់)
- របស់កែច្នៃត្រូវមានលក្ខណៈទាក់ទាញ ប្លែក ស្អាត មានគុណភាព និងតម្លៃសមរម្យ
- បង្កើតការផ្សព្វផ្សាយដើម្បីរកទីផ្សារលក់ផលិតផលតាមរយៈកាសែត ទូរទស្សន៍ផ្សេងៗ
- មានកម្មករជំនាញ និងពង្រឹងសមត្ថភាពប្រជាជនក្នុងសហគមន៍

- **ការកែច្នៃផលិតផលឈើដោយដៃ**

  **និងម៉ាស៊ីនស្វ័យប្រវត្តិផ្តល់សក្តានុពលដល់ការអភិវឌ្ឍផលិតផលឈើ:**

**ដោយដៃ**

- ការកែច្នៃដោយដៃរបស់អ្នកស្រុកផ្ទាល់ សម្រាប់ប្រើប្រាស់ក្នុងស្រុក
- ផលិតបានតិច និងចំណាយពេលវេលាច្រើន
- ការកែច្នៃផលិតផលនេះមិនសូវមានគុណភាព ប៉ុន្តែត្រូវបានគេនិយម
- បង្កើនគំនិតច្នៃប្រឌិតផលិតផលឈើ ដើម្បីឱ្យមានលក្ខណៈល្អប្រសើរជាងមុន

**ម៉ាស៊ីនស្វ័យប្រវត្តិ**

- ចំណាយពេលវេលាតិច ផលិតបានច្រើនអាចបំពេញតម្រូវការនាំចេញ
- ផលិតផលមានគុណភាព និងប្រើប្រាស់ឈើអស់លទ្ធភាព

# អនុកម្មវិធីទី៨ ៖ ការអភិវឌ្ឍន៍បច្ចេកវិជ្ជាឈើ និងការកែច្នៃ

- **អភិវឌ្ឍបច្ចេកវិជ្ជាឈើ និងការកែច្នៃឈើអាចផ្តល់ប្រយោជន៍ដល់សហគមន៍មូលដ្ឋាន ដែលគួរអភិវឌ្ឍ និងអភិវឌ្ឍន៍ សេដ្ឋកិច្ចជាតិ ៖**

- ផ្តល់ឱកាសឱ្យប្រជាជនមានការងារធ្វើ រកប្រាក់ចំណូល និងកាត់បន្ថយភាពក្រីក្រ
- រួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម
- ងាយស្រួលផលិត និងស្វែងរកទីផ្សារ
- ទទួលបានចំណេះដឹងស្តីពីបច្ចេកទេសកែច្នៃ

- **ដៃគូអភិវឌ្ឍបច្ចេកវិជ្ជាឈើ និងការកែច្នៃ:**

- សហគមន៍ព្រៃឈើ និងសហគមន៍មូលដ្ឋាន
- រដ្ឋបាលព្រៃឈើ
- អង្គការជាតិ និងអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ម្ចាស់រោងសិប្បកម្ម
- ក្រុមហ៊ុនឯកជន
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី
- មន្ទីរបរិស្ថាន
- មន្ទីរអភិវឌ្ឍន៍ជនបទ។

- **បញ្ហាប្រឈមក្នុងការអភិវឌ្ឍបច្ចេកវិជ្ជាឈើ និងការកែច្នៃ :**

- បច្ចេកទេស ធនធានមនុស្ស ថវិកា ទីផ្សារក្នុងនិងក្រៅស្រុក ការនាំចេញ ពន្ធនាំចេញ គុណភាព និង បរិមាណ
- សហគមន៍ខ្វះធនធានមនុស្ស
- សហគមន៍គ្មានបទពិសោធន៍ និងការអនុវត្តន៍
- គ្មានអ្នកជំនាញច្បាស់លាស់
- គ្មានទីផ្សារពិតប្រាកដ
- ច្បាប់គ្រប់គ្រងសិប្បកម្មនៅមានកំរិត
- ការកែច្នៃធ្វើតាមបែបប្រពៃណី និងមិនទាន់មានគំរូពិតប្រាកដ
- ការប្រកួតប្រជែងតម្លៃរវាងផលិតផលធ្វើដោយដៃ និងដោយមាស៊ីន
- គ្មានសម្ភារៈ ថវិកាគ្រប់គ្រាន់
- ខ្វះបច្ចេកទេស និងមិនទាន់មានការបណ្តុះបណ្តាលដល់សហគមន៍

# អរគុណចំពោះ

# ការយកចិត្តទុកដាក់ស្តាប់



# ក្រុមពិភាក្សាទី៣ៈ

# កម្មវិធីពង្រឹងការអនុវត្តច្បាប់

# ស្តីពីព្រៃឈើនិងអភិបាលកិច្ច

*សក្ខាសាលាពគ្រោះយោបលស្តពី កម្មវិធីព្រៃឈើជាតិ*

*ក្រចេះ, ថ្ងៃទី ២៥-២៦ ខែ មីនា ឆ្នាំ ២០០៩*

**តំណាងក្រុម ៖ លោក យុ ភាណវិមាន**

**អ្នកធ្វើបទបង្ហាញ ៖ លោក សែ សុភី**

**សមាជិក ២៧ នាក់**

# ១_សូមមានមតិយោបល់បន្ថែមលើអនុកម្មវិធីនាំងបី

**អនុកម្មវិធីទី១ : ការកែទំរង់ច្បាប់ និងរដ្ឋបាល**

- ការរៀបចំលិខិតបទដ្ឋាន : គួរមានការចូលរួមផ្តល់មតិយោបល់ពីភាគីពាក់ព័ន្ធ
- ការធ្វើឱ្យប្រសើរនូវរចនាសម្ព័ន្ធ : គួរធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធគ្រប់គ្រងឱ្យមានប្រសិទ្ធភាព (ឧ. ខណ្ឌរដ្ឋបាលព្រៃឈើខ្លះមានបីខេត្ត គួរសំរួលខណ្ឌមួយខេត្តមួយ)
- ធ្វើឱ្យប្រសើរសមត្ថភាពគ្រប់គ្រង និងដោះស្រាយទំនាស់ : គួរមានការបណ្តុះបណ្តាល ការផ្សព្វផ្សាយ សិក្ខាសាលា ការដោះស្រាយក្រៅ-ក្នុងប្រព័ន្ធតុលាការ

**អនុកម្មវិធីទី២: ការពង្រឹងការអនុវត្តច្បាប់ ការតាមដាននិងរាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើ**

- ស្នើប្តូរ " កិច្ចសហប្រតិបត្តិការជាមួយគណៈកម្មាធិការជាតិ អនុគណៈកម្មាធិការខេត្ត... " ទៅជា "ពង្រឹងតួនាទីជាលេខាប្រតិបត្តិក្នុងគណៈកម្មាធិការជាតិ អនុគណៈកម្មាធិការខេត្ត"

## ២.តើភាគីពាក់ព័ន្ធណាខ្លះដែលគួរចូលរួមក្នុងការពង្រឹងការអនុវត្តច្បាប់ និងអភិបាលកិច្ច ហើយមានតួនាទីអ្វីខ្លះ?

- ស្ថាប័នតុលាការ:

  - បើកសវនាការសំណុំរឿងបទល្មើសព្រៃឈើឱ្យទាន់ពេលវេលា

  - ព្រះរាជអាជ្ញាសហការល្អក្នុងការស្រាវជ្រាវ ទប់ស្កាត់ និង បង្រ្កាបបទល្មើសព្រៃឈើគ្រប់ប្រភេទ (ឧ. ការចេញដីកា)

  - ចូលរួមប្រជុំ សិក្ខាសាលា ការពិគ្រោះយោបល់ពាក់ព័ន្ធនឹងវិស័យព្រៃឈើ

- គណៈមេធាវី ៈផ្តល់មេធាវីការពារក្តីបទល្មើសព្រៃឈើដោយមិនគិតកំរៃសេវាកម្ម
- អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ៈ

- បញ្ឈប់ការបញ្ជាក់លើលិខិតទិញ-លក់ ការកាន់កាប់ ការតាំងទីលំនៅលើដីព្រៃឈើ

- គ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ ( ប្រជាពលរដ្ឋចំណូលថ្មី)

- ពង្រឹងការចូលរួមសហការជាមួយជំនាញរដ្ឋបាលព្រៃឈើក្នុងការស្រាវជ្រាវទប់ស្កាត់ និងបង្ក្រាបសកម្មភាពបទល្មើសព្រៃឈើគ្រប់ប្រភេទ

- ផ្តល់ពត៌មានពីបទល្មើសព្រៃឈើ

- ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យព្រៃឈើ

- កងកំលាំងប្រដាប់អាវុធ ៖

  - ផ្តល់កំលាំងសហការ/អន្តរាគមន៍តាមការស្នើសុំពីសមត្ថកិច្ចជំនាញ ក្នុងការស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើគ្រប់ប្រភេទ

  - ផ្តល់ពត៌មានពីបទល្មើសព្រៃឈើ

- មន្ទីរពាក់ព័ន្ធ (មន្ទីរបរិស្ថាន មន្ទីរដែនដី មន្ទីរកសិកម្ម មន្ទីរឧស្សាហកម្ម មន្ទីរវប្បធម៌ មន្ទីរអប់រំ មន្ទីរអភិវឌ្ឍន៍ជនបទ....) ៖

  - ផ្តល់ពត៌មានពីបទល្មើសព្រៃឈើ

  - អប់រំផ្សព្វផ្សាយពាក់ព័ន្ធនឹងវិស័យព្រៃឈើ

  - បញ្ចូលកម្មវិធីផ្សព្វផ្សាយធនធានព្រៃឈើក្នុងកម្មវិធីអប់រំ

- សហគមន៍មូលដ្ឋានៈ

  - ផ្តល់ពត៌មាន និងចូលរួមស្រាវជ្រាវ ទប់ស្កាត់បទល្មើសព្រៃឈើគ្រប់ប្រភេទ
  - ចូលរួមថែរក្សាការពារធនធានព្រៃឈើ
  - ចូលរួមក្នុងការធ្វើផែនការទប់ស្កាត់ និងបង្រ្កាបបទល្មើសព្រៃឈើ

- សង្គមស៊ីវិល/អង្គការក្រៅរដ្ឋាភិបាល ៈ

  - ចូលរួមផ្តល់ថវិកា-បច្ចេកទេស កសាងសមត្ថភាព
  - ផ្តល់ពត៌មានបទល្មើសព្រៃឈើគ្រប់ប្រភេទ
  - ផ្ទៀងផ្ទាត់ពត៌មានឱ្យបានច្បាស់លាស់មុនធ្វើការផ្សព្វផ្សាយ

- ដៃគូអភិវឌ្ឍន៍៖

  - ផ្តល់ជំនួយបច្ចេកទេស និងថវិកា

  - ចែករំលែកបទពិសោធន៍ និង ចំណេះដឹង

  - ជួយពង្រឹងសមត្ថភាពជំនាញ





# ៣.តើអភិបាលកិច្ចល្អក្នុងវិស័យព្រៃឈើមានអ្វីខ្លះ?

- មានផែនការសកម្មភាព
- បង្កើនសមត្ថភាពមន្ត្រីជំនាញ និងភាគីពាក់ព័ន្ធ
- ពង្រឹងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពពីភាគីពាក់ព័ន្ធ
- អប់រំផ្សព្វផ្សាយជាសាធារណៈ
- មានថវិកា មធ្យោបាយ-សំភារៈសំរាប់អនុវត្តការងារ
- ការចូលរួមពីភាគីពាក់ព័ន្ធ
- មានតម្លាភាព និងការទទួលខុសត្រូវតាមតួនាទី (ការត្រួតពិនិត្យ និងវាយតំលៃ...)
- ទំនាក់ទំនង និង កិច្ចសហការល្អ

# ៤. តើមធ្យោបាយផ្សព្វផ្សាយណាខ្លះដើម្បីបង្កើនការយល់ដឹងជាសាធារណៈ អំពីច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋាននានាឱ្យមានប្រសិទ្ធភាពខ្ពស់?

- ការប្រជុំ សិក្ខាសាលា
- ការចុះផ្សព្វផ្សាយដល់មូលដ្ឋាន
- ប្រព័ន្ធផ្សព្វផ្សាយ (វិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី ស៊ីឌី )
- ផ្ទាំងប៉ាណូ រូបត្លុក រូបភាព
- ការសំដែងសិល្បះ
- វេទិកាសាធារណៈ
- គេហទំព័រ
- កម្មវិធីសិក្សា

# ៥. តើការផ្តល់ពត៌មានបទល្មើសព្រៃឈើគួរធ្វើតាមវិធីណាខ្លះ?

- តាមទូរស័ព្ទ វិទ្យុទាក់ទង
- លិខិតស្នាម របាយការណ៍ពិត
- ផ្ទាល់មាត់
- បណ្តាញផ្តល់ពតិមាន
- ជនបង្គោល (Focal Point)
- រូបថត
- ប្រព័ន្ធសារពតិមាន

# សូមអរព្រះគុណ និង អរគុណ!



# លទ្ធផលក្រុមទី ៤

## កម្មវិធីសហគមន៍ព្រៃឈើ

**១ តើលោក លោកស្រីមានបទពិសោធន៍អ្វីខ្លះពីការចូលរួមគ្រប់គ្រងធនធានព្រៃឈើនៅក្នុងមូលដ្ឋានរបស់លោកអ្នក ?**

- ចូលរួមទប់ស្កាត់បទល្មើស
- រៀបចំសហគមន៍ព្រៃឈើ
- រៀបចំគណកម្មការសហគមន៍ និងអនុគណកម្មការ
- អប់រំផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធ
- រៀបចំផែនការសកម្មភាពប្រចាំខែ
- កំណត់ព្រំប្រទល់សហគមន៍
- ការពារភ្លើងព្រៃ
- រៀបចំបង្កើតសហគមន៍ព្រៃឈើ
- ចងក្រងបណ្តាញសហគមន៍ព្រៃឈើ
- រៀបចំប្រជុំគណកម្មការ
- សហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន
- មានជំនាញសប្រមសម្រួល
- ចេះធ្វើគម្រោងផែនការ
- យល់ដឹងពីសហគមន៍ព្រៃឈើ
- ពង្រឹងពីការអនុវត្តន៍ច្បាប់ព្រៃឈើ
- ធ្វើសារពើរភ័ណ្ឌព្រៃឈើ
- ចេះកំណត់សក្តានុពលសហគមន៍ព្រៃឈើ

## ២. តើការចូលរួមគ្រប់គ្រងធនធានព្រៃឈើកន្លងមករបស់លោក លោកស្រី បានជួបការលំបាក យ៉ាងណាខ្លះ ?

- ខ្វះការចូលរួមពីស្ថាប័នពាក់ព័ន្ធក្នុងការចូលរួមសហគមន៍ឈើ
- មានអំពើហឹង្សាក្នុងគ្រួសារ ដែលធ្វើឱ្យមានផលប៉ះពាល់ដល់ការចូលរួមសកម្មភាពព្រៃឈើ
- ខ្វះការយល់ដឹងពីផលប្រយោជន៍សហគមន៍ព្រៃឈើ
- ខ្វះជំនាញផ្សព្វផ្សាយ
- បទល្មើសកើនឡើងដោយសារអ្នកមានអំណាច និងមានលុយ
- រណាយន្តកើនឡើង
- ការអនុវត្តច្បាប់ និងការចូលរួមទប់ស្កាត់បទល្មើសព្រៃឈើនៅមានកំរិត
- ដំណើការរៀបចំសហគមន៍យឺតយារ
- ជនល្មើសប្រើប្រាស់អាវុធគំរាម
- ពិបាករៀបចំឯកសារស្នើសុំបង្កើតសហគមន៍ព្រៃឈើនៅថ្នាក់ខេត្ត
- លំបាកធ្វើផែនទី ព្រៃឈើសហគមន៍
- មិនទាន់មានជំនាញក្នុងការទប់ស្កាត់ភ្លើងព្រៃ
- បំផ្លាញព្រៃសហគមន៍ពីអ្នកខាងក្រៅ
- ខ្វះកិច្ចសហការគ្នារវាងអ្នកពាក់ព័ន្ធ
- ខ្វះថវិកាសំរាប់រៀបចំសហគមន៍ព្រៃឈើ
- ជនខិលខូចលួចកាប់ឈើព្រៃសហគមន៍
- ខ្វះការសិក្សាទាក់ទងក្នុងការកំណត់សក្តានុពលសហគមន៍ព្រៃឈើ
- ខ្វះពត៌មានពីការផ្តល់ព្រៃសហគមន៍អោយទៅក្រុមហ៊ុនឯកជន
- ក្រុមហ៊ុនចិនឈូសឆាយដីព្រៃ ដីស្រែ និងច្បោះដំរ
- មានការកាប់ទន្រ្ទានព្រៃយកដីលក់
- មិនមានសំភារៈល្បាត
- ការចូលរួមមានការស្ទាក់ស្ទើរ និងភ័យខ្លាច

- ចំណេះដឹងទៅលើបញ្ហាសហគមន៍ព្រៃឈើនៅមានកំរិត
- មានសកម្មភាពបរបាញ់ និងដាក់អន្ទាក់សត្វព្រៃ
- ពិបាកទំនាក់ទំនងជាមួយអ្នកមានអំណាច
- លំបាកក្នុងការដោះស្រាយទំនាស់ក្នុង និងក្រៅសហគមន៍
- អ្នកមានលុយ និងអំណាចរំលោភច្បាប់ (រំលោភសិទ្ធិសហគមន៍)
- ល្បឿននៃការបំផ្លាញព្រៃឈើលឿនជាងល្បឿននៃការអភិវឌ្ឍន៍សហគមន៍ព្រៃឈើ

## ៣.តើគួរមានអនុកម្មវិធីអ្វីបន្ថែមទៀតដើម្បីធានាថាបំរើការងារសហគមន៍ព្រៃឈើនៅមូលដ្ឋានរបស់យើង ?

- ទី ១ ស្នើរសុំបង្រួមចំណងជើង ការកំណត់សក្តានុពលសហគមន៍ព្រៃឈើ មក "ការបង្កើត សហគមន៍ព្រៃឈើ " វិញ
- សុំបន្ថែមអនុកម្មវិធីទី៤ ស្តីពីការត្រួតពិនិត និងវាយតំលៃ (ដើម្បីតំរងទិស អនុកម្មវិធិទី១ទី២ និងទី៣ ) និងបន្ថែមសកម្មភាពទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃ

## ៤.តើគួរមានសកម្មភាពសំខាន់ៗ អ្វីខ្លះទៀតនៅក្នុងអនុកម្មវិធី នីមួយៗ ?

- **អនុកម្មវិធី ទី ១ សកម្មភាពត្រូវបន្ថែមមាន**

- នៅចន្លោះជំហាន 0 និង ១ សូមបន្ថែមជំហានផ្សព្វផ្សាយ
- ចន្លោះជំហាន ៣ និង ៤ សុំបន្ថែម (ការស្នើរសុំបង្កើតព្រៃសហគមន៍ទៅនាយខ័ណ្ឌរដ្ឋបាលព្រៃឈើ ) ។
- ជំរុញអោយមានការទទួលស្គាល់សះកមនព្រៃឈើអោយបានឆាប់

- **អនុកម្មវិធី ទី ២ សកម្មភាពត្រូវបន្ថែមមាន**

- កែច្នៃអនុផលព្រៃឈើអោយបានល្អប្រសើរ
- បណ្តុះបណ្តាលជំនាញកែច្នៃអនុផលព្រៃឈើ
- ស្វែងរកទីផ្សាផល–អនុផលព្រៃឈើដល់សហគមន៍

- រក្សាគុណភាពអនុផលព្រៃឈើដូចជា ទឹកឃ្មុំ...

❖ **អនុកម្មវិធី ទី ៤ សកម្មភាពត្រូវបន្ថែមមាន**

- សកម្មភាពទប់ស្កាត់និងបង្រ្កាបបទល្មើសព្រៃឈើ និងសត្វព្រៃ ក្នុងព្រៃសហគមន៍
- កត់ត្រាពីបទល្មើសកើតឡើងនៅក្នុងសហគមន៍
- បង្កើតប្រព័ន្ធត្រួតពិនិត្យ និងវាយតំលៃអោយបានសមស្រប
- តម្រូវអោយមានការត្រួតពិនិត្យ និងវាយតំលៃទាំងក្នុងនិងក្រៅ

## ៥ . ក្នុងរយះពេល ៥ ឆ្នាំដំបូង តើយើងគួរអនុវត្តសសកម្មភាពសំខាន់ៗ អ្វីខ្លះ? ហើយរំពឹងថានឹងទទួលបាន លទ្ធផលដូចម្តេច ?

**សកម្មភាពសំខាន់ៗ**

- ❖ ជំរុញអោយមានការចុះកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើដែលមានស្រាប់ អោយបានលឿន ។
- ❖ បន្តការគាំទ្រសហគមន៍ព្រៃឈើដែលបង្កើតថ្មី
- ❖ បង្កើនសមត្ថភាព គណកម្មការ និងសមាជិកសហគមន៍ ព្រៃឈើ
- ❖ ស្វែងរកទីផ្សារអនុផលព្រៃឈើ សំរាប់សហគមន៍
- ❖ ផ្សព្វផ្សាយពីច្បាប់ពាក់ព័ន្ធ និងការបង្កើតសហគមន៍ព្រៃឈើ
- ❖ ចងក្រងក្រុមយុវជន យុវនារី អោយចូលរួមក្នុងសកម្មភាពការងារសហគមន៍ព្រៃឈើ
- ❖ ប្រើប្រាស់ថវិកាវិនិយោគឃុំ ស្រុក ខេត្តដើម្បីគាំទ្រការងារសហគមន៍ព្រៃឈើ
- ❖ ពង្រឹងការអនុវត្តច្បាប់ក្នុងការទប់ស្កាត់បទល្មើសព្រៃឈើ

**លទ្ធផលរំពឹងទុក**

- ❖ សហគមន៍ព្រៃឈើដែលមានស្រាប់នឹងទទួលបាន កិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ
- ❖ គណកម្មការ និងសមាជិកសហគមន៍ នឹងទទួលបានវគ្គបណ្តុះបណ្តាល ចំនួន ២0 វគ្គ
- ❖
- ❖

**៦.តើគួរពង្រឹងកិច្ចសហប្រតិបត្តការបែបណា រវាង រដ្ឋបាលព្រៃឈើ សហគមន៍ អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធផ្សេងទៀត ?**

- បង្កើតក្រុមការងារពាក់ព័ន្ធការគាំទ្រសហគមន៍ព្រៃឈើថ្នាក់ឃុំ ស្រុក និងខេត្ត និងប្រជុំផ្ទៃផែនការជាប្រចាំ
- ពង្រឹងការចូលរួម និងបន្តការគាំទ្រដល់សហគមន៍ព្រៃឈើពីសំណាក់អ្នកពាក់ព័ន្ធអាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន ។

**៧.តើត្រូវការអភិវឌ្ឍន៍ព្រៃសហគមន៍យ៉ាងដូចម្តេចដើម្បីធានាអោយមានការផ្តល់ផល–អនុផលព្រៃឈើសំរាប់បំរើអោយសេចក្តីត្រូវការ និងកាត់បន្ថយភាពក្រីក្រ ?**

- អភិវឌ្ឍន៍ព្រៃសហគមន៍
- រកទីផ្សារ
- ដាំដុះបន្ថែម ការពារ និងថែរក្សា
- ការពារជីវកសត្វក្នុងព្រៃសហគមន៍
- រៀបចំ និងពង្រឹងកំលាំងល្បាត
- រៀបចំការប្រមូលផល–អនុផលឱ្យមាននិរន្តរភាព
- រៀបចំតំបន់ទេសចរណ៍ធម្មជាតិនៅក្នុងព្រៃសហគមន៍

**៨.ដើម្បីគាំទ្រដល់ការអនុវត្តសហគមន៍ប្រៃឈើអោយមានប្រសិទ្ធភាព តើលោក លោកស្រីត្រូវការចំណេះដឹង និងជំនាញថ្មី ៗអ្វីខ្លះ ?**

- ជំនាញគ្រប់គ្រងលើវិស័យព្រៃឈើ
- ចំណេះដឹងពីច្បាប់ និងបច្ចេកទេសដកហូតផល–អនុផលព្រៃឈើ
- ជំនាញកែច្នៃ និង សិប្បកម្មដែលបានមកពីផលអនុផលព្រៃឈើ

- ជំនាញសម្របសម្រួល
- ជំនាញកសិកម្មដូចជាចិញ្ចឹមសត្វ
- ជំនាញរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍
- ជំនាញក្នុងការធ្វើសារពើភ័ណ្ឌ
- ជំនាញក្នុងការដោះស្រាយទំនាស់។

# ប្រធានបទទី៥

## ការអភិវឌ្ឍន៍សមត្ថភាព និងការស្រាវជ្រាវ

អ្នកចូលរួម ១៩ នាក់

ដោយៈ លោកស្រី នេត សុខសាន

ជំនប់ទី១ ឃុំវត្តប្អូនៈ ស្រុកសំបូរ ខេត្តក្រចេះ

# មាតិកា

១-តើគួរមានយុទ្ធសាស្ត្របែបណាដើម្បីឱ្យការអភិវឌ្ឍន៍សមត្ថភាពនៃអ្នកដែលពាក់ព័ន្ធក្នុង
ការគ្រប់គ្រងព្រៃឈើឆ្លើយតបទៅនឹងការអនុវត្តកម្មវិធីព្រៃឈើជាតិនៅមូលដ្ឋាន?

២-តើសេវាកម្មផ្សព្វផ្សាយព្រៃឈើគួររៀបចំឱ្យមានកម្មវិធីអ្វីខ្លះដែលសមស្របសំរាប់មូលដ្ឋាន?

៣-តើវិធីសាស្ត្រណាខ្លះដែលអាចជួយកំណត់ពីប្រសិទ្ធិភាពនៃការផ្សព្វផ្សាយព្រៃឈើ?

៤-តើត្រូវមានយុទ្ធសាស្ត្របែបណាដើម្បីឱ្យការស្រាវជ្រាវឆ្លើយតបទៅនឹងការអនុវត្តកម្មវិធី
ព្រៃឈើជាតិនៅមូលដ្ឋាន?

៥-តើវិញ្ញាបនប័ត្រព្រៃឈើមានសារសំខាន់ដូចម្ដេចខ្លះដល់ការអនុវត្តកម្មវិធីព្រៃឈើជាតិ?

**១-តើគួរមានយុទ្ធសាស្ត្របែបណាដើម្បីឱ្យការអភិវឌ្ឍន៍សមត្ថភាពនៃអ្នកដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងព្រៃឈើឆ្លើយតបនៅនឹងការអនុវត្តកម្មវិធីព្រៃឈើជាតិនៅមូលដ្ឋាន?**

- ធ្វើការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការបង្កើតកម្មវិធីព្រៃឈើជាតិ ដើម្បីឱ្យសហគមន៍មូលដ្ឋានយល់ដឹងអំពីកម្មវិធីនេះបានទូលំទូលាយ
- បង្កើតប្រព័ន្ធអប់រំ ដើម្បីធានាសមត្ថភាព គុណភាពអ្នកពាក់ព័ន្ធដែលត្រូវចូលរួមអនុវត្តការគ្រប់គ្រងព្រៃឈើស្របតាមកម្មវិធីព្រៃឈើជាតិ
- បង្កើតកម្មវិធីបណ្តុះបណ្តាល ដល់អ្នកពាក់ព័ន្ធ ពីច្បាប់ ផលប្រយោជន៍ព្រៃឈើដល់សហគមន៍មូលដ្ឋាន ភូមិ ឃុំ ។
- សិក្សាឱ្យបានច្រើន និងចុះអនុវត្តជាក់ស្តែងអំពីកម្មវិធីព្រៃឈើជាតិ
- ផ្តល់ជំនាញក្នុងការស្រាវជ្រាវដល់សហគមន៍មូលដ្ឋាន ក្នុងការអនុវត្តកម្មវិធីព្រៃឈើជាតិឱ្យបានច្បាស់លាស់

## ទី១- (ត)

- ចុះសិក្សាដល់មូលដ្ឋាន ដើម្បីស្រាវជ្រាវរកមូលហេតុ
- គួរបង្កើនជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន (ចិញ្ចឹមសត្វ ដាំបន្លែ ...)
- បង្កើន/ពង្រឹងសមត្ថភាពគ្រប់គ្រង និងការទទួលខុសត្រូវ ដល់សហគមន៍មូលដ្ឋាន ដើម្បីឱ្យគាត់អាចគ្រប់គ្រងដោយខ្លួនឯង
- បង្កើតវគ្គបណ្តុះបណ្តាលដល់សហគមន៍មូលដ្ឋានដោយមិនបង់ប្រាក់ និងបញ្ជ្រាបការអប់រំផ្សព្វផ្សាយ តាមគ្រឹះស្ថានសិក្សា
- ជ្រើសរើសមន្ត្រីថ្មី និងអភិវឌ្ឍធនធានមនុស្ស នៅក្នុងរដ្ឋបាលព្រៃឈើ ។
- មន្ត្រីជំនាញគួរចែករំលែកបទពិសោធន៍ ស្តីពីធនធានព្រៃឈើដល់បណ្តាភាគីពាក់ព័ន្ធ ។

## ២ - តើសេវាកម្មផ្សព្វផ្សាយព្រៃឈើគួររៀបចំឱ្យមានកម្មវិធីអ្វីខ្លះដែលសមស្របសំរាប់មូលដ្ឋាន?

- ☞ ដាក់តាំងឯកសារសំខាន់ៗពាក់ព័ន្ធវិស័យព្រៃឈើ ដើម្បីបង្ហាញអ្នកទស្សនាស្វែងយល់
- ☞ បង្កើនសកម្មភាពផ្សព្វផ្សាយ ដល់គ្រូបង្រៀន សិស្ស និស្សិត
- ☞ បង្កើតមធ្យោបាយផ្សព្វផ្សាយ : ប្រជុំ លើកប៉ាណូ បញ្ចាំងវីដេអូ តាមវិទ្យុ ទូរទស្សន៍
- ☞ កម្មវិធីអប់រំ ត្រូវចែករំលែកព័ត៌មាន អំពីសកម្មភាព និងទំនាក់ទំនង ក្នុងវិស័យព្រៃឈើឱ្យបានកាន់តែប្រសើរឡើង
- ☞ ផ្តល់សេវាកម្មផ្សព្វផ្សាយ: បច្ចេកទេស ច្បាប់ ការការពារព្រៃឈើជាតិនៅមូលដ្ឋាន វិធីសាស្ត្រដោះស្រាយទំនាស់ក្នុងសហគមន៍

# ទី២ (គ)

- ☞ ការផ្សព្វផ្សាយត្រូវផ្ដោតលើចំណេះដឹងសំរាប់អនុវត្តជាក់ស្ដែង
- ☞ គួររៀបចំផ្សព្វផ្សាយតាមក្រុមគោលដៅ សហការជាមួយរដ្ឋបាលព្រៃឈើ សហគមន៍មូលដ្ឋាន និងអង្គភាពពាក់ព័ន្ធ
- ☞ ការផ្សព្វផ្សាយ ធ្វើឱ្យចំគោលដៅ

## ៣-តើវិធីសាស្ត្រណាខ្លះដែលអាចជួយគាំណត់ពីប្រសិទ្ធិភាពនៃការផ្សព្វផ្សាយព្រៃឈើនៅថ្នាក់មូលដ្ឋាន?

- ដាក់តាំងឯកសារ រូបភាព និងប្រើភាសាងាយយល់
- ជាសារសំឡេង (វិទ្យុ)
- បដា ពាក្យស្លោក
- ជួយបង្ហាញគំរូនៃការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និងជោគជ័យនៃការដាំឈើឡើងវិញ
- វិធីសាស្ត្រពន្យល់រូបភាព
- វិធីសាស្ត្រត្រូវផ្សព្វផ្សាយទៅកាន់អ្នកមិនយល់ (ជារបៀបណែនាំ)
- រាល់ការផ្សព្វផ្សាយ ធ្វើឱ្យដល់ទីតាំងគោលដៅ និងជារបៀបលើកទឹកចិត្ត ឱ្យមានការចូលរួម និងទទួលខុសត្រូវ

# ៨- តើត្រូវមានយុទ្ធសាស្ត្របែបណាដើម្បីឱ្យការស្រាវជ្រាវឆ្លើយតបទៅនឹងការអនុវត្តកម្មវិធីព្រៃឈើជាតិនៅមូលដ្ឋាន?

- គួរសិក្សាស្រាវជ្រាវ អំពី អត្តសញ្ញាណព្រៃជំនឿសាសនានានា ដែលពាក់ព័ន្ធទៅនឹងការរស់នៅរបស់ប្រជាជន
- ប្រសិទ្ធិភាពនៃការចូលរួមគ្រប់គ្រងព្រៃសហគមន៍
- មានការស្រាវជ្រាវប្រកបដោយសមត្ថភាព និងច្បាស់លាស់ ហើយចំគោលដៅដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់ នាពេលបច្ចុប្បន្ន និងតាមបច្ចេកវិជ្ជាទំនើប
- បង្កើតគណៈកម្មធិការតម្រង់ទិសមួយសំរាប់វិស័យស្រាវជ្រាវព្រៃឈើជាតិដែលនិងផ្តោតទៅលើផ្នែកសេដ្ឋកិច្ច សង្គម បរិស្ថាន និងច្បាប់ក្នុងវិស័យព្រៃឈើ

# ទី៨ (ត)

- វិទ្យាស្ថានស្រាវជ្រាវ មានសមត្ថភាពពេញលេញទាំងធនធានមនុស្ស និងសម្ភារៈបរិក្ខាសំរាប់ពិសោធន៍ ដែលឆ្លើយតបនឹងតម្រូវការស្រាវជ្រាវ ជាពិសេសការទាក់ទាញរកថវិកាស្រាវជ្រាវ ពីស្ថាប័នផ្តល់ជំនួយនានា
- គួរសិក្សាស្រាវជ្រាវអំពីធនធានធម្មជាតិគ្រប់ប្រភេទនៅក្នុងព្រៃឈើជាតិ : ជីវៈចំរុះ ស្ថានភាពដី ប្រភេទដី (ដីរ៉ែ-ដីសម្បទានសេដ្ឋកិច្ច-ដីដាំកៅស៊ូ) ប្រភេទព្រៃ និងប្រភេទសត្វព្រៃ តម្រូវការប្រើប្រាស់សំរាប់អភិវឌ្ឍ និងអភិរក្ស ប្រភេទឈើ
- ស្រាវជ្រាវជីវម៉ាសរបស់ព្រៃ

# ទី៨ (គ)

- ☞ គួរស្រាវជ្រាវអំពីអាកាស្យា និងប្រេងខ្យល់ ដែលគណៈកម្មការគ្រោះរាំងស្ងួត ផ្សាយថា ការដាំឈើប្រភេទនេះ ធ្វើឱ្យបាត់បង់ទឹក
- ☞ ស្រាវជ្រាវប្រភេទឈើសំរាប់យកទៅធ្វើឱសថ ប្រភេទសត្វព្រៃមានដោយកម្រ-ជិតផុតពូជ និងព្រៃសំរាប់ប្រមូលគ្រាប់ពូជ។

# ៥-តើវិញ្ញាបនប័ត្រព្រៃឈើមានសារសំខាន់ដូចម្តេចខ្លះ ដល់ការអនុវត្តកម្មវិធីព្រៃឈើជាតិ?

- ការបញ្ចូលវិញ្ញាបនប័ត្រព្រៃឈើ ក្នុងកម្មវិធីព្រៃឈើជាតិ ជាកម្មវិធីល្អប្រសើរបំផុត ដែលរាល់ស្ថាប័នពាក់ព័ន្ធគួរជំរុញធ្វើឱ្យបានឆាប់ និងសំរេចជាស្ថាពរ ។
- មានសារៈសំខាន់ក្នុងការគ្រប់គ្រងតាមក្រមបច្ចេកទេសព្រៃឈើ ធានានិរន្តរភាព គុណភាពព្រៃ តម្លៃ និងមានការទទួលស្គាល់ជាសកល ។
- ជួយពង្រីកទីផ្សារឱ្យបានទូលាយ កម្ពុជា រហូតដល់អឺរ៉ុប
- ជួយជំរុញសហគមន៍ព្រៃឈើ ឱ្យពង្រឹងការគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព
- មានសារៈសំខាន់ ដល់ការអនុវត្តច្បាប់ ទាំងរដ្ឋបាលព្រៃឈើ ទាំងសហគមន៍មូលដ្ឋាន ដើម្បីធានានិរន្តរភាពក្នុងការគ្រប់គ្រងព្រៃឈើ

# ចប់

## សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់
## របស់លោក – អ្នក

# ក្រុមទី ៦

## លទ្ធផលពិភាក្សា

# អ្នកចូលរួម និង សំនួរ

- តំណាងក្រុម អ្នកស្រី មុំ សាគីន
- អ្នកចូលរួម: ១0 នាក់ ( មន្ទីរពាក់ព័ន្ធ រដ្ឋបាលព្រៃឈើ អង្គការ សហគមន៏មូលដ្ឋាន)
- សំនួរ : មាន ៥ សំនួរ

១. ក្នុងមាតិការរឿងនៃ *ឯកសារគោលកម្មវិធីព្រៃឈើជាតិ* តើមានចំនុចខ្វះខាតអ្វីខ្លះ?

២.តើភាគីពាក់ពន្ធ័នៅមូលដ្ឋានអាចចូលរួមតាមដាននិងវាយតំលៃការអនុវត្តកម្មវិធីព្រៃឈើជាតិ
បានយ៉ាងដូចម្តេច?

៣. តើអ្វីខ្លះដែលអាចយកមកធ្វើជា សូចនករ សំរាប់តាមដានវាយតំលៃការ អនុវត្តកម្មវិធី ព្រៃឈើជាតិ?

៤. តើតំបន់ព្រៃសម្បទានដែលត្រូវបានផ្អាកដំណើរការកន្លងមកនេះ គួរត្រូវបានគ្រប់គ្រង
យ៉ាងណាដើម្បីកុំអោយមានផល ប៉ះពាល់ដល់ជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ?

៥.តើកម្មវិធីព្រៃឈើជាតិអាចជយដោះស្រាយទំនាស់ដែលកើតឡើងពីការផល់ដីសម្បទានសេដកិចបានយ៉ាង

**ក្នុងមាតិការរឿងនៃ _ឯកសារគោលកម្មវិធីព្រៃឈើជាតិ_ តើមានចំនុចខ្វះខាតអ្វីខ្លះ?**

១. សេចក្ដីផ្ដើម

- ដូរពាក្យទស្សនះទាន ទៅជាទស្សនះវិស័យ
- ត្រូវដាក់គោលបំណង និងគោលដៅឱ្យបានច្បាស់លាស់

២- កែចំណងជើងផ្នែកទី៣ នៃ ឯកសារគោល _បញ្ហាប្រឈមក្នុងវិស័យព្រៃឈើ_ ទៅជា _បញ្ហាប្រឈម និងសក្ដានុពលក្នុងវិស័យព្រៃឈើ_។

៣. គួរមានដាក់-បព្រៀបអនេដរេ ក្នុងផ្នែកណាមួយនៃកម្មវិធីព្រៃឈើជាតិ

## ២.តើភាគីពាក់ពន្ធ័នៅមូលដ្ឋានអាចចូលរួមតាមដាននិងវាយតំលៃការអនុវត្តកម្មវិធីព្រៃឈើជាតិ បានយ៉ាងដូចម្តេច?

- ត្រូវបង្កើតក្រុមការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃដែលមានការចូលរួមគ្រប់ភាគីពាក់ពន្ធ័រួមទាំងសហគមន៏មូលដ្ឋាន
- ត្រូវធ្វើសិក្ខាសាលាឆ្លុះបញ្ចាំងកម្មវិធីព្រៃឈើជាតិថ្នាក់ខេត្តក្នុង រយៈពេល១ឆ្នាំ១ម្តង និងថ្នាក់ជាតិ ២ឆ្នាំ១ម្តង ដោយមានការចូលរួមពី ភាគីពាក់ព័ន្ធទាំងអស់

# ៣. តើអ្វីខ្លះដែលអាចយកមកធ្វើជា សូចនករ សំរាប់តាមដានវាយតំលៃការអនុវត្តកម្មវិធី ព្រៃឈើជាតិ?

- គោលដៅអភិវឌ្ឍន៏សហសវត្ស (២០១៥ = គំរបព្រៃ ៦0 ភាគរយ)
- របាយការណ៏តាមដានត្រួតពិនិត្យ និងរាយការណ៏
- ប្រជុំបូកសរុប វាយតម្លៃ បូកសរុបលទ្ធផល និងទិសដៅអនុវត្តន៏បន្ត

## តើតំបន់ព្រៃសម្បទានដែលត្រូវបានផ្អាកដំណើរការកន្លងមកនេះ គួរត្រូវបានគ្រប់គ្រងយ៉ាងណាដើម្បីកុំអោយមានផល ប៉ះពាល់ដល់ជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ?

- កំណត់រយៈពេលដែលត្រូវរៀបចំបញ្ចប់ផែនការគ្រប់គ្រងរបស់ក្រុមហ៊ុនព្រៃសម្បទានយ៉ាងយូរត្រឹមដំណាច់ឆ្នាំ២០១០
- ព្រៃសម្បទានដែលត្រូវត្រូវលុបកិច្ចព្រមព្រាងត្រូវគ្រប់គ្រងដូចខាងក្រោមៈ

— ដាំដើមឈើឡើងវិញដោយរដ្ឋ ឯកជន និងសហគមន៍

—បង្កើតសហគមន៍ព្រៃឈើតាមភូមិឃុំ

— ព្រៃគុបប្រចាំឆ្នាំ

— ព្រៃអភិរក្សជីវសាស្ត្រចំរុះ

— បង្កើតតំបន់ព្រៃសំរាប់ស្រាវជ្រាវ

## ៥.តើកម្មវិធីព្រៃឈើជាតិអាចជួយដោះស្រាយទំនាស់ដែលកើតឡើងពីការផ្តល់ដីសម្បទានសេដ្ឋកិច្ចបានយ៉ាងណាខ្លះ?

- អាជ្ញាធរភូមិឃុំត្រូវគ្រប់គ្រងស្ថិតិដីភោគៈ និងលំនៅដ្ឋានឱ្យបានច្បាស់លាស់
- ការផ្តល់ដីសម្បទានសេដ្ឋកិច្ចត្រូវមានការផ្សព្វផ្សាយជាសាធារណៈ និងមានការចូលរួមគ្រប់ភាគីពាក់ព័ន្ធ
- ក្រុមហ៊ុនត្រូវកំណត់ និងបោះបង្គោលព្រំដីសម្បទានរបស់ខ្លួនឱ្យបានច្បាស់លាស់

- សូមអរព្រះគុណ
- សូមអរគុណ

# របាយការណ៍

# ស្តីពី

# ការបូកសរុបលទ្ធផលសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ

**សាលមហោស្រពខេត្តក្រចេះ, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៩**

- សូមក្រាបថ្វាយបង្គំព្រះថេរា នុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈដ៏ខ្ពង់ខ្ពស់

-សូមគោរពឯកឧត្តម **ធុន គ្រី** អភិបាលខេត្តក្រចេះ ជាទីគោរព

- សូមគោរពឯកឧត្តម ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើ ជាទីគោរព

-សូមគោរព ឯកឧត្តម អស់លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវជាតិ និង អន្តរជាតិទាំងអស់ជាទីមេត្រី

តាងនាមអង្គសិក្ខាសាលនិងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវមនោសញ្ចេតនាដឹងគុណជាអនេកចំពោះការអញ្ជើញចូលរួមរបស់ឯកឧត្តម ធុន គ្រី អធិបាលរងខេត្តក្រចេះ ឯកឧត្តម ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើ ឯកឧត្តម អស់លោកតំណាងខេត្តកំពង់ចាម ព្រៃវែង ស្វាយរៀង អស់លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ ក្នុងពិធី **បូកសរុបលទ្ធផលពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ** នាវសៀលនេះ ដែលញាំងឱ្យពិធីនេះមានសភាពអធិកអធមប្រកបដោយកិត្តិយសដ៏ខ្ពង់ខ្ពស់ និង សបញ្ជាក់អំពីការយកចិត្តទុកដាក់ខ្ពស់បំផុតរបស់ ព្រះតេជគុណ ឯកឧត្តម អស់លោក លោកស្រី អ្នកនាងកញ្ញា ដែលជានិច្ចជាកាលតែងតែគាំទ្រសហការយ៉ាងជិតស្និតនិងអនុវត្តយ៉ាងយកចិត្តទុកដាក់លើកម្មវិធីកំណែទំរង់វិស័យព្រៃឈើរបស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ប៊ិនប្រសប់ និង ម៉ឺងម៉ាត់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

***ព្រះថេរ៉ា នុថេរ៉ាក់គ្រប់ព្រះអង្គជាទីសក្ការៈដ៏ខ្ពង់ខ្ពស់***

***គណៈអធិបតី ឯកឧត្តម អស់លោក លោកស្រី អ្នកនាងកញ្ញា ជាទីគោរព***

ជាមួយសេចក្តីគោរពស្វាគមន៍ដ៏កក់ក្តៅនេះ ខ្ញុំព្រះកុរណាខ្ញុំ ខ្ញុំបាទសូមអនុញ្ញាតទូលថ្វាយនិងរាយការណ៍ដោយសង្ខេបជូនព្រះតេជគុណ ឯកឧត្តម អស់លោក លោកស្រី អ្នកនាងកញ្ញា និងអង្គពិធីទាំងមូលអំពីដំណើរការនិង **លទ្ធផលនៃការពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ** ក្នុងរយៈពេល២ថ្ងៃ កន្លងមកនេះមានដូចតទៅ :

អង្គសិក្ខាសាលា បានប្រព្រឹត្តទៅរយៈពេល ២ ថ្ងៃ គឺថ្ងៃទី ២៥-២៦ ខែ មីនា ឆ្នាំ ២០០៩ នៅសាលមហោស្រពខេត្តក្រចេះហើយមានអ្នកចូលរួមអញ្ជើញមកពីបណ្តាខេត្តនានាក្នុងអធិការដ្ឋានរដ្ឋបាលព្រៃឈើមេគង្គក្នុងនោះមានខេត្តក្រចេះ កំពង់ចាម ព្រៃវែង ស្វាយរៀង ស្ទឹងត្រែង រតនគីរី និង មណ្ឌលគីរី ព្រមទាំងមានការចូលរួមពីអង្គភាពពាក់ពន្ធ័ក្នុងខេត្ត ក្រចេះ រដ្ឋបាលព្រៃឈើ វិស័យឯកជន អង្គការសង្គមស៊ីវិល និង សារពតិមាន សរុបចំនួន ១៨១ នាក់ គឺលើសផែនការគ្រោងទុក ១៦០ នាក់។

សិក្ខាសាលានេះមានការអញ្ជើញចូលរួមអធិបតី និង ថ្លែងសុន្ទរកថាស្វាគមន៍ដោយឯកឧត្តម ធុន គ្រី អភិបាលរងខេត្តក្រចេះ និង ថ្លែងសុន្ទរកថាបើកដោយឯកឧត្តម ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើ ។

អង្គសិក្ខាសាលាបានធ្វើបទបង្ហាញអំពី សេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ ហើយក៏បានធ្វើការពិភាក្សាផ្តល់មតិដើម្បីកែលំអរ កំណត់នូវទិសដៅយុទ្ធសាស្ត្រនិងផែនការសកម្មភាព សំរាប់អនុវត្តការងារក្នុងវិស័យព្រៃឈើ ឱ្យស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិ ច្បាប់ស្តីពីព្រៃឈើ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ គោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព សូចនាករតាមដានរួមស្តីពី កំណែទំរង់ព្រៃឈើដើម្បីឈានឆ្ពោះដល់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ ទន្ទឹមនឹងនេះ នៅថ្ងៃទី ១ ត្រូវនឹងថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៩ អង្គសិក្ខាសាលាក៏បានធ្វើបទបង្ហាញចំនួន ៩ មានដូចតទៅ :

១- គោលបំណង និង លទ្ធផលរំពឹងទុកពីសិក្ខាសាលា

២- ដំណើរការអភិវឌ្ឍកម្មវិធីព្រៃឈើជាតិ

៣-ឯកសារគោលកម្មវិធីព្រៃឈើជាតិ

៤-កម្មវិធីស្តីពី ការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍

៥-កម្មវិធីស្តីពី ការគ្រប់គ្រងធនធានព្រៃឈើជាតិ និងការអភិរក្ស

៦-កម្មវិធីស្តីពីការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ និងអភិបាលកិច្ច

៧-កម្មវិធីស្តីពី សហគមន៍ព្រៃឈើជាតិ

៨-កម្មវិធីស្តីពី ការពង្រឹងសមត្ថភាព និងអភិវឌ្ឍការងារស្រាវជ្រាវ

៩-កម្មវិធីស្តីពីការប្រើប្រាស់ហិរញ្ញប្បទានប្រកបដោយនិរន្តរភាព

នៅថ្ងៃទី ២ ត្រូវនឹងថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៩ សិក្ខាសាលាបានធ្វើការបែងចែកជាក្រុមពិភាក្សាចំនួន ៦ ក្នុងនោះពិនិត្យឃើញថា ក្រុមពិភាក្សាស្តីពីកម្មវិធីការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និង ការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ និង ក្រុមពិភាក្សាស្តីពីកម្មវិធី សហគមន៍ព្រៃឈើជាតិ មានអ្នកចូលរួមច្រើនជាងគេ គឺ ៣0 នាក់ ក្នុង ១ ក្រុម ។ ក្រុមពិភាក្សាកម្មវិធីស្តីពីការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ និងអភិបាលកិច្ច មានអ្នកចូលរួមចំនួន ២១ នាក់ ក្រុមពិភាក្សាកម្មវិធីស្តពីការគ្រប់គ្រងធនធានព្រៃឈើជាតិ និងការអភិរក្ស និង ក្រុមពិភាក្សាកម្មវិធីស្តីពី ការពង្រឹងសមត្ថភាព និង អភិវឌ្ឍការងារស្រាវជ្រាវ មានអ្នកចូលរួមចំនួន ១៨ នាក់ ក្នុង ១ ក្រុម ហើយក្រុមពិភាក្សាស្តីពី ឯកសារ គោលកម្មវិធីព្រៃឈើជាតិ មានចំនួនតិចជាងគេគឺ ៩ នាក់ ។

ឆ្លងតាមរយះការពិភាក្សាផ្លាស់ប្តូរយោបល់គ្នាយ៉ាងល្អិតល្អន់លើកម្មវិធីនីមួយៗ ក្នុងក្រុមពិភាក្សា រយៈពេល ២ ថ្ងៃមកយើងទទួលបានលទ្ធផលដូចខាងក្រោម :

### ១_កម្មវិធីស្តីពីការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍

-ការផ្សព្វផ្សាយព្រៃឈើ និងការផ្តល់ចំណេះដឹងជាសាធារណៈ ត្រូវមានការព្រមព្រាងពីប្រជាជន សហគមន៍ជាមុនៗ និងបោះបង្គោលព្រំបែងចែងដីព្រៃសង្គមកិច្ច និងសេដ្ឋកិច្ចអោយបានច្បាស់លាស់

-គួរអនុវត្តច្បាប់ផ្តន្ទាទោសអោយបនម៉ឹងម៉ាត់ និងត្រូវមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន ។

-ត្រូវមានការផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បច្ចេកទេស និងបទដ្ឋានផ្សេងៗ ដែលពាក់ពន្ធ័នឹងព្រៃឈើដល់ប្រជាជនអោយបានយល់ទូលំទូលាយជាសាធារណៈ។

-ត្រូវមានឆន្ទៈខ្ពស់ក្នុងការចូលរួមកំណត់ព្រំប្រទល់ និងត្រូវមានការចូលរួមគ្រប់ភាគីពាក់ពន្ធ័

-ត្រូវមានការផ្សព្វផ្សាយពីសារៈសំខាន់ពីការបោះបង្គោលព្រំ ហើយត្រូវមានធនធានមនុស្ស និងសមត្ថភាពជំនាញ និងមានផែនការសកម្មភាពជាក់លាក់ សំរាប់ការអនុវត្តបោះបង្គោលព្រំកំណត់ដែនព្រៃឈើ ។

-គ្រប់ភាគីពាក់ពន្ធ័ ត្រូវមានឆន្ទៈខ្ពស់ក្នុងការចូលរួម ហើយអាជ្ញាធរមូលដ្ឋានត្រូវបង្កលក្ខណៈងាយស្រួលដល់មន្ត្រីរដ្ឋបាលព្រៃឈើក្នុងការអនុវត្តការងារបោះបង្គោលព្រំ និងចូលរួមដោះស្រាយទំនាស់ពីគ្រប់ភាគីពាក់ពន្ធ័ ។

-ស្ថាប័ន និងភាគីពាក់ពន្ធ័ចូលរួមក្នុងការចាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៏ត្រូវមានរដ្ឋបាលព្រៃឈើ បរិស្ថាន អាជ្ញាធរដែនដីមូលដ្ឋាន មន្ទីរកសិកម្ម សុរិយោដី កងកំលាំងប្រដាប់អាវុធ មន្ទីរទេសចរណ៏ មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ចាស់ទុំក្នុងភូមិ សហគមន៏ អង្គការក្រៅរដ្ឋាភិបាល ។

-គ្រប់ភាគីពាក់ពន្ធ័ ត្រូវសហការទប់ស្កាត់រាល់បទល្មើស ប្រមូលពតិមាន និងភស្តុតាង រាយការណ៏ទៅអាជ្ញាធរ និងស្ថាប័នពាក់ពន្ធ័ ដើម្បីចាត់វិធានការ និងត្រូវមានផែនការ ការពារ យាមល្បាតជាប្រចាំ ក្នុងការថែរក្សាការពារព្រៃឈើ ។

## ២. កម្មវិធីស្តីពី សហគមន៍ព្រៃឈើជាតិ

នៅក្នុងកម្មវិធីសហគមន៏ព្រៃឈើជាតិនេះ ក្រុមពិភាក្សាបានសំណូមពរអោយមានការបន្ថែមអនុកម្មវិធី និងសកម្មភាពមួយចំនួនដូចខាងក្រោម :

ក. អនុកម្មវិធីទី១ ដោយប្តូរពីចំនងជើងថា ការកំណត់តំបន់សក្តានុពល និងការបង្កើតសហគមន៏ព្រៃឈើ ទៅជាការបង្កើតសហគមន៏ព្រៃឈើវិញ។

ខ. គួរមានអនុកម្មវិធីទី៤ ស្តីពីការត្រួតពិនិត្យ និងវាយតំលៃដែលអាចគ្របដណ្តប់ និងជួយតំរង់ទិសដល់ការអនុកម្មវិធីទី១ ទី២ និងទី៣ ។

សកម្មភាពសំខាន់ៗ ក្នុងអនុកម្មវិធីទាំងនោះមាន :

ក្នុងអនុកម្មវិធីទី១ សុំបន្ថែមសកម្មភាព

-នៅចន្លោះជំហ៊ាន0 និងជំហ៊ាន១ សុំបន្ថែមជំហ៊ានផ្សព្វផ្សាយ

-ចន្លោះជំហ៊ានទី៣ និងជំហ៊ានទី៤ សុំបន្ថែមការស្នើសុំបង្កើតព្រៃសហគមន៏ទៅនាយខណ្ឌរដ្ឋបាលព្រៃឈើ

-ជំរុញអោយមានការទទួលស្គាល់សហគមន៏ព្រៃឈើអោយបានឆាប់

ក្នុងអនុកម្មវិធី២ សុំបន្ថែមសកម្មភាព

-កែច្នៃអនុផលព្រៃឈើអោយបានល្អប្រសើរ

-បណ្តុះបណ្តាលជំនាញកែច្នៃអនុផលព្រៃឈើ

-ស្វែងរកទីផ្សារផល អនុផលព្រៃឈើដល់សហគមន៏

-រក្សាគុណភាពអនុផលព្រៃឈើ ដូចជាទឹកឃ្មុំ......

ក្នុងអនុកម្មវិធីទី៤ សុំបន្ថែមសកម្មភាព

-សកម្មភាពទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃ ក្នុងព្រៃសហគមន៏

-កត់ត្រាពីបទល្មើសកើតឡើងនៅក្នុងសហគមន៏

-បង្កើតប្រព័ន្ធត្រួតពិនិត្យ និងវាយតំលៃអោយសមស្រប

-ត្រូវមានការត្រួតពិនិត្យអោយមានតម្លៃ ទាំងក្នុងទាំងក្រៅ

**៣.កម្មវិធីស្តីពីការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ និង អភិបាលកិច្ច**

ក្នុងអនុកម្មវិធីទី១ : ការកែទំរង់ច្បាប់ និងរដ្ឋបាល ស្នើសុំបញ្ចូលត្រង់ចំណុច :

-ការរៀបចំលិខិតបទដ្ឋានៈ គួរធ្វើបច្ចុប្បន្នភាព រចនាសម្ព័ន្ធគ្រប់គ្រងអោយមានប្រសិទ្ធភាព (ឧៈ ខណ្ឌរដ្ឋបាលព្រៃឈើខ្លះ គួរសំរួលខណ្ឌ១ គ្រប់គ្រងធនធានព្រៃឈើក្នុងខេត្ត១)

-ធ្វើអោយប្រសើរឡើងនូវសមត្ថភាពគ្រប់គ្រងនិងដោះស្រាយទំនាស់បទល្មើសព្រៃឈើ : គួរមានការបណ្តុះបណ្តាលផ្សព្វផ្សាយ សិក្ខាសាលា និងដោះស្រាយក្នុង និងក្រៅប្រពន្ធ័តុលាការ ។

ក្នុងអនុកម្មវិធីទី២ : ការពង្រឹងការអនុវត្តច្បាប់ និងការតាមដាន និងរាយការណ៍ពីឧក្រិត្យកម្មព្រៃឈើ ស្នើសុំប្តូរពាក្យកិច្ចសហប្រតិបត្តិការ ទៅជាពង្រឹងតួនាទីជាលេខាប្រតិបត្តិក្នុងគណៈកម្មាធិការជាតិ អនុគណៈកម្មាធិការខេត្ត ។

**៤. កម្មវិធីស្តីពីការគ្រប់គ្រងធនធានព្រៃឈើ និងការអភិរក្ស**

-ត្រូវមានផែនការគ្រប់គ្រងព្រៃឈើជាតិ និងមានទិន្នន័យគ្រប់គ្រាន់សំរាប់អនុវត្តអោយមានប្រសិទ្ធភាព ហើយផែនការនោះត្រូវធ្វើសំរាប់រយៈពេល១០-១៥ឆ្នាំ ។

-ត្រូវធ្វើសារពើភណ្ឌព្រៃឈើជាតិដែលអនុវត្ត៥ឆ្នាំម្តង ដើម្បីរបមូលទិន្នន័យធនធានព្រៃឈើ សត្វព្រៃ ជីវម៉ាស់ និងស្ថានភាពសេដ្ឋកិច្ចសង្គម របស់ប្រជាជននៅក្នុងតំបន់ព្រៃឈើ ។

-ត្រូវបញ្ចូលទិន្នន័យក្នុងទំរង់បែបបទ តាមដាន ត្រួតពិនិត្យ វាយតំលៃ និងធ្វើរបាយការណ៍ ដើម្បីផ្ទៀងផ្ទាត់ការងារអនុវត្តកន្លងមក ។

-ព្រៃបំរុងទុកអចិន្ត្រៃយ៍ក្រៅពីព្រៃសហគមន៍ ចាំបាច់ត្រូវមានប្រពន្ធ័គ្រប់គ្រងមួយប្រកបដោយប្រសិទ្ធភាព ផ្តោតលើព្រៃសហគមន៍ ព្រៃសម្បទាន ព្រៃគុបផ្តល់ផល ព្រៃស្តារឡើងវិញ ព្រៃដៃគូរ និងដីសម្បទានផងដែរ ។

-ត្រូវស្វែងយល់ពីធនធានហ្សេនេទិកព្រៃឈើ ការជ្រើសរើសពូជ និងការដាំឈើ សំរាប់ការប្រើប្រាស់ច្រើនយ៉ាង ជាពិសេស ជ្រើសរើសពូជសំរាប់ដាំ ដូចជា : បេង នាងនួន ឈើទាល ផ្ចឹក ដូនចែម គគីរ .....ឈើលូតលាស់លឿន ដូចជា អាកាស្យា ប្រេងខ្យល់ អង្គារដី កន្ទំថេត និងប្រភេទឈើហូបផ្លែ សំរាប់ដាំជារបង លំនៅដ្ឋាន បរិវេណវត្តអារ៉ាម សាលារៀន និងទីសាធារណៈ ។

-ត្រូវគិតគូរដល់ការរៀបចំតំបន់ព្រៃការពារជីវចំរុះ ទេសចរណ៏ធម្មជាតិ កន្លែងកីឡាប្រម៉ាញ់ ។

-ត្រូវរៀបចំវិធានការ ទប់ស្កាត់ និងបង្ក្រាបអំពើល្មើសច្បាប់ក្នុងការកាប់បំផ្លាញប្រភេទឈើដែលមានដោយកំរ និងជិតផុតពូជ ។

-ត្រូវពង្រឹង និងជំរុញទីផ្សារ ផលិតផលឈើ ផលិតផល អនុផលព្រៃឈើ ពិសហគមន៍មូលដ្ឋាន រហូតដល់ទិផ្សារជាតិ និងអន្តរជាតិ ដើម្បីលើកស្ទួយកំរិតជីវភាពសហគមន៍មូលដ្ឋាន និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។

-រាជរដ្ឋាភិបាល គួរលើកទឹកចិត្តដល់ផលិតផលកែច្នៃដោយដៃ ចេញពីសហគមន៍ ទាំងបរិមាណ និងគុណភាព ព្រមទាំងផ្តល់ការបណ្តុះបណ្តាលបច្ចេកវិទ្យាកែច្នៃផល អនុផលព្រៃឈើដល់សហគមន៍មូលដ្ឋាន ។

-ក្នុងអនុកម្មវិធីទី៥ ត្រូវមានការផ្សព្វផ្សាពីប្រភេទឈើដែលអាចប្រើប្រាស់បានច្រើនយ៉ាង និងផ្តល់កូនឈើដល់សហគមន៍ ដើម្បីជាការលើកទឹកចិត្ត និងទាក់ទាញការចូលរួម ។

-ក្នុងអនុកម្មវិធីទី៦ គួរពង្រឹងការអនុវត្តច្បាប់ និងផ្សព្វផ្សាយអោយបានទូលំទូលាយ ។

-ក្នុងអនុកម្មវិធីទី៧ ត្រូវបណ្តុះបណ្តាល និងបង្កើតគំនិត កែច្នៃប្រឌិត ផលិតផលព្រៃឈើ ដល់សហគមន៍មូលដ្ឋាន ដើម្បីអោយស្របទៅនឹងតំរូវការទីផ្សារ ។

ក្នុងអនុកម្មវិធីទី៨ ត្រូវអភិវឌ្ឍន៍បច្ចេកវិទ្យាឈើ និងការកែច្នៃឈើដល់ផលិតករ ដើម្បីធ្វើការកែច្នៃផលិតផល ឆ្លើយតបតាមតម្រូវការទីផ្សារ ។

## ៥-កម្មវិធីស្តីពីការពង្រឹងសមត្ថភាព និងអភិវឌ្ឍការងារស្រាវជ្រាវ

-ត្រូវរៀបចំសេវាកម្មផ្សព្វផ្សាយព្រៃឈើដែលសមស្របដល់សហគមន៍មូលដ្ឋាន ជាពិសេស បច្ចេកទេសធ្វើចំណាត់ថ្នាក់ព្រៃឈើ ទៅតាមមុខងារព្រៃឈើ បច្ចេកទេសងាយៗ លើការងារដាំឈើ

-ជម្រុញដំណើរការរៀបចំវិញ្ញាបនប័ត្រព្រៃឈើ ឱ្យបានកាន់តែឆាប់កាន់តែល្អ ដើម្បីជួយជម្រុញការងារគ្រប់គ្រងព្រៃឈើបានល្អ ។

-ត្រូវសិក្សាអំពីតម្រូវការចាំបាច់របស់មូលដ្ឋាន និង ត្រូវរៀបចំវគ្គបណ្តុះបណ្តាលអំពីជំនាញព្រៃឈើនានា រួមទាំងកម្មវិធីព្រៃឈើជាតិដល់មូលដ្ឋាន ។

-ត្រូវចែករំលែកពត៌មានតាមរយៈការបង្កើតសំភារៈផ្សព្វផ្សាយគ្រប់ប្រភេទ ។

-ត្រូវសិក្សាពីបញ្ហារបស់មូលដ្ឋាន និងតម្រង់ទិសសម្រាប់ការងារស្រាវជ្រាវ ដោយផ្តោតលើបញ្ហា សង្គម សេដ្ឋកិច្ច និង បរិស្ថាន ។

## ៦-ឯកសារគោលកម្មវិធីព្រៃឈើជាតិ

-ជារួមអង្គសិក្ខាសាលាបានឯកភាពលើមាតិការឿង នៃឯកសារគោល កម្មវិធីព្រៃឈើជាតិ និងស្នើដាក់គោលបំនង និង គោលដៅអោយបានច្បាស់លាស់ ។

-ត្រូវបង្កើតក្រុមការងារតាមដានត្រួតពិនិត្យ និងវាយតំលៃដោយមានការចូលរួមពីគ្រប់ភាគីពាក់ពន្ធ័ រួមទាំងសហគមន៍មូលដ្ឋាន ។

-ត្រូវធ្វើសិក្ខាសាលាឆ្លុះបញ្ចាំងពីកម្មវិធីព្រៃឈើជាតិ ថ្នាក់ខេត្ត ក្នុងរយៈពេល១ឆ្នាំម្តង និងថ្នាក់ជាតិ២ឆ្នាំម្តង ដោយមានការចូលរួមពីគ្រប់ភាគីពាក់ពន្ធ័ រួមទាំងសហគមន៍មូលដ្ឋាន ។

-សូចនករសំរាប់តាមដានវាយតំលៃ ការអនុវត្តកម្មវិធីព្រៃឈើជាតិ អាចរួមមានគោលដៅ អភិវឌ្ឍន៍ សហសវត្សកម្ពុជា( គំរបព្រៃឆ្នាំ២០១៥ ) របាយការណ៍តាមដានត្រួតពិនិត្យ និងរាយការណ៍ប្រជុំបូកសរុប វាយតំលៃ លទ្ធផល និង ទិសដៅអនុវត្តបន្ត ។

-ត្រូវកំណត់រយៈពេលដែលត្រូវរៀបចំបញ្ចប់ផែនការគ្រប់គ្រង របស់ក្រុមហ៊ុនព្រៃសម្បទានយ៉ាងយូរ ត្រឹមដំណាច់ឆ្នាំ២០១០ ។

-ព្រៃសម្បទានដែលបានលប់កិច្ចព្រមព្រាង ត្រូវគ្រប់គ្រងតាមរយៈការដាំឈើឡើងវិញ ដោយរដ្ឋ ឯកជន និងសហគមន៍ បង្កើតសហគមន៍ព្រៃឈើតាមភូមិ-ឃុំ ព្រៃគុបប្រចាំឆ្នាំ ព្រៃអភិរក្ស ជីវសាស្ត្រចំរុះ តំបន់ទេសចរណ៍ធម្មជាតិ និងតំបន់សិក្សាស្រាវជ្រាវព្រៃឈើ និងសត្វព្រៃ ។

-កម្មវិធីព្រៃឈើជាតិអាចជួយដោះស្រាយទំនាស់ដែលកើតឡើងពីការផ្តល់ដីសម្បទានសេដ្ឋកិច្ច តាមរយៈការបង្កើតអោយមានផែនការ ឬយន្តការដែលក្នុងនោះតម្រូវអោយ :

- អាជ្ញាធរភូមិ-ឃុំ ត្រូវគ្រប់គ្រងស្ថិតិដីភោគៈ និងលំនៅដ្ឋានអោយបានច្បាស់លាស់
- ការផ្តល់ដីសម្បទានសេដ្ឋកិច្ច ត្រូវមានការផ្សព្វផ្សាយជាសាធារណៈ និងមានការចូលរួមពីគ្រប់ភាគីពាក់ពន្ធ័
- ក្រុមហ៊ុនត្រូវកំណត់ និងបោះបង្គោលព្រំដីសម្បទានរបស់ខ្លួនអោយបានច្បាស់លាស់

***គណៈអធិបតី ឯកឧត្តម អស់លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិទាំងអស់ ជាទីគោរព***

ជាថ្មីម្តងទៀត ក្នុងនាមអង្គសិក្ខាសាលាទាំងមូល ខ្ញុំសូមសំដែងនូវការគោរពដឹងគុណ និងកាតញ្ញូតាធមិដ៏ជ្រាលជ្រៅបំផុតចំពោះវត្តមានរបស់ព្រះតេជគុណ ឯកឧត្តម អស់លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ ដែលបានអញ្ជើញពីបណ្តាខេត្តទាំង៧ ក្នុងអធិការដ្ឋានរដ្ឋបាលព្រៃឈើមេគង្គ គឺខេត្តក្រចេះ ស្ទឹងត្រែង រតនគីរី មណ្ឌលគីរី កំពង់ចាម ព្រៃវែង និងស្វាយរៀង មកចូលក្នុងសិក្ខាសាលាស្តីពីការពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ ដែលបានប្រព្រឹត្តិទៅអស់រយៈពេល២ថ្ងៃនេះ។ សកម្មភាពទាំងនេះឆ្លុះបញ្ចាំងឱ្យឃើញថា ព្រះតេជគុណ ឯកឧត្តម អស់លោក លោកស្រី អ្នកនាងកញ្ញាបានចូលរួម ផ្តល់វិភាគទានដ៏មាន តំលៃក្នុង ការកសាងនូវកម្មវិធីព្រៃឈើជាតិរបស់យើង មានលក្ខណៈជាតិស្របទៅតាមតំរូវការក្នុងមូលដ្ឋាន មានតម្លាភាព និងមានសុខដុមនាកម្មទៅនឹង ច្បាប់ស្តីពីព្រៃឈើ គោលនយោបាយយុទ្ធសាស្ត្រចតុកោណជំហាន២ របស់រាជរដ្ឋាភិបាល និងគោលដៅអភិវឌ្ឍសហសវត្សន៍កម្ពុជា ដើម្បីគ្រប់គ្រង និងប្រើប្រាស់ធនធានព្រៃឈើរបស់យើងប្រកបដោយនិរន្តភាព សំរាប់កូនចៅជំនាន់ក្រោយ។

សំរាប់ឱកាសនេះ ខ្ញុំព្រះកុរុណា ខ្ញុំបាទសូមអនុញ្ញាតគោរពជូនពរ ឯកឧត្តម អស់លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ជួប ប្រទះនូវជ័យជំនះ សំណាងល្អ និង សុភមង្គលគ្រប់ប្រការកុំបីឃ្លៀងឃ្លាតឡើយ។

***សូមអរគុណ!***

កម្មវិធីទី១

ការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និងការចុះបញ្ជីការសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ （លោក ប៉ក់ ជាលី ）

**សំនួរទី១ :**

-ព្រះសង្ឃ（ជឹម ពាន់）គង់នៅវត្តសិរីសុន្ទរវង្ស ក្រចេះក្រុង : ក្រៅពីព្រៃបានបែងចែករួចហើយ តើព្រៃប្រជាពលរដ្ឋអាចធ្វើសំណើសុំកាប់ឈើសំរាប់ធ្វើផ្ទះបានដែរឺទេ?

**ចំលើយទី១:**

-កំណត់ដីព្រៃឈើ ដីមិនមែនព្រៃ

-ព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន

-ព្រៃការពារ

-ផ្ទៃដីព្រៃសំរាប់ផ្ទេរក្នុងគោលបំនងផ្សេងៗ ការប្រើប្រាស់ជាលក្ខណៈប្រព្រៃណី គឺនៅក្នុងច្បាប់ស្តីពីព្រៃឈើ

**សំនួរទី២ :**

-លោក យូវ៉ា មកពីស្ទឹងត្រែង（អង្គការ）: តើមានចំណុចលំអិតអ្វីផ្សេងទៀតទេ ដើម្បីដាក់ក្នុងកម្មវិធី ពិភាក្សានៅថ្ងៃស្អែក?

**ចំលើយទី២ :**

-ថ្ងៃស្អែកក្នុងក្រុមពិភាក្សានីមួយៗ មានសំនួរចំនួន៦ ក្នុងអនុកម្មវិធីមួយមាន០៣សំនួរ ហើយលោក សុខ ហេង បានបន្ថែមចំលើយថា កម្មវិធីលំអិតយើងមិនមានពេលវេលាច្រើនទេ ប៉ុន្តែមុននឹងពិភាក្សាអ្នកសំរបសំរួលនឹងពន្យល់បន្ថែម ។

**សំណួរទី៣:**

-លោក ថៃ ប៊ុនសុង នៅភូមិស្រែត្នោយ ឃុំកំពង់ចាម ស្រុកសំបូរ សួរថា : ដីព្រៃក្រោយពីចែកព្រំប្រទល់ហើយ តើដីព្រៃនៅសល់ល្អ តើត្រូវអោយទៅក្រុមហ៊ុន ឬ ដីសម្បទានសេដ្ឋកិច្ចខាងណា ?

**ចំលើយទី៣ :**

-ក្រោយពីយើងបានបែងចែកច្បាស់លាស់ហើយ យើងនិងដឹងថាព្រៃកន្លែងណាសំរាប់ទុកអភិវឌ្ឍន៍ហើយកន្លែងណា ទុកសំរាប់ការពារ និងអភិរក្ស។ ( ក្នុងកម្មវិធីទី១ : ការកំណត់ព្រំប្រទល់ )

កម្មវិធីទី២

ការគ្រប់គ្រង និងអភិរក្សព្រៃឈើ

**សំនួរទី១ :**

-លោក ហ៊ុន ណារ៉េន មន្ត្រីខណ្ឌរដ្ឋបាលព្រៃឈើរតនៈគីរី : តើមានវិធីសាស្ត្រគ្រប់គ្រងបែបណា ដើម្បីធានាអោយបានទូវលំនឹងភាពចំពោះវត្តមានសត្វព្រៃ ដែលមាននៅក្នុងតំបន់ប្រម៉ាញ់នោះ ។

-តើចំពោះប្រភេទសត្វព្រៃដែលបានចាត់ថ្នាក់ ជាប្រភេទ Endangered or critically endangered Species នៅក្នុងសៀវភៅក្រហម IUNC អនុញ្ញាតអោយមានការប្រមាញ់ដែររឺទេ ?

**ចំលើយទី១ :**

-សិក្សាស្រាវជ្រាវស្ថានភាពសត្វព្រៃនៅក្នុងតំបន់

-រៀបចំផែនការយុទ្ធសាស្ត្រ

-កំណត់កូតា ដកហូតសត្វព្រៃ

-កម្មវិធីតាមដានស្ថានភាពសត្វព្រៃ

-ការពិនិត្យសើរើផែនការ និងវាយតំលៃឡើងវិញ

**សំនួរទី២ :**

-តើមានយន្តការអ្វីកើនឡើង បើមួយឆ្នាំទៅមួយឆ្នាំព្រៃឈើកាន់តែបាត់បង់ និងមានកំណើនដីកសិកម្ម

**ចំលើយទី២:**

-មាននៅក្នុងអនុកម្មវិធីទាំង៦ យើងទើបតែបានបង្ហាញអនុកម្មវិធី២ ដូចជា ការបោះបង្គោលព្រំ និង ការគ្រប់គ្រងអភិរក្សព្រៃឈើ

-ដាំឈើ, ស្តារព្រៃឈើឡើងវិញ

-គ្រប់គ្រងព្រៃឈើឡើងវិញ

**សំនួរទី៣:**

-លោក ឡុង យិន ប្រជាជនស្រុកក្រចេះ ខេត្តក្រចេះ : តើចំការព្រៃដាំ ផលព្រៃឈើនោះ សហគមន៍មូលដ្ឋានទទួលភាពជាម្ចាស់ រឺ កម្មករ ?

**ចំលើយទី៣:** ( **លោក អួន សំអុល** )

-ការធ្វើជាម្ចាស់លើចំការព្រៃដាំ បើបងចេញទុន់លើដីរដ្ឋ បងជាម្ចាស់ រដ្ឋក៏ជាម្ចាស់ដែរ ហើយការបែងចែកផលតាមកិច្ចសន្យា

-បើជាកម្មករ បងក៏រកកំរៃពេលកម្មពីចំការព្រៃដាំ របស់គេ រឺ របស់រដ្ឋ ។

## កម្មវិធីទី៣

## ការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ ( លោក សួន សុវណ្ណ )

លោក ស៊ុន យ៉ូវ៉ា អង្គការភូមិខ្ញុំ

សំណូមពរ : សូមបញ្ចូលសហគមន៍មូលដ្ឋានទៅក្នុងការអនុវត្តច្បាប់ និងអភិបាលកិច្ចស្តីពីព្រៃឈើ។ ដោយសារសហគមន៍ត្រូវបានអនុញ្ញាតិធ្វើការគ្រប់គ្រងព្រៃឈើ ដូច្នេះគួរមានជនបង្គោលសហគមន៍ ដើម្បីបង្កើតជាបណ្តាញរបស់រដ្ឋបាលព្រៃឈើក្នុងការគ្រប់គ្រងព្រៃឈើ ?

ចំលើយ : ករណីនេះមានអនុកម្មវិធីមួយទៀត ក្នុងសហគមន៍ព្រៃឈើ នឹងធ្វើបទបង្ហាញល្ងាចនេះ។

**សំនួរទី១:** ( លោក ថៃ ប៊ុនលាង ) ភូមិស្រែត្នោយ ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ

-បញ្ហាទំនាស់ដីធ្លី : បើសិនបុគ្គល " ក " អ្នកក្រ ហើយបុគ្គល " គ " អ្នកមានលុយ តើករណីទំនាស់ដោះស្រាយយ៉ាងណា?

**ចំលើយទី១ :** យើងមានច្បាប់ បទបញ្ជារផ្សេងៗ ច្បាប់មិនបានលើកលែងទោសចំពោះអ្នកមាន អ្នកក្រទេ។ ហើយយើងមានយន្តការដោះស្រាយទំនាស់ដីធ្លីតាំងពីថ្នាក់លើ រហូតដល់ថ្នាក់ស្រុក ។

**សំនួរទី២ :** ( លោក សា ខូយ ) ភូមិកំពង់ក្បឿង ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ

-តើការនាំចេញផល អនុផលព្រៃឈើ មានផលប្រយោជន៏សំរាប់សហគមន៍ក៏រិតណា? សំរាប់រដ្ឋាភិបាលប៉ុណ្ណា?

**ចំលើយទី២** ( លោក សូ លន ឆ្លើយ ): សហគមន៍ព្រៃឈើដែលស្របច្បាប់មានសិទ្ធិប្រមូលផល កែច្នៃ នាំចេញទៅលក់នៅទីផ្សារ ដូចអ្នកដទៃដែរ ដោយមិនតំរូវអោយបង់ថ្លៃសួយសារឡើយ ។

**សំនួរទី៣ :** ( អនកស្រី មុំ សាគីម) ភូមិឃ្សឹម ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ

បង្កើតពណិមានក្នុងការទប់ស្កាត់បទល្មើសព្រៃឈើ តើវាអាចគ្របដណ្តប់ វាអាចមានប្រសិទ្ធិភាពដល់ព្រៃឈើជាតិដែរឬទេ?

**ចំលើយទី៣ :** ក្នុងច្បាប់ស្តីពីព្រៃឈើ រដ្ឋបានប្រគល់សិទ្ធិទៅអោយរដ្ឋបាលព្រៃឈើជាអ្នកអនុវត្តច្បាប់ ។ ក្នុង ច្បាប់ស្តីពីព្រៃឈើមាត្រាអ្នករួមសហការក៏មានសិទ្ធិផ្តល់ពតិមានដល់មន្ត្រីរដ្ឋបាលព្រៃឈើនៅក្បែរ ឬ ជិត ហើយមានប្រសិទ្ធិភាព។

## កម្មវិធីទី៤

## សហគមន៍ព្រៃឈើជាតិ ( លោក ឡាវ  សេដ្ឋាផល )

**សំនួរទី១ :** ( លោក សែ សុភី ) អង្គការអភិវឌ្ឍន៍ភាពជាដៃគូរ នៅរតនៈគីរី

-តើកម្មវិធីសហគមន៍ព្រៃឈើកំពុងបង្ហាញ តើមានភាពប្រទាំងប្រទិសគ្នាជាមួយនឹងការកំពុងអនុវត្តដែរឺទេ ?

**ចំលើយទី១ :** មិនមានភាពប្រទាំងប្រទិសគ្នាទេ ។

**សំនួរទី២ :** ( សោម ផល្លា ) មកពីសហគមន៍ខេត្តក្រចេះ

សហគមន៍ព្រៃឈើបានកាត់ជារូបរាងរួចមកហើយ សហគមន៍ខ្លះដែលនៅជាប់នឹងព្រៃ ប៉ុន្តែសព្វថ្ងៃរដ្ឋាភិបាលបានប្រគល់ដីនោះ ទៅអោយក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច តើធ្វើយ៉ាងណាដើម្បីអោយមានសហគមន៍មានសង្ឃឹមឡើងវិញ ?

**ចំលើយទី២ :** សហគមន៍ព្រៃឈើដែលអង្គការបានបង្កើតឡើងនោះ ពុំមានកិច្ចសហការពីរដ្ឋបាលព្រៃឈើ និងអាជ្ញាធរដែនដីគួរធ្វើការសំរបសំរួលជាមួយម្ចាស់ដីសម្បទាន ។

**សំនួរទី៣ :** ( យិន ប៊ុនទិត ) អភិបាលរងខេត្តកំពង់ចាម

-ស្នើពន្យល់ពាក្យឥណទានកាបូន ?

-តាមការសង្កេតនៃបទបង្ហាញ ខ្ញុំពុំបានឃើញពីហានិភ័យដែលនឹងអាចកើតមានឡើង ក្រៅតែពីលទ្ធផលរំពឹងទុក ?

**ចំលើយទី៣ :** កាបូនគឺខ្យល់បរិសុទ្ធ លក់អោយប្រជាជនពិភពលោក ព្រោះបច្ចុប្បន្នភពផែនដីមានការប្រែប្រួលឡើងកំដៅធ្វើអោយរលាយទឹកកកជាបណ្តើរៗនៅប៉ូលខាងជើង ដូច្នេះការព្រួយបារម្ភរបស់ពួកគេក្នុងការបំរែបំរួលបរិស្ថាននេះ គេបានផ្តល់ឥណទានសំរាប់រក្សាខ្យល់បរិសុទ្ធ ។

-ឯរឿងហានិភ័យដែលអាចកើតមានជាមួយនឹងការរំពឹងទុក យើងនឹងលើកយកមកពិចារណាលើកក្រោយ ។

កម្មវិធីទី៥

ការពង្រឹងសមត្ថភាព និងអភិវឌ្ឍន៍ការងារស្រាវជ្រាវ (ជាក្រុម)

**សំនួរទី១ :** ព្រះតេជគុណ ជឹម ពាន់

-បើសិនជាការស្រាវជ្រាវមានការភ្លាំងភ្លាត់ និងមិនច្បាស់លាស់ តើអាចប៉ះពាល់ដល់ពង្រឹងសមត្ថភាពអភិវឌ្ឍន៍ដែរឬទេ? ហើយតើមានវិធីសាស្រ្តបែបណា ដើម្បីធ្វើអោយការស្រាវជ្រាវរបស់យើងមិនមានការភ្លាំងភ្លាត់ ឬមិនច្បាស់លាស់នោះ ?

**ចំលើយទី១ :** បើយើងចេះច្បាស់យើងមានសមត្ថភាពពេញលេញ ធ្វើអោយការស្រាវជ្រាវបានលទ្ធផលល្អ ដូចច្នេះត្រូវពង្រឹងសមត្ថភាពរបស់យើង និងបណ្តុះបណ្តាល បើយើងមិនចេះច្បាស់ ការស្រាវជ្រាវមិនបានល្អ ។

**សំនួរទី២ :** តើប្រពន្ធ័អប់រំ មជ្ឈមណ្ឌលផ្សព្វផ្សាយ និងសកលវិទ្យាល័យព្រៃឈើ មានលក្ខណៈយ៉ាងដូចម្តេច ?

-តើរដ្ឋបាលព្រៃឈើគ្រោងនឹងបង្កើតសកលវិទ្យាល័យព្រៃឈើឬយ៉ាងណា ?

-តើមជ្ឈមណ្ឌលផ្សព្វផ្សាយអាចបង្កើតបានគ្រប់ខេត្ត-ក្រុង ទាំងអស់នោះទេ ?

**ចំលើយទី២ :** មជ្ឈមណ្ឌលមានតែមួយទេ ដោយឡែកយន្តការផ្សព្វផ្សាយយើងធ្វើទូទាំងប្រទេស។

**សំនួរទី៣ :** អ្នកស្រី មុំ សាគីម មកពីសហគមន៍ព្រៃឈើស្រុកស្អួល

-ត្រូវបានលើកទឹកចិត្តដល់មន្ត្រីអនុវត្តគំរោងកម្មវិធីព្រៃឈើជាតិ ២០១០-២០១៥ ដើម្បីការពារគ្រប់គ្រងអោយបានល្អ ក្នុងនោះលោកបានបញ្ចូលរាប់ព្រៃឈើដាំ ឬតែព្រៃឈើធម្មជាតិ ?

-លោកមានកត្តាអ្វីសំគាល់ថា និងការរំពឹងឆ្លើយតបទៅនឹងព្រៃឈើជាតិអោយបានកំណើន ៦០% នៃព្រៃឈើ សំរាប់ឆ្នាំ ២០១៥ ?

-តាមបទបង្ហាញយើងឃើញថាមានការលើកទឹកចិត្តដល់មន្ត្រីរដ្ឋបាលព្រៃឈើរហូតដល់ឆ្នាំ២០១៥ តើរាប់តាមព្រៃដាំ ឬព្រៃធម្មជាតិ ?

-តើយើងមានយន្តការបែបណាដើម្បីអោយឆ្នាំ២០១៥ មានគំរបព្រៃឈើ៦០% ?

**ចំលើយទី៣ :** កន្លងមកយើងធ្វើការប៉ាន់ស្មានឆ្នាំ២០០៥-២០០៦ គំរបព្រៃឈើមាន ៥៩.១៥% ដូច្នេះក្នុងកម្មវិធីទី១ យើងបានកំណត់ព្រំប្រទល់បានច្បាស់លាស់ យើងអាចគិតបានទាំងព្រៃដាំ ទាំងព្រៃធម្មជាតិ ដូច្នេះ រហូតដល់ឆ្នាំ២០១៥ អាចឡើងដល់៦០% ។

កម្មវិធីសំនួរ-ចំលើយ

**សំនួរ :** ( លោក ហ៊ុល សឿង មេឃុំបឹងចារ )

**១**-តើពីពេលនេះទៅ ដល់ការអនុវត្តបាននូវគោលការផែនការ តើមានរយៈពេលប៉ុន្មានទៀត ? តើការអនុវត្តរបស់យើងដែលនៅអូសបន្លាយនេះ មានការរាំងស្ទះនៅចំនុចណា? ហើយតើអាចរកដំណោះស្រាយសមស្របយ៉ាងណាមួយអោយបានឆាប់ដែរឬទេ?

**ចំលើយ** : ( ចំលើយរបស់លោក សួន សុវណ្ណ )

**១**-ដូច្នេះយើងបាន និងកំពុងបង្កើតព្រៃឈើជាតិនេះឡើង ដែលមាន ០៦ កម្មវិធីធំៗនេះឡើង ដូច្នេះដែលយើងបានធ្វើសិក្ខាសាលាអោយមានការចូលរួមមតិយោបល់ទាំងអស់គ្នា ពីគ្រប់អង្គភាពពាក់ពន្ធ័និងប្រជាជនសហគមន៍មូលដ្ឋាន ។ ខ្ញុំនឹងសង្ឃឹមថា កម្មវិធីព្រៃឈើជាតិអាចធ្វើអោយកើនគំរបព្រៃឈើរហូតដល់ ៦០% នាពេលខាងមុខ ។

**សំនួរ :** លោក ឡុង យិន ភូមិក្រូច ឃុំដីរផុង ស្រុកឆ្លូង

**១**-តើការផ្តល់សិទ្ធទៅអោយក្រុមហ៊ុន ឯកជនវិនិយោគ គឺលឿនដែលមានការចាប់អារម្មណ៏ពីរដ្ឋាភិបាល ប៉ុន្តែពេលដែលដីព្រៃឈើបង្កើតសហគមន៏ ហេតុអ្វីក៏យឺត? តើផ្តល់សម្បទានដីព្រៃអោយទៅក្រុមហ៊ុនធ្វើវិនិយោគ និងអោយប្រជាជនពឹងស្នាក់អាស្រ័យ តើមួយណាសំខាន់ជាង ?

**ចំលើយ:** ( ចំលើយរបស់លោក អ៊ួន សំអុល )

**១**-ការធ្វើដីសម្បទានសេដ្ឋកិច្ច ដោយមានក្រុមការងារចុះសិក្សាវាយតំលៃផលប៉ះពាល់ច្បាស់លាស់ អំពីសក្តានុពលព្រៃឈើរួចជាមុន ដូច្នេះ ដោយគេមានប្រាក់គ្រប់គ្រាន់គយបផ្សំផងនោះ ធ្វើអោយការវិនិយោគរបស់គេបានលឿន ។ ឧទាហរណ៏: នៅក្នុងសតវត្សទី២១ ប្រទេស១០ បានធ្វើអោយកំដៅកើនឡើង ដើម្បីធ្វើអោយកាត់បន្ថយកំដៅថយចុះ យើងធ្វើតាមរយៈការដាំឈើ ដើម្បីយកថាមពល ។

-ពេលដែលដីព្រៃបង្កើតដោយសហគមន៏ បានជាយឺត មកពីការរៀបចំសហគមន៏ព្រៃឈើនៅប្រទេសយើងមានការយឺតយ៉ាវ ប៉ុន្តែពេលនេះរដ្ឋបាលព្រៃឈើបានកំពុងជំរុញធ្វើអោយបានលឿន គឺអោយសហគមន៏ព្រៃឈើធ្វើយ៉ាងណាអោយថ្នាក់លើទទួលស្គាល់ ។

**សំនួរ :** លោក ថៃ ចុងលាង នៅភូមិស្រែត្នាយ ឃុំកំពង់ចាម ស្រុកសំបូរ

-កម្មវិធីព្រៃឈើជាតិ ដើម្បីថែរក្សាអោយមាននិរន្តរភាព ទៅលើព្រៃធម្មជាតិ ដើម្បីអភិរក្ស និងការពារ ប៉ុន្តែបើសម្បទានអោយក្រុមហ៊ុនធ្វើអាជីវកម្មព្រៃឈើ តើព្រៃត្រូវបាត់បង់ដែរឬទេ?

-បើសម្បទានដីព្រៃឈើរិចរិលអោយទៅអ្នកមានលុយ ដីធំ តើមានផលប៉ះពាក់ព្រៃឈើដែរឬទេ?

-តើកូនចៅអ្នកស្រុកនៅមូលដ្ឋាន ត្រូវការដីព្រៃរិចរិល សំរាប់ចិញ្ចឹមគោ-ក្របី តើមានការប៉ះពាល់ដែរឬទេ?

**ចំលើយ:**

**-**សំរាប់ដីរិចរិលសំរាប់ធ្វើការអភិវឌ្ឍន៏ជាគោលការណ៏របស់រាជរដ្ឋាភិបាល បើយើងយកដីនេះសំរាប់លែងគោ-ក្របី និងប្រគល់អោយក្រុមហ៊ុនធ្វើអាជីវកម្ម តើលោក-លោកស្រី យល់ថាមួយណាមានប្រយោជន៏ជាង ។ ( ចំលើយរបស់ លោក ប៉ក់ ជាលី )

-ការប្រមូលផលព្រៃឈើដោយអនុវត្តតាមក្បួនខ្នាត បច្ចេកទេស បានល្អគឺធានាបាននិរន្តរភាព មិនមានការប៉ះពាល់។
-ចំណែកការទុកដីរិចរិលអោយប្រជាជន កុំអោយក្រុមហ៊ុន ខ្ញុំសូមអោយអ្នកទាំងអស់គ្នាពិចារណា
ពីឆ្នាំ ១៩៩៧-១៩៩០ តើយើងមានអ្វីខ្លះ ?
ពីឆ្នាំ ១៩៩០-២០០០ យើងធ្វើបានអ្វីខ្លះ ?
ពីឆ្នាំ២០០០-បច្ចុប្បន្ន តើយើងមានធ្វើអ្វីខ្លះ? ដូច្នេះយើងត្រូវអភិវឌ្ឍន៏អោយមានការផ្សារភ្ជាប់គ្នា ពីទីក្រុងមកជនបទ។ បើយើងបានប្តូរខ្លះចំពោះដីរិចរិលយើងបានចំណេញ យើង មានផ្លូវ សាលារៀន ទឹកស្អាត មន្ទីរពេទ្យ ។ល។ ការអភិវឌ្ឍន៏ត្រូវថ្លឹងថ្លែងទៅនឹងការអភិរក្ស ឆ្លងកាត់ការអភិវឌ្ឍន៏កូនចៅយើងនៅទីនេះនឹងមានលទ្ធភាពដូចអ្នកទីក្រុងដែរ។
-គាត់ខ្វល់ដល់សហគមន៏កម្មវិធីព្រៃឈើជាតិនេះធ្វើតែ ០២ថ្ងៃ តែសំរាប់២០ឆ្នាំ។ នេះហើយដែលយើងត្រូវការបងប្អូនមកពិភាក្សាពេលនេះ ហើយបញ្ចេញយោបល់អោយអស់សំរាប់ថ្ងៃស្អែក ។ ដូច្នេះថ្ងៃស្អែកត្រូវ បញ្ចេញកង្វល់អោយអស់ បើមិនអស់ទេយើងទុកពេលអោយទៀត។ ( ចំលើយរបស់ ឯ.ឧ ជា សំអាង )

**សំនួរៈ**

-ការចំណាត់ថ្នាក់ផ្ទៃដីសំរាប់ផ្ទេរ ដើម្បីគោលបំនងអភិវឌ្ឍន៍ផ្សេងៗ កន្លងមកការផ្តល់ដីសម្បទានសេដ្ឋកិច្ចភាគច្រើនប៉ះទៅលើរណ្តៅដីរច្បោះរបស់ប្រជាពលរដ្ឋ មានការព្រួយបារម្ភចំពោះបញ្ហានេះ ចង់សូមអោយបញ្ជាក់អោយបានច្បាស់លាស់នូវចំនុចនេះ តើការផ្ទេរដីនេះ របៀបណា?

**ចំលើយៈ**

**តារាងសង្ខេបលទ្ធផលពិភាក្សារបស់ក្រុមទី ១:** (Forest Demarcation Classification and Registration Permanent Forest Estate)

| **កម្មវិធីទី ១: ការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍** | **មតិដែលគួរទទួលយក** | **មតិដែលមិនគួរទទួលយក** |
| --- | --- | --- |
| **១.តើអ្នកយល់ដូចម្តេច ចំពោះកម្មវិធីការ កំណត់ព្រំ ប្រទល់ ការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើ អចិន្ត្រៃយ៍? គួរបន្ថែមអនុកម្មវិធីអ្វីទៀត?** | • ចូលរួមដោយស្ម័គ្រចិត្តពីអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ<br>•រយៈពេលរង់ចាំតវ៉ា គួរ ៤៥ ទៅ ៦០ថ្ងៃ ព្រោះមានបងប្អូន ខ្លះនៅឆ្ងាយ<br>•ត្រូវតែដាក់បញ្ចូលកម្មវិធីនេះ ទៅក្នុងផែនការ គណៈកម្មាធិការ ជាតិ សម្រាប់ការអភិវឌ្ឍន៍ តាមបែប ប្រជាធិបតេយ្យ ថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)<br>•គួរអនុវត្តច្បាប់ផ្តន្ទាទោសឱ្យបានម៉ឺងម៉ាត់ | •មុននឹងកំណត់ព្រំប្រទល់សូមសិក្សាស្រាវជ្រាវដែនដី របស់សហគមន៍<br>•គួរធ្វើការផ្សព្វផ្សាយច្បាប់ បរិស្ថានបន្ថែមផងដែរ<br>• ត្រូវសិក្សាអំពីការពាក់ព័ន្ធ មុននឹង កំណត់ព្រំប្រទល់<br>• អញ្ជើញអ្នកពាក់ព័ន្ធមកដោះស្រាយ មុននឹងកំណត់ព្រំប្រទល់<br>• ផ្សព្វផ្សាយដើម្បីឱ្យមានការចូលរួម សហការរវាង ស្ថាប័នពាក់ព័ន្ធ និងផ្តល់ពត៌មានទៅវិញទៅមក<br>• ការផ្សព្វផ្សាយពីព្រៃឈើ និង ការផ្តល់ចំណេះដឹងជា សាធារណៈ<br>• ត្រូវមានការព្រមព្រៀងពីប្រជាជនសហគមន៍<br>• បែងចែកដីព្រៃសង្គមកិច្ច និងសេដ្ឋកិច្ចឱ្យបានច្បាស់លាស់ |

| | | |
|---|---|---|
| | | • ត្រូវមានការចូលរួមពីតំណាងអាជ្ញាធរមូលដ្ឋាន |
| **២.ដំណោះស្រាយ ចំពោះបញ្ហាប្រឈម ក្នុងការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍** | • ធ្វើការបដិសេធប័ណ្ណកម្មសិទ្ធិលើដីព្រៃឈើ<br>• អាជ្ញាធរមូលដ្ឋានគួរទប់ស្កាត់ប្រជាជនធ្វើពរនេចរ<br>• អាជ្ញាធរមូលដ្ឋានត្រូវបញ្ឈប់ការ ចេញលិខិតកាន់កាប់ដីព្រៃ<br>• អនុញ្ញាតអោយប្រជាជន បន្តការ ប្រើប្រាស់ជាប្រពៃណី បន្ទាប់ពីបោះបង្គោលព្រំរួច<br>• ធ្វើផ្លូវភ្លើងជុំវិញសហគមន៍<br>• គួរមានកម្មវិធីលើកទឹកចិត្ត<br>• គួរកំណត់យកស្ថានភាពជាក់ស្តែង កុំពឹងផ្អែកលើផែនទីឆ្នាំ២០០២<br>• គួរផ្តល់ថវិកាទាន់ពេល | • ផ្សព្វផ្សាយច្បាប់ដល់ប្រជាជនមូល ដ្ឋានដែលមានដីពាក់ព័ន្ធ<br>•<br>ធ្វើកំណត់ហេតុដោយមានការឯកភាពពីម្ចាស់ដីពាក់ព័ន្ធ<br>• គួរមានថវិកាគ្រប់គ្រាន់ និងថវិកាជួសជុលបង្គោលព្រំ<br>• ធ្វើការសំរបសំរួលលើការប៉ះពាល់ជាក់ស្តែង<br>• ផ្តន្ទាទោសតាមច្បាប់ ចំពោះអ្នកបំផ្លាញបង្គោលព្រំ និងលើកទឹកចិត្តអ្នកចូលរួមថែរក្សា ការពារ<br>• ធ្វើការប្រកាសផ្សព្វផ្សាយជាមុន មុនការកំណត់ព្រំ<br>• គួរមានក្រុមការងារថ្នាក់កណ្តាលជាអ្នកអនុវត្តដំណើរការនេះ<br>• គួរមានស្ថាប័នបីចូលរួម: រដ្ឋបាលព្រៃឈើ ដែនដីនគរូបនីយកម្ម និងអាជ្ញាធរមូលដ្ឋាន<br>• អនុវត្តតាមគោលការណ៍ច្បាប់<br>• ជំរុញការផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីការបោះបង្គោលព្រំ តាមវិទ្យុ ទូរទស្សន៍ និងការប្រជុំផ្សព្វផ្សាយ មុនការបោះ បង្គោល |

| | | |
|---|---|---|
| | | • មានការតាមដាន ត្រួតពិនិត្យ<br>ឱ្យបានជាប្រចាំពីស្ថាប័ន ជំនាញ<br>• មានវិធានការណ៍តាមផ្លូវច្បាប់ចំពោះជនខិលខូច<br>• ធ្វើការបដិសេធប័ណ្ណកម្មសិទ្ធដែលពាក់ព័ន្ធជាមួយ<br>ដីព្រៃដែលបានកាន់កាប់ក្រោយឆ្នាំ២០០២<br>• ជំរុញការដោះស្រាយទំនាស់ មុននិងបោះបង្គោលព្រំ<br>• ត្រូវដោះស្រាយដោយយកច្បាប់ជាធំ<br>ដោយទទួលផល<br>ប្រយោជន៍ស្មើភាព និងយុត្តិធមិ<br>• មន្ត្រីជំនាញគួរតែអនុវត្តឱ្យបានច្បាស់ ជាពិសេសធ្វើ<br>ផែនការសកម្មភាព ដូចជាធ្វើ<br>សារពើភ័ណ្ឌនឹងផែនការប្រើ<br>ប្រាស់ព្រៃឈើដោយមានការចូលរួម<br>• ផ្សព្វផ្សាយច្បាប់ព្រៃឈើ បច្ចេកទេស<br>និងបទដ្ឋានផ្សេងៗ ដែលពាក់ព័នពីព្រៃឈើដល់<br>ប្រជាជនឱ្យបានទូលំទូលាយ និងជាសាធារណៈ<br>• ដោះស្រាយគោលនយោបាយ<br>• តាមដានត្រួតពិនិត្យ តើគ្រួសារដែលកាប់រានថ្មីនោះ<br>គាត់មានដីហើយ ឬនៅ? បើគ្មាន គួរតែដោះស្រាយ |

| | | |
|---|---|---|
| | | ដីជូនគាត់<br>• មានការចូលរួមពីអាជ្ញាធរមូលដ្ឋាន អង្គការពាក់ព័ន ប្រជា ពលរដ្ឋ<br>• ការចូលរួមត្រូវមានឆន្ទៈ<br>• ឯកភាពពីប្រជាពលរដ្ឋ<br>• អនុវត្តច្បាប់ព្រៃឈើឱ្យបានតឹងរឹងចំពោះអ្នកប្រព្រឹត្តបទល្មើស<br>• ត្រូវរៀបចំបង្កើតផែនទីឱ្យបានរហ័ស<br>•ធ្វើការសម្របសម្រួលគ្រប់ភាគីពាក់ព័ន<br>• ចុះទប់ស្កាត់ឱ្យបានទាន់ពេលវេលាចំពោះការកាប់រាន ដីព្រៃឈើដោយខុសច្បាប់<br>និងធ្វើការអប់រំដល់ពួកគាត់<br>• ពេលចុះកំណត់ព្រំប្រទល់ ត្រូវឱ្យមានការចូលរួមគ្រប់ភាគីពាក់ព័ន្ធទាំងអស់<br>• កំណត់អោយច្បាស់ព្រំប្រទល់ដីភូមិ និងដីព្រៃ<br>• ត្រូវមានការចូលរួមពីអាជ្ញាធរ មូលដ្ឋាន<br>ស្ថាប័នពាក់ព័ន្ធ និងសហគមន៍ មូលដ្ឋាន<br>ក្នុងការបោះបង្គោលព្រំ<br>• សំរបសំរួលជាមួយប្រជាជន |

| | | |
|---|---|---|
| | | ដែលរស់នៅក្នុងតំបន់ព្រៃ<br>• ត្រូវមានការឯកភាពពីសហគមន៍ អាជ្ញាធរនិងស្ថានប័ន ពាក់ព័ន្ធ ។<br>• ចុះអប់រំផ្សព្វផ្សាយច្បាប់ព្រៃឈើ ច្បាប់ភូមិបាល<br>• លើកកំពស់ការចូលរួមថែរក្សា ព្រៃឈើឡើងវិញ<br>• ធ្វើការស្រាវជ្រាវជីពលរដ្ឋសំរាប់ បង្កបង្កើនផល<br>• សំអាតនូវរាល់ទំនាស់នៅទីកន្លែងបោះបង្គោលព្រំ |
| **៣.តើត្រូវធ្វើដូចម្តេចដើម្បីបង្កើនការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍សម្រេចបានឆាប់រហ័ស ?** | • មានថវិកាគ្រប់គ្រាន់ និងទាន់ពេលវេលា<br>• ត្រូវដាក់កម្មវិធីនេះចូលទៅ ក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់<br>• មានធនធានមនុស្ស និងសមត្ថភាពជំនាញ<br>• មានការគាំទ្រពីអាជ្ញាធរខេត្ត ស្ថាប័ន និងមានការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋ<br>• ត្រូវមានស្មារតីទទួលខុសត្រូវខ្ពស់ ដោយមិនចាត់ទុកថាការបោះបង្គោលព្រំជាការងាររបស់រដ្ឋបាលព្រៃឈើតែម្នាក់ឯង | • ត្រូវមានការចូលរួម និងគាំទ្រ ពេញលេញពីគ្រប់ភាគីពាក់ព័ន្ធ<br>• ជូនដំណឹង និងផ្សព្វផ្សាយដល់ប្រជាជន នៅមូលដ្ឋានដែលត្រូវកំណត់ព្រំប្រទល់ ព្រោះការយល់ដឹងពួកគាត់នៅមានកំរិត<br>• ផ្សព្វផ្សាយមុនចុះអនុវត្តន៍<br>• ដោះស្រាយទំនាស់ព្រំប្រទល់ជាមុន<br>• មានសម្ភារៈ ថវិកាគ្រប់គ្រាន់ និងទាន់ពេលវេលាមានកិច្ចសហប្រតិបត្តិការពីស្ថប័នពាក់ព័ន្ធ និងបង្កើតក្រុមការងារ ឱ្យបានឆាប់រហ័ស |

| | | |
|---|---|---|
| | | • ត្រូវមានឆន្ទៈក្នុងការចូលរួម និងត្រូវមានផែនការរួមសម្រាប់អ្នកពាក់ព័ន្ធ<br>• ត្រូវសិក្សាស្រាវជ្រាវពីដីពាក់ព័ន្ធឱ្យបានឆាប់<br>• បង្កើនការដោះមីនពីដីព្រៃ<br>• ត្រូវមានការផ្សព្វផ្សាយពីសារៈសំខាន់នៃការបោះព្រំ<br>• មានការឯកភាពគ្នា<br>• សហការណ៍ និងទំនាក់ទំនង ល្អជាមួយអ្នកពាក់ព័ន<br>• សិក្សាពីផលប៉ះពាល់ជាមុន<br>• មានការចូលរួមពីចាស់ស្រុក នៅក្នុងភូមិ<br>• មានផែនការសកម្មភាពការងារជាក់លាក់<br>• បង្កើតក្រុមការងារ និងក្រុមបច្ចេកទេស<br>• រៀបចំថវិកា មធ្យោបាយ សំភារៈ<br>• មានផែនការមេច្បាស់លាស់<br>• ផែនទីច្បាស់លាស់<br>• ផ្សព្វផ្សាយអោយប្រជាជនយល់ពីផលប្រយោជន៏ព្រៃឈើ<br>• ជំរុញការដោះស្រាយបញ្ហាពាក់ព័ន្ធឱ្យបានឆាប់មុនបោះ បង្គោលព្រំ<br>• ត្រូវមានផ្លាកសហគមន៏ជុំវិញព្រំដីរបស់សហគមន៏ |

| | | |
|---|---|---|
| | | • ត្រូវមានការត្រួតពិនិត្យ និងវាយតំលៃពីការបោះបង្គោលព្រំ<br>• ត្រូវមានរបាយការណ៍ កំណត់ ហេតុ បញ្ជីវត្ថុមាន និងឯកសារពាក់ព័ន្ធអោយ បានគ្រប់គ្រាន់ |
| **៤: តើអជ្ញាធរ សហគមន៍ និងប្រជាជនមូលដ្ឋាន ចូលរួមដូចម្តេចក្នុងការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍?** | • តាមដានសកម្មភាពបំផ្លាញបង្គោលព្រំ<br>• ផ្តល់ព័តិមានដល់សមត្ថកិច្ចពេលជួបហេតុការណ៍<br>• ត្រូវចូលរួមទប់ស្កាត់ជំលោះដីធ្លីក្នុងមូលដ្ឋាន<br>• អាជ្ញាធរត្រូវបង្កលក្ខណៈងាយស្រួលដល់មន្ត្រីរដ្ឋបាលព្រៃឈើក្នុងការបោះសបង្គោលព្រំ<br>• អាជ្ញាធរមូលដ្ឋានត្រូវចូលរួមផ្សព្វ ផ្សាយ និងសំរបសំរួលដល់ប្រជាជន ក្នុងការបោះបង្គោលព្រំ<br>• អាជ្ញាធរត្រូវបំផុសស្មារតីប្រជាជនមូលដ្ឋានឱ្យចូលរួម<br>• អាជ្ញាធរត្រូវបង្ហាញទីតាំងដីស្រែ ចំការក្នុងមូលដ្ឋានរបស់ខ្លួន (ឯកសារពាក់ព័ន្ធ)<br>• អាជ្ញាធរមូលដ្ឋានត្រូវជួយគាំទ្រដល់ដំណើរការបោះបង្គោលព្រំ | • ចូលរួមដោយស្ម័គ្រចិត្ត និង មានសុឆន្ទៈ<br>• ថែទាំបង្គោលព្រំ<br>• ចូលរួមផ្សព្វផ្សាយច្បាប់<br>• កំណត់ពេលវេលាឱ្យបានច្បាស់<br>• ចូលរួមបញ្ជាក់ទីតាំងឱ្យបានច្បាស់<br>• ចូលរួមបញ្ចេញពលកម្ម និង គាំទ្រកម្មវិធី<br>• ចូលរួមសហកាជាមួយមន្ត្រីជំនាញ<br>• អាជ្ញាធរត្រូវដឹងឮ ក្នុងការកំណត់ព្រំ និងជួយដោះស្រាយ ទំនាស់<br>• សហគមន៏ត្រូវសម្របសម្រួល និង ដឹងឮពីព្រំប្រទល់ដីព្រៃ<br>• គ្រប់ភាគីពាក់ព័ន្ធត្រូវមានឆន្ទៈខ្ពស់ក្នុងការចូលរួម<br>• អាជ្ញាធរ ស្ថាប័នពាក់ព័ន ត្រូវចូលរួមដឹងឮទទួលស្គាល់ |

| | | |
|---|---|---|
| | | ការផ្តល់យោបល់<br>• សហគមន៍ត្រូវចូលរួមក្នុងការចង្អុលបង្ហាញ និងកំណត់ ទីតាំង ពេលវេលា កំលាំងពលកម្ម<br>• ស្រុក ឃុំ ភូមិ សហគមន៍ និងប្រជាពលរដ្ឋ ចុះជួបជាមួយ គ្នាដល់ទីកន្លែង<br>• ចូលរួមទទួលខុសត្រូវ និងធ្វើឯកសារក្នុងការ កំណត់ទីតាំង<br>• រក្សាចំនុចដែលត្រូវបោះបង្គោល<br>• ត្រូវចូលរួមសិក្សាវាយតម្លៃ ចង្អុលបង្ហាញព្រំប្រទល់<br>• ចូលរួមធ្វើសេចក្តីសំរេចចិត្ត<br>• ចូលរួមក្នុងការដោះស្រាយទំនាស<br>• ត្រូវមានសមត្ថភាព និងសិទ្ធសំរេច និងការទទួល ខុសត្រូវខ្ពស់<br>•ស្ថាប័នពាក់ព័ន្ធត្រូវចូលរួមសហការណ៍ឱ្យបានល្អ<br>• ប្រជាជនត្រូវធ្វើការសំរបសំរួល អោយដំណើរការ បោះបង្គោលព្រំ ប្រព្រឹត្តិទៅបានល្អប្រសើរ<br>• សហគមន៍មូលដ្ឋានគួរបង្ហាញពីដីពាក់ព័ន្ធរបស់ខ្លួន ព្រមទាំងឯកសារផង<br>• សហគមន៍ត្រូវចូលរួមក្នុងការបោះ បង្គោលព្រំ |

| | | |
|---|---|---|
| | | • ត្រូវចូលរួមរៀបចំផែនការកម្មវិធី និងផែនការសកម្មភាព<br>• អាជ្ញាធរដែនដីជាអ្នកដឹកនាំដោះស្រាយបញ្ហាទំនាស់<br>• ត្រូវមានឆន្ទៈខ្ពស់ក្នុងការអនុវត្តន៏ច្បាប់<br>•ហ៊ានបញ្ចេញយោបល់ពិតអំពីប្រវត្តិនៃទីតាំងបោះបង្គោលព្រំ<br>•ប្រជាពលរដ្ឋត្រូវចូលរួមដោះស្រាយ និងផ្តល់យោបល់ |
| **៥.តើត្រូវមានស្ថាប័ន ពាក់ព័ន្ធណាខ្លះ ចូលរួមក្នុងការចាត់ថ្នាក់ សម្បត្តិព្រៃឈើអចិន្ត្រៃយ៍?** | • អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់<br>• ប្រជាជនរស់នោជិតដំបន់ព្រៃ<br>• រដ្ឋបាលព្រៃឈើ<br>•បរិស្ថាន<br>• អធិការកិច្ចខេត្ត<br>• កសិកម្ម<br>• សុរិយោដី<br>• កងកម្លាំងប្រដាប់អាវុធ<br>• ចាស់ទុំក្នុងភូមិ<br>• អង្គការ NGOs<br>• ទេសចរណ៍ | |

| | | |
|---|---|---|
| | • ឧស្សាហកម្ម រ៉ែ និងថាមពល<br>• ព្រៃសម្បទានិក<br>• សហគមន៍មូលដ្ឋាន<br>• វប្បធម៌ | |
| **៦) បន្ទាប់ពីបានកំណត់ព្រំប្រទល់ព្រៃ រួច តើអាជ្ញាធរដែនដី សហគមន៍ និងប្រជាពលរដ្ឋមូលដ្ឋានចូលរួមដូចម្តេច ក្នុងការថែរក្សាព្រំប្រទល់ឱ្យបានគង់វង្ស?** | • ទប់ស្កាត់ការចូលរុករានដែនព្រៃដោយខុសច្បាប់<br>• តាមដាននិង ផ្តល់ព័ត៌មាន<br>• បង្កើតក្រុមការងារចុះល្បាត បង្គោលព្រំ<br>• ទប់ស្កាត់ភ្លើងឆេះព្រៃ<br>• ផ្តល់ព័ត៌មានអំពីការរំលោភបំពានព្រំដីព្រៃ<br>• លើកប៉ាណូ ផែនទី ព័ត៌មាននៅទីកន្លែង<br>• មានកម្មវិធីល្បាត ឃ្លាំមើលជាប្រចាំ | • អនុវត្តច្បាប់ និង ផ្សព្វផ្សាយ<br>• រាយការពីការណ៍បំផ្លាញបង្គោលព្រំ<br>• បង្កើតបណ្តាញការពារបង្គោលព្រំ<br>• ត្រូវចុះបញ្ជិកាដី សម្គាល់ថាជាសម្បត្តិសាធារណៈ<br>• មានវិធានការណ៍តាមច្បាប់ចំពោះជនល្មើស<br>• អប់រំកូនចៅឱ្យចូលរួមថែរក្សាបង្គោលព្រំ<br>• ធ្វើការប្រជុំជាប្រចាំ ក្នុងការការពារបង្គោលព្រំ<br>• សហការរួមកំលាំងគ្នាទប់ស្កាត់រាល់បទល្មើស<br>• យកព័ត៌មានប្រមូលភ័ស្តុតាង<br>រាយការណ៍ទៅអាជ្ញាធរ និងស្ថាប័នពាក់ព័ន<br>• ធ្វើផែនការការពារ<br>• យាមល្បាតជាប្រចាំ<br>• រាយការណ៍ពីសកម្មភាពដែលកើតមាន<br>• បំផុសឱ្យប្រជាជនយល់ដឹងពីសារៈសំខាន់ពីការបោះ |

| | | |
|---|---|---|
| | | បង្គោលព្រំ<br>• ទប់ស្កាត់បទល្មើស<br>• ការពារមិនឱ្យជនល្មើសវាយបំបាក់បង្គោលព្រំ<br>• ត្រូវមានការចូលរួមថែរក្សាពី សហគមន៍មូលដ្ឋាន អាជ្ញាធរ និងកងកំលាំងប្រដាប់អាវុធ<br>• មានការលើកទឹកចិត្តចំពោះអ្នកផ្តល់ព័តិមានស្តីពីអ្នកបំផ្លាញបង្គោលព្រំ<br>• ផ្សព្វផ្សាយឱ្យប្រជាជនយល់ពីអត្ថន័យរបស់បង្គោលព្រំ<br>• ដាក់បន្ទុកលើកអាជ្ញាធរមូលដ្ឋាន ក្នុងការថែរក្សាបង្គោលព្រំ<br>• រដ្ឋបាលព្រៃឈើត្រូវផ្សព្វផ្សាយដល់ អាជ្ញាធរភូមិ ឃុំ ម្ចាស់ក្បាលដី ដែលនៅជាប់នឹងបង្គោលព្រំ ឱ្យជួយថែរក្សាបង្គោលព្រំ<br>• ធ្វើកំណត់ហេតុអោយបានត្រឹមត្រូវ ជាមួយអាជ្ញាធរមូលដ្ឋានសហគមន៍<br>• បង្គោលព្រំ ត្រូវធ្វើអោយរឹងមាំ<br>• ដាក់ទោសទ័ណ្ឌដល់អ្នកបំផ្លាញបង្គោលព្រំ<br>• ត្រូវមានការផ្សព្វផ្សាយតាមវិទ្យុ ដើម្បីឱ្យប្រជាជន |

| | | |
|---|---|---|
| | | ចូលរួមថែរក្សាបង្គោលព្រំ<br>• គណៈកម្មការសហគមន៍ត្រូវចាត់សមាជិកអោយចុះយាមល្បាតបង្គោលព្រំ ឱ្យបានប្រាកដ |